# តម្រូវការផ្នែកកិច្ចការពារ និងការអប់រំ

## សម្រាប់កុមារ និងក្មេងជំទង់
## នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ




unicef
for every child

**To request permission and for any information on the publication, please contact:**


## UNICEF Cambodia

Exchange Square, 5th floor, Blog. no. 19 & 20, street 106.
Sangkat Wat Phnom, Khan Daun Penh
Phnom Penh, Cambodia

P.O. Box 176

Tel.: +855-23 260 204

Email: phnompenh@unicef.org

Website: https://www.unicef.org/cambodia/



**Photo credit:** Fani Llauradó


**សេចក្តីបញ្ជាក់:**

ទស្សនៈនិងការវិភាគក្នុងឯកសារនេះ
គឺរបស់ក្រុមអ្នកសិក្សាវាយតម្លៃ
នៃក្រុមហ៊ុន Ernst & Young LLP និង
មិនឆ្លុះបញ្ចាំងពីទស្សនៈ ឬគោលជំហរ
របស់យូនីសេហ្វទេ។

# សាររបស់នាយិកា យូនីសេហ្វប្រចាំកម្ពុជា

រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលនយោបាយ ការទូត វប្បធម៌ សេដ្ឋកិច្ច និងសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។ រាជធានីនេះក៏ជាប្រភពមិនចេះរីងស្ងួតនៃឱកាស ភាពចម្រុះ ការរីកចម្រើន និងការច្នៃប្រឌិត ហើយបច្ចុប្បន្ននេះកំពុងមានការផ្លាស់ប្តូរក្នុងល្បឿនយ៉ាងលឿន និងក្នុងវិសាលភាពមួយដែលមិនធ្លាប់មានក្នុងពេលកន្លងមក។ ការផ្លាស់ប្តូរបែបនេះបាននាំមកជាមួយនូវកាលានុវត្តភាពផង និងបញ្ហាប្រឈមផងសម្រាប់ប្រទេសជាតិ និងប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីនេះ។

រាជធានីភ្នំពេញមានតួនាទីយ៉ាងសំខាន់បំផុតក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍ឆ្នាំ២០៣០ របស់កម្ពុជា ជាពិសេសគោលដៅទី១១ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ស្តីពីការធ្វើឱ្យទីក្រុងមានបរិយាប័ន្ន មានភាពធន់ និងចីរភាព។ ជាងនេះទៀត រាជធានីភ្នំពេញក៏មានតួនាទីសំខាន់ផងដែរក្នុងការសម្រេចនូវចក្ខុវិស័យរបស់កម្ពុជា ដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។

នគរូបនីយកម្មដ៏ឆាប់រហ័ស និងស្មុគស្មាញបែបនេះ រមែងនាំមកជាមួយនូវបញ្ហាប្រឈម និងហានិភ័យ។ កំណើននូវតម្រូវការទឹកស្អាត អគ្គិសនី ការគ្រប់គ្រងកាកសំណល់ លំនៅដ្ឋាន គុណភាពខ្យល់ ការដឹកជញ្ជូន បរិយាកាសរស់នៅ សុវត្ថិភាព និងសន្តិសុខ គឺគ្រាន់តែជាបញ្ហាប្រឈមខ្លះៗដែលត្រូវដោះស្រាយឱ្យបានសមស្រប។ ចំណែកឯបញ្ហាភាពក្រីក្រ និងវិសមធម៌នៃលទ្ធភាពទទួលបានសេវាអប់រំ ការថែទាំសុខភាព អាហារូបត្ថម្ភ ទឹកស្អាត អនាម័យ ព្រមទាំងកិច្ចការពារ ក្នុងចំណោមប្រជាពលរដ្ឋនៅតាមសហគមន៍ក្រីក្រ និងអ្នកខ្សត់ខ្សោយក្នុងទីក្រុង ក៏តម្រូវឱ្យមានការដោះស្រាយដូចគ្នាដែរ។

ការសិក្សាស្តីពី *"តម្រូវការផ្នែកកិច្ចការពារ និងការអប់រំសម្រាប់កុមារ និងក្មេងជំទង់នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ"* គឺជាកិច្ចខិតខំប្រឹងប្រែងរួមមួយក្នុងចំណោមកិច្ចខិតខំប្រឹងប្រែងរួមដទៃទៀត រវាងរដ្ឋបាលរាជធានីភ្នំពេញនិងយូនីសេហ្វនៅកម្ពុជា ក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋងាយរងគ្រោះបំផុតនៅទីក្រុង។ ការសិក្សានេះបានធ្វើការវិភាគលើហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារ ការអប់រំសម្រាប់កុមារនិងក្មេងជំទង់ កម្មវិធីអន្តរាគមន៍ គោលនយោបាយពាក់ព័ន្ធ និងផ្តល់ជាអនុសាសន៍ ដែលមានអត្ថប្រយោជន៍ដល់ការកសាងផែនការ និងធ្វើអន្តរាគមន៍ឱ្យមានប្រសិទ្ធភាព។ ខ្ញុំសង្ឃឹមថាស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននឹងទទួលបានព័ត៌មានល្អៗពីរបកគំហើញទាំងនេះ។

ក្នុងនាមយូនីសេហ្វ ខ្ញុំសូមសំដែងនូវការកោតសរសើរដល់រដ្ឋបាលរាជធានីភ្នំពេញចំពោះការដឹកនាំ និងសូមថ្លែងអំណរគុណ ដល់អ្នកចូលរួមឆ្លើយសំណួរទាំងអស់ និងដល់ក្រុមទីប្រឹក្សាដែលបានខិតខំរួមគ្នាបញ្ចប់ការសិក្សានេះ។

***ដេបូរ៉ា គូមីនី***

*នាយិកា យូនីសេហ្វប្រចាំកម្ពុជា*

# សេចក្តីសង្ខេប

## សាវតារ

ចាប់តាំងពីការដួលរលំរបបខ្មែរក្រហម កាលពីឆ្នាំ១៩៧៩ មក រាជធានីភ្នំពេញចាប់ផ្តើមមានមនុស្សមករស់នៅជាបណ្តើរៗ ដូចជា អតីតអ្នករស់នៅក្នុងទីក្រុងនេះកាលពីមុន ជនភៀសខ្លួន ជនបាត់បង់ទីលំនៅ និងអ្នកចំណាកស្រុកពីតំបន់ជនបទ។ ការកាន់កាប់អគារនានា គឺធ្វើឡើងដោយ "អ្នកមកមុន កាន់កាប់មុន" ហើយអ្នកចូលមកក្រោយៗ និងប្រជាជនក្រីក្រ នាំគ្នាបង្កើតកន្លែងតាំងទីលំនៅមិនរៀបរយនេះជាលើកដំបូងនៅចុងទសវត្សរ៍១៩៨០។[1] កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សបានទាក់ទាញអ្នកធ្វើចំណាកស្រុកជាច្រើននាក់ ឲ្យចូលមករស់នៅក្នុងរាជធានីភ្នំពេញ នាំឲ្យចំនួនប្រជាជនក្នុងទីក្រុងភ្នំពេញកើនឡើងទ្វេដង ពីឆ្នាំ១៩៩៨ ដល់២០០៨ និងនាំឲ្យមានការពង្រីកទីក្រុងនេះទៅតំបន់ខាងក្រៅ ដែលនៅជិតៗបន្ថែមទៀត។

បច្ចុប្បន្ននេះ ទីក្រុងភ្នំពេញមានខណ្ឌចំនួន១២ ហើយមានប្រជាជនប្រមាណ ១,៦ លាននាក់។ អ្នករស់នៅក្នុងទីក្រុងប្រមាណជាមួយភាគបួនរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ពោលគឺក្រោម ១,៥៨ ដុល្លារក្នុងមួយថ្ងៃ។[2] ប្រជាពលរដ្ឋក្រីក្រទាំងនេះរស់នៅតាមតំបន់តូចៗ ផ្សេងៗគ្នា តាមខណ្ឌដែលស្ថិតនៅកណ្តាលក្រុង និងខណ្ឌជាយក្រុង របស់រាជធានីភ្នំពេញ។ កន្លងមកមានការអង្កេតមួយចំនួនបានវិភាគទៅលើការតាំងទីលំនៅសហគមន៍ក្រីក្រទាំងនេះ។ ក្នុងនោះរួមមាន "ការអង្កេតអំពីស្ថានភាពនៃតំបន់តាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា" ធ្វើឡើងក្នុងឆ្នាំ១៩៩៧ និងបន្ទាប់មក "ការអង្កេតលើខណ្ឌចំនួន៨" ក្នុងឆ្នាំ២០០៩ ដោយមានសមាគមធាងត្នោត និងការអង្កេតថ្មីចុងក្រោយគេគឺ "ការវាយតម្លៃលើប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងភ្នំពេញ" ដែលធ្វើឡើងដោយរដ្ឋបាលរាជធានីភ្នំពេញកាលពីឆ្នាំ២០១២។ ប៉ុន្តែ ការអង្កេតទាំងនេះផ្តោតការយកចិត្តទុកដាក់តែលើស្ថានភាពសង្គម សេដ្ឋកិច្ច អប់រំ សុខភាព និងអនាម័យ របស់ប្រជាពលរដ្ឋក្រីក្រទូទៅក្នុងទីក្រុងតែប៉ុណ្ណោះ ដោយមិនបានផ្តោតទៅលើក្រុមដែលងាយរងគ្រោះបំផុត គឺកុមារ និងក្មេងជំទង់នោះទេ។ ដូច្នេះយើងនៅមិនទាន់មានការយល់ដឹងស៊ីជម្រៅអំពីស្ថានភាពរបស់ពួកគេនៅឡើយ។

រដ្ឋបាលរាជធានីភ្នំពេញ និងយូនីសេហ្វនៅកម្ពុជា បានធ្វើការរួមគ្នាដើម្បីលើកកម្ពស់សុខុមាលភាព និងស្ថានភាពនៃការរស់នៅរបស់កុមារ និងក្រុមគ្រួសាររបស់ពួកគេដែលកំពុងរស់នៅតាមតំបន់ក្រីក្រ ក្នុងរាជធានីភ្នំពេញ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងយល់ឱ្យបានច្បាស់អំពីស្ថានភាពរបស់កុមារ និងក្មេងជំទង់នៅក្នុងសហគមន៍ទាំងនេះ យូនីសេហ្វនៅកម្ពុជា ដោយមានការគាំទ្រពីរដ្ឋបាលរាជធានីភ្នំពេញ បានសហការជាមួយក្រុមហ៊ុន Ernst & Young LLP ប្រចាំនៅប្រទេសឥណ្ឌា ធ្វើការសិក្សានេះ។ ការសិក្សានេះធ្វើឡើង នៅចន្លោះពីខែកុម្ភៈ ឆ្នាំ២០១៦ និងខែមេសា ឆ្នាំ២០១៧ ហើយមានគោលបំណង៖

- កំណត់ពីហានិភ័យសំខាន់ៗជុំវិញកិច្ចការពារកុមារ ដែលកុមារក្នុងវ័យរៀននៅមត្តេយ្យសិក្សា និងក្មេងជំទង់ជួបប្រទះ
- កំណត់ពីកត្តារាំងស្ទះ និងកត្តាអំណោយផល ពាក់ព័ន្ធនឹងភាពក្រីក្រក្នុងទីក្រុង ដែលធ្វើឲ្យកុមារដល់អាយុចូលរៀននៅមត្តេយ្យសិក្សា និងក្មេងជំទង់ មិនអាចទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិប្រកបដោយគុណភាព និងបរិយាប័ន្នបាន
- កំណត់ពីទំនាក់ទំនងទៅវិញទៅមករវាងហានិភ័យពាក់ព័ន្ធនឹងការការពារកុមារ និងការទទួលបានការអប់រំនៅសាលារៀន

[1] *សមាគមធាងត្នោត (២០១៤) ការអង្កេតក្នុងទីក្រុងភ្នំពេញ៖ ការសិក្សាអំពីតំបន់តាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រ ក្នុងទីក្រុងភ្នំពេញ។*
[2] *សមាគមធាងត្នោត (២០១៤) ការអង្កេតក្នុងទីក្រុងភ្នំពេញ៖ ការសិក្សាអំពីតំបន់តាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រ ក្នុងទីក្រុងភ្នំពេញ។*

- កំណត់ពីសេវាដែលមានស្រាប់ ឬសេវាដែលនៅខ្វះខាត ដើម្បីឆ្លើយតបនឹងតម្រូវការនៃការការពារកុមារ និងការអប់រំ ក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង
- កំណត់ពីអាទិភាពសម្រាប់ការអភិវឌ្ឍសមត្ថភាព ដើម្បីផ្តល់លទ្ធភាពឲ្យរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ផ្តល់សេវា និងអន្តរាគមន៍ចាំបាច់នានាផ្នែកកិច្ចការពារកុមារ។

## គោលបំណងនៃរបាយការណ៍

របកគំហើញនៃការវាយតម្លៃនេះ នឹងយកទៅប្រើប្រាស់ជាព័ត៌មាន សម្រាប់រៀបចំយុទ្ធសាស្ត្រការពារសិទ្ធិរបស់កុមារ និងក្មេងជំទង់ ដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ ក៏ដូចជាជួយកំណត់ពីឱកាសនានា ដើម្បីបន្តពង្រឹងសេវាអប់រំ និងសេវាកិច្ចការពារសម្រាប់កុមារដល់អាយុរៀននៅមត្តេយ្យសិក្សា និងក្មេងជំទង់ មកពីសហគមន៍ក្រីក្រក្នុងរាជធានី។

## វិធីសាស្ត្រដែលបានប្រើសម្រាប់ការវាយតម្លៃនេះ

ដើម្បីទទួលបានរបកគំហើញដែលមានការបញ្ជាក់ផ្ទៀងផ្ទាត់ថាពិតជាត្រឹមត្រូវ ការវាយតម្លៃនេះប្រើប្រាស់វិធីសាស្ត្រវាយតម្លៃចម្រុះដោយមានទាំងបែបគុណវិស័យផង និងបរិមាណវិស័យ។ ក្រុមវាយតម្លៃបានប្រើប្រាស់កម្រងសំណួរគ្រួសារដែលបានរៀបចំទុកជាមុន ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ (semi-structured interviews) និងការពិភាក្សាក្រុមជាមួយអ្នកពាក់ព័ន្ធជាក់លាក់។ កម្រងសំណួរគ្រួសារ ត្រូវបានប្រើប្រាស់ជាឧបករណ៍បែបបរិមាណវិស័យ សម្រាប់សួរអ្នកពាក់ព័ន្ធសំខាន់ៗ ដូចជាឪពុកម្តាយឬអាណាព្យាបាលកុមារ (អាយុពី៣ ដល់៥ឆ្នាំ) និងក្មេងជំទង់ (អាយុពី១០ ដល់១៨ឆ្នាំ)។ ចម្លើយពីការអង្កេតនេះ បង្កើតបានជាទិន្នន័យ ដែលត្រូវយកទៅបញ្ជាក់ផ្ទៀងផ្ទាត់ និងវិភាគបន្ថែមទៀតដោយប្រើប្រាស់ឧបករណ៍បែបគុណវិស័យ ដូចជា ការពិភាក្សាក្រុមគោលដៅជាមួយនឹងសមាជិកសហគមន៍ ឪពុកម្តាយ/អ្នកផ្តល់ការថែទាំ និងក្មេងជំទង់អាយុពី១០ ដល់១៨ឆ្នាំ ក៏ដូចជាសម្ភាសន៍ដោយប្រើសំណួរព្រាងទុកជាមុនផង និងមិនបានព្រាងទុកជាមុនផង ជាមួយនឹងតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល គ្រូបង្រៀនមកពីតាមសាលារៀននានាក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង និងមន្ត្រីរដ្ឋាភិបាលមកពីតាមក្រសួងពាក់ព័ន្ធសំខាន់ៗ។

ស្របតាមការរៀបចំការវាយតម្លៃនេះ កម្រងសំណួរត្រូវបានប្រើប្រាស់ជាមួយនឹងអ្នកឆ្លើយតបចំនួន ១១៩០ នាក់ ដែលត្រូវបានជ្រើសរើសជាសំណាក ក្នុងនោះមានឪពុកម្តាយឬអាណាព្យាបាលកុមារអាយុពី៣ ដល់៥ឆ្នាំ ចំនួន៣៨០នាក់ និងឪពុកម្តាយឬអាណាព្យាបាលក្មេងជំទង់អាយុពី១០ ដល់១៨ឆ្នាំចំនួន ៣៨០នាក់ ដោយមានក្មេងស្រីជំទង់ចំនួន១៩០នាក់ និងក្មេងប្រុសជំទង់ ១៩០នាក់ ក្នុងក្រុមអាយុ១០ ដល់១៨ឆ្នាំផងដែរ។ បញ្ជីឈ្មោះគ្រួសារត្រូវបានរៀបចំទុកជាមុន ដើម្បីកំណត់រកគ្រួសារ និងធានាថាព័ត៌មានដែលប្រមូលសម្រាប់កុមារក្នុងក្រុមអាយុ៣ ដល់៥ឆ្នាំ និងក្មេងជំទង់ ក្នុងក្រុមអាយុ ១០ ដល់១៨ឆ្នាំ មិនត្រូវបានប្រមូលពីគ្រួសារដដែលឡើយ។

## របកគំហើញសំខាន់ៗ៖

ក) **ហានិភ័យសំខាន់ៗពាក់ព័ន្ធនឹងកិច្ចការពារកុមារ** ដែលត្រូវបានរកឃើញក្នុងសហគមន៍ ហើយដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងភាពក្រីក្រ និងការខ្វះការថែទាំឲ្យបានគ្រប់គ្រាន់ពីសំណាក់ឪពុកម្តាយ រួមមាន ការប្រើបំពានសារធាតុ ការចូលរួមក្នុងក្រុមយុវជនទំនើង ដែលនាំឲ្យមានទំនាស់នឹងច្បាប់ ការដាក់ទណ្ឌកម្មលើរាងកាយ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការបំពានផ្លូវភេទ អាពាហ៍-ពិពាហ៍កុមារ និងពលកម្មកុមារ។ បន្ថែមពីលើហានិភ័យទាំងនេះ កុមារ និងក្មេងជំទង់ ក៏មានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាថែទាំសុខភាព និងអនាម័យផងដែរ ហើយជារឿយៗ ពុំមានបរិក្ខាររូបវន្តជាមូលដ្ឋានសម្រាប់ប្រើប្រាស់ ដូចជាបង្គន់ និងទឹកស្អាតសម្រាប់ផឹកឡើយ។ ក្រុមដែលកាន់តែងាយរងគ្រោះជាងគេ រួមមាន កុមារ និងក្មេងជំទង់ដែលមានពិការភាព កុមារកំព្រា និងកុមារត្រូវបានគេបោះបង់ចោលគ្មានទីជម្រកសម្រាប់ជ្រកកោន។ កុមារ និងក្មេងជំទង់

ដែលមានពិការភាព ជារឿយៗគឺជាក្រុមដែលត្រូវបានគេផាត់ចេញពីក្របខ័ណ្ឌសង្គម។

ខ) **ភាពក្រីក្រ និងហានិភ័យសំខាន់ៗ** ដែលកុមារ និងក្មេងជំទង់តាមសហគមន៍ក្រីក្រក្នុងទីក្រុង ជួបប្រទះ មានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ។ ការមានប្រាក់ចំណូលទាបមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការថែទាំកុមារមិនបានជិតដល់ពីសំណាក់ឪពុកម្តាយឬអាណាព្យាបាល ដោយសារពួកគាត់ត្រូវចំណាយពេលភាគច្រើនរកចំណូល ដើម្បីបំពេញតម្រូវការជាមូលដ្ឋានក្នុងគ្រួសារ។ ការប្រើបំពានសារធាតុញៀន ក្នុងចំណោមអ្នកឆ្លើយតបជាក្មេងជំទង់ ត្រូវបានរកឃើញថាកើតមានច្រើនដោយពួកគេប្រមាណជា ៨១,៤ ភាគរយ (ស្រី ៧៥,២ ភាគរយ និងប្រុស ៨៨,២ ភាគរយ) លើកឡើងថាពួកគេជាអ្នកប្រើជាតិស្រវឹង (ជាពិសេស ស្រាបៀរ)។ អ្វីដែលរឹតតែសំខាន់ទៅទៀតគឺ ៤៣,៨ ភាគរយនៃក្មេងជំទង់ (ស្រី ២៦,៦ ភាគរយ និងប្រុស ៦១ ភាគរយ) ដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ បានប្រើប្រាស់គ្រឿងញៀន (ជាពិសេស កញ្ឆា ហេរ៉ូអ៊ីន និងមេតំហ្វេតាមីន) យ៉ាងហោចណាស់ម្តងក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ។ ការប្រើបំពានសារធាតុញៀន ក៏មានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងការចូលជាសមាជិកក្នុងក្រុមយុវជនទំនើងផងដែរដោយក្រុមទំនើងទាំងនេះ តែងតែប្រព្រឹត្តអំពើហិង្សា និងវាយតប់គ្នា។ ក្មេងជំទង់ជាងពាក់កណ្តាល (៥២,៤ ភាគរយ) ដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញមានមិត្តភក្តិ ឬអ្នកស្គាល់គ្នា (ក្នុងក្រុមដែលមានអាយុស្របាលគ្នា) ជាសមាជិករបស់ក្រុមទំនើងណាមួយ។ អំពើហិង្សាក្នុងគ្រួសារក៏ជាករណីដែលតែងកើតឡើងញឹកញាប់ផងដែរ។ ក្មេងប្រុសប្រមាណជា ៦៥,៩ ភាគរយ និងក្មេងស្រី ៦៥,៣ ភាគរយ លើកឡើងថា ពួកគេធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារ (ក្នុងរយៈពេល១២ខែចុងក្រោយនេះ) កើតឡើងក្នុងផ្ទះ ឬក្នុងសហគមន៍។ អាពាហ៍ពិពាហ៍កុមារ គឺជាហានិភ័យសំខាន់មួយទៀត ហើយមានគ្រួសារ ៩,៩ ភាគរយរាយការណ៍ថា ពួកគេបានរៀបការឲ្យក្មេងជំទង់ចេញពីគ្រួសារ មុនពេលពួកគេអាយុ១៨ ឆ្នាំ។ ខណៈពេលដែលទិន្នន័យដែលប្រមូលបានអំពីករណីពលកម្មកុមារមានកម្រិតទាបជាងកម្រិតមធ្យមនៅថ្នាក់ជាតិ អត្រាទាបបែបនេះកើតឡើងដោយសារតែអ្នកឆ្លើយតបមានការស្ទាក់ស្ទើរមិនចង់ឆ្លើយសំណួរព្រោះពួកគេដឹងថា ពលកម្មកុមារគឺជាសកម្មភាពខុសច្បាប់។

គ) **ឧបសគ្គសំខាន់ៗ ដែលរាំងស្ទះដល់ការទទួលបានការអប់រំ និងហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងសាលារៀន** រួមមាន អត្រាចុះឈ្មោះចូលរៀនទាបនៅកម្រិតមត្តេយ្យសិក្សា ការចូលរៀនមានកម្រិតទាប ការបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់នៅកម្រិតមធ្យមសិក្សា ការបង្រៀនមានគុណភាពទាប ភាពចាំបាច់ក្នុងការបង់ប្រាក់ក្រៅផ្លូវការ ការដាក់ទណ្ឌកម្មលើរាងកាយ ការសម្លុតគំរាម និងការខ្វះខាតសម្ភារបរិក្ខា សម្រាប់បំពេញតម្រូវការរបស់កុមារពិការ។ បើទោះបីទាំងកុមារ និងឪពុកម្តាយសុទ្ធតែមានបំណងប្រាថ្នាខ្ពស់ពាក់ព័ន្ធនឹងការអប់រំក៏ការចុះឈ្មោះចូលរៀននៅកម្រិតមត្តេយ្យសិក្សាក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងនៅមានកម្រិតទាប ដោយមានកុមារអាយុពី៣ ទៅ៥ឆ្នាំ ត្រឹមតែ ២៩ ភាគរយប៉ុណ្ណោះ បានចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យក្នុងទម្រង់ណាមួយ។ ខណៈដែលអត្រាចុះឈ្មោះចូលរៀនបានកើនឡើងក្នុងចំណោមកុមារមកពីសហគមន៍ក្រីក្រដែលមានអាយុច្រើនជាងនេះ ដែលក្នុងនោះក្មេងជំទង់អាយុពី ១០ ដល់ ១៤ឆ្នាំ ប្រមាណជា ៨៥ ភាគរយ បានចុះឈ្មោះចូលរៀនតាមសាលារៀនក្នុងប្រព័ន្ធក្តី ក៏អត្រាបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាមានការកើនឡើងផងដែរ។ ក្នុងចំណោមក្មេងជំទង់ដែលបោះបង់ចោលការសិក្សាកាលពីពេលថ្មីៗនេះ ៨៧,៥ ភាគរយ បានលើកឡើងថា ពួកគេធ្លាប់បានចូលរៀន។ ការខ្វះការយកចិត្តទុកដាក់ពីគ្រូក៏ដូចជាភាពចាំបាច់ក្នុងការបង់ថ្លៃក្រៅផ្លូវការ ឬការផ្តល់ប្រាក់ដល់គ្រូ គឺជាឧបសគ្គសំខាន់ៗដែលបន្ថយបង្អាក់ដល់ការចូលរៀន និងការបន្តរៀនសូត្រតាមសាលារៀននានា។ ដោយហេតុថាពួកគេកំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្ររួចទៅហើយនោះ ឪពុកម្តាយមិនអាចមានលទ្ធភាពបង់ថ្លៃសេវាក្រៅផ្លូវការបានឡើយ។ ការបង្រៀន

មានគុណភាពទាប គឺជាឧបសគ្គចម្បងមួយទៀតចំពោះការអប់រំ ដោយសារគ្រូបង្រៀនពុំបានទទួលបៀវត្សគ្រប់គ្រាន់ ហើយពួកគេពុំបានទទួលការបណ្តុះបណ្តាលចាំបាច់នានាដើម្បីឲ្យពួកគេមានវិធីសាស្រ្តបង្រៀនប្រកបដោយប្រសិទ្ធភាពឡើយ។ លើសពីនេះ ការខ្វះការបណ្តុះបណ្តាលអំពីរបៀបទំនាក់ទំនងជាមួយសិស្សមានពិការភាព គឺជាបញ្ហាប្រឈមដ៏ចម្បងមួយ ចំពោះការបង្កើតបរិយាកាសបរិយាប័ន្ន (មានការចូលរួមពីកុមារពិការ) ក្នុងសាលារៀន។ ការដាក់ទណ្ឌកម្មលើរាងកាយ និងការរករឿងឈ្លោះ ក៏កើតមានជាទូទៅនៅតាមសាលារៀនក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងផងដែរ។ សិស្ស ២៥,៧ ភាគរយ បានលើកឡើងថា ធ្លាប់ទទួលរងការរករឿងឈ្លោះក្នុងសាលារៀន ហើយក្នុងចំណោមក្មេងជំទង់ដែលធ្លាប់ទៅសាលារៀន មាន ៣០,៥ ភាគរយ រាយការណ៍ ថាធ្លាប់ទទួលរងការដាក់ទណ្ឌកម្មលើរាងកាយ។

## អនុសាសន៍៖

អនុសាសន៍ចេញពីការស្រាវជ្រាវនេះ ផ្តោតលើការអភិវឌ្ឍសមត្ថភាព និងការពង្រឹងការងារសំខាន់ៗនៅកម្រិតសាលារៀន កម្រិតសហគមន៍ និងថ្នាក់ជាតិ ដូចជា៖

- ការរៀបចំអន្តរាគមន៍សម្រាប់ដោះស្រាយបញ្ហាអំពើហិង្សា ការរករឿងឈ្លោះ ការអប់រំផ្លូវភេទ និងការបំពានសារធាតុញៀន ដោយការបញ្ចូលមេរៀនពាក់ព័ន្ធនឹងបញ្ហាទាំងនេះក្នុងកម្មវិធីសិក្សា។
- យុទ្ធនាការផ្លាស់ប្តូរឥរិយាបថតាមសហគមន៍ ដែលផ្តោតការយកចិត្តទុកដាក់លើការប្រើបំពាន សារធាតុ ការដាក់ទណ្ឌកម្មលើរាងកាយ អាពាហ៍ពិពាហ៍ របស់ក្មេងជំទង់ អំពើហិង្សាលើកុមារ និងការជួញដូរមនុស្ស
- បង្កើតក្រុមសុវត្ថិភាពសហគមន៍ ដើម្បីការពារ និងថែរក្សា សន្តិសុខ និងសុវត្ថិភាពក្នុងសហគមន៍។
- ការបណ្តុះបណ្តាលសមាជិកស្ថាប័នពង្រឹងការអនុវត្តច្បាប់
- គំនិតផ្តួចផ្តើមទាក់ទងនឹងផ្នែកតម្រូវការ និងការផ្គត់ផ្គង់ ដើម្បីបង្កើនលទ្ធភាពទទួលបានទឹកស្អាត
- ការប្រែក្លាយសហគមន៍ក្រីក្រក្នុងទីក្រុងជាសហគមន៍ដែលពុំមានការបន្ទោរបង់ពាសវាលពាសកាល
- ការចុះបញ្ជី និងការគ្រប់គ្រងមណ្ឌលកុមារកំព្រា ឬមណ្ឌលថែទាំកុមារ
- ការចូលរួមរបស់អង្គការសង្គមស៊ីវិលលើការងារសវនកម្មសង្គម និងធានាឲ្យមានការអនុលោមតាមបញ្ញត្តិច្បាប់
- ការបណ្តុះបណ្តាលក្រុមប្រឹក្សាកុមារ និងបុគ្គលជំនាញផ្នែកសង្គមកិច្ច។
- ការរៀបចំមាគ៌ាអាជីពសម្រាប់គ្រូបង្រៀន
- ការបង្កើនប្រសិទ្ធភាពការងារនៃគណៈកម្មាធិការពិនិត្យតាមដានការងារសាលារៀន
- ការកែលម្អយន្តការបណ្តុះបណ្តាលគ្រូដែលមានស្រាប់
- ការបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន
- ការបង្កើតក្របខ័ណ្ឌពិនិត្យតាមដានសិទ្ធិកុមារសម្រាប់រាជធានីភ្នំពេញ។

# ពាក្យសរសេរកាត់

| | | |
|---|---|---|
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **AIDS** | Acquired Immune Deficiency Syndrome | ចង្កោមរោគសញ្ញាដែលធ្វើឲ្យចុះខ្សោយដល់ប្រព័ន្ធភាពស៊ាំរាងកាយ |
| **CAFEMBA-PAECL** | CAMFEBA Plan of Action on the Elimination of Child Labor (WF) | ផែនការសកម្មភាពស្តីពីការលុបបំបាត់ពលកម្មកុមាររបស់ CAMFEBA |
| **CCWC** | Commune Committee for Women and Children | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ |
| **CDIDF** | Cambodia Disability Inclusive Development Fund | មូលនិធិអភិវឌ្ឍន៍ជនពិការនៅកម្ពុជា |
| **CFSP** | Child Friendly School Policy | គោលនយោបាយសាលាកុមារមេត្រី |
| **CLFCLS** | Cambodia Labour Force and Child Labour Survey | ការអង្កេតស្តីពីកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជា |
| **CMDG** | Cambodian Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា |
| **CNCC** | Cambodia National Council for Children | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| **CPCCL** | Child Protection Code in Cambodian Law | ក្រមស្តីពីការការពារកុមារក្នុងច្បាប់កម្ពុជា |
| **CRC** | United Nations Convention on the Rights of the Child | អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| **DRIC** | Disability Rights Initiative | គំនិតផ្តួចផ្តើមសិទ្ធិជនពិការ |
| **EFA** | Education For All | ការអប់រំសម្រាប់ទាំងអស់គ្នា |
| **ESP** | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| **ESSP** | Education Sector Support Programme | វិធីគាំទ្រវិស័យអប់រំ |
| **EWSG** | Education Working Sector Group | ក្រុមការងារវិស័យអប់រំ |
| **FTI** | Fast Track Initiative | គំនិតផ្តួចផ្តើមពន្លឿនការអប់រំ |
| **FTIRM** | Fast Track Initiative Road Map for Reducing Maternal and Newborn Morality | ផែនទីបង្ហាញផ្លូវនៃគំនិតផ្តួចផ្តើមពន្លឿនការកាត់បន្ថយមរណភាពមាតា និងទារកទើបកើត |
| **HIV** | Human Immunodeficiency Virus | វីរុសដែលធ្វើឲ្យចុះខ្សោយដល់ប្រព័ន្ធភាពស៊ាំរាងកាយ |
| **MoEYS** | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoI** | Ministry of Interior | ក្រសួងមហាផ្ទៃ |
| **MoJ** | Ministry of Justice | ក្រសួងយុត្តិធម៌ |
| **MoSVY** | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | | |
|---|---|---|
| **NAPECD** | National Action Plan on Early Childhood Care and Development | ផែនការសកម្មភាពជាតិស្តីពីកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច |
| **NEP** | NGO Education Partnership | ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| **NGO** | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| **NPACTP** | National Plan of Action on Counter Trafficking in Persons | ផែនការសកម្មភាពជាតិស្តីពីការប្រឆាំងការជួញដូរមនុស្ស |
| **NPATPSE** | National Plan of Action against Trafficking in Persons and Sexual Exploitation | ផែនការសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ |
| **NPA-WFCL** | National Plan of Action on the Elimination of the Worst Forms of Child Labor | ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ |
| **NPP** | National Population Policy | គោលនយោបាយជាតិស្តីពីប្រជាជន |
| **NRHP** | National Reproductive Health Programme | កម្មវិធីជាតិសុខភាពបន្តពូជ |
| **NSMAP** | National Safe Motherhood Action Plan | ផែនការសកម្មភាពជាតិស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ |
| **PACC** | Policy on Alternative Care for Children | គោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ |
| **PDVPV** | Prevention of Domestic Violence and Protection of Victims | ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ |
| **PEWFCL** | Plan on the Elimination of the Worst Forms of Child Labor | ផែនការស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **SHSP** | Second Health Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលដំណាក់កាលទីពីរ |
| **UNDP** | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **UNESCO** | United Nations Education, Science and Cultural Organization | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ |
| **UNFPA** | United Nations Population Fund | មូលនិធិសហប្រជាជាតិដើម្បីប្រជាជន |
| **UNHABITAT** | United Nations Human Settlements Programme | កម្មវិធីលំនៅដ្ឋានមនុស្សរបស់សហប្រជាជាតិ |
| **UNICEF** | United Nations Children's Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| **VAC** | Cambodia's Violence Against Children Survey | ការអង្កេតលើអំពើហិង្សាលើកុមារនៅកម្ពុជា |
| **WASH** | Water Sanitation and Hygiene | ទឹកស្អាត និងអនាម័យ |
| **WHO** | World Health Organization | អង្គការសុខភាពពិភពលោក |

# មាតិកា



១៤
សាវតារ


៧៧
ស្ថានភាពគោលនយោបាយ និងកម្មវិធីបច្ចុប្បន្ន


២៦
អភិក្រម និងវិធីសាស្ត្រ


១០៤
ការអភិវឌ្ឍសមត្ថភាពក្រសួង ឬស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល


៣៦
ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ ក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ


១០៩
សេចក្តីសន្និដ្ឋាន


៦០
ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារតាមសាលារៀន


១១២
អនុសាសន៍

# បញ្ជីរូបភាព


| | | |
|---|---|---|
| រូបភាពទី១៖ | កម្រិតនៃការចូលរួមរបស់ឪពុកម្ដាយក្នុងការចិញ្ចឹមកូន ទៅតាមការរាយការណ៍របស់ក្មេងជំទង់ | ៣៨ |
| រូបភាពទី២៖ | ភាគរយនៃក្មេងជំទង់ ដែលប្រើប្រាស់ជាតិស្រវឹង ឬគ្រឿងញៀន | ៣៩ |
| រូបភាពទី៣៖ | ភាគរយនៃក្មេងជំទង់ ដែលមានមិត្តភក្តិឬអ្នកស្គាល់គ្នាជាសមាជិករបស់ក្រុមទំនើង | ៤១ |
| រូបភាពទី៤៖ | ភាគរយនៃក្មេងជំទង់ដែលដឹងពីករណីក្មេងជំទង់មានទំនាស់ជាមួយច្បាប់ | ៤១ |
| រូបភាពទី៥៖ | ភាគរយឪពុកម្ដាយ ដែលរាយការណ៍ថាបានប្រើប្រាស់ការដាក់ទណ្ឌកម្មរាងកាយដើម្បីដាក់វិន័យកូនរបស់ខ្លួន | ៤២ |
| រូបភាពទី៦៖ | ភាគរយនៃក្មេងជំទង់ដែលរាយការណ៍ថាធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារ | ៤៣ |
| រូបភាពទី៧៖ | ភាគរយគ្រួសារ ដែលរាយការណ៍ថាពុំបានធ្វើសកម្មភាពអ្វីទាំងអស់ បន្ទាប់ពីបានសង្កេតឃើញមានករណីអំពើហិង្សាកើតមានឡើង | ៤៤ |
| រូបភាពទី៨៖ | ភាគរយគ្រួសារដែលរាយការណ៍ថាបានដឹងពីករណីរំលោភបំពាន ឬអំពើហិង្សាផ្លូវភេទ | ៤៤ |
| រូបភាពទី៩៖ | ភាគរយគ្រួសារដែលរាយការណ៍ថាបានដឹងពីករណីកុមារបាត់ខ្លួន | ៤៦ |
| រូបភាពទី១០៖ | ភាគរយគ្រួសារដែលរាយការណ៍ថា កុមារបាត់ខ្លួនអាចប្រឈមនឹងហានិភ័យត្រូវបានគេយកទៅលក់ | ៤៦ |
| រូបភាពទី១១៖ | ភាគរយនៃគ្រួសារដែលមើលថែកុមារដែលជាកូនកំព្រា ឬកូនដែលត្រូវបានគេបោះបង់ចោល | ៤៧ |
| រូបភាពទី១២៖ | ភាគរយនៃគ្រួសារដែលរាយការណ៍ថា កុមារដែលត្រូវបានគេបោះបង់ចោលទទួលរងការរំលោភបំពានពីសមាជិកសហគមន៍ | ៤៨ |
| រូបភាពទី១៣៖ | ភាគរយនៃកុមារនិងក្មេងជំទង់ដែលមានសំបុត្រកំណើត | ៤៩ |
| រូបភាពទី១៤៖ | ភាគរយនៃកុមារ និងក្មេងជំទង់ ដែលមានពិការភាពក្នុងទម្រង់ណាមួយ | ៤៩ |
| រូបភាពទី១៥៖ | ប្រភេទពិការភាព | ៥០ |
| រូបភាពទី១៦៖ | ភាគរយនៃគ្រួសារដែលរាយការណ៍ពីករណីអាពាហ៍ពិពាហ៍កុមារ | ៥២ |
| រូបភាពទី១៧៖ | មូលហេតុដែលនាំឲ្យមានការរៀបអាពាហ៍ពិពាហ៍ឲ្យកុមារមុនពេលពួកគេឈានដល់នីតិភាព សម្រាប់អាពាហ៍ពិពាហ៍ | ៥២ |
| រូបភាពទី១៨៖ | ភាគរយនៃគ្រួសារដែលរាយការណ៍ពីការចូលរួមរបស់កុមារក្នុងកម្លាំងពលកម្ម | ៥៣ |

| | | |
|---|---|---|
| រូបភាពទី១៩៖ | ភាគរយគ្រួសារដែលរាយការណ៍ថាមានបង្គន់ប្រើប្រាស់ក្នុងផ្ទះ | ៥៥ |
| រូបភាពទី២០៖ | ភាគរយនៃកុមារ និងមនុស្សពេញវ័យដែលលាងសម្អាតដៃ (ជាមួយសាប៊ូ) ក្រោយប្រើបង្គន់រួច | ៥៥ |
| រូបភាពទី២១៖ | ភាគរយនៃកុមារ និងក្មេងជំទង់ ដែលដុសធ្មេញជាប្រចាំ | ៥៦ |
| រូបភាពទី២២៖ | ប្រភពទឹកសម្រាប់ផឹក | ៥៧ |
| រូបភាពទី២៣៖ | ការមានប្រព័ន្ធចម្រោះទឹកក្នុងផ្ទះ | ៥៧ |
| រូបភាពទី២៤៖ | ភាគរយនៃក្មេងជំទង់ដែលសកម្មខាងផ្លូវភេទ | ៥៨ |
| រូបភាពទី២៥៖ | ភាគរយនៃករណីក្មេងជំទង់មានផ្ទៃពោះ ដែលមានបញ្ហាសុខភាព | ៥៩ |
| រូបភាពទី២៦៖ | បំណងប្រាថ្នាពីការអប់រំ តាមការលើកឡើងរបស់ក្មេងជំទង់កំពុងរៀនតាមសាលា | ៦០ |
| រូបភាពទី២៧៖ | ស្ថិតិបង្ហាញពីការចុះឈ្មោះចូលរៀនរបស់កុមារក្នុងក្រុមអាយុ៣ ដល់៥ឆ្នាំ | ៦២ |
| រូបភាពទី២៨៖ | ស្ថិតិនៃការចុះឈ្មោះចូលរៀនរបស់ក្មេងជំទង់អាយុពី១០ ដល់១៨ឆ្នាំ | ៦២ |
| រូបភាពទី២៩៖ | មូលហេតុដែលនាំឲ្យកុមារអាយុ៣ ដល់៥ឆ្នាំ មិនបានចូលរៀន | ៦៣ |
| រូបភាពទី៣០៖ | មូលហេតុ ដែលនាំឲ្យកុមារក្នុងក្រុមអាយុ១០ ដល់១៨ឆ្នាំ មិនបានទៅរៀន | ៦៣ |
| រូបភាពទី៣១៖ | ការបោះបង់ចោលការសិក្សា គិតជាភាគរយនៃកុមារក្រៅសាលា | ៦៤ |
| រូបភាពទី៣២៖ | មូលហេតុដែលនាំឲ្យកុមារក្នុងក្រុមអាយុ១០ ដល់១៨ឆ្នាំ មិនបានទៅរៀន | ៦៥ |
| រូបភាពទី៣៣៖ | អត្រានៃការសិក្សារបស់កុមារ និងក្មេងជំទង់មានពិការភាព | ៦៦ |
| រូបភាពទី៣៤៖ | ស្ថានភាពនៃការសិក្សាកន្លងមករបស់ក្មេងជំទង់មានពិការភាពដែលបច្ចុប្បន្នកំពុងនៅក្រៅសាលា | ៦៦ |
| រូបភាពទី៣៥៖ | ការយល់ឃើញរបស់ឪពុកម្តាយអំពីភាពគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធ/បរិក្ខារក្នុងសាលារៀនសម្រាប់សិស្សមានពិការភាព | ៦៧ |

| | | |
|---|---|---|
| រូបភាពទី៣៦៖ | កម្រិតនៃការពេញចិត្តរបស់ឪពុកម្ដាយជាមួយហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន សុវត្ថិភាព និងសមត្ថភាពរបស់គ្រូ | ៦៨ |
| រូបភាពទី៣៧៖ | ការយល់ឃើញរបស់ឪពុកម្ដាយអំពីសមត្ថភាពរបស់គ្រូក្នុងការបំពេញទៅតាមតម្រូវការនៃការរៀនសូត្រនៃសិស្សពិការ | ៦៨ |
| រូបភាពទី៣៨៖ | ភាគរយនៃក្មេងជំទង់ដែលរាយការណ៍ថាធ្លាប់ត្រូវបានគេរករឿងឈ្លោះក្នុងសាលារៀន | ៧០ |
| រូបភាពទី៣៩៖ | ការយល់ឃើញរបស់សិស្សពីមូលហេតុដែលករណីរករឿងឈ្លោះកើតមានឡើង | ៧១ |
| រូបភាពទី៤០៖ | ករណីរករឿងឈ្លោះក្នុងសាលារៀន ទៅតាមការលើកឡើងរបស់ក្មេងជំទង់ពិការ | ៧២ |
| រូបភាពទី៤១៖ | ភាគរយនៃក្មេងជំទង់ទៅសាលារៀន ដែលរាយការណ៍ថាធ្លាប់ទទួលរងទណ្ឌកម្មលើរាងកាយ | ៧២ |
| រូបភាពទី៤២៖ | ការយល់ឃើញរបស់ឪពុកម្ដាយចំពោះការដាក់ទណ្ឌកម្មរាងកាយ នៅតាមសាលារៀន | ៧៣ |
| រូបភាពទី៤៣៖ | ការឆ្លើយតបរបស់ឪពុកម្ដាយចំពោះករណីទណ្ឌកម្មលើរាងកាយក្នុងសាលារៀន | ៧៣ |
| រូបភាពទី៤៤៖ | ភាគរយនៃក្មេងជំទង់ ដែលចូលរួមក្នុងវគ្គបង្កើនការយល់ដឹងអំពីសុខភាព និងអនាម័យតាមសាលារៀន | ៧៤ |
| រូបភាពទី៤៥៖ | ភាគរយនៃក្មេងជំទង់ ដែលចូលរួមក្នុងវគ្គផ្សព្វផ្សាយអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជតាមសាលារៀន | ៧៥ |
| រូបភាពទី៤៦៖ | ភាគរយរបស់ក្មេងជំទង់ក្រៅសាលា ដែលប្រឡូកក្នុងពលកម្មកុមារ | ៧៥ |

# បញ្ជីតារាង

| | | |
|---|---|---|
| តារាងទី១៖ | របាយអាយុរបស់ក្មេងជំទង់ និងកម្រិតថ្នាក់ដែលពួកគេកំពុងសិក្សា | ៦៥ |



# សាវតារ

# រាជធានីភ្នំពេញ៖ ទិដ្ឋភាពរួម

ភ្នំពេញដែលជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា មានទីតាំងស្ថិតនៅភូមិភាគខាងត្បូង-កណ្តាលនៃប្រទេស។ រាជធានីនេះត្រូវបានបង្កើតឡើងក្នុងសម័យបារាំងធ្វើអាណានិគមលើប្រទេសកម្ពុជា ហើយបច្ចុប្បន្ននេះ រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ច នយោបាយ និងវប្បធម៌។ ដូច្នេះ គ្មានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលទីក្រុងនេះគឺជាទីតាំងមួយក្នុងចំណោមខេត្តដែលមានចំនួនប្រជាជនច្រើនជាងគេក្នុងប្រទេសនោះ។[3]

ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម កាលពីឆ្នាំ១៩៧៩ មក ទីក្រុងភ្នំពេញចាប់ផ្តើមមានមនុស្សមករស់នៅជាបណ្តើរៗ ដូចជា អ្នកធ្លាប់រស់នៅទីក្រុងនេះកាលពីមុនសង្គ្រាម ជនភៀសខ្លួន ជនបាត់បង់ទីលំនៅ និងអ្នកចំណាកស្រុកពីតំបន់ជនបទ។ ការកាន់កាប់អគារនានា គឺធ្វើឡើងដោយ "អ្នកមកមុន កាន់កាប់មុន" ហើយអ្នកចូលមកក្រោយៗ និងប្រជាជនក្រីក្រ នាំគ្នាបង្កើតកន្លែងតាំងទីលំនៅមិនរៀបរយលើកដំបូងក្នុងទីក្រុងនេះ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០។[4] កំណើនសេដ្ឋកិច្ចយ៉ាងលឿនបានទាក់ទាញអ្នកធ្វើចំណាកស្រុកជាច្រើនឲ្យចូលមករស់នៅក្នុងរាជធានីភ្នំពេញ នាំឲ្យចំនួនប្រជាជនក្នុងទីក្រុងភ្នំពេញកើនឡើងទ្វេដង ពីឆ្នាំ១៩៩៨ ដល់២០០៨ និងនាំឲ្យមានការពង្រីកទីក្រុងនេះទៅតំបន់ខាងក្រៅដែលនៅជិតៗបន្ថែមទៀត។ បច្ចុប្បន្ន រាជធានីភ្នំពេញមាន១២ខណ្ឌ (ខណ្ឌចំការមន ដូនពេញ ៧មករា ទួលគោក ដង្កោ មានជ័យ ឬស្សីកែវ សែនសុខ ពោធិសែនជ័យ ជ្រោយចង្វារ ព្រែកព្នៅ និងច្បារអំពៅ) ដែលមានទីតាំងនៅក្នុង និងនៅតាមជាយទីក្រុងភ្នំពេញ។

បើតាមការអង្កេតមួយក្នុងទីក្រុងភ្នំពេញ កាលពីឆ្នាំ២០១៤ ដែលមានឈ្មោះថា ការសិក្សាអំពីការតាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងភ្នំពេញ ចំនួនប្រជាជនសរុបតាមខណ្ឌទាំងនេះគឺប្រមាណជា ១,៦ លាននាក់ ហើយអ្នករស់នៅក្នុងទីក្រុងប្រមាណមួយភាគបួនរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ពោលគឺក្រោម ១,៥៨ ដុល្លារក្នុងមួយថ្ងៃ។[5] ប្រជាពលរដ្ឋក្រីក្រទាំងនេះរស់នៅតាមតំបន់តូចៗផ្សេងៗគ្នា តាមខណ្ឌដែលស្ថិតនៅកណ្តាលក្រុង និងខណ្ឌជាយក្រុង របស់រាជធានីភ្នំពេញ។ ប៉ុន្តែ បញ្ហាប្រឈមដែលលេចឡើងថ្មី គឺការកំណត់និយមន័យថា តើសហគមន៍ប្រភេទណាដែលជាសហគមន៍ក្រីក្រក្នុងទីក្រុង ដោយហេតុថាការកំណត់ភាពក្រីក្រទៅតាមកម្រិតដាច់ណាត់គឺមិនទាន់គ្រប់គ្រាន់ឡើយ។ ដូច្នេះ សម្រាប់គោលបំណងនៃការសិក្សានេះ ក្រុមការងារនៃក្រុមហ៊ុន Ernst and Young LLP បានយកនិយមន័យដែលប្រើដោយរដ្ឋបាលរាជធានីភ្នំពេញមកប្រើប្រាស់៖[6]

- សហគមន៍ដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ (ដូចជានៅតាមផ្លូវដែក ផ្លូវគោក ប្រឡាយ បឹង មាត់ទន្លេ លើដំបូលអគារចាស់ៗ វត្តអារាម កន្លែងសក្ការៈ ឬកន្លែងកប់សព) ដីឯកជនរបស់រដ្ឋ ដីសហគមន៍ ដីឯកជនរបស់បុគ្គល កន្លែងដែលរដ្ឋាភិបាលផ្តល់សម្រាប់បង្កើតតំបន់តាំងទីលំនៅថ្មីៗ និងដីឯកជន ដែលសហគមន៍ ឬរដ្ឋាភិបាលជួលឲ្យសហគមន៍តាំងទីលំនៅ។
- សហគមន៍ដែលមានប្រជាពលរដ្ឋចាប់ពី៣០គ្រួសារ ឬ៣០ខ្នងផ្ទះឡើងទៅ។
- ក្នុងករណីដែលសហគមន៍ មានតិចជាង៣០គ្រួសារ ឬខ្នងផ្ទះ ដូចដែលលើកឡើងខាងលើ អាជ្ញាធរមូលដ្ឋានអាចធ្វើការកំណត់ថាតើពួកគេជាសហគមន៍ក្រីក្រ ឬជាផ្នែកមួយនៃសហគមន៍ក្រីក្រដែរឬទេ ផ្អែកទៅតាមស្ថានភាពជាក់ស្តែង។
- សហគមន៍ដែលលំនៅដ្ឋានមានស្ថានភាពមិនរៀបរយ ដូចជាផ្ទះតង់ ផ្ទះស្បូវ ផ្ទះចាស់ខ្លាំង។ល។
- សហគមន៍ដែលប្រជាពលរដ្ឋធ្វើការជាកម្មកររោងចក្រ កម្មករសំណង់ អ្នករត់ម៉ូតូឌុប អ្នករត់រ៉ឺម៉ក អ្នកលក់ដូរតាមសហគមន៍ អ្នកផលិតគ្រឿងសិប្បកម្ម អ្នករើសអេតចាយ អ្នកផ្តល់សេវានានា ដូចជា អ្នកធ្វើការងារតាមរង្គសាល កន្លែងម៉ាស្សា អ្នកធ្វើការតាមផ្ទះ។ល។

[3] *រដ្ឋបាលរាជធានីភ្នំពេញ*
[4] *សមាគមធាងត្នោត (២០១៤) ការអង្កេតក្នុងទីក្រុងភ្នំពេញ៖ ការសិក្សាអំពីតំបន់តាំងទីលំនៅរបស់ប្រជាជនក្រីក្រ ក្នុងទីក្រុងភ្នំពេញ។*
[5] *សមាគមធាងត្នោត (២០១៤) ការអង្កេតក្នុងទីក្រុងភ្នំពេញ៖ ការសិក្សាអំពីតំបន់តាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រ ក្នុងទីក្រុងភ្នំពេញ។*
[6] *សាលារាជធានីភ្នំពេញ៖ និយមន័យប្រើដោយការិយាល័យសហគមន៍ក្រីក្រនៃរដ្ឋបាលរាជធានីភ្នំពេញ។*

- សហគមន៍ដែលនៅមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដូចជាប្រព័ន្ធលូ ផ្លូវ អគ្គិសនី ទឹកស្អាត បង្គន់ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តផ្សេងទៀត។

និយមន័យខាងលើផ្តល់លទ្ធភាពឲ្យក្រុមការងារកំណត់យ៉ាងច្បាស់លាស់នូវសំណាកគំរូរបស់យើង និងរកក្រុមដែលមានលក្ខណៈដូចគ្នាសម្រាប់ប្រមូលទិន្នន័យពីពួកគេ។ ប៉ុន្តែ វាមានន័យផងដែរថា ក្រុមជនអនាថា ឬសំណង់ ដែលមិនសមស្របទៅតាមលក្ខណៈវិនិច្ឆ័យនេះមិនត្រូវបានបញ្ចូលទៅក្នុងការសិក្សានេះឡើយ។

## បញ្ហាប្រឈមនៃភាពក្រីក្រក្នុងទីក្រុង និងភាពចាំបាច់ ដើម្បីឲ្យមានការសិក្សានេះ

ទីក្រុង គឺជាកន្លែងដែលផ្តល់ឱកាសផ្នែកសង្គមសេដ្ឋកិច្ច ដែលប្រជាពលរដ្ឋក្រីក្រអាចចូលរួមយ៉ាងសកម្ម ក្នុងដំណើរការនៃការផ្លាស់ប្តូរសង្គម សេដ្ឋកិច្ច និងនយោបាយ។[7] ប៉ុន្តែ បើទោះបីជាតំបន់ទីក្រុងផ្តល់ឱកាសសម្រាប់កាត់បន្ថយភាពក្រីក្រក៏ដោយ ការធ្វើចំណាកស្រុកដោយគ្មានការទប់ស្កាត់បានបង្កើតនូវស្ថានភាពមួយ ដែលបច្ចុប្បន្ននេះ ចំនួនប្រជាជនក្រីក្រក្នុងទីក្រុងមានការកើនឡើងក្នុងអត្រាមួយលឿនជាងទីជនបទទៅទៀត។ ការកើនឡើងនូវដង់ស៊ីតេប្រជាជនទាមទារឲ្យមានភាពចាំបាច់ ក្នុងការបង្កើតឲ្យមាននូវប្រព័ន្ធផ្តល់សេវាដែលមានលក្ខណៈស្មុគស្មាញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្នែកធនធាន និងសេវានានា (ដូចជាចំណីអាហារ ជម្រក ទឹក ការដឹកជញ្ជូន និងគ្រប់គ្រងសំណល់)។[8] ក្នុងករណីជាច្រើន រដ្ឋបាលមិនអាចផ្តល់សេវាទាំងនេះបានឡើយ ដោយសារតែកង្វះធនធាន ការពុំមានយន្តការសម្រាប់អនុវត្ត និងពិនិត្យតាមដាន និងដោយសារតែមានការយល់ដឹងនៅមានកម្រិតអំពីឧបសគ្គ និងបញ្ហាប្រឈម ដែលសហគមន៍ក្រីក្រក្នុងទីក្រុងជួបប្រទះ។[9] ក្នុងករណីប្រទេសកម្ពុជា ប្រជាជនក្រីក្រជាច្រើននាក់ត្រូវបានបង្ខំឲ្យរស់នៅកន្លែងតាំងទីលំនៅដែលមានមនុស្សរស់នៅកកកុញច្រើន និងពុំមានសេវាគ្រប់គ្រាន់ ដែលការគំរាមកំហែងចំពោះបញ្ហាសុខភាព ដោយសារតែការខ្វះសេវាសាធារណៈជាមូលដ្ឋាន និងការខ្វះលទ្ធភាពទទួលបានការអប់រំ គឺជាបញ្ហាដែលកើតមានជាប្រចាំ។ ទំនាក់ទំនងសង្គមក្នុងតំបន់ទីក្រុង គឺខុសពីទំនាក់ទំនងនៅតំបន់ជនបទ ហើយងាយរងគ្រោះ ដោយសារឥទ្ធិពលពីខាងក្រៅ។ ដូច្នេះ អ្នកដែលរស់នៅតាមតំបន់ទាំងនោះ ជាពិសេសកុមារ និងក្មេងជំទង់ ងាយរងគ្រោះច្រើនដោយសារហានិភ័យនានាដូចជា ពលកម្មកុមារ អំពើហិង្សា ការរំលោភបំពាន ការជួញដូរមនុស្ស និងបទល្មើសដែលមានអង្គការចាត់តាំង។ ចុងក្រោយ ចំនួនដីដែលមានធៀបនឹងកំណើនប្រជាជន មានន័យថា សិទ្ធិកាន់កាប់ដីធ្លីនៅមានការខ្វះខាត ហើយបញ្ហានេះតែងនាំឲ្យមានការបណ្តេញចេញ និងការបាត់បង់លំនៅដ្ឋាន ដែលធ្វើឲ្យបញ្ហាប្រឈមខាងលើកាន់តែបន្តកើនឡើងបន្ថែមទៀត។ ដោយសារតែបញ្ហាប្រឈមដ៏ពិសេស ដែលប្រជាពលរដ្ឋរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងជួបប្រទះ ជាពិសេសកុមារ និងក្មេងជំទង់។ ដោយសារតែការខ្វះព័ត៌មាន សម្រាប់រៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយ ទើបការសិក្សានេះត្រូវបានធ្វើឡើង។ ផ្តួចផ្តើមដោយយូនីសេហ្វកម្ពុជា និងអនុវត្តដោយក្រុមហ៊ុន Ernst & Young LLP ឥណ្ឌា ចន្លោះពីខែ កុម្ភៈ ២០១៦ និងខែមេសា ឆ្នាំ២០១៧ ការសិក្សានេះផ្តោតសំខាន់លើការផ្តល់ព័ត៌មានស៊ីជម្រៅអំពីហានិភ័យ ឧបសគ្គ និងទិដ្ឋភាពគោលនយោបាយ ពាក់ព័ន្ធជាមួយនឹងកិច្ចការពារកុមារ និងការអប់រំ។

## ការកាន់កាប់ដីធ្លី

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ចំនួនសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ មានការថយចុះពី ៤១០កន្លែង ក្នុងឆ្នាំ២០០៩ មកនៅត្រឹម៣៤០កន្លែង ក្នុងឆ្នាំ ២០១៣ ដោយចំនួនប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងមានការថយចុះ ៧០០០គ្រួសារ។[10] ប៉ុន្តែ គេមិនគួរបកស្រាយខុសថាការថយចុះបែបនេះថាជាសញ្ញាដែលបង្ហាញ

*[7] ការឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃភាពក្រីក្រក្នុងតំបន់ទីក្រុង៖ ឯកសារយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍អន្តរជាតិ (DfID)*

*[8] Ibid*

*[9] Ibid*

*[10] ច្បាប់ភូមិបាល ធ្វើវិសោធនកម្មកាលពីខែសីហា ឆ្នាំ២០០១ ផ្តល់លទ្ធភាពឲ្យបុគ្គលមួយចំនួនដែលកាន់កាប់ដីមុនពេលមានការអនុម័តច្បាប់នេះ និងដែលអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ អាចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លីបាន។*

ពីការរីកចម្រើនខាងសេដ្ឋកិច្ច ឬសង្គមរបស់ក្រុមប្រជាពលរដ្ឋទាំងនេះឡើយ។ តំបន់តាំងទីលំនៅរបស់សហគមន៍ក្រីក្រក្នុងទីក្រុងភាគច្រើន កើតឡើងចន្លោះពីឆ្នាំ១៩៧៩ ដល់២០០១ មុនការអនុវត្តច្បាប់ភូមិបាល (២០០១)។[11] កន្លែងតាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រជាធម្មតាត្រូវបានធ្វើឡើងលើដីសាធារណៈ ឬលើដីឯកជន ដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកដែលចូលទៅកាន់កាប់។ ក្រោយពេលដែល "ច្បាប់ភូមិបាល" ចូលជាធរមាន លំនៅដ្ឋានដែលសាងសង់ ដោយពុំមានលិខិតអនុញ្ញាតិត្រឹមត្រូវ ឬដែលត្រូវបានជួលដោយគ្មានកិច្ចសន្យាផ្លូវការ ងាយនឹងទទួលរងការបណ្តេញចេញ។[12] ការថយចុះជិតពាក់កណ្តាលដូចរៀបរាប់ខាងលើកើតឡើងដោយសារការចាកចេញរបស់អ្នកកាន់កាប់ ឬការបណ្តេញចេញនូវអ្នកកាន់កាប់ដែលនេះទំនងជាដើមចម ដែលនាំឲ្យមានការបាត់រូបរាងតំបន់តាំងទីលំនៅទាំងនេះ។ ហេតុផលទីពីរ ដែលនាំឲ្យមានការថយចុះនេះ គឺការការអភិវឌ្ឍនៅនឹងកន្លែង និងការផ្លាស់ប្តូរព្រំប្រទល់តំបន់ភូមិសាស្ត្រ។[13,14] លើសពីនេះប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញជាច្រើនគ្រួសារបានទៅតាំងទីលំនៅនៅកន្លែងផ្សេងៗពាសពេញទីក្រុងដោយពួកគេជាច្រើននាក់រស់នៅតាមផ្លូវ។ ដូច្នេះ បើទោះបីជាចំនួនតំបន់តាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងមានការថយចុះក៏ដោយ ចំនួនប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងភ្នំពេញបែរជាមានការកើនឡើងទៅវិញចាប់តាំងពីឆ្នាំ២០០១មក។

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ

ពាក់ព័ន្ធនឹងកិច្ចការពារកុមារ ប្រទេសកម្ពុជាជួបប្រទះនឹងឧបសគ្គធំៗជាយូរមកហើយ ដូចជាការខ្វះធនធាន ការខ្វះសមត្ថភាពអនុវត្តច្បាប់ និងការអនុវត្តគោលនយោបាយពុំមានសង្គតិភាព ដែលរារាំងកុមារមិនឲ្យទទួលបានជំនួយដែលពួកគេត្រូវការ។ លើសពីនេះក៏មានឧបសគ្គខាងវប្បធម៌ និងសង្គមមួយចំនួនផងដែរ ដែលទាំងនេះកើតចេញពីឥរិយាបថរបស់មនុស្សចំពោះការរំលោភបំពាន ដែលធ្វើឲ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមការពារកុមារ និងរឹតតែធ្វើឲ្យមានឧបសគ្គបន្ថែមទៀត ចំពោះការទទួលបានសេវាស្តារនីតិសម្បទា និងសេវាផ្តល់ប្រឹក្សា។ ការអង្កេតស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣ រកឃើញថា ៣៥-៤០ភាគរយ នៃអ្នកឆ្លើយតបក្នុងក្រុមអាយុពី ១៣ ដល់២៤ឆ្នាំ ទាំងអស់យល់ថា អំពើហិង្សាផ្នែកផ្លូវកាយ ដែលប្រព្រឹត្តដោយប្តីឬប្រពន្ធ គឺជាទង្វើដែលអាចទទួលយកបានក្នុងកាលៈទេសៈមួយចំនួន ហើយមានអ្នកឆ្លើយតបមួយភាគធំ ក៏គាំទ្រអំពើហិង្សាដែលកើតឡើងរវាងដៃគូស្និទ្ធស្នាលផងដែរ។ ស្ត្រីស្ទើរតែទាំងអស់ជាពិសេស ស្ត្រីដែលរស់នៅក្នុងរាជធានី ជឿថា គេគួរអត់ឱនឲ្យការរំលោភបំពានក្នុងគ្រួសារ ដោយសារតែយល់ថាការរាយការណ៍ពីករណីអំពើហិង្សាបែបនេះអាចនាំឲ្យមានការលែងលះ និងប៉ះពាល់ដល់សុខុមាលភាពរបស់កូន។ ការអង្កេតបែបគុណវិស័យបានបង្ហាញថាកុមារ ឬក្មេងជំទង់តែងត្រូវបានគេមិនលើកទឹកចិត្តឲ្យលើកឡើងពីការព្រួយបារម្ភរបស់ខ្លួនពាក់ព័ន្ធនឹងការរំលោភបំពានឡើយ ដើម្បីកិត្តិយសគ្រួសារ ឬដោយខ្លាចមានការសងសឹកពីសំណាក់អ្នកប្រព្រឹត្តអំពើរំលោភបំពាននេះ។[15]

បើតាមការអង្កេតអំពីអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣ អំពើហិង្សាផ្នែកផ្លូវកាយ គឺជាប្រភេទនៃអំពើហិង្សាដែលត្រូវបានលើកឡើងញឹកញាប់ជាងគេ។ អ្នកឆ្លើយតបជាងពាក់កណ្តាលធ្លាប់ទទួលរងអំពើហិង្សាយ៉ាងហោចណាស់ម្តង មុនពេលពួកគេគ្រប់អាយុ ១៨ឆ្នាំ។ ការអង្កេតនេះបានរកឃើញថា អ្នកឆ្លើយតបក្នុងក្រុមអាយុពី១៨ ដល់២៤ឆ្នាំ ចំនួន៥៥ភាគរយ និងអ្នកឆ្លើយតបក្នុងក្រុមអាយុពី១៣ ដល់ ១៨ឆ្នាំ លើសពី ៥០ភាគរយបន្តិច បានរាយការណ៍ថា ឪពុកម្តាយ អាណាព្យាបាល ឬសាច់ញាតិជាមនុស្សពេញវ័យផ្សេងទៀត គឺជាអ្នកដែលប្រព្រឹត្តអំពើហិង្សាផ្លូវកាយដំបូងលើកុមារ ដោយអ្នកដែលប្រព្រឹត្តអំពើហិង្សាដែល

---

*11 ច្បាប់ភូមិបាល ធ្វើវិសោធនកម្មកាលពីខែសីហា ឆ្នាំ២០០១ ផ្តល់លទ្ធភាពឲ្យបុគ្គលមួយចំនួន ដែលកាន់កាប់ដីមុនមានការអនុម័តច្បាប់នេះ និងដែលអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ អាចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លីបាន។*

*12 People In Need និង UNICEF (២០១៤)៖ របាយការណ៍វាយតម្លៃលើសូចនាករចម្រុះក្នុងទីក្រុងភ្នំពេញ ដោយយូនីសេហ្វ។*

*13 Ibid*

*14 រដ្ឋបាលរាជធានីភ្នំពេញ៖ របាយការណ៍ស្ថានភាពសហគមន៍ក្រីក្ររាជធានីភ្នំពេញ (២០១២)។*

*15 ក្រសួងកិច្ចការនារី៖ របកគំហើញនៃការអង្កេតលើអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣។*

ត្រូវបានលើកឡើងញឹកញាប់ជាងគេគឺម្តាយ បន្ទាប់មកគឺឪពុក និងឪពុកចុង។[16] ប៉ុន្តែ គួរកត់សម្គាល់ថា ភាពញឹកញាប់នៃការរាយការណ៍ គឺជាចំណុចដែលមានភាពស្មុគស្មាញច្រើន។ ដោយសារតែលក្ខណៈរសើបពាក់ព័ន្ធនឹងករណីរំលោភបំពានផ្លូវភេទ អាចថាករណីទាំងនេះមិនត្រូវបានរាយការណ៍គ្រប់ចំនួន ឬមិនត្រូវបានអ្នកឆ្លើយតបក្នុងការអង្កេតនេះរាយការណ៍តែម្តង ដែលធ្វើឲ្យមានការយល់ថា អំពើហិង្សាផ្លូវកាយអាចមិនមែនជាទម្រង់នៃការរំលោភបំពានដែលកើតឡើងញឹកញាប់ជាងគេនោះទេ។

ក្នុងចំណោមអ្នកឆ្លើយតបក្នុងក្រុមអាយុ១៨ ដល់២៤ឆ្នាំ អាយុជាមធ្យមដែលទទួលរងការរំលោភបំពានផ្លូវភេទលើកដំបូង គឺ១៥ឆ្នាំ សម្រាប់អ្នកឆ្លើយតបជាស្ត្រី និង ១០ឆ្នាំ សម្រាប់អ្នកឆ្លើយតបជាបុរស។ ក្នុងក្រុមអាយុពី ១៣ ដល់១៧ឆ្នាំវិញ អ្នកឆ្លើយតបជាបុរស ៦,៤ ភាគរយ និងអ្នកឆ្លើយតបជាស្ត្រី ៥,២ ភាគរយ បានលើកឡើងពីករណីរំលោភបំពានផ្លូវភេទយ៉ាងហោចណាស់ក៏ម្តងដែរ។ ស្របជាមួយនឹងរបកគំហើញសម្រាប់ករណីអំពើហិង្សាផ្លូវកាយ ក៏មានការរកឃើញផងដែរថា ជារឿយៗ កុមារក្នុងប្រទេសកម្ពុជាស្គាល់អ្នកដែលរំលោភបំពានផ្លូវភេទលើពួកគេ។ ក្នុងចំណោមអ្នកឆ្លើយតបអាយុពី១៨ ដល់២៤ឆ្នាំ អ្នកឆ្លើយតបជាស្ត្រី ២៨ភាគរយ និងអ្នកឆ្លើយតបជាបុរស ៣៧ភាគរយ ដែលជាជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ លើកឡើងថាអ្នកដែលប្រព្រឹត្តអំពើហិង្សាផ្លូវភេទញឹកញាប់ជាងគេ គឺអ្នកជិតខាង។ ក្នុងក្រុមអាយុតិចជាងនេះ អ្នកប្រព្រឹត្តអំពើហិង្សាផ្លូវភេទញឹកញាប់ជាងគេ ដែលលើកឡើងដោយអ្នកឆ្លើយតបជាស្ត្រីគឺមិត្តភក្តិ ហើយអ្នកប្រព្រឹត្តអំពើហិង្សាផ្លូវភេទញឹកញាប់ជាងគេ ដែលលើកឡើងដោយអ្នកឆ្លើយតបជាបុរស គឺសមាជិកគ្រួសារ។[17] នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ អំពើហិង្សាក្នុងគ្រួសារត្រូវបានរាយការណ៍ថាបានកើតឡើងក្នុងសហគមន៍ ៤៣ភាគរយ ការប្រើគ្រឿងញៀនកើតឡើងក្នុងសហគមន៍ ១៤ភាគរយ និងការរំលោភបំពានផ្លូវភេទកើតឡើងក្នុងសហគមន៍ ៩% ក្នុងចំណោមសហគមន៍ទាំងអស់។[18]

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសប្រភពដើម ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅចម្បងមួយ នៃករណីជួញដូរមនុស្ស។ របាយការណ៍ស្តីពីការរំលោភសេពសន្ថវៈ ការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលបានពីមូលដ្ឋានទិន្នន័យស្ថិតិរួមគ្នារបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងឆ្នាំ២០១០ បានបង្ហាញពីការជួញដូរផ្លូវភេទចំនួន៣៩ករណី ដែលក្នុងនោះជនរងគ្រោះ ៥៦,៤ ភាគរយ មានអាយុតិចជាង១៨ឆ្នាំ។ ក្នុងឆ្នាំ ២០១១ ចំនួនករណីដែលត្រូវបានរាយការណ៍ បានកើនឡើងជិតពីរដងដល់៧១ករណី ហើយ៧៥ភាគរយនៃករណីទាំងនេះ មានពាក់ព័ន្ធជាមួយកុមារ/ឬក្មេងជំទង់។[19] ក្នុងខេត្តក្រុងដែលមានប្រជាជនច្រើន ដូចជារាជធានីភ្នំពេញជាដើម ករណីទាំងនេះ គឺជាលទ្ធផលនៃកត្តាជំរុញ ពាក់ព័ន្ធនឹងលក្ខណៈភូមិសាស្ត្រមួយចំនួន ដូចជាភាពក្រីក្រដែលកើតមានជាទូទៅ អត្រាអ្នកអត់ការងារធ្វើខ្ពស់ កម្រិតអក្ខរកម្មទាប និងឱកាសរកប្រាក់ចំណូលមានកម្រិត។[20] កត្តាទាំងនេះធ្វើឲ្យការលក់កុមារឬក្មេងជំទង់ អាចជាជម្រើសមួយដើម្បីរកប្រាក់ចំណូលរបស់គ្រួសារ ហើយក៏ជាកត្តាជំរុញឲ្យមានការជួញដូរកុមារផងដែរ។ គិតត្រឹមឆ្នាំ២០០៩ មូលនិធិសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) បានប៉ាន់ប្រមាណថា អត្រាចុះសំបុត្រកំណើតមានកម្រិតត្រឹមតែ ៧៨ ភាគរយប៉ុណ្ណោះ ហើយការមិនមានសំបុត្រកំណើតជាហានិភ័យមួយចំពោះកុមារដែលបាត់ខ្លួន។[21] ខណៈដែលដំណើរការសម្រួលដល់ការចុះសំបុត្រកំណើត ត្រូវបានបង្កើតឡើងដំបូងកាលពីឆ្នាំ២០០២ ជាលទ្ធផល មានប្រជាពលរដ្ឋតិចជាង៣ភាគរយ ក្នុងចំណោមប្រជាពលរដ្ឋសរុបប៉ុណ្ណោះដែលបានចុះសំបុត្រកំណើតរបស់ខ្លួន។ ការបាត់ខ្លួន ឬករណីស្លាប់របស់កុមារឬក្មេងជំទង់ អាចនឹងមិនត្រូវបានគេរាយការណ៍ទេ ប្រសិនបើកុមារ

---

*16 ក្រសួងកិច្ចការនារី៖ របកគំហើញនៃការអង្កេតលើអំពើហិង្សាលើកុមារនៅកម្ពុជា ឆ្នាំ ២០១៣។*

*17 ក្រសួងកិច្ចការនារី៖ របកគំហើញនៃការអង្កេតលើអំពើហិង្សាលើកុមារនៅកម្ពុជា ឆ្នាំ ២០១៣។*

*18 របាយការណ៍ស្ថានភាពសហគមន៍ក្រីក្ររាជធានីភ្នំពេញ ឆ្នាំ ២០១២។*

*19 របាយការណ៍ស្តីពីការរំលោភសេពសន្ថវៈ ការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលបានពីមូលដ្ឋានទិន្នន័យស្ថិតិរួមគ្នារបស់អង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ ២០១១។ សង្ខេបគោលនយោបាយស្តីពីការការពារកុមារឆ្នាំ ២០១៥ អង្គការទស្សនៈពិភពលោក។*

*20 ការវិភាគលើស្ថានភាពស្ត្រី និងកុមារ ក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៩ យូនីសេហ្វ។*

*21 ការវិភាគលើស្ថានភាពស្ត្រី និងកុមារ ក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៩ យូនីសេហ្វ។*

ឬក្មេងជំទង់រូបនោះពុំបានចុះសំបុត្រកំណើត។ ដូច្នេះ ការមិនបានចុះសំបុត្រកំណើតនាំឲ្យកុមារកាន់តែងាយរងគ្រោះដោយសារការចាប់ពង្រាត់ ការជួញដូរ ការយកទៅចិញ្ចឹមដោយខុសច្បាប់ និងការកេងប្រវ័ញ្ច។

បើទោះបីជាគោលនយោបាយរបស់រាជរដ្ឋាភិបាលចែងថា ការថែទាំតាមគ្រួសារ និងការថែទាំតាមសហគមន៍ គឺជាជម្រើសល្អបំផុត សម្រាប់ការផ្ដល់ការថែទាំជំនួសដល់កុមារក៏ដោយ ការយកកុមារទៅដាក់តាមមណ្ឌលថែទាំ កាន់តែកើតឡើងញឹកញាប់ក្នុងប្រទេសកម្ពុជា។[22] បើតាមការអង្កេតកំណត់ពីទីតាំងនៃមណ្ឌលថែទាំកុមារនៅរាជធានីភ្នំពេញនិងខេត្តចំនួនបួនទៀត ដែលធ្វើឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមការឧបត្ថម្ភពីយូនីសេហ្វ បច្ចុប្បន្ននេះ មានមណ្ឌលថែទាំកុមារចំនួន២៦៧កន្លែង ដែលក្នុងនោះ១៧១កន្លែង មានទីតាំងក្នុងរាជធានីក្រុងភ្នំពេញ។[23] គិតត្រឹមឆ្នាំ២០១៦ មានកុមារសរុប ៩២២៣ នាក់ រស់នៅតាមមណ្ឌលថែទាំទាំងនេះក្នុងរាជធានីភ្នំពេញ។[24] ពួកគេភាគច្រើនមកពីគ្រួសារងាយរងគ្រោះ និងត្រូវបានឪពុកម្ដាយរបស់ពួកគេនាំមកដាក់ក្នុងមណ្ឌល។ មានកត្តាមួយចំនួនដែលបង្កើនភាពងាយរងគ្រោះរបស់កុមារមកពីគ្រួសារក្រីក្រ ដែលពួកគេកំពុងតែមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាសុវត្ថិភាពសង្គម និងសេវាគាំទ្រតាមសហគមន៍។ កត្តាទាំងនេះរួមមានការផ្លាស់ប្ដូរស្ថានភាពក្នុងគ្រួសារ ដូចជាមរណភាពរបស់ឪពុកឬម្ដាយ ការលែងលះ និងការរៀបការប្ដីឬប្រពន្ធថ្មី ក៏ដូចជាការឈឺថ្កាត់ និងការធ្វើចំណាកស្រុកជាដើម។ ក្នុងកាលៈទេសៈមួយចំនួន មណ្ឌលថែទាំកុមារកេងប្រវ័ញ្ចលើភាពងាយរងគ្រោះ ដោយសារភាពក្រីក្រនេះ ដោយមណ្ឌលទាំងនោះចេញទៅ "ជ្រើសរើស" កុមារពីគ្រួសារក្រីក្រយកមកដាក់មណ្ឌលតែម្ដងដោយធ្វើការបញ្ចុះបញ្ចូល បង្ខំ ឬថែមទាំងបង់ប្រាក់ឲ្យឪពុកម្ដាយ ដើម្បីយកកូនចេញពីពួកគេទៀតផង។[25] ដោយឡែកសម្រាប់ឪពុកម្ដាយវិញ ពួកគេភាគច្រើនជឿថា កូនៗរបស់ពួកគេនឹងទទួលបានការថែទាំប្រសើរជាងដោយសារតែនៅតាមមណ្ឌលទាំងនោះមានការផ្ដល់សេវាសុខភាព និងសេវាអប់រំជាមូលដ្ឋាន ដោយពួកគេពុំបានដឹងពីហានិភ័យដែលកើតឡើងចំពោះកុមារ នៅតាមមណ្ឌលណាដែលពុំមានការគ្រប់គ្រងត្រឹមត្រូវ ដូចជាការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអាចមានទាំងការជួញដូរមនុស្សទៀតផង។ ផលអវិជ្ជមានផ្សេងទៀតនៃការដាក់កុមារក្នុងមណ្ឌលថែទាំរួមមាន ការបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍសង្គម ការអភិវឌ្ឍផ្លូវកាយ ការអភិវឌ្ឍបញ្ញាស្មារតី និងការអភិវឌ្ឍផ្លូវចិត្តរបស់កុមារ ដោយសារតែអវត្តមានអ្នកថែទាំឲ្យបានជាប់លាប់ដល់ពួកគេ ការបាត់បង់ជាបណ្ដើរៗនូវរចនាសម្ព័ន្ធសម្រាប់ផ្ដល់ការថែទាំបែបប្រពៃណីក្នុងសង្គម ការលំបាកក្នុងការធ្វើសមាហរណកម្មចូលមកក្នុងសង្គមវិញ និងក្នុងករណីមួយចំនួន ដែលកន្លែងថែទាំកុមារជួបប្រទះនឹងបញ្ហាហិរញ្ញវត្ថុ ដែលកុមារត្រូវរងគ្រោះដោយសារខ្វះអាហារហូបចុក ការអប់រំ និងត្រូវរស់នៅក្នុងស្ថានភាពមិនល្អជាដើម។[26]

## ទិដ្ឋភាពទូទៅនៃគោលនយោបាយស្ដីពីកិច្ចការពារកុមារ

ជំហានទីមួយ ក្នុងចំណោមជំហានសំខាន់ៗដំបូងដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើដើម្បីផ្ដល់កិច្ចការពារដល់កុមារ គឺការផ្ដល់សច្ចាប័នលើអនុសញ្ញាសហប្រជាជាតិស្ដីពីសិទ្ធិកុមារក្នុងឆ្នាំ១៩៩២។[27] ដូច្នេះ មាត្រានានានៃអនុសញ្ញានេះត្រូវបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ហើយបច្ចុប្បន្ននេះ គឺជាមូលដ្ឋាន សម្រាប់រៀបចំ និងពង្រឹងការអនុវត្តច្បាប់ប្រឆាំងអំពើហិង្សា/ការរំលោភបំពានក្នុងគ្រួសារ ជាពិសេស អំពើហិង្សាលើកុមារ។[28] ចាប់តាំងពីពេលនោះមក រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើ

22 *មណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា យូនីសេហ្វ www.uniceg.org/cambodia*
23 *ការប្រមូលទិន្នន័យបឋម និងរបកគំហើញ៖ ការកំណត់ទីតាំងមណ្ឌលថែទាំកុមារក្នុងទីក្រុងភ្នំពេញឆ្នាំ២០១៦ ដោយ USAID និងក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា។*
24 *ឯកសារព័ត៌មានបង្ហាញទិន្នន័យបឋម និងរបកគំហើញ៖ ការកំណត់ទីតាំងមណ្ឌលថែទាំកុមារក្នុងទីក្រុងភ្នំពេញ ខេត្តសៀមរាប បាត់ដំបង កណ្ដាល និងព្រះសីហនុ៖ ប្រទេសកម្ពុជាឆ្នាំ២០១៦ ដោយ USAID និងក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា។*
25 *មណ្ឌលថែទាំកុមារ ក្នុងប្រទេសកម្ពុជា យូនីសេហ្វ www.uniceg.org/cambodia*
26 *Ibid*
27 *សង្ខេបគោលនយោបាយស្ដីពីកិច្ចការពារកុមារឆ្នាំ២០១៥ អង្គការទស្សនៈពិភពលោក។*
28 *លទ្ធផលពីការអង្កេតស្ដីពីអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣*

យន្តការជាច្រើន ដើម្បីបង្កើតនូវប្រព័ន្ធការពារកុមារដែលមានលក្ខណៈកាន់តែគ្រប់ជ្រុងជ្រោយ ដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ។[29] ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ បំពេញតួនាទីជាស្ថាប័នបង្គោលសម្របសម្រួលគ្រប់សកម្មភាពទាំងអស់ ពាក់ព័ន្ធជាមួយនឹងបញ្ហាកុមារ ក្នុងប្រទេសកម្ពុជា។ គណៈកម្មការទទួលបន្ទុក កិច្ចការនារី និងកុមារឃុំ ដែលត្រូវបានសាកល្បងក្នុងឆ្នាំ២០០៤ គឺជាគណៈកម្មាធិការថ្នាក់ក្រោមជាតិមួយ ដែលទទួលខុសត្រូវពិនិត្យតាមដាន និងវាយតម្លៃស្ថានភាពស្ត្រី និងកុមារក្នុងឃុំ និងផ្តល់ជំនួយដល់ក្រុមប្រឹក្សាឃុំ ក្នុងសកម្មភាពសេវាសង្គមនានា ផ្អែកទៅតាមតម្រូវការរបស់អ្នកទទួលផល។[30] គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ ជាគណៈកម្មាធិការនៅថ្នាក់ស្រុក ខណ្ឌ និងរាជធានីខេត្ត ដែលទទួលខុសត្រូវផ្តល់យោបល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីរបៀបដាក់បញ្ចូលតម្រូវការរបស់ស្ត្រី យុវជន កុមារ និងជនរងគ្រោះទៅក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់ក្រុមប្រឹក្សា។ គណៈកម្មាធិការទាំងនេះក៏លើកទឹកចិត្តឲ្យមានការរៀបចំច្បាប់ និងគោលនយោបាយ ដែលផ្តោតការយកចិត្តទុកដាក់លើក្រុមខាងលើផងដែរ និងផ្តល់អនុសាសន៍ឲ្យមានការពង្រឹងការសម្របសម្រួលរវាងសកម្មភាពរបស់មន្ទីរ អ្នកផ្តល់សេវា ក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍នានាផងដែរ ដើម្បីឲ្យការអនុវត្តសកម្មភាពអាចធ្វើទៅបានប្រកបដោយជោគជ័យ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាក្រសួងដែលបំពេញតួនាទីសំខាន់ក្នុងការគ្រប់គ្រងការងារការពារសិទ្ធិមនុស្ស និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិនៅទូទាំងប្រទេសកម្ពុជា។ ក្រសួងនេះផ្តោត ជាចម្បងលើវិស័យចំនួនបួន គឺវិស័យសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។ ក្រសួងផ្សេងទៀតរបស់រដ្ឋាភិបាល ដូចជា ក្រសួងមហាផ្ទៃ ដែលទទួលខុសត្រូវលើការងារអនុវត្តច្បាប់ និងក្រសួងយុត្តិធម៌ ដែលទទួលបន្ទុករៀបចំក្របខ័ណ្ឌច្បាប់របស់ប្រទេស គឺជាក្រសួងដែលធ្វើការងាររួមជាមួយនឹងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីឲ្យក្របខ័ណ្ឌ និងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាកាន់តែមានភាពល្អប្រសើរជាងមុន និងធានាឲ្យមានការការពារសិទ្ធិកុមារ។

ខណៈពេលដែលព្រះរាជាណាចក្រកម្ពុជាពុំទាន់មានច្បាប់ស្តីពីកុមារ ឬក្រមស្តីពីកិច្ចការពារកុមារដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ឬលក្ខណៈក្តោបរួមនៅឡើយ បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងកុមារ គឺមាននៅរាយប៉ាយ ក្នុងក្រម និងច្បាប់នានាជាច្រើន។[31] ឧទាហរណ៍ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ឆ្នាំ២០០៥ មានបញ្ញត្តិស្តីពីកិច្ចការពារកុមារដែលស្ថិតក្រោមបន្ទុកពីអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្តដែលកើតឡើងក្នុងគ្រួសារ។ ឯកសារផ្សេងទៀតដែលផ្តោតលើសិទ្ធិកុមារ និងកិច្ចការពារកុមារផងដែរនោះរួមមាន ផែនការស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០០៨-២០១២ គោលនយោបាយស្តីពីការផ្តល់ការថែទាំជំនួសដល់កុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលទើបនឹងត្រូវបានអនុម័ត កាលពីពេលថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំច្បាប់មួយចំនួននៅតែមានចន្លោះប្រហោងជាច្រើន ហើយច្បាប់មួយចំនួនទៀតត្រូវការយន្តការអនុវត្តដែលមានប្រសិទ្ធភាព។ ឧទាហរណ៍ ច្បាប់ស្តីពីការងារពុំបានគ្របដណ្តប់ វិស័យមិនរៀបរយឡើយ ហើយមានកុមារជាច្រើនត្រូវបានគេជួលឲ្យធ្វើការដែលនេះជាករណីពលកម្មកុមារ។ ច្បាប់ដែលចែងពីការរំលោភបំពានផ្លូវកាយក៏មានចំណុចខ្វះខាតមួយចំនួនផងដែរ។ បើតាមរបាយការណ៍នៃគំនិតផ្តួចផ្តើមសកល ដើម្បីបញ្ចប់ការដាក់ទណ្ឌកម្មផ្លូវកាយលើកុមារ[32] ការដាក់ទណ្ឌកម្មផ្លូវកាយនៅក្នុងផ្ទះ ត្រូវបានគេចាត់ទុកថាជាទង្វើស្របច្បាប់។ ការពុំបានបញ្ចូលនិយមន័យនៃពាក្យថា "អំណាចមេបា" ក្នុងក្រមរដ្ឋប្បវេណី ធ្វើឲ្យការដាក់ទណ្ឌកម្មផ្លូវកាយដែលគេប្រើប្រាស់តាមមណ្ឌលថែទាំកុមារ ក៏ក្លាយជាទង្វើស្របច្បាប់ផងដែរ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

*29 សង្ខេបគោលនយោបាយស្តីពីការការពារកុមារឆ្នាំ២០១៥ អង្គការទស្សនៈពិភពលោក។*
*30 ដំណើរការនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ រាជរដ្ឋាភិបាលកម្ពុជា។*
*31 ការវិភាគលើស្ថានភាពស្ត្រី និងកុមារនៅកម្ពុជាឆ្នាំ២០០៩ ដោយយូនីសេហ្វ។*
*32 ការដាក់ទណ្ឌកម្មលើរាងកាយក្នុងប្រទេសកម្ពុជា គំនិតផ្តួចផ្តើមជាសកលដើម្បីបញ្ចប់រាល់ទម្រង់នៃទណ្ឌកម្មរាងកាយលើកុមារ បច្ចុប្បន្នភាពខែមករា ឆ្នាំ២០១៦។*

ដែលទើបនឹងត្រូវបានអនុម័តកាលពីខែឧសភា ឆ្នាំ ២០១៦ ថ្មីៗនេះ មានបញ្ញត្តិដែលចែងពីការបង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌមួយ ដែលផ្ដោតការយកចិត្តទុកដាក់លើយុត្តិធម៌បែបជាការស្ដារសម្បទាឡើងវិញ សម្រាប់កុមារមានទំនាស់នឹងច្បាប់។

រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុវត្តផែនការសកម្មភាពជាច្រើន ដែលផ្ដោតលើសិទ្ធិកុមារ និងកិច្ចការពារកុមារផងដែរ ជាពិសេសកិច្ចការពារកុមារពីការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ ដូចជាផែនការសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ២០០៦-២០១០ ដែលបានកំណត់គោលដៅ និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ននានា និងជួយដល់ក្រសួងស្ថាប័នក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលកំពុងមានជាធរមាន និងផែនការសកម្មភាពប្រឆាំងការជួញដូរមនុស្ស ២០១៤-២០១៨ ដែលមានគោលបំណងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទ ជាពិសេសរបស់ស្ត្រី និងកុមារក្នុងប្រទេសកម្ពុជា។[33]

បន្ថែមពីលើគោលនយោបាយដូចរៀបរាប់ខាងលើ ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទាក៏បានអនុវត្តអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកាលពីឆ្នាំ២០១៥ផងដែរ ដោយអនុក្រឹត្យនេះតម្រូវឲ្យមានការបង្កើនគុណភាព និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមណ្ឌលថែទាំ និងការពារកុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពាននានា ដែលកើតមាននៅតាមកន្លែងផ្ដល់ការថែទាំ ដូចជាមណ្ឌលកុមារកំព្រា មណ្ឌលសំចតផ្ទះស្នាក់នៅជាក្រុម មណ្ឌលថែទាំតាមវត្តអារាម និងអគារសាសនាផ្សេងទៀតជាដើម។[34] បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះរួមមាន ការតម្រូវឲ្យមណ្ឌលថែទាំដែលដំណើរការមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវសុំការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គោលការណ៍ណែនាំស្ដីពីការទទួលយកកុមារឲ្យស្នាក់នៅក្នុងមណ្ឌលថែទាំ និងការហាមប្រាមមិនឲ្យយកកុមារអាយុក្រោម៣ឆ្នាំមកដាក់ក្នុងមណ្ឌល ការចែងអំពីការធ្វើសមាហរណកម្មកុមារដែលចេញពីមណ្ឌល និងការរៀបចំផែនការសម្រាប់កុមារ និងយុវជនគ្រប់រូបដែលកំពុងស្នាក់នៅក្នុងមណ្ឌលឲ្យបានត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦ ការផ្ដល់ពេល ៤៨ម៉ោង ឲ្យមណ្ឌលថែទាំឆ្លើយតបចំពោះករណីមិនប្រក្រតីដែលត្រូវបានរកឃើញ និងការបង្កើតក្រុមឆ្លើយតបរហ័ស ដើម្បីឆ្លើយតបចំពោះករណីលើកឡើងខាងលើ។[35]

## លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព

ចំណុចសំខាន់ដែលត្រូវយល់នៅទីនេះគឺថា ការពុំបានទទួលបានការអប់រំប្រកបដោយគុណភាព គឺជាកត្តាដែលនាំឲ្យមានហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារមានការកើនឡើង។ បើតាមរបាយការណ៍របស់ USAID[36] រាជធានីភ្នំពេញមានអត្រាបោះបង់ចោលការសិក្សា អត្រាឡើងថ្នាក់ អត្រាគង់វង្ស និងអត្រាឆ្លងភូមិសិក្សា នៅកម្រិតមធ្យមសិក្សាបឋមភូមិខ្ពស់ជាងគេបើធៀបជាមួយនឹងខេត្តផ្សេងទៀត។ គិតត្រឹមឆ្នាំ ២០១២ អត្រាចុះឈ្មោះចូលរៀននៅតាមសាលាបឋមសិក្សាក្នុងរាជធានីមានកម្រិតខ្ពស់គឺ ៩១ ភាគរយ។[37] ប៉ុន្តែ អត្រាឆ្លងភូមិសិក្សាទៅកម្រិតមធ្យមសិក្សាបឋមភូមិបែរជាថយចុះទៅវិញ ដោយក្នុងចំណោមគ្រួសារដែលមានកូនជំទង់អាយុពី១២ ដល់ ១៤ឆ្នាំទាំងអស់ មានតែ៧២ភាគរយប៉ុណ្ណោះ ដែលរបាយការណ៍នេះបញ្ជាក់ថា បានបញ្ជូនកូនរបស់ខ្លួនទៅរៀននៅសាលាមធ្យមសិក្សា។[38]

កម្រិតចំណូលទាបក្នុងចំណោមប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ជារឿយៗបង្ខំឲ្យក្មេងជំទង់ទៅរកការងារធ្វើ ពេលដែលពួកគេកំពុងសិក្សា ឬលែងទៅរៀនតែម្ដង។ ការបាត់បង់ឱកាសរៀនសូត្រ (មាន

33 *ការវិភាគលើស្ថានភាពរបស់ស្ត្រី និងកុមារ នៅកម្ពុជា ឆ្នាំ ២០០៩ យូនីសេហ្វ។ ផែនការសកម្មភាពជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ២០១៤-២០១៨។*

34 *ការប្ដេជ្ញាចិត្តអនុវត្តអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខែ ធ្នូ ឆ្នាំ ២០១៥។*

35 *Ibid*

36 *កម្មវិធីសាកល្បងការទប់ស្កាត់ការបោះបង់ចោលការសិក្សាតាមសាលារៀន ការវិភាគលើនិន្នាការនៃការបោះបង់ចោលការសិក្សា ខែ សីហា ឆ្នាំ ២០១១។*

37 *Ibid*

38 *Ibid*

ន័យថា ពេលវេលាដែលត្រូវរៀនសូត្រ ត្រូវចំណាយដើម្បីរកចំណូលវិញ) បានធ្វើឲ្យអត្រាបោះបង់ចោលការសិក្សាមានការកើនឡើង ហើយអត្រាចូលរៀន និងអត្រាគង់វង្សមានការថយចុះ។ បើតាមការអង្កេតលើកម្លាំងពលកម្ម និងពលកម្មកុមារ (CLFCLS) ឆ្នាំ២០១២ កុមារ/ក្មេងជំទង់អាយុ៥ ដល់១៧ឆ្នាំ ចំនួន១៩ ភាគរយ ត្រូវបានរកឃើញថា កំពុងប្រឡូកយ៉ាងសកម្មក្នុងសកម្មភាពសេដ្ឋកិច្ច ដែលក្នុងនោះ ៥៦,៩ ភាគរយ ជាពលករកុមារ និង ៣១,៣ ភាគរយ ចូលរួមក្នុងពលកម្មប្រកបដោយគ្រោះថ្នាក់។ មានការប៉ាន់ប្រមាណថា ពលករកុមារជាងពាក់កណ្តាលមិនធ្លាប់បានចូលរៀនឡើយ ឬធ្លាប់បោះបង់ចោលការសិក្សា។[39] ក្រៅពីមានផលប៉ះពាល់លើការអប់រំ ពលកម្មកុមារក៏ធ្វើឲ្យកុមារកាន់តែប្រឈមនឹងការបំពារបំពាន និងការរំលោភបំពានសិទ្ធិ នៅកន្លែងធ្វើការផងដែរ។ ដូចដែលបានរកឃើញក្នុងការអង្កេតលើកម្លាំងពលកម្ម និងពលកម្មកុមារ (CLFCLS) ឆ្នាំ២០១២ ក្មេងស្រី ០,២ ភាគរយ និងក្មេងប្រុស ០,១ ភាគរយ ធ្លាប់ទទួលរងការរំលោភបំពាន បើទោះបីជាពុំមានអ្នកឆ្លើយតបណាលើកឡើងថា ពួកគេធ្លាប់ទទួលរងការរំលោភបំពានផ្លូវកាយ នៅកន្លែងធ្វើការក៏ដោយ។[40] បើទោះបីជាតួលេខនេះបង្ហាញពីស្ថានភាពល្អប្រសើរយ៉ាងណាក៏ដោយ អាចមានករណីរំលោភបំពានមួយចំនួន ដែលមិនត្រូវបានគេរាយការណ៍ ដោយសារតែមានការបង្ខិតបង្ខំ ឬដោយសារពួកគេខ្លាចបាត់បង់ការងារជាដើម។

បើទោះបីជាការអប់រំគឺជាសិទ្ធិជាមូលដ្ឋានក្នុងប្រទេសកម្ពុជា (ហើយការអប់រំតាមសាលារៀនសាធារណៈត្រូវបានផ្តល់ដោយមិនគិតថ្លៃ) ក៏ដោយ ការផ្តល់ប្រាក់បៀវត្សទាបដល់គ្រូ ដែលធ្វើការងារតាមសាលារៀនសាធារណៈពេលខ្លះ ធ្វើឲ្យគ្រូត្រូវរកចំណូលបន្ថែម ដោយប្រមូល "ថ្លៃសេវាក្រៅផ្លូវការ" ពីសិស្ស តាមរយៈការបង្រៀនគួរ។ ការបង្រៀនក្រៅផ្លូវការទាំងនេះត្រូវបានរៀបចំឡើងបន្ទាប់ពីការបង្រៀនម៉ោងធម្មតារួច។ ដើម្បីបង្កើតឲ្យមានតម្រូវការសម្រាប់ការបង្រៀនគួរ ជារឿយៗ គ្រូមិនបង្រៀនដោយយកចិត្តទុកដាក់ខ្លាំងក្នុងម៉ោងបង្រៀនធម្មតាឡើយ ដែលធ្វើឲ្យកុមារ/ក្មេងជំទង់ចាំបាច់ត្រូវចូលរៀនគួរបង់ប្រាក់បន្ថែមទៀត។ ថ្លៃសេវាក្រៅផ្លូវការ គួបផ្សំជាមួយនឹងការចំណាយបន្ថែមលើចំណីអាហារ សៀវភៅ និងឯកសណ្ឋានផង អាចបង្ខំឲ្យគ្រួសារក្រីក្រដកកូនចេញពីសាលារៀនមកវិញ។ គ្រូជាច្រើននាក់ក៏ត្រូវធ្វើការងារបន្ថែម និងត្រូវបង្រៀនគួរផងដែរ ដែលអាចឲ្យពួកគេទទួលបានចំណូលខ្ពស់ជាងមុន។ ការថយចុះគុណភាពនៃការបង្រៀនតាមសាលារៀនសាធារណៈ ជាកត្តាដែលបង្កើតនូវទីផ្សារសម្រាប់គ្រូបង្រៀនគួរឯកជន ហើយលើកទឹកចិត្តឲ្យគ្រូបង្រៀនកាន់តែច្រើននាក់ អនុវត្តបែបនេះ ដូច្នេះវាក្លាយជាវដ្តមួយដែលចេះតែបន្តទៅមុខទៀតដោយខ្លួនឯងឥតឈប់ឈរ។[41]

សម្រាប់កន្លែងតាំងទីលំនៅក្នុងទីក្រុងភ្នំពេញដែលនៅដាច់ឆ្ងាយពីគេ ចម្ងាយផ្លូវទៅសាលារៀនក៏ជាឧបសគ្គមួយធំ ដែលធ្វើឲ្យរាំងស្ទះដល់ការទទួលបានការអប់រំផងដែរ។ នៅពេលពុំមានមធ្យោបាយធ្វើដំណើរគ្រប់គ្រាន់ សាលារៀនក្លាយជាកន្លែងដែលសិស្សមិនអាចទៅដល់បាន នៅពេលដែលមានអាកាសធាតុមិនល្អ។ លើសពីនេះ សុវត្ថិភាពបានក្លាយជាការព្រួយបារម្ភដ៏សំខាន់មួយរបស់ឪពុកម្តាយ នៅពេលដែលបទល្មើសលើកុមារកើតឡើងច្រើនករណីបន្ថែមពីលើបញ្ហាចម្ងាយផ្លូវឆ្ងាយទៅសាលារៀននេះ។[42] ចំណុចនេះបង្ខំឪពុកម្តាយ ឲ្យទុកកូននៅផ្ទះ ឬឲ្យកូនទៅរៀនជាមួយសាលាឯកជនប្រសិនបើពួកគេមានលទ្ធភាព។ ប៉ុន្តែ ដោយសារតែការបង្រៀនឯកជនទាមទារឲ្យមានការបង់ថ្លៃ ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងជាច្រើនគ្រួសារពុំមានលទ្ធភាពឲ្យកូនទៅរៀនតាមសាលាឯកជនឡើយ។ សុវត្ថិភាពតាមសាលារៀនគឺជាការព្រួយបារម្ភធំមួយទៀតពាក់ព័ន្ធនឹងសិទ្ធិកុមារ ហើយក៏មានផលប៉ះពាល់ផងដែរលើសូចនាករអប់រំរបស់ប្រទេសកម្ពុជា។ ការសិក្សាមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការស្រាវជ្រាវអំពីស្ត្រី និងអង្គការភ្លែនអន្តរជាតិ[43] បង្ហាញថា សិស្សចំនួន៧៣ភាគរយរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាយ៉ាងហោចណាស់

[39] *ការអង្កេតអំពីកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជាឆ្នាំ២០១២៖ របាយការណ៍ស្តីពីពលកម្មកុមារ របស់ ILO។*
[40] *ការអង្កេតអំពីកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជា ឆ្នាំ ២០១២៖ របាយការណ៍ស្តីពីពលកម្មកុមារ របស់ ILO។*
[41] *ការអប់រំបំពេញបន្ថែមនៅកម្ពុជា ដោយ Dawson, W. (2011)។*
[42] *ការអប់រំបំពេញបន្ថែមនៅកម្ពុជា ដោយ Dawson, W. (2011)។*
[43] *តើសាលារៀន គឺជាកន្លែងដែលមានសុវត្ថិភាព និងធានានូវសមភាពយេនឌ័រដែរឬទេ? មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការស្រាវជ្រាវអំពីស្ត្រី អង្គការភ្លែនអន្តរជាតិឆ្នាំ២០១៥។*

ក៏មួយទម្រង់ដែរ (អំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ) ក្នុងសាលារៀន។

## ទិដ្ឋភាពគោលនយោបាយ

គោលនយោបាយវិស័យអប់រំដែលត្រូវបានអនុម័តក្នុងប្រទេសនេះ គឺស្របទៅតាមគោលការណ៍នៃចលនាអប់រំសម្រាប់ទាំងអស់គ្នា (EFA) របស់អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ (UNESCO) ឆ្នាំ ១៩៩០។ ក្រសួងរបស់រដ្ឋាភិបាលដែលបំពេញមុខងារចម្បង ក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា គឺក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងនេះមានចក្ខុវិស័យអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងក្រមសីលធម៌ខ្ពស់បំផុត ដោយផ្តោតការយកចិត្តទុកដាក់រយៈពេលវែងលើការទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងលើបរិយាប័ន្ននៃការអភិវឌ្ឍ។ មានស្ថាប័នពីរដែលជួយដល់ក្រសួងក្នុងការសម្រេចចក្ខុ វិស័យនេះនោះគឺក្រុមការងារវិស័យអប់រំ (ESWG) និងភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)។ សមាជិកសំខាន់ៗរបស់ ESWG រួមមាន អង្គការយូណេស្កូ យូនីសេហ្វ មូលនិធិសហប្រជាជាតិ ដើម្បីប្រជាជន (UNFPA) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ដោយឡែក NEP គឺជាក្រុមអង្គការបណ្តាញ ដែលមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលជាង ១០០ ធ្វើការងារក្នុងវិស័យអប់រំនៅកម្ពុជា។[44]

ដំណើរការរៀបចំគោលនយោបាយសំខាន់ៗរបស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់ផ្តើមធ្វើឡើងក្នុងឆ្នាំ ២០០១ ជាមួយនឹងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ទីមួយ និងកម្មវិធីគាំទ្រវិស័យអប់រំ (ESSP)។ ដោយអនុវត្តជាផែនការរយៈពេល ៥ឆ្នាំ ទាំង ESP និង ESSP រៀបរាប់ពីប្រព័ន្ធ កម្មវិធី និងធនធាន ដែលនឹងត្រូវដាក់ឲ្យអនុវត្ត ដើម្បីរួមចំណែកសម្រេចគោលដៅសកល នៃការអប់រំសម្រាប់ទាំងអស់គ្នានៅកម្រិតបឋមសិក្សាត្រឹមឆ្នាំ២០១៥។ ក្នុងអាណត្តិទីបួននេះផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ផ្តោតការយកចិត្តទុកដាក់លើការពង្រីកការអប់រំកុមារតូច និងការទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងការអប់រំបច្ចេកទេសវិជ្ជាជីវៈ ប្រកបដោយគុណភាព។ ស្របគ្នានឹងការអប់រំទាំងអស់គ្នា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ គំនិតផ្តួចផ្តើមពន្លឿនការអប់រំ (FTI) នៃកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា បានចាប់ផ្តើមអនុវត្តក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០០២ ដោយមានថវិការហូតដល់ ៥៧,៤ លានដុល្លារ សម្រាប់រយៈពេល៣ឆ្នាំ។[45] ធនធានហិរញ្ញវត្ថុរបស់កម្មវិធី FTI មានគោលបំណងគាំទ្រដល់អាទិភាពគោលនយោបាយ ដែលត្រូវបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ ហើយស្របពេលជាមួយគ្នា បំពេញបន្ថែមលើគោលដៅរយៈពេលវែងនៃកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា។

ដើម្បីគ្រប់គ្រងវិស័យអប់រំ និងគោលនយោបាយនានាដែលត្រូវបានដាក់ចេញក្នុងវិស័យអប់រំ ប្រទេសកម្ពុជាបានដាក់ឲ្យអនុវត្តច្បាប់ស្តីពីការអប់រំ កាលពីខែធ្នូ ឆ្នាំ២០០៧ ដែលចែងថា "កុមារដល់អាយុចូលរៀនគ្រប់រូប (អាយុចាប់ពី ៦ឆ្នាំឡើងទៅ) គួរអាចចូលរៀននៅបឋមសិក្សាដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់"។[46] ច្បាប់នេះគឺជាលិខិតុបករណ៍គតិយុត្តិដ៏សំខាន់មួយរបស់រដ្ឋាភិបាលសម្រាប់គ្រប់គ្រងលើគ្រឹះស្ថានអប់រំ និងសកម្មភាពអប់រំ ក្នុងគ្រឹះស្ថានឯកជន និងគ្រឹះស្ថានសាធារណៈ។ គោលនយោបាយផ្សេងទៀត ដែលរដ្ឋាភិបាលបានដាក់ឲ្យអនុវត្តផងដែរ រួមមានគោលនយោបាយសាលាកុមារមេត្រី និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច (NAPECD)។ ដើម្បីដោះស្រាយបញ្ហាការដាក់ទណ្ឌកម្មផ្លូវកាយនៅតាមសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយយូនីសេហ្វ បានអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្មីមួយអំពីការដាក់វិន័យបែបវិជ្ជមាន សម្រាប់គ្រូបង្រៀន។ កម្មវិធីនេះផ្តោតការយកចិត្តទុកដាក់លើការបង្កើនចំណេះដឹងតាមសាលារៀនអំពីមូលហេតុ និងផលវិបាកនៃប្រភេទផ្សេងៗនៃអំពើហិង្សា និងការទទួលខុសត្រូវ របស់នាយកសាលា គ្រូ សិស្ស និងឪពុកម្តាយ ក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ។[47]

---

[44] *យុទ្ធសាស្ត្រគាំទ្រវិស័យអប់រំសម្រាប់ប្រទេសកម្ពុជា ២០១០-២០១៣ របស់យូណេស្កូ។*
[45] *យុទ្ធសាស្ត្រគាំទ្រវិស័យអប់រំសម្រាប់ប្រទេសកម្ពុជា ២០១០-២០១៣ របស់យូណេស្កូ។*
[46] *រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧។*
[47] *បញ្ចប់អំពើហិង្សាតាមសាលារៀន - ការបណ្តុះបណ្តាលគ្រូអំពីការដាក់វិន័យបែបវិជ្ជមាន www.unicef.org ។*

បន្ថែមពីលើហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការអប់រំ ដែលទទួលរងដោយកុមារក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ការថែទាំសុខភាព ទឹកស្អាត និងអនាម័យ ក៏ជាក្តីបារម្ភផងដែរ។ បើតាមរបាយការណ៍ប្រចាំឆ្នាំរបស់យូនីសេហ្វ (២០១៣) មានការសម្រេចបាននូវលទ្ធផលខាងសុខភាពគួរឲ្យកត់សម្គាល់ពីឆ្នាំ២០០៥ ដល់២០១០ ដោយអត្រាមរណភាពមានការថយចុះយ៉ាងគំហុក ហើយវិសាលភាពនៃការផ្តល់ថ្នាំបង្ការ និងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់មានការកើនឡើងខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ មរណភាពទារកទើបកើត នៅពុំមានការប្រែប្រួលឡើយ ដែលនេះជាហេតុផលដែលនាំឲ្យមានការព្រួយបារម្ភ ព្រោះថាមូលហេតុសំខាន់ៗដែលធ្វើឲ្យទារកទើបកើតស្លាប់ គឺជំងឺរលាកសួត និងជំងឺរាករូស ដែលជំងឺទាំងពីរនេះគឺសុទ្ធតែកើតឡើងដោយសារតែមានការវិនិយោគតិចតួចលើទឹកស្អាត និងអនាម័យ។ តម្រូវការសេវាពន្យារកំណើតដែលពុំមានការឆ្លើយតបក្នុងចំណោមស្ត្រីដែលរៀបការហើយ ក៏មានការថយចុះផងដែរពី ២៥ភាគរយ ក្នុងឆ្នាំ២០០៥ មក ១៧ភាគរយក្នុងឆ្នាំ២០១០ដែលនេះជានិន្នាការវិជ្ជមានមួយ។ ប៉ុន្តែវឌ្ឍនភាពដែលសម្រេចបាននេះគឺ ពុំមានសង្គតិភាពដូចគ្នា ក្នុងគ្រប់ក្រុមប្រជាជនទាំងអស់ឡើយ ហើយការទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជជាសកលនៅតែមិនទាន់សម្រេចបានជាពិសេស ក្នុងចំណោមស្ត្រីដែលមានស្ថានភាពសង្គមសេដ្ឋកិច្ចទាប ដែលទាមទារឲ្យមានការពង្រឹង និងកែសម្រួលយន្តការសមធម៌សុខាភិបាលឡើងវិញ។

វិស័យសុខាភិបាលក្នុងប្រទេសកម្ពុជាទទួលបានធនធានហិរញ្ញប្បទានពីប្រភពសំខាន់ៗមួយចំនួន ដូចជា ក) ថវិកាវិស័យសុខាភិបាលរបស់រដ្ឋាភិបាល ខ) ការផ្តល់មូលនិធិរបស់អ្នកផ្តល់ជំនួយ និងដៃគូសុខាភិបាល និង គ) ចំណាយផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋ។ គោលនយោបាយដែលត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីពង្រឹងវិស័យសុខាភិបាលរួមមាន ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលដំណាក់កាលទីពីរ (២០០៨-១៥) កម្មវិធីជាតិសុខភាពបន្តពូជ (១៩៩៤-៩៥ គោលនយោបាយស្តីពីការពន្យារកំណើត (១៩៩៥) ផែនការសកម្មភាពជាតិស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ (២០០១-២០០៥ ធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០០៩) គោលនយោបាយជាតិស្តីពីប្រជាជន (២០០៣) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (២០០០)។ ផែនទីបង្ហាញផ្លូវនៃគំនិតផ្តួចផ្តើមពន្លឿនការកាត់បន្ថយមរណភាពមាតា និងទារក (២០១០-១៥) បានដាក់ចេញអាទិភាពមួយចំនួនដូចជា សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបកើត ការសម្រាលកូនដោយឆ្មបជំនាញ ការរៀបចំផែនការគ្រួសារ ការផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង និងការឃ្លាំមើលករណីមរណភាពមាតា។ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ពីភាពចាំបាច់ដើម្បីទប់ស្កាត់ការឆ្លងរាលដាលមេរោគ/ជំងឺអេដស៍ផងដែរ តាមរយៈការអនុម័តច្បាប់ស្តីពីការទប់ស្កាត់ និងការត្រួតពិនិត្យមេរោគ/ជំងឺអេដស៍ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការឆ្លើយតបពហុវិស័យគ្រប់ជ្រុងជ្រោយចំពោះមេរោគ/ជំងឺអេដស៍ (២០០៦-២០១០) លើកទីពីរ ដែលផ្តល់អនុសាសន៍ឲ្យមានការបង្កើនវិសាលភាពនៃអន្តរាគមន៍បង្ការប្រកបដោយប្រសិទ្ធភាព។

ការវិភាគស៊ីជម្រៅលើចំណាយសរុបក្នុងវិស័យសុខាភិបាលនៃប្រទេសកម្ពុជាបង្ហាញថា ចំណាយលើសេវាសុខាភិបាល ៦២ភាគរយ ត្រូវបានរ៉ាប់រងដោយប្រជាពលរដ្ឋខ្លួនឯង ដោយសារតែពួកគេត្រូវទៅរកអ្នកផ្តល់ សេវាថែទាំសុខភាពឯកជន។ ដោយសារតែប្រជាពលរដ្ឋនិយមទៅរកសេវាឯកជន ការអនុវត្តច្បាប់ និងគោលនយោបាយដែលលើកឡើងខាងលើ ធ្វើឡើងមិនបានគ្រប់ជ្រុងជ្រោយឡើយ។ ទំនាក់ទំនងរវាងគម្លាតក្នុងការអនុវត្ត និងចំណាយខ្ពស់លើសេវាថែទាំសុខភាពឯកជន គឺជាមូលហេតុចម្បង ដែលនាំឲ្យមានបញ្ហាវិសមធម៌ ក្នុងការទទួលបានសេវាសុខភាពជាសកលក្នុងប្រទេសកម្ពុជា ជាពិសេស ក្នុងចំណោមក្រុមប្រជាជនរស់នៅតាមតំបន់ទីក្រុង និងតំបន់ជនបទដែលមានស្ថានភាពសង្គមសេដ្ឋកិច្ចផ្សេងៗគ្នា។

ដូចលើកឡើងខាងលើ ការវិនិយោគតិចតួចលើសេវាទឹកស្អាត និងអនាម័យ គឺជាមូលហេតុចម្បង ដែលនាំឲ្យមានជំងឺកើតឡើង ជាពិសេស ជំងឺរលាកសួត និងជំងឺរាករូស ដែលនាំឲ្យអត្រាមរណភាពទារកទើបកើតមានកម្រិតខ្ពស់ និងមានផលប៉ះពាល់អវិជ្ជមានលើសុខភាពរបស់កុមារ/ក្មេងជំទង់ ក្នុងប្រទេសកម្ពុជា។ ការទទួលបានសេវាអនាម័យពុំបានគ្រប់គ្រាន់ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាធំៗជាងគេ ដែលមានផលប៉ះពាល់

ដល់សុខភាពរបស់កុមារ និងក្មេងជំទង់ក្នុងទីក្រុងភ្នំពេញ។ ពួកគេជាច្រើននាក់ពុំបានទទួលទឹកស្អាតសម្រាប់ផឹកគ្រប់គ្រាន់ឡើយ ពួកគេខ្វះបង្គន់ប្រើប្រាស់ ហើយមិនដឹងពីសារៈសំខាន់នៃការលាងសម្អាតដៃជាមួយសាប៊ូឡើយ។មានការប៉ាន់ប្រមាណថាក្នុងមួយឆ្នាំៗមានមនុស្សស្លាប់ប្រមាណជា ១០០០០ ករណី ដោយសារតែការអនុវត្តអនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួននៅមានកម្រិតខ្សោយនៅឡើយ។[48]

ជារួម កិច្ចការពារកុមារ ការអភិវឌ្ឍកុមារគ្រប់ជ្រុងជ្រោយ និងការលើកកម្ពស់សិទ្ធិកុមារ គឺជាភារកិច្ចរបស់រដ្ឋ មានន័យថាវាក៏ជាភារកិច្ចរបស់អាជ្ញាធរគ្រប់ជាន់ថ្នាក់ផងដែរ។ ការងារនេះទាមទារមិនត្រឹមតែយុទ្ធសាស្ត្រការពារប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការវិភាគលើតម្រូវការផ្នែកការការពារកុមារ និងការអប់រំ ដែលមិនទាន់បានទទួលការឆ្លើយតបទៀតផង។ ការកំណត់រកឧបសគ្គពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងស្ថាប័ន និងការលុបបំបាត់ឧបសគ្គទាំងនេះ គឺមានសារៈសំខាន់ ដើម្បីធានាឲ្យមានការអនុវត្តច្បាប់ និងគោលនយោបាយដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការកំណត់ពីបញ្ហាប្រឈមដែលត្រូវដោះស្រាយតាមរយៈកំណែទម្រង់វិធានការគោលនយោបាយផងដែរ។

---

[48] *ទឹក និងអនាម័យ យូនីសេហ្វ កម្ពុជា* www.unicef.org




# អភិក្រម
# និង វិធីសាស្ត្រ

# គោលបំណង និងគោលដៅនៃការវាយតម្លៃនេះ

យូនីសេហ្វសហការជាមួយក្រុមហ៊ុន EY LLP ឥណ្ឌា ធ្វើការសិក្សាវាយតម្លៃនេះ ក្នុងគោលបំណង៖

- កំណត់ពីហានិភ័យសំខាន់ៗផ្នែកកិច្ចការពារកុមារ ដែលកុមារក្នុងវ័យរៀននៅមត្តេយ្យសិក្សា និងក្មេងជំទង់ជួបប្រទះ
- កំណត់ពីកត្តារាំងស្ទះ និងកត្តាអំណោយផលជាក់លាក់នានា ទាក់ទិននឹងភាពក្រីក្រក្នុងទីក្រុង ហើយដែលប៉ះពាល់ដល់លទ្ធភាពកុមារក្នុងការចូលរៀននៅមត្តេយ្យសិក្សា និងក្មេងជំទង់ក្នុងការទទួលបានការអប់រំនៅមធ្យមសិក្សាបឋមភូមិប្រកបដោយគុណភាព និងបរិយាប័ន្ន
- កំណត់ពីទំនាក់ទំនងទៅវិញទៅមករវាងហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងការអប់រំ
- កំណត់ពីព័ត៌មានផ្នែកសេវាដែលមានស្រាប់ ឬសេវាដែលនៅខ្វះខាត សម្រាប់ឆ្លើយតបចំពោះតម្រូវការផ្នែកកិច្ចការពារកុមារ និងការអប់រំ នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុង
- កំណត់ពីការអភិវឌ្ឍសមត្ថភាពជាអាទិភាព ដើម្បីឲ្យរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអាចផ្តល់សេវា និងធ្វើអន្តរាគមន៍ចាំបាច់នានាសម្រាប់ផ្តល់កិច្ចការពារដល់កុមារ

លទ្ធផលនៃការវាយតម្លៃនេះនឹងត្រូវប្រើប្រាស់សម្រាប់ជាធាតុចូលដល់យូនីសេហ្វ និងរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីរៀបចំយុទ្ធសាស្ត្រពង្រឹងការផ្តល់សេវាការពារកុមារ និងធានាយ៉ាងណាឲ្យកុមារ និងក្មេងជំទង់មកពីតាមសហគមន៍ក្រីក្រក្នុងរាជធានីអាចទទួលបានសេវាអប់រំ។

# វិសាលភាពទីតាំងភូមិសាស្ត្រ និងអ្នកពាក់ព័ន្ធក្នុងការសិក្សានេះ

ការសិក្សានេះផ្តោតការយកចិត្តទុកដាក់លើសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញជាពិសេសសហគមន៍ក្នុងខណ្ឌចំនួន ៥ (ខណ្ឌដង្កោ ពោធិសែនជ័យ សែនសុខ មានជ័យ និងឫស្សីកែវ)។ ខណ្ឌទាំងនេះមានសហគមន៍ក្រីក្រចំនួន ១៩៤ និងប្រជាជនសរុប ៨៩.៣២៦នាក់។ សហគមន៍ក្រីក្រក្នុងទីក្រុងទាំងនេះកើតឡើងក្នុងទម្រង់ជាកន្លែងតាំងទីលំនៅមិនរៀបរយក្នុងទំហំខុសៗគ្នារ៉ាយប៉ាយច្រើនទីតាំង តាមខណ្ឌនីមួយៗ។ ជាធម្មតាតំបន់តាំងទីលំនៅមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវធំៗ (ដូចជា ផ្លូវជាតិ និងផ្លូវរថភ្លើង ជាដើម) ក្នុងទិសដៅចូលមកក្នុងក្រុង និងចេញទៅក្រៅក្រុង។ ខណ្ឌដង្កោ និងខណ្ឌពោធិសែនជ័យ មានទីតាំងនៅតាមបណ្តោយផ្លូវធំ ខណ្ឌមានជ័យមានទីតាំងតាមបណ្តោយប្រឡាយទឹក ហើយខណ្ឌឫស្សីកែវមានទីតាំងតាមបណ្តោយទន្លេមេគង្គ។ ការស្រាវជ្រាវនេះផ្តោតសំខាន់លើសហគមន៍ទាំងនេះ ក្នុងគោលបំណងស្វែងរកព័ត៌មានស៊ីជម្រៅដែលពាក់ព័ន្ធ ដោយប្រើប្រាស់កម្រងសំណួរដែលរៀបចំទុកជាមុន និងការពិភាក្សាក្រុមគោលដៅជាមួយនឹងកុមារក្នុងក្រុមអាយុពី៣ ដល់ ៥ឆ្នាំ អ្នកផ្តល់ការថែទាំចម្បងរបស់ពួកគេ ក្មេងជំទង់ក្នុងក្រុមអាយុពី១០ ដល់ ១៤ឆ្នាំ និងអ្នកផ្តល់ការថែទាំចម្បងរបស់ពួកគេ។

## អភិក្រម និងវិធីសាស្ត្រ

អភិក្រម និងវិធីសាស្ត្រ ប្រើប្រាស់សម្រាប់ការវាយតម្លៃពីតម្រូវការនេះ ត្រូវបានរៀបចំឡើងដោយគោរពទៅតាម "នីតិវិធីស្តង់ដាក្រមសីលធម៌ក្នុងការស្រាវជ្រាវ ការវាយតម្លៃ ការប្រមូលទិន្នន័យ និងការវិភាគរបស់យូនីសេហ្វ"។ លើសពីនេះ ក្រុមការងារក៏បានគិតគូរពីបញ្ហាសិទ្ធិមនុស្ស និងសមភាពយេនឌ័រផងដែរ ពេលចុះប្រមូលព័ត៌មានតាមមូលដ្ឋាន សម្រាប់ការស្រាវជ្រាវនេះ។

## ការពិចារណាពីក្រមសីលធម៌ សិទ្ធិមនុស្ស និងសមភាពយេនឌ័រ

**ក្រមសីលធម៌៖** ក្រុមការងារបានរៀបចំក្រមសីលធម៌មួយ ដោយប្រើប្រាស់នីតិវិធីស្តង់ដាក្រមសីលធម៌របស់យូនីសេហ្វជាគោល។ អ្នកស្រាវជ្រាវត្រូវគោរពតាមក្រមសីលធម៌នេះ នៅពេលដែលពួកគេចុះទៅប្រមូលទិន្នន័យពីទីវាលមក។ ដើម្បីធានាថាអ្នកស្រាវជ្រាវពិតជាគោរពតាមក្រមសីលធម៌ប្រាកដមែន ពួកគេត្រូវបានពិនិត្យតាមដានជាប្រចាំ ដោយអ្នកជំនាញជាន់ខ្ពស់ពីក្រុមហ៊ុន Ernst and Young LLP ឥណ្ឌា។ ចំណុចផ្សេងៗដូចជា ការយល់ព្រម ការរក្សាការសម្ងាត់ ភាពរសើបនៃសំណួរ ភាពងាយស្រួលរបស់អ្នកឆ្លើយតប និងសមធម៌ក៏ត្រូវបានយកមកគិតពិចារណាផងដែរពេលរៀបចំបង្កើតឧបករណ៍ សម្រាប់ការស្រាវជ្រាវនេះ ហើយមានការពង្រឹងបន្ថែមទៀត ផ្អែកទៅតាមលទ្ធផលនៃការធ្វើតេស្តសាកល្បង។

**ការបណ្តុះបណ្តាលអ្នកស្រាវជ្រាវ៖** ក្រមសីលធម៌នេះត្រូវបានពន្យល់ទៅកាន់អ្នកស្រាវជ្រាវ ក្នុងសិក្ខាសាលា "បណ្តុះបណ្តាលអ្នកស្រាវជ្រាវ" ពិសេសមួយ ដែលរៀបចំធ្វើឡើងនៅការិយាល័យយូនីសេហ្វក្នុងនៅភ្នំពេញ។ ការធ្វើបែបនេះ គឺដើម្បីធានាថា សាវតារ សមត្ថភាព និងជំនាញរបស់អ្នកស្រាវជ្រាវគឺពិតជាដល់កម្រិតស្តង់ដាមួយ ដែលការពារមិនឲ្យមានការបង្កគ្រោះថ្នាក់ដល់អ្នកឆ្លើយតប ទោះជាតាមរយៈការធ្វើសកម្មភាពក្តី ឬការមិនធ្វើសកម្មភាពក្តី។

**ការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ ក្នុងរដ្ឋាភិបាល និងយូនីសេហ្វកម្ពុជា៖** អភិក្រម និងវិធីសាស្ត្រ ប្រើប្រាស់សម្រាប់ធ្វើការសិក្សាស្រាវជ្រានេះ សំណួរស្រាវជ្រាវសំខាន់ៗ ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ/ព័ត៌មានប្រវត្តិសាវតាររបស់អ្នកស្រាវជ្រាវ និងទម្រង់ផ្តល់ការយល់ព្រម ត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយនឹងយូនីសេហ្វ និងរដ្ឋបាលរាជធានីភ្នំពេញ។ លើសពីនេះ ការចុះប្រមូលទិន្នន័យត្រូវបានធ្វើឡើង បន្ទាប់ពីអ្នកដឹកនាំសហគមន៍ ឪពុកម្តាយ/អាណាព្យាបាល និងក្មេងជំទង់ ត្រូវបានប្រាប់ពីគោលបំណងនៃការសិក្សានេះ។ ចំណុចសំខាន់ជាងគេគឺការបណ្តុះបណ្តាលអ្នកស្រាវជ្រាវតាមមូលដ្ឋានធ្វើឡើង ក្នុងការិយាល័យយូនីសេហ្វនៅភ្នំពេញ ដែលផ្តល់លទ្ធភាពឲ្យបុគ្គលិកយូនីសេហ្វចូលរួមក្នុងដំណើរការនេះយ៉ាងសកម្មផងដែរ។

**សិទ្ធិមនុស្ស និងសមភាពយេនឌ័រ៖** ក្រុមអ្នកស្រាវជ្រាវត្រូវបានបង្កើតឡើងឲ្យមានតុល្យភាពយេនឌ័រ ហើយអ្នកស្រាវជ្រាវជាស្ត្រីត្រូវបានប្រគល់ការទទួលខុសត្រូវឲ្យធ្វើការងារជាមួយអ្នកឆ្លើយតបជាស្ត្រី។ លើសពីនេះ កម្រងសំណួរត្រូវបានប្រើប្រាស់ សម្រាប់សម្ភាសប្រមូលព័ត៌មានសំខាន់ៗ នៅកម្រិតគ្រួសារ ដើម្បីប្រមូលទិន្នន័យ/ព័ត៌មាន ដែលអាចយកមកវិភាគដោយបែងចែកតាមយេនឌ័រ ហើយក៏នឹងមានការឆ្លុះបញ្ចាំងដូចគ្នានេះ ក្នុងរបាយការណ៍នេះទាំងមូលផងដែរ។ ទំហំសំណាកគំរូសម្រាប់ប្រមូលការឆ្លើយតបពីក្រុមគោលដៅនីមួយៗ ត្រូវបានកំណត់ ដោយមានការធានាថាអ្នកឆ្លើយតបពាក់កណ្តាល គឺជាស្ត្រី/ក្មេងស្រី។

**ទម្រង់ផ្តល់ការយល់ព្រម៖** ចំណុចសំខាន់ជាងគេ កម្រងសំណួរត្រូវបានប្រើប្រាស់ ដើម្បីសួរអ្នកឆ្លើយតប ក្រោយពីមានការទទួលការយល់ព្រមជាផ្លូវការពីអ្នកឆ្លើយតប។ ក្រុមការងារបានព្រាងទម្រង់ផ្តល់ការយល់ព្រម ដែលតម្រូវឲ្យអ្នកស្រាវជ្រាវពន្យល់ពីគោលបំណងនៃការសិក្សានេះ និងលក្ខណៈនៃសំណួរទៅកាន់អ្នកឆ្លើយតប។

អ្នកស្រាវជ្រាវក៏ត្រូវពន្យល់ប្រាប់អ្នកឆ្លើយតបផងដែរថា ពួកគេអាចមិនឆ្លើយសំណួរណាមួយ ដែលធ្វើឲ្យពួកគេពិបាកឆ្លើយបាន និងអាចបដិសេធមិនបន្តចូលរួមនៅពេលណាក៏បាន។ ការធ្វើបែបនេះអាចធានាបាននូវភាពម្ចាស់ការរបស់អ្នកឆ្លើយតប និងទទួលស្គាល់ពីលទ្ធភាពរបស់អ្នកឆ្លើយតបក្នុងការគ្រប់គ្រងខ្លួនឯង ធ្វើការវិនិច្ឆ័យ លើកឡើងពីការយល់ឃើញរបស់ពួកគេ និងធ្វើការសម្រេចចិត្ត។

ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រចម្រុះ ដែលត្រូវបានរៀបចំឡើងជុំវិញគោលបំណងនៃការស្រាវជ្រាវ ដូចបញ្ជាក់ខាងលើ និងត្រូវបានបែងចែកជាដំណាក់កាលៗ ដោយមានទំនាក់ទំនងនឹងគ្នា។ វិធីសាស្ត្របែបបរិមាណវិស័យ រួមមាន ការប្រើប្រាស់កម្រងសំណួរសម្រាប់ប្រមូលព័ត៌មានតាមគ្រួសារ ដោយឡែកវិធីសាស្ត្របែបគុណវិស័យ រួមមាន ការសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធ និងបញ្ជីត្រួតពិនិត្យសម្រាប់ការពិភាក្សាក្រុមគោលដៅ។ ដំណាក់កាលទីមួយផ្តោតលើការពិនិត្យឯកសារពាក់ព័ន្ធ ដំណាក់កាលទីពីរ មានការបង្កើតក្របខ័ណ្ឌសម្រាប់ការវាយតម្លៃទាំងមូល និងការរៀបចំឧបករណ៍សម្រាប់ប្រមូលទិន្នន័យ/ព័ត៌មាន ដំណាក់កាលទីបីផ្តោតលើការប្រមូលទិន្នន័យ ហើយដំណាក់កាលចុងក្រោយ គឺការវិភាគលើទិន្នន័យដែលប្រមូលបាន និងការសរសេររបាយការណ៍។ ជំហានដែលប្រើប្រាស់សម្រាប់ដំណាក់កាលនីមួយៗ ដូចរៀបរាប់ខាងក្រោម គឺជាមូលដ្ឋាននៃវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់ការវាយតម្លៃនេះ។

## ការពិនិត្យលើឯកសារពាក់ព័ន្ធ

ក្នុងដំណាក់កាលនេះ ក្រុមការងារបានពិនិត្យលើឯកសារនានា ពាក់ព័ន្ធនឹងហានិភ័យទាក់ទិននឹងកិច្ចការពារកុមារ និងបញ្ហាអប់រំ ដែលកុមារឬក្មេងជំទង់ជួបប្រទះ។ ឯកសារពាក់ព័ន្ធ ដែលត្រូវបានប្រមូលយកមកពិនិត្យមានបីកម្រិត៖ ឯកសារនៅកម្រិតអន្តរជាតិ ឯកសារជាតិ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋក្រីក្រក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ពាក់ព័ន្ធនឹងចំណុចនេះ ក្រុមការងារក៏បានទាក់ទងទៅមន្ត្រីយូនីសេហ្វ ដើម្បីសុំឯកសារពាក់ព័ន្ធផងដែរ និងបានទទួលឯកសារជាច្រើន។ ការពិនិត្យលើឯកសារទាំងនេះបានជួយផ្តល់ឲ្យក្រុមការងារនូវការយល់ដឹងជាមូលដ្ឋាន ដែលចាំបាច់ដើម្បីរៀបចំក្របខ័ណ្ឌសម្រាប់ការស្រាវជ្រាវនេះ បង្កើតឧបករណ៍ប្រមូលទិន្នន័យ និងរៀបចំផែនការសម្រាប់រៀបចំរបាយការណ៍ចុងក្រោយ។ ក្រុមការងារបានរៀបចំនូវតារាងមួយ ដែលបង្ហាញពីឯកសារដែលក្រុមការងារបានពិនិត្យ និងព័ត៌មានសំខាន់ៗដែលទទួលបានពីឯកសារទាំងនេះ។ តារាងនេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទី៣។

## ការរៀបចំក្របខ័ណ្ឌ និងឧបករណ៍វាយតម្លៃ

ផ្អែកតាមលទ្ធផលនៃការពិនិត្យឯកសារពាក់ព័ន្ធ ក្រុមការងារបានបង្កើតនូវក្របខ័ណ្ឌសម្រាប់ការស្រាវជ្រាវមួយ ដែលរៀបរាប់លម្អិតពីគោលបំណងនៃការស្រាវជ្រាវ ដូចដែលត្រូវបានបញ្ជាក់ក្នុងលក្ខខណ្ឌប្រតិបត្តិ (ToR) និងដូចដែលបញ្ជាក់ពីខាងដើម។ ក្របខ័ណ្ឌនេះត្រូវបានបំបែកជាសំណួរស្រាវជ្រាវតូចៗ រួចយកមកផ្ទៀបនឹងសូចនាករសំខាន់ៗ ដែលប្រើប្រាស់សម្រាប់ប្រមូលព័ត៌មាន។ ការធ្វើបែបនេះផ្តល់លទ្ធភាពឲ្យក្រុមការងារអាចរៀបចំព័ត៌មានពាក់ព័ន្ធនឹងការស្រាវជ្រាវនេះជារចនាសម្ព័ន្ធត្រឹមត្រូវ។ លើសពីនេះ ក្នុងក្របខ័ណ្ឌនេះ មានការផ្ទូវផ្គងសូចនាករសម្រាប់ការស្រាវជ្រាវ ជាមួយនឹងអ្នកពាក់ព័ន្ធ ដែលអាចផ្តល់ទិន្នន័យ ឬព័ត៌មានចាំបាច់នានា និងអំពីឧបករណ៍ដែលគេអាចប្រើប្រាស់ ដើម្បីប្រមូលទិន្នន័យ ឬព័ត៌មានទាំងនេះ។

ដោយសារតម្រូវការរបស់កុមារក្នុងក្រុមអាយុពី៣ ទៅ ៥ឆ្នាំ ខុសពីតម្រូវការរបស់ក្មេងជំទង់ក្នុងក្រុមអាយុពី ១០ ទៅ ១៧ឆ្នាំ មានការរៀបចំក្របខ័ណ្ឌវាយតម្លៃផ្សេងគ្នាសម្រាប់ក្រុមទាំងពីរនេះ។ ក្របខ័ណ្ឌស្រាវជ្រាវនេះគឺជាមូលដ្ឋាន ដែលក្រុមការងារប្រើប្រាស់ សម្រាប់រៀបចំ

ឧបករណ៍ប្រមូលទិន្នន័យ ឬព័ត៌មាន (សូមមើលឧបសម្ព័ន្ធទី២)។

**កម្រងសំណួរគ្រួសារ៖** កម្រងសំណួរគ្រួសារត្រូវបានរៀបចំឡើងសម្រាប់កុមារផ្សេង និងសម្រាប់ក្មេងជំទង់ផ្សេង។ លើសពីនេះ ក៏មានការរៀបចំកម្រងសំណួរផ្សេងៗគ្នា សម្រាប់ឪពុកម្តាយឬអាណាព្យាបាល របស់កុមារក្នុងក្រុមអាយុពី៣ ដល់ ៥ឆ្នាំ និងក្មេងជំទង់ក្នុងក្រុមអាយុពី១០ ដល់ ១៩ឆ្នាំ និងសម្រាប់ក្មេងជំទង់ដើម្បីផ្តល់លទ្ធភាពឲ្យគេអាចធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលបានពីប្រភពផ្សេងៗគ្នាក្នុងដំណើរការនៃការវិភាគនេះ។ ក្នុងគ្រួសារដែលមានកូនអាយុពី៣ ដល់ ៥ឆ្នាំ កម្រងសំណួរសម្រាប់កុមារ និងកម្រងសំណួរសម្រាប់អ្នកផ្តល់ការថែទាំ ត្រូវបានប្រើប្រាស់ទាំងពីរជាមួយនឹងអ្នកផ្តល់ការថែទាំចម្បងដល់កុមារ។ ក្នុងគ្រួសារដែលមានក្មេងជំទង់ (ប្រុស ឬស្រី) មានការប្រើប្រាស់កម្រងសំណួរជាមួយក្មេងជំទង់ផ្សេង និងជាមួយអាណាព្យាបាលរបស់ពួកគេផ្សេង។ ការប្រើប្រាស់ឧបករណ៍ទាំងនេះមានគោលបំណងសំខាន់ គឺប្រមូលទិន្នន័យដែលចាំបាច់នានា ដើម្បីស្វែងយល់ពីការចូលរួមរបស់កុមារ និងក្មេងជំទង់ក្នុងសេវាអប់រំ តម្រូវការកិច្ចការពារកុមារ និងការចូលរួមរបស់ឪពុកម្តាយក្នុងការអប់រំកូន និងការចិញ្ចឹមបីបាច់កូន ក៏ដូចជាពីហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងសុខភាព ដែលកុមារ និងក្មេងជំទង់ជួបប្រទះ។ ដើម្បីកាត់បន្ថយកំហុសឲ្យបានជាអតិបរមា មានការដាក់លេខកូដលើក្រដាសចម្លើយឲ្យត្រូវគ្នាជាមួយនឹងកម្រងសំណួរទាំងនេះ។ ទំហំសំណាកគំរូសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗត្រូវបានបង្ហាញដូចខាងក្រោម៖

## កម្រងសំណួរគ្រួសារ

| ៣៨០ | ៣៨០ | ១៩០ | ១៩០ |
|---|---|---|---|
| ឪពុកម្តាយដែលមានកូនជាកុមារក្នុងក្រុមអាយុពី៣ ដល់ ៥ឆ្នាំ (ស្ត្រី/ក្មេងស្រី ៥០ ភាគរយ) | ឪពុកម្តាយដែលមានកូនជាក្មេងជំទង់ក្នុងក្រុមអាយុពី១០ ដល់ ១៩ឆ្នាំ (ស្ត្រី/ក្មេងស្រី ៥០ ភាគរយ) | ក្មេងប្រុសជំទង់ក្នុងក្រុមអាយុពី ១០ ដល់ ១៩ឆ្នាំ | ក្មេងស្រីជំទង់ក្នុងក្រុមអាយុពី ១០ ដល់ ១៩ឆ្នាំ |

**បញ្ជីត្រួតពិនិត្យសម្រាប់ការពិភាក្សាក្រុមគោលដៅ (FGD)៖** បញ្ជីត្រួតពិនិត្យសម្រាប់ការពិភាក្សាក្រុមគោលដៅ ត្រូវបានរៀបចំឡើង ដើម្បីពិភាក្សាបែបគុណវិស័យលម្អិតជាមួយនឹងក្មេងជំទង់ និងសមាជិកសហគមន៍ (ដូចជាប្រធានសហគមន៍ ឪពុកម្តាយ និងចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ជាដើម)។ ការពិភាក្សាក្រុមគោលដៅជាមួយក្មេងជំទង់ ត្រូវបានធ្វើឡើងក្នុងទម្រង់ជាសិក្ខាសាលា ហើយមានការពិភាក្សាជាមួយក្មេងប្រុស ផ្សេងពីក្មេងស្រី។ ការពិភាក្សាក្រុមគោលដៅនេះផ្តោតលើការប្រមូលព័ត៌មានស៊ីជម្រៅអំពីទម្លាប់ក្នុងសហគមន៍ ការទម្លាប់ក្នុងគ្រួសារ និងទម្លាប់របស់បុគ្គលម្នាក់ៗ ពាក់ព័ន្ធនឹងការឆ្លើយតបនឹងតម្រូវការរបស់កុមារ និងក្មេងជំទង់។ ក្នុងការពិភាក្សាក្រុមគោលដៅនេះ មានការប្រមូលព័ត៌មានលើសពីសូចនាករ ឬបញ្ហានៅកម្រិតគ្រួសារ និងផ្តោតការយកចិត្តទុកដាក់លើការស្វែងយល់ពីស្ថានភាពជារួមនៃបញ្ហាប្រឈមនៅកម្រិតសហគមន៍ ឬជាទូទៅ។

## ការពិភាក្សាក្រុមគោលដៅ (FGDs)

| ៩ (៤៨) | ៩ (៤៨) | ៩ (៤៨) |
|---|---|---|
| សមាជិកសហគមន៍ (អ្នកចូលរួម ១២នាក់ ក្នុងមួយក្រុមស្ត្រី/ក្មេងស្រី ៥០ភាគរយ) | ក្មេងប្រុសជំទង់ (អ្នកចូលរួម ១២នាក់ ក្នុងមួយក្រុម) | ក្មេងស្រីជំទង់ (អ្នកចូលរួម ១២នាក់ ក្នុងមួយក្រុម) |

**កម្រងសំណួរសម្ភាសន៍ពាក់កណ្ដាលរចនាសម្ព័ន្ធ៖** កម្រងសំណួរពាក់កណ្ដាលរចនាសម្ព័ន្ធត្រូវបានរៀបចំឡើងដើម្បីពិភាក្សាប្រមូលព័ត៌មានពីមន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល ប្រធានសហគមន៍ និងតំណាងសាលារៀន។ សម្ភាសន៍ពាក់កណ្ដាលរចនាសម្ព័ន្ធមានគោលបំណងស្វែងយល់ពីគោលនយោបាយ កម្មវិធី យន្តការ និងគំនិតផ្ដួចផ្ដើមនានា ដែលអ្នកពាក់ព័ន្ធនឹងទង្វើផ្សេងៗដើម្បីជួយកុមារ និងក្មេងជំទង់ឲ្យទទួលបានការអប់រំ ឬដើម្បីការពារសិទ្ធិរបស់ពួកគេ។ កម្រងសំណួរទាំងនេះក៏ប្រមូលនូវទស្សនៈរបស់អ្នកឆ្លើយតបជុំវិញបញ្ហាប្រឈមនានា ដែលកុមារ និងក្មេងជំទង់ជួបប្រទះហើយនឹងបានជាព័ត៌មាន សម្រាប់ផ្ទៀងផ្ទាត់នូវលទ្ធផលរកឃើញ ទាញចេញពីទិន្នន័យដែលប្រមូលបានដោយប្រើប្រាស់កម្រងសំណួរគ្រួសារ។ ការពិភាក្សាទាំងនេះក៏បានជួយឲ្យក្រុមការងារយល់ពីបញ្ហាប្រឈមដែលស្ថាប័ននានាជួបប្រទះ ក្នុងការឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់កុមារ និងក្មេងជំទង់ផងដែរ។

## សម្ភាសន៍ពាក់កណ្ដាលរចនាសម្ព័ន្ធ

| ៨ | ៩ | ៦ |
|---|---|---|
| អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល | គ្រូបង្រៀន (ស្រី ៦០ភាគរយ) | មន្ត្រីរដ្ឋាភិបាល |

## សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ

ក្នុងដំណាក់កាលនេះ ការជួបសម្ភាសផ្ទាល់ត្រូវបានធ្វើឡើងនៅនឹងផ្ទះផ្ទាល់តែម្តងជាមួយនឹងអ្នកឆ្លើយតបចំនួន ១១៩០នាក់ (ស្រី ៥០ភាគរយ) មកពីសហគមន៍ក្រីក្រក្នុងទីក្រុងចំនួន ១៣ទីតាំង ក្នុងខណ្ឌទាំង៥ នៃរាជធានីភ្នំពេញ។ ការបង្កើតសំណាកគំរូសម្រាប់សម្ភាសន៍នេះធ្វើឡើងជា២ដំណាក់កាល។ ក្នុងដំណាក់កាលទីមួយ សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញចំនួន១៣ (ស្មើនឹង៥ភាគរយនៃសហគមន៍ក្រីក្រក្នុងទីក្រុងសរុប ២៦០) ត្រូវបានជ្រើសរើស ដោយប្រើប្រាស់វិធីសាស្រ្ត “ប្រូបាប៊ីលីតេ សមាមាត្រនឹងទំហំ (probability proportionate to size)”។ សហគមន៍ទាំងនេះត្រូវបានជ្រើសរើស ដោយប្រើប្រាស់វិធីសាស្រ្តបែបនេះ និងមានរៀបរាប់ដូចខាងក្រោម៖

| ខណ្ឌ | ដង្កោ | ពោធិ៍សែនជ័យ | សែនសុខ | មានជ័យ | ឫស្សីកែវ |
|---|---|---|---|---|---|
| សហគមន៍ | • ទួលសំបូរ | • ថ្មគោល១<br>• ពង្រោសែនជ័យ<br>• ត្រពាំងអញ្ចាញ | • សែនសួស្តី<br>• ជឿនលឿន | • ឫស្សី<br>• ព្រះពោះ<br>• ព្រះតាគង់១ | • ផ្សារតូច<br>• សន្តិភាព<br>• មិត្តភាព<br>• កំបុត |

បន្ទាប់មក ក្រុមការងាររៀបចំបញ្ជីឈ្មោះគ្រួសារតាមសហគមន៍នីមួយៗ ក្នុងចំណោមសហគមន៍ទាំង១៣ ដោយរៀបរាប់លម្អិតពីឈ្មោះ និងអាយុរបស់កុមារ និងក្មេងជំទង់ទាំងអស់ តាមខ្នងផ្ទះនីមួយៗ។ បញ្ជីនេះត្រូវបានប្រើប្រាស់ ដើម្បីជ្រើសរើសគ្រួសារដែលត្រូវចុះទៅប្រមូលព័ត៌មាន ដោយប្រើប្រាស់កម្រងសំណួរសម្រាប់កុមារ កម្រងសំណួរសម្រាប់ក្មេងជំទង់ និងកម្រងសំណួរសម្រាប់អាណាព្យាបាល ដោយការជ្រើសរើសនេះធ្វើឡើងតាមបែបចៃដន្យ។ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺការជ្រើសរើសគ្រួសារធ្វើឡើង ដោយធ្វើយ៉ាងណាឲ្យមានការចុះប្រមូលព័ត៌មានពីគ្រួសារនីមួយៗ ដោយប្រើប្រាស់កម្រងសំណួរសម្រាប់កុមារ ឬកម្រងសំណួរសម្រាប់ក្មេងជំទង់។ *ក្នុងកំឡុងពេលរៀបចំបញ្ជីឈ្មោះគ្រួសារគ្រួសារមួយចំនួនមិនចង់ចូលរួមឡើយ ហើយលើសពីនេះ សហគមន៍តូចៗពុំមានគ្រួសារគ្រប់ចំនួនសម្រាប់សម្ភាសន៍ឡើយ។ ដូច្នេះ អ្នកស្រាវជ្រាវត្រូវរកសហគមន៍ធំៗ ឬបញ្ចូលសហគមន៍តូចៗជាមួយគ្នាដើម្បីសម្រេចទៅតាមគោលដៅដែលបានកំណត់។*

បន្ទាប់មកក្រុមការងារចុះតាមគ្រួសារដែលមានឈ្មោះក្នុងបញ្ជី ដើម្បីប្រមូលព័ត៌មាន ដោយប្រើប្រាស់កម្រងសំណួរបែបបរិមាណវិស័យ។ បន្ថែមពីលើកម្រងសំណួរសម្រាប់ចុះប្រមូលព័ត៌មានតាមគ្រួសារ កម្រងសំណួរពាក់កណ្តាលរចនាសម្ព័ន្ធដែលប្រើប្រាស់ជាមួយនឹងមន្រ្តីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលឬអង្គការសង្គមស៊ីវិល និងគ្រូបង្រៀន ក៏មានការពិភាក្សាក្រុមគោលដៅជាមួយសមាជិកសហគមន៍ ដូចជា ឪពុកម្តាយ ប្រធានសហគមន៍ បុគ្គលសំខាន់ៗ និងចាស់ព្រឹទ្ធាចារ្យផងដែរ។

## ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍

ដើម្បីធានាថារបាយការណ៍ចុងក្រោយពិតជាឆ្លើយទៅនឹងសំណួរវាយតម្លៃលើតម្រូវការពិតមែន ក្របខ័ណ្ឌវាយតម្លៃត្រូវបានប្រើប្រាស់ សម្រាប់តម្រង់ទិសដល់ការវិភាគ។ ទិន្នន័យដែលប្រមូលបានតាមរយៈកម្រងសំណួរគ្រួសារ ត្រូវបានយកមកវិភាគ ដើម្បីបង្កើតជាក្រាហ្វ និងតារាង ដែលក្រោយមកផ្ញើទៅយូនីសេហ្វ ក្នុងទម្រង់ជាបទបង្ហាញ។ កិច្ចការនេះត្រូវបានធ្វើឡើង ដើម្បីធានាថាពុំមានការរំលងការវិភាគសំខាន់ៗណាឡើយ។ លើសពីនេះ ក្រុមការងារបានរៀបចំសេចក្តីព្រាងមាតិកា សម្រាប់របាយការណ៍ចុងក្រោយ និងសុំយោបល់ពីអ្នកជំនាញរបស់យូនីសេហ្វ។ ការរៀបចំសេចក្តីព្រាងរបាយការណ៍នេះធ្វើឡើង ទៅតាមមាតិកានេះ និងផ្អែកទៅតាមព័ត៌មានស៊ីជម្រៅ ដែលទទួលបានតាមរយៈការផ្ទៀងផ្ទាត់លើទិន្នន័យ ដែលប្រមូលបានដោយប្រើប្រាស់កម្រងសំណួរបែបបរិមាណ វិស័យនិងព័ត៌មានដែលប្រមូលបានតាមរយៈការពិភាក្សាក្រុមគោលដៅ និងសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ។

## ដែនកំណត់នៃការវាយតម្លៃនេះ

| ដែនកំណត់ | ដំណោះស្រាយ |
|---|---|
| ដោយសារស្ថានភាពក្នុងរាជធានីភ្នំពេញមានការប្រែប្រួល យើងមិនអាចប្រើប្រាស់ការអង្កេតមុនៗ ដើម្បីកំណត់រកទីតាំងសហគមន៍ក្រីក្រ ក្នុងទីក្រុងបានឡើយ ព្រោះថាប្រសិនបើប្រើប្រាស់ការអង្កេតទាំងនេះមែននោះ ក្រុមការងារមិនអាចមានទិន្នន័យថ្មីៗចុងក្រោយមកប្រើប្រាស់ឡើយ។ | ទីប្រឹក្សាថ្នាក់ជាតិបានជួយកំណត់រកសហគមន៍ក្រីក្រ ក្នុងទីក្រុង ហើយព័ត៌មានអំពីទីតាំងរបស់សហគមន៍ទាំងនេះ ក៏ទទួលបានពីការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដែលធ្វើការងារជាមួយប្រជាជនក្រីក្រក្នុងទីក្រុងផងដែរ។ |
| ការប្រែប្រួលស្ថានភាពក្នុងទីក្រុង មានន័យថា គេអាចកំណត់ដឹងពីទំហំរបស់សហគមន៍នីមួយៗ តែក្រោយពេលចុះទៅកាន់សហគមន៍ទាំងនោះតែប៉ុណ្ណោះ។ | សម្រាប់ករណីមួយចំនួន ក្នុងដំណាក់កាលរៀបចំបញ្ជីឈ្មោះគ្រួសារ សហគមន៍តូចៗដែលមានទីតាំងនៅជិតគ្នាត្រូវបានដាក់បញ្ចូលគ្នា និងចាត់ទុកថាជាសហគមន៍ធំមួយ។ ក្នុងករណីផ្សេងទៀត ចំនួនគ្រួសារក្នុងបញ្ជីគឺលើសពីចំនួនដែលចង់បាន ដោយសារតែ តំបន់តាំងទីលំនៅនោះមានទំហំធំជាងទំហំដែលបង្ហាញក្នុងឯកសាររបស់រដ្ឋាភិបាល។ |

| ដែនកំណត់ | ដំណោះស្រាយ |
| --- | --- |
| មានឧបសគ្គខាងផ្នែកភាសា ក្នុងកំឡុងពេលបណ្តុះបណ្តាលសមាជិកក្រុមស្រាវជ្រាវ និងក្នុងពេលចុះប្រមូលទិន្នន័យ។ | ទីប្រឹក្សាថ្នាក់ជាតិ និងសមាជិកក្រុមការងារដែលចេះភាសាខ្មែរស្ទាត់ជំនាញបានជួយក្នុងពេលបណ្តុះបណ្តាល។ រាល់ឧបករណ៍ទាំងអស់ត្រូវបានបកប្រែជាភាសាខ្មែរដោយអ្នកបកប្រែអាជីព។ ការបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងនៅការិយាល័យរបស់យូនីសេហ្វ ដើម្បីឲ្យបុគ្គលិកយូនីសេហ្វអាចបញ្ជាក់ផ្ទៀងផ្ទាត់លើសមត្ថភាពរបស់អ្នកចុះស្រាវជ្រាវដល់មូលដ្ឋាន និងគុណភាពនៃវគ្គបណ្តុះបណ្តាលដែលផ្តល់ដល់ពួកគេ។ |
| សុពលភាពនៃទិន្នន័យដែលប្រមូលបានត្រូវទទួលរងផលប៉ះពាល់ ដោយសារតែភាពស្ទាក់ស្ទើររបស់អ្នកឆ្លើយតបក្នុងការផ្តល់ចម្លើយដែលត្រឹមត្រូវចំពោះបញ្ហាដែលមានលក្ខណៈរសើប ដូចជា បញ្ហាពលកម្មកុមារជាដើម។ | ការផ្ទៀងផ្ទាត់លើទិន្នន័យបរិមាណវិស័យ និងគុណវិស័យ បានផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីបញ្ហាពលកម្មកុមារ។ |
| ស្ថានភាពគោលនយោបាយចេះតែបន្តប្រែប្រួលដែលអាចមិនត្រូវបានឆ្លុះបញ្ចាំងទាំងស្រុងក្នុងរបាយការណ៍នេះ។ | ការសិក្សានេះធ្វើឡើងចំពេលដែលរដ្ឋសភាធ្វើការពិភាក្សាពីច្បាប់សំខាន់មួយចំនួន។ ក្រុមការងារបានធ្វើការតាមដានលើការវិវឌ្ឍផ្នែកច្បាប់ទាំងនេះ តាមលទ្ធភាពដែលអាចធ្វើបាន ហើយបានព្យាយាមរក្សាផ្នែកដែលពិភាក្សាពីគោលនយោបាយក្នុងការសិក្សានេះឲ្យមានបច្ចុប្បន្នភាព តាមដែលអាចធ្វើទៅបាន។ |
| សំណាកគំរូសម្រាប់កុមារ និងក្មេងជំទង់មានពិការភាពនៅមានទំហំតូច | ការវិភាគជុំវិញកុមារ និងក្មេងជំទង់ធ្វើឡើងដោយមានកម្រិតបើគិតពីលក្ខណៈស្ថិតិ ដោយសារតែទំហំសំណាកគំរូនៅមានកម្រិត។ ការវិភាគដែលបង្ហាញជូននេះគួរចាត់ទុកថាជាការវិភាគដែលមានលក្ខណៈតំណាងប៉ុណ្ណោះ។ |




# ហានិភ័យពាក់ព័ន្ធនឹង កិច្ចការពារកុមារ ក្នុងសហគមន៍ ក្រីក្រក្នុងរាជធានីភ្នំពេញ

# សេចក្តីផ្តើម

កុមារក្នុងក្រុមអាយុពី៣ ដល់ ៥ឆ្នាំ និងក្មេងជំទង់ក្នុងក្រុមអាយុពី១០ ដល់ ១៩ឆ្នាំ ដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ ហើយដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ កំពុងប្រឈមនឹងហានិភ័យធំៗមួយចំនួន ពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ ហានិភ័យទាំងនេះ រួមមាន ការខ្វះការថែទាំពីឪពុកម្តាយឲ្យបានគ្រប់គ្រាន់ ការប្រើបំពានសារធាតុញៀន ការចូលរួមក្នុងក្រុមយុវជនទំនើងដែលនាំឲ្យពួកគេត្រូវមានទំនាស់ជាមួយច្បាប់ ការដាក់ទណ្ឌកម្មលើរាងកាយ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងពលកម្មកុមារ។ ការទទួលបានសេវាថែទាំសុខភាព និងបរិក្ខារអនាម័យនៅមានកម្រិតមានន័យថាក្រុមនេះជារឿយៗ ពុំបានទទួលសេវាជាមូលដ្ឋាន ដូចជា បង្គន់ និងទឹកស្អាតសម្រាប់ផឹកគ្រប់គ្រាន់ឡើយ។ ក្រុមដែលរឹតតែងាយរងគ្រោះទៅទៀតគឺកុមារ និងក្មេងជំទង់មានពិការភាព ដែលជារឿយៗ ត្រូវបានគេផាត់ចេញពីក្របខ័ណ្ឌសង្គម និងកុមារកំព្រា និងកុមារត្រូវបានគេបោះបង់ចោល ដែលពុំមានជម្រកសម្រាប់ជ្រកកោន។

## ភាពក្រីក្រ និងហានិភ័យពាក់ព័ន្ធ នឹងកិច្ចការពារកុមារ

កុមារ និងយុវជន ក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងត្រូវបានគេចាត់ទុកថាជាក្រុមមួយ ក្នុងចំណោមក្រុមងាយរងគ្រោះជាងគេក្នុងសង្គម ដោយសារតែពួកគេស្ថិតក្នុងវ័យកុមារនៅឡើយ ហើយកុមារពុំមានសមត្ថភាពការពារខ្លួនឡើយ ដែលតម្រូវឲ្យមានការថែទាំ និងការគាំទ្រជាប្រចាំពីគ្រួសារ និងសហគមន៍របស់ពួកគេ។ ប៉ុន្តែឪពុកម្តាយរបស់ពួកគេដែលជាអ្នកមានស្ថានភាពសេដ្ឋកិច្ចសង្គមខ្សត់ខ្សោយដែរនោះ ពួកគាត់ច្រើនតែមិនអាចផ្តល់ការថែទាំ និងការយកចិត្តទុកដាក់ដល់ពួកគេឲ្យបានគ្រប់គ្រាន់ឡើយ។

ចំណូលប្រចាំថ្ងៃទាប គួបផ្សំនឹងប្រការដែលថាជាមធ្យម អ្នករកចំណូលម្នាក់ត្រូវផ្គត់ផ្គង់សមាជិកគ្រួសារជាមធ្យមបួននាក់នោះ បង្ហាញយ៉ាងច្បាស់ថា ឪពុកម្តាយត្រូវចំណាយពេលភាគច្រើនរកចំណូល ដើម្បីរ៉ាប់រងចំណាយជាប្រចាំរបស់គ្រួសារ។ ពួកគេភាគច្រើនជាអ្នកទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃ ហើយពួកគេចំណាយពេលវេលាយ៉ាងច្រើន ដើម្បីស្វែងរកការងារធ្វើ។ កត្តានេះធ្វើឲ្យឪពុកម្តាយមានពេលវេលាតិចតួចបំផុត ដើម្បីមើលថែកូន។ ការពិភាក្សាជាមួយនឹងសហគមន៍បង្ហាញថា ចំណូលសម្រាប់មនុស្សម្នាក់ របស់គ្រួសារភាគច្រើនក្នុងសហគមន៍ គឺមិនគ្រប់គ្រាន់ សម្រាប់បំពេញតម្រូវការរស់នៅប្រចាំថ្ងៃឡើយ។ កត្តានេះមានផលប៉ះពាល់ផ្ទាល់លើលទ្ធភាពរបស់គ្រួសារក្នុងការបញ្ជូនកូនៗដែលជាកុមារ ឬក្មេងជំទង់ទៅសាលារៀន (ការរ៉ាប់រងការបង់ថ្លៃ[49] សម្រាប់សេវាអប់រំ) ក៏ដូចជាផ្តល់ឲ្យកូននូវអាហារដែលមានជីវជាតិ ឬប្រើប្រាស់បរិក្ខារអនាម័យជាដើម។ ក្នុងពេលជាមួយគ្នា ការសម្ភាសក្រុមគោលដៅជាមួយនឹងអ្នកដឹកនាំក្នុងសហគមន៍និងចាស់ព្រឹទ្ធាចារ្យបង្ហាញថាគ្រួសារច្រើនតែចំណាយប្រាក់ចំណូលមួយភាគធំ ដើម្បីបំពេញតម្រូវការរបស់កុមារ និងក្មេងជំទង់ដែលជាកូនពួកគេ។ ក្នុងការពិភាក្សាក្រុមគោលដៅមួយ អ្នកចូលរួមម្នាក់បាននិយាយថា "ជារឿយៗ យើងតែងចំណាយលុយ ដើម្បីទិញរបស់របរប្រើប្រាស់ប្រចាំថ្ងៃឲ្យកូនរបស់យើង រួមទាំងអាហារដែលពួកគេចូលចិត្តញ៉ាំ និងសម្លៀកបំពាក់ជាដើម"។ ការចាយវាយបែបនេះគឺត្រូវប្តូរជាមួយនឹងការបំពេញតម្រូវការរបស់មនុស្សចាស់ (ជាពិសេស ឪពុកម្តាយ ខ្លួនឯង) ក្នុងគ្រួសារ។ នៅពេលសាកសួរ អំពីការយកចិត្តទុកដាក់ខុសគ្នាចំពោះក្មេងប្រុស និងក្មេងស្រី មានការលើកឡើងថា ក្មេងស្រីទទួល

[49] *ចំណាយឯកជនលើការអប់រំ សំដៅលើចំណាយក្រៅពីថ្លៃសាលា (ដែលចំណាយនេះគឺចេញដោយរដ្ឋាភិបាល)។ ចំណាយឯកជននេះមានដូចជា ចំណាយលើឯកសណ្ឋាន សៀវភៅ សម្ភារសិក្សាផ្សេងទៀត ។ល។*

បានការយកចិត្តទុកដាក់ស្មើគ្នានឹងក្មេងប្រុសដែរ។ អ្នកឆ្លើយតបម្នាក់បាននិយាយថា "សម្រាប់យើង កូនប្រុស និងកូនស្រី គឺស្មើគ្នា អ្វីក៏ដោយដែលយើងអាចទិញបានជាមួយនឹងចំណូលដ៏ស្តួចស្តើងរបស់យើង គឺយើងទិញឲ្យកូនប្រុសផង និងកូនស្រីផង ទៅតាមសេចក្តីត្រូវការ ហើយយេនឌ័រមិនមែនជាកត្តាកំណត់ឡើយ"។ នៅត្រង់នេះ គួរកត់សម្គាល់ថាពុំមានភស្តុតាងណាមួយបង្ហាញថា សហគមន៍មានការលម្អៀងផ្នែកយេនឌ័រឡើយ ពាក់ព័ន្ធនឹងចំណាយចំពោះកូនៗរបស់គេ។

**រូបភាពទី១៖** **កម្រិតនៃការចូលរួមរបស់ឪពុកម្តាយក្នុងការចិញ្ចឹមកូន ទៅតាមការរាយការណ៍របស់ក្មេងជំទង់**






## ការប្រើបំពានសារធាតុញៀន

បើតាមការសិក្សានៅថ្នាក់ជាតិ ការប្រើសារធាតុញៀនក្នុងចំណោមយុវជន គឺជាបញ្ហាប្រឈមដ៏ធំមួយដែលប្រទេសកម្ពុជាជួបប្រទះ។ តាមសហគមន៍ក្រីក្រក្នុងទីក្រុង ការពុំមានការឃុំគ្រងឲ្យបានគ្រប់គ្រាន់ពីសំណាក់ឪពុកម្តាយ ធ្វើឲ្យក្មេងជំទង់ងាយធ្លាក់ចូលទៅក្នុងរណ្តៅសង្គមមួយនេះ។ ការប្រើសារធាតុញៀនក្នុងចំណោមអ្នកឆ្លើយតបជាក្មេងជំទង់ គឺជាការប្រព្រឹត្តដែលកើតឡើងជាទូទៅ ដោយពួកគេប្រមាណជា ៨១,៤ ភាគរយ (ស្រី ៧៥,២ ភាគរយ និងប្រុស ៨៨,២ ភាគរយ) លើកឡើងថាពួកគេជាអ្នកផឹកគ្រឿងស្រវឹង (ជាពិសេសស្រាបៀរ)។ អ្វីដែលសំខាន់ជាងនេះទៀតនោះ គឺក្មេងជំទង់រស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ ៤៣,៨ ភាគរយ (ស្រី ២៦,៦ ភាគរយ និងប្រុស ៦១ ភាគរយ) ធ្លាប់ប្រើប្រាស់គ្រឿងញៀន (ភាគច្រើន ជាកញ្ឆា ហេរ៉ូអ៊ីន និងមេតំហ្វេតាមីន) យ៉ាងហោចណាស់ម្តង កាលពីឆ្នាំមុន។ គួរកត់សម្គាល់ថា ក្នុងករណីភាគច្រើនឪពុកម្តាយមិនដឹងថាកូនៗរបស់ខ្លួនចាប់យកទម្លាប់ និងបន្តទម្លាប់ប្រើបំពានសារធាតុនោះទេ *"ខ្ញុំជឿទុកចិត្ត ថាកូនៗរបស់ខ្ញុំមិនប្រើបំពានសារធាតុញៀនឡើយ ប៉ុន្តែខ្ញុំមិនអាចដឹងឲ្យប្រាកដពីមិត្តភក្តិរបស់ពួកគេឡើយ"*។ ក្នុងកំឡុងពេលពិភាក្សាក្រុមគោលដៅ អ្នកឆ្លើយតបភាគច្រើនរាយការណ៍ថាកូនៗរបស់ពួកគេមិនមែនជាអ្នកញៀនថ្នាំឡើយ។ លើសពីនេះ ការពិភាក្សាក្រុមគោលដៅក៏បង្ហាញផងដែរថា ក្មេងប្រុសច្រើនតែប្រឡូកក្នុងការប្រើប្រាស់សារធាតុញៀន។ ឪពុកម្តាយម្នាក់និយាយថា *"ជាធម្មតា គឺក្មេងប្រុស ដែលច្រើនប្រឡូកក្នុងការប្រើបំពានសារធាតុញៀន ដោយសារតែពួកគេងាយចូលទៅកាន់ទីផ្សារលក់សារធាតុញៀននេះជាង"*។

**រូបភាពទី២៖ ភាគរយនៃក្មេងជំទង់ ដែលប្រើប្រាស់ជាតិស្រវឹង ឬគ្រឿងញៀន**




ឥរិយាបថមួយចំនួន ក្នុងចំណោមឥរិយាបថសង្គមទាំងនេះ កើតឡើងដោយសារតែឪពុកម្តាយរបស់ក្មេងជំទង់ទាំងនេះក៏ចូលរួមក្នុងការប្រើប្រាស់សារធាតុញៀនផ្សេងៗដែរ។ ក្មេងជំទង់ប្រមាណជា ៦៥,៤ ភាគរយរាយការណ៍ថា ឪពុកម្តាយរបស់ពួកគេជាអ្នកផឹកគ្រឿងស្រវឹង។ ក្មេងជំទង់ក៏អាចទទួលរងឥទ្ធិពលពីការប្រើបំពានសារធាតុរបស់ឪពុកម្តាយនេះផងដែរ ដែលធ្វើឲ្យគំនិតប្រើប្រាស់សារធាតុញៀននេះក្លាយជារឿងធម្មតា។ ចំណុចនេះត្រូវបានបង្ហាញរឹតតែច្បាស់បន្ថែមទៀត តាមរយៈការពិភាក្សាក្រុមគោលដៅជាមួយក្មេងជំទង់ ដែលថាឪពុកម្តាយរបស់ពួកគេបើកឲ្យពួកគេផឹកគ្រឿងស្រវឹង និង/ឬងាយទទួលយកការផឹកគ្រឿងស្រវឹងរបស់កូន ដោយសារតែពួកគេក៏ជាអ្នកផឹកគ្រឿងស្រវឹងដែរ។ ក្មេងជំទង់ភាគច្រើនគិតថា ការផឹកស្រាគឺជាទង្វើដែលអាចទទួលយកបាន ហើយសង្គមរបស់ពួកគេក៏ទទួលយកទង្វើនេះបានផងដែរ។ ក្មេងប្រុសជំទង់ម្នាក់បាននិយាយថា *"ឪពុកម្តាយរបស់ខ្ញុំផឹកស្រា ហើយក៏មិនប្រកាន់អ្វីនោះដែរ ប្រសិនបើខ្ញុំផឹកដែរនោះ"*។ អ្នកចូលរួមម្នាក់យល់ស្របនឹងការយល់ឃើញបែបនេះដែរ ហើយបាននិយាយថា *"ឪពុករបស់ខ្ញុំ និងឪពុកមិត្តភក្តិរបស់ខ្ញុំផឹកគ្រឿង ស្រវឹង ហើយចាត់ទុកវាជារឿងធម្មតា ប្រសិនបើខ្ញុំផឹកដែរ។ គាត់បានបន្ថែមទៀតថា ក្នុងតំបន់របស់យើង ការផឹកគ្រឿងស្រវឹងត្រូវបានចាត់ទុកថាជារឿងធម្មតា ប៉ុន្តែមនុស្សវ័យខ្ញុំនេះមិនផឹកដោយចំហនោះទេ"*។ សមាជិកសហគមន៍ដែលចូលរួមក្នុងការពិភាក្សាក្រុមគោលដៅក៏គាំទ្រការលើកឡើងនេះផងដែរ។ ខណៈពេលដែលឪពុកម្តាយមិនលើកទឹកចិត្តកូនៗរបស់ខ្លួនឲ្យផឹកគ្រឿងស្រវឹង ពួកគេមិនជាច្រើននាក់នោះទេដែលឃាត់កូនមិនឲ្យធ្វើបែបនេះ។ ស្ថានភាពនេះកាន់តែពិបាកទៅទៀត ដោយសារតែពុំមានការកំណត់អាយុអប្បបរមាក្នុងច្បាប់ ដែលអនុញ្ញាតឲ្យប្រើគ្រឿងស្រវឹងបានក្នុងប្រទេសកម្ពុជា ដូច្នេះក្មេងជំទង់អាចទិញ និងប្រើគ្រឿងស្រវឹងដោយស្របច្បាប់បាន។

មានក្មេងជំទង់ត្រឹមតែ ១០,៥ ភាគរយប៉ុណ្ណោះ ដែលរាយការណ៍ថា សមាជិកគ្រួសាររបស់ពួកគេប្រើគ្រឿងស្រវឹង។ ប៉ុន្តែ ការពិភាក្សាក្រុមគោលដៅជាមួយនឹងចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍បង្ហាញថា ឪពុកម្តាយរបស់ក្មេងៗទាំងនេះភាគច្រើនធ្លាប់ប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀនផ្សេងទៀតកាលពីពេលពួកគេនៅជាក្មេងជំទង់។ ពេលខ្លួនកាន់តែចាស់ កាន់តែពេញវ័យ និងមានទំនួលខុសត្រូវក្នុងគ្រួសារនោះ ពួកគេលែងបន្តប្រើប្រាស់ទៀត *"ដោយសារតែចំណាយមានការកើនឡើង តែមានចំណូលតិចតួច ពួកគេផឹកតែម្តងម្កាល ហើយច្រើនតែទុកលុយ សម្រាប់ចំណាយ ដើម្បីបំពេញតម្រូវការរបស់ក្រុមគ្រួសារ"*។ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយនឹងអង្គការសង្គមស៊ីវិល បង្ហាញឲ្យឃើញពីករណីឪពុកម្តាយប្រើប្រាស់គ្រឿងស្រវឹងបង្ខំឲ្យកូនៗអាយុក្រោម ១៣ឆ្នាំ ទិញគ្រឿងស្រវឹងឲ្យពួកគេ។ ដោយសារតែនីតិភាពក្នុងប្រទេសនេះគឺ ១៨ឆ្នាំ កុមារដែលត្រូវបានគេចាប់បានពេលកំពុងទិញគ្រឿងស្រវឹងមិនអាចត្រូវបានគេឃាត់ខ្លួនឡើយ។ ប៉ុន្តែតាមរយៈការប្រើប្រាស់កូនៗរបស់ខ្លួនទៅទិញគ្រឿងញៀន ពួកគេកំពុងឲ្យកូនប្រឈមនឹងហានិភ័យ និងគ្រោះថ្នាក់ជាច្រើន។

ក្នុងការពិភាក្សាក្រុមគោលដៅ ឪពុកម្តាយមួយចំនួនតូចបានលើកឡើងថា ពួកគេក៏ធ្លាប់ប្រើគ្រឿងញៀន

កាលពីនៅជាយុវជនដែរ។ សមាជិកសហគមន៍ទាំងអស់ យល់យ៉ាងច្បាស់ពីផលវិបាកជាអវិជ្ជមាននៃការប្រើប្រាស់ គ្រឿងញៀន និងពុំបានលើកទឹកចិត្តឲ្យក្មេងជំទង់ ប្រើប្រាស់គ្រឿងញៀនដូចពួកគេនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ភាពងាយរកបាននៃគ្រឿងញៀន គួបផ្សំជាមួយនឹងកត្តាផ្សេងទៀត ដូចជាសម្ពាធពីមិត្តភក្តិជាដើម ធ្វើឲ្យការប្រើប្រាស់គ្រឿងញៀនកើតមានជាទូទៅ។ សមាជិកសហគមន៍តែងដឹងពីអ្នកប្រើ និងអ្នកលក់គ្រឿងញៀន ប៉ុន្តែការចាត់វិធានការ និងការការពារ (សម្រាប់អ្នកផ្តល់ព័ត៌មានសម្ងាត់) នៅមានកម្រិតពីសំណាក់នគរបាល ដែលនេះជាកត្តារារាំងមិនឲ្យពួកគេរាយការណ៍ពីករណីទាំងនេះ។ ពួកគេក៏មានការបារម្ភផងដែរថា គ្រឿងញៀនដែលក្មេងជំទង់អាចរកបាននាពេលនេះ អាចបង្កគ្រោះថ្នាក់ខ្លាំងជាងគ្រឿងញៀនដែលពួកគេធ្លាប់ប្រើប្រាស់ កាលពីពេលដែលពួកគេនៅជាក្មេងជំទង់។ បើតាមការលើកឡើងរបស់តំណាងសង្គមស៊ីវិល ដែលធ្វើការងារជាមួយនឹងសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ កម្រិតនៃការទទួលបានសេវាពីមណ្ឌលបន្សាបគ្រឿងញៀន និងមណ្ឌលស្តារនីតិសម្បទាបច្ចុប្បន្នមានកម្រិតទាបខ្លាំង (ស្ទើរតែពុំមានតែម្តង)។ ជាលទ្ធផល ក្មេងជំទង់ និងយុវជនជួបការលំបាកយ៉ាងខ្លាំងក្នុងការលះបង់ការញៀនថ្នាំរបស់ពួកគេ។

## វប្បធម៌ទំនើង និងបទល្មើស ដែលប្រព្រឹត្តដោយអនីតិជន

ក្រុមយុវជនទំនើងត្រូវបានគេដឹងថាកំពុងមានវត្តមានរាយប៉ាយក្នុងរាជធានីភ្នំពេញ។ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ជាមួយអង្គការសង្គមស៊ីវិល និងអ្នកដឹកនាំសហគមន៍បង្ហាញថា ជាធម្មតា ក្រុមទំនើងទាំងនេះតែងប្រព្រឹត្តអំពើហិង្សា និងប្រយុទ្ធគ្នាទៅវិញទៅមក។ ការមានទំនាក់ទំនងតិចតួចជាមួយឪពុកម្តាយ ការមានប្រាក់ចំណូលទាប និង/ឬការនៅក្រៅសាលាផងនោះ ទាំងនេះជាកត្តា ដែលជំរុញឲ្យកុមារចូលប្រឡូកក្នុងក្រុមទំនើង និងស្វែងរកចំណូលពីប្រភពផ្សេងទៀត ដែលជារឿយៗ នាំឲ្យមានការប្រព្រឹត្តបទល្មើស។ ក្មេងជំទង់រស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញជាងពាក់កណ្តាល (៥២,៤ ភាគរយ) មានមិត្តភក្តិ ឬមនុស្សធ្លាប់ស្គាល់គ្នា (ក្នុងក្រុមអាយុស្របាលគ្នា) ជាសមាជិករបស់ក្រុមទំនើងណាមួយ។ ក្រុមទំនើងទាំងនេះច្រើនចូលលួចក្នុងផ្ទះរបស់ប្រជាពលរដ្ឋ លួចសត្វដែលគេចិញ្ចឹម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន ឬសាធារណៈ និងតែងបង្កជម្លោះដោយប្រើអាវុធ (ភាគច្រើន ប្រើប្រាស់កាំបិត ប៉ុន្តែក៏មានករណីប្រើកាំភ្លើងផងដែរ) ជាមួយនឹងក្រុមទំនើងផ្សេងទៀត។ កុមារក្រៅសាលាច្រើនមានទំនោរខ្ពស់ក្នុងការប្រឡូកជាមួយនឹងក្រុមទំនើង។ លើសពីនេះ ក្មេងអនាថា ជាកុមារឬក្មេងជំទង់ ច្រើនចូលរួមក្នុងក្រុមទំនើង ដើម្បីការពារខ្លួន។ ពួកគេច្រើនចាប់ផ្តើមចាត់ទុកក្រុមទំនើងថាជាគ្រួសាររបស់ពួកគេ ហើយងប់ងល់ចង់តែប្រើអំពើហិង្សា និងបង្កការបំផ្លិចបំផ្លាញ។ តំណាងអង្គការសង្គមស៊ីវិលមួយរូបបានលើកឡើងថា *"កុមារដែលពុំបានទៅសាលារៀន ងាយនឹងចូលប្រឡូកក្នុងក្រុមទំនើង ពួកគេលើកឡើងថា ពួកគេរងសម្ពាធពីមិត្តភក្តិ និងបន្តចូលរួមក្នុងក្រុមទំនើងទាំងនេះ ដោយសារតែពួកគេអាចទទួលបានប្រយោជន៍មកវិញ"*។

ការពិភាក្សាក្រុមគោលដៅជាមួយឪពុកម្តាយដែលមានកូនជាក្មេងជំទង់ រស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ បង្ហាញថា ពួកគេមានការព្រួយបារម្ភជាប្រចាំអំពីកូនៗរបស់ពួកគេ ដែលកំពុងមានទំនាក់ទំនងជាមួយនឹងក្រុមទំនើងទាំងនេះ និងចូលប្រឡូកក្នុងសកម្មភាពបទល្មើសនានា។ លើសពីនេះ ក៏ធ្លាប់មានករណីដែលសមាជិកក្រុមទំនើងត្រូវបានគេទុកចោលជិតស្លាប់ បន្ទាប់ពីមានការវាយប្រហារដោយប្រើប្រាស់អាវុធផងដែរ។ ពួកគេមិនរំពឹងថានឹងទទួលបានការការពារពីនគរបាលឡើយ ជាពិសេស ដោយសារតែប្រវត្តិធ្លាប់ប្រព្រឹត្តបទល្មើសរបស់ពួកគេ។

**រូបភាពទី៣៖** **ភាគរយនៃក្មេងជំទង់ ដែលមានមិត្តភក្តិឬអ្នកស្គាល់គ្នាជាសមាជិករបស់ក្រុមទំនើង**




ក្មេងជំទង់ក្នុងសហាគមន៍ក្រីក្រក្នុងទីក្រុងប្រមាណជា ១៧,៦ ភាគរយ បានដឹងពីករណីដែលអ្នកមកពីក្រុមអាយុរបស់ពួកគេ ធ្លាប់មានទំនាស់ជាមួយច្បាប់កាលពីពេលថ្មីៗនេះ។ តំណាងអង្គការសង្គមស៊ីវិលដែលធ្វើការងារជាមួយកុមារ និងក្មេងជំទង់នៅរាជធានីភ្នំពេញលើកឡើងថា *"ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាជួបឧបសគ្គ ដោយសារតែសមត្ថភាពនៅមានកម្រិត ហើយកុមារដែលមានទំនាស់ជាមួយច្បាប់ (មិនថាពួកគេជាអ្នកប្រព្រឹត្ត ឬជាជនរងគ្រោះនោះទេ) បានទទួលការគាំទ្រ/មេធាវីតំណាងតាមផ្លូវច្បាប់តិចតួច ឬគ្មានសោះតែម្តង ពីរដ្ឋ"*។ មានករណីដែលសហាគមន៍ដើរតួជាតុលាការ និងធ្វើការផ្តន្ទាទោសអ្នកប្រព្រឹត្តដោយខ្លួនឯងតែម្តង។

ខណៈពេលដែលមាត្រា៣៨នៃក្រមព្រហ្មទណ្ឌកំណត់អាយុ ១៨ឆ្នាំ ជាអាយុអប្បបរមា សម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ ក្រមនេះនុញ្ញាតឲ្យមានការផ្តន្ទាទោសអនីតិជនអាយុចាប់ពី១៤ឆ្នាំនេះទៅ ក្នុងកាលទេសៈពិសេស និងទៅតាមចរិតនៃបទល្មើសដែលបានប្រព្រឹត្ត។ មុនពេលមានការដាក់ឲ្យអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនកាលពីខែឧសភា ឆ្នាំ២០១៦ ជារឿយៗ កុមារដែលជាប់តែងទទួលទោសដូចមនុស្សពេញវ័យដែរ។ ពួកគេត្រូវបានដាក់ក្នុងពន្ធនាគារជាមួយមនុស្សពេញវ័យ ដោយទទួលបានការអប់រំ ឬការស្តារនីតិ សម្បទាតិចតួច ឬពុំបានទទួលតែម្តង។ ពេលស្ថិតក្នុងពន្ធនាគារ កុមារទាំងនេះងាយទទួលរងការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ ឥលូវនេះ រដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តច្បាប់នេះ ដើម្បីឲ្យមានការផ្លាស់ប្តូរជាក់ស្តែងក្នុងមូលដ្ឋាន។

ច្បាប់យុត្តិធម៌អនីតិជន ដាក់ចេញនូវក្របខ័ណ្ឌច្បាប់សម្រាប់បង្កើតតុលាការអនីតិជន និងប្រព័ន្ធឃុំឃាំងអនីតិជនដោយឡែក ដើម្បីផ្តល់យុត្តិធម៌ស្តារនីតិសម្បទាឡើងវិញដល់ជនល្មើសដែលនៅក្មេង។

**រូបភាពទី៤៖** **ភាគរយនៃក្មេងជំទង់ដែលដឹងពីករណីក្មេងជំទង់មានទំនាស់ជាមួយច្បាប់**



# អំពើហិង្សាលើកុមារ

មាត្រា ១០៤៩ នៃក្រមព្រហ្មទណ្ឌចែងថា "ជនដែលមានអំណាចមេបា អាចដាក់វិន័យកូនរបស់ខ្លួន ដោយខ្លួនឯង ក្នុងវិសាលភាពដែលចាំបាច់"។ ដូច្នេះការដាក់ទណ្ឌកម្មលើរាងកាយ មិនត្រូវបានចាត់ទុកថាជាទង្វើខុសច្បាប់ឡើយក្នុងប្រទេសកម្ពុជា។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ (២០០៥) ពុំបានហាមឃាត់ ការដាក់ទណ្ឌកម្មរាងកាយនៅផ្ទះឡើយ ហើយបញ្ញត្តិផ្សេងទៀតក្នុងរដ្ឋធម្មនុញ្ញដែលហាមប្រាមមិនឲ្យមានអំពើហិង្សា ក៏មិនបានចាត់ទុកការដាក់ទណ្ឌកម្មរាងកាយ ក្នុងការចិញ្ចឹមបីបាច់កុមារថាជាទង្វើខុសច្បាប់ដែរ។ ដូច្នេះ អំពើហិង្សាផ្លូវកាយលើកុមារអាចកើតឡើង ក្រោមលេសថាជាការដាក់វិន័យ។ ការខ្វះការកំណត់និយមន័យពាក្យថា "អំណាចមេបា" ក្នុងក្រមរដ្ឋប្បវេណី អាចធ្វើឲ្យការដាក់ទណ្ឌកម្មរាងកាយនៅតាមកន្លែងថែទាំកុមារ ដូចជា តាមមណ្ឌលកុមារកំព្រា និងកន្លែងថែទាំកុមារជាដើម ក្លាយជាទង្វើស្របច្បាប់។ ដូច្នេះ វាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលឪពុកម្តាយមានកូនជាកុមារ/ឬក្មេងជំទង់រស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញជិត ៦០ ភាគរយ លើកឡើងថា ពួកគេប្រើប្រាស់កម្លាំងបាយ (ការដាក់ទណ្ឌកម្មរាងកាយ) ដើម្បីដាក់វិន័យកូននោះ។ ការពិភាក្សាជាមួយក្មេងជំទង់តាមសហគមន៍ បង្ហាញថា ការរំលោភបំពានផ្លូវកាយ ឬការដាក់ទណ្ឌកម្មរាងកាយ ឧស្សាហ៍កើតមានតាមផ្ទះ។ អ្នកចូលរួមភាគច្រើនធ្លាប់ទទួលរងការរំលោភបំពានផ្លូវកាយនៅផ្ទះ ហើយជាធម្មតា ត្រូវទទួលរងការវាយដំ នៅពេលដែលពួកគេប្រព្រឹត្តកំហុស ឬធ្វើអ្វីមួយខុស។

**រូបភាពទី៥៖ ភាគរយឪពុកម្តាយ ដែលរាយការណ៍ថាបានប្រើប្រាស់ការដាក់ទណ្ឌកម្មរាងកាយ ដើម្បីដាក់វិន័យកូនរបស់ខ្លួន**




ការពិភាក្សាក្រុមគោលដៅ ជាមួយនឹងក្មេងជំទង់ បង្ហាញថា ពួកគេភាគច្រើនជឿថា វាមិនជាបញ្ហាអ្វីនោះទេ ដែលឪពុកម្តាយរបស់ពួកគេប្រើប្រាស់មធ្យោបាយហិង្សា ដើម្បីដាក់វិន័យលើពួកគេនោះ "*ខ្ញុំមិនចូលចិត្តឲ្យគេវាយខ្ញុំឡើយ ប៉ុន្តែខ្ញុំគិតថា ឪពុកម្តាយរបស់ខ្ញុំវាយខ្ញុំ តែនៅពេលចាំបាច់ប៉ុណ្ណោះ*"។ ប៉ុន្តែ ក៏មានករណីដែលកុមាររត់ចេញពីផ្ទះ ដោយសារតែពួកគេរងការវាយដំញឹកញាប់ពីឪពុកម្តាយរបស់ពួកគេផងដែរ។

ទិន្នន័យដែលប្រមូលតាមរយៈកម្រងសំណួរជាមួយនឹងក្មេងស្រី និងក្មេងប្រុសជំទង់មកពីសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ បង្ហាញថា អំពើហិង្សាក្នុងគ្រួសារគឺជាករណីដែលតែងកើតមានជាប្រចាំ។ ក្មេងប្រុសប្រមាណ ៦៥,៩ ភាគរយ និងក្មេងស្រី ៦៥,៣ ភាគរយ រាយការណ៍ថា ពួកគេតែងឃើញករណីអំពើហិង្សាក្នុងគ្រួសារកើតមានឡើង (ក្នុងរយៈពេល១២ខែចុងក្រោយនេះ) ក្នុងផ្ទះ ឬក្នុងសហគមន៍។ តួលេខនេះគឺខ្ពស់ជាងតួលេខក្នុង

ការអង្កេតថ្នាក់ជាតិស្តីពីអំពើហិង្សាលើកុមារកាលពីឆ្នាំ ២០១៣ ដែលបង្ហាញថា មានក្មេងស្រី ៣៨,៣ ភាគរយ និងក្មេងប្រុស ៤៣,៧ ភាគរយ បានរាយការណ៍ថាធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារកើតឡើងក្នុងផ្ទះ ឬក្នុងសហគមន៍។ ការពិភាក្សាក្រុមគោលដៅជាមួយសមាជិកសហគមន៍បានបង្ហាញពីអំពើហិង្សាក្នុងគ្រួសារជាច្រើនករណី ហើយករណីភាគច្រើនត្រូវបានប្រព្រឹត្តលើស្ត្រី និងកុមារ ហើយកើតឡើង នៅពេលដែលអ្នកប្រព្រឹត្តអំពើហិង្សាស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង។ ប៉ុន្តែ ពួកគេក៏បន្ថែមផងដែរថា មានករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ដោយម្តាយប្រព្រឹត្តការវាយដំរាងកាយលើកូនៗរបស់ខ្លួន ឬមានករណីឈ្លោះប្រកែកគ្នារវាងម្តាយក្មេក និងកូនប្រសារស្រី។ លើសពីនេះ ពួកគេក៏បានពិភាក្សាពីគំនិតដែលថា ឥរិយាបថហិង្សារបស់មនុស្សម្នាក់គឺកើតឡើង ដោយសារតែជននោះធ្លាប់ជាជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារដែរ នៅពេលគេនៅជាកុមារ។ ពួកគេថែមទាំងលើកឧទាហរណ៍ជាក់ស្តែងពីសហគមន៍ ដើម្បីបញ្ជាក់ពីការលើកឡើងនេះផងដែរ។

**រូបភាពទី៦៖ ភាគរយនៃក្មេងជំទង់ដែលរាយការណ៍ថាធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារ**




អំពើហិង្សាក្នុងគ្រួសារ មិនត្រឹមតែកើតមានជាទូទៅប៉ុណ្ណោះទេ ប៉ុន្តែជារឿយៗ ក៏មិនត្រូវបានគេរាយការណ៍ផងដែរ។ ក្នុងចំណោមសមាជិកសហគមន៍ ដែលរាយការណ៍ថាធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារ ប្រមាណជា ៥៩,២ ភាគរយ និយាយថា ពួកគេពុំបានរាយការណ៍ពីករណីអំពើហិង្សានេះទៅកាន់មេភូមិ/ឬអាជ្ញាធរមូលដ្ឋាន ឬទៅកាន់នគរបាលឡើយ។ ការពិភាក្សាក្រុមគោលដៅ ជាមួយសហគមន៍ បង្ហាញថាចំណុចខាងលើនេះអាចបកស្រាយបានថា មានការទទួលយក ឬការអត់ឱនឲ្យជាទូទៅដល់អំពើហិង្សាក្នុងគ្រួសារ ដែលប្រព្រឹត្តដោយសមាជិកគ្រួសារជាបុរស។ មនុស្សភាគច្រើនឯកភាពថា អំពើហិង្សាក្នុងគ្រួសារមានផលប៉ះពាល់ជាអវិជ្ជមានលើកុមារ (ប៉ះពាល់ផ្ទាល់លើសុខុមាលភាពផ្លូវកាយ ឬដោយប្រយោលលើសុខុមាលភាពផ្លូវចិត្ត) ប៉ុន្តែស្ត្រីនៅតែមិនអើពើលើផលប៉ះពាល់បែបនេះទេ ដោយសារតែគេគិតថា ការបែកបាក់ចំណងអាពាហ៍ពិពាហ៍នឹងមានផលប៉ះពាល់ធំមកលើកូនៗរបស់ពួកគេ។ មូលហេតុមួយទៀតគឺ ជាទូទៅ សមាជិកគ្រួសារជាបុរសអាចរកចំណូលបានច្រើនជាង ហើយចំណូលនេះគឺសំខាន់សម្រាប់ការចិញ្ចឹមបីបាច់កូន។ ស្ត្រីម្នាក់និយាយថា *"ប្រសិនបើយើងប្តឹងបុរសដែលវាយដំលើយើង លទ្ធភាពដែលគាត់ចាកចេញពីយើងគឺខ្ពស់ ហើយនឹងបង្កឲ្យមានជាបញ្ហាមិនខាន ដោយសារតែចំណូលមួយភាគធំរបស់គ្រួសារគឺបានពីគេ"*។

ការពិភាក្សាជាមួយអង្គការសង្គមស៊ីវិលបង្ហាញថា មានសេវាតិចតួចប៉ុណ្ណោះ សម្រាប់ជួយជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ដើម្បីឲ្យពួកគេមានភាពម្ចាស់ការផ្នែកសេដ្ឋកិច្ច មិនចាំបាច់ពឹងផ្អែកលើប្តីរបស់ពួកគេទៀតនោះ។ ជនរងគ្រោះអាចទទួលបានសេវាគាំទ្រចិត្តសង្គមតិចតួច ដែលរឹតតែធ្វើឲ្យពួកគេមិនអាចចេញមកខាងក្រៅដើម្បីដាក់ពាក្យបណ្តឹងជនប្រព្រឹត្តបាន។ *"ជម្រើសមានតិចតួចបំផុត ហើយក្នុងករណីដែលបុរស និងស្ត្រីទទួលបានការផ្តល់ប្រឹក្សា ជារឿយៗ ចុងក្រោយពួកគេសុខចិត្តទទួលយកស្ថានភាពបែបនេះ ហើយបណ្តែតបណ្តោយឲ្យស្ថានភាពនេះនៅតែបន្តកើតឡើង ដោយគិតថាពេលវេលានឹងជួយឲ្យអ្វីៗវិលមករកភាពប្រក្រតីវិញ"*។

សមាជិកសហគមន៍មួយចំនួនបានលើកឡើងពីករណីដែលជនប្រព្រឹត្តអំពើហិង្សាត្រូវបានឃាត់ខ្លួន និងយកទៅកាន់ប៉ុស្ដ៍នគរបាល។ ប៉ុន្តែពុំមានការដាក់ពាក្យបណ្ដឹងផ្លូវការឡើយដោយសារតែពួកគេចង់រក្សាកិត្តិយសគ្រួសារ និងឋានៈក្នុងសង្គម។ តាមពិត ក្នុងករណីភាគច្រើន ជនរងគ្រោះ (ជាធម្មតា ជាប្រពន្ធរបស់ជនប្រព្រឹត្តអំពើហិង្សា) គឺជាអ្នកមកសុំឲ្យមានការដោះលែងជនប្រព្រឹត្តពីប៉ុស្ដ៍នគរបាល តាមរយៈការដកបណ្ដឹងរបស់នាងចេញវិញ។ សហគមន៍ក៏បានរាយការណ៍ពីករណីដែលកូនៗរត់ចេញពីផ្ទះ ដែលមានការឈ្លោះប្រកែកគ្នាផងដែរ។ ក្រោយមកពួកគេត្រលប់មកផ្ទះវិញដោយខ្លួនឯង ឬត្រូវបានឪពុកម្ដាយតាមរក ក៏ប៉ុន្តែក៏មានមួយចំនួនមិនត្រលប់មកផ្ទះវិញផងដែរ។

**រូបភាពទី៧៖** **ភាគរយគ្រួសារ ដែលរាយការណ៍ថាពុំបានធ្វើសកម្មភាពអ្វីទាំងអស់ បន្ទាប់ពីបានសង្កេតឃើញមានករណីអំពើហិង្សាកើតមានឡើង**




អ្នកដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង អាចកំណត់ដឹងថា អំពើហិង្សាអាចកើតឡើងក្នុងបីទម្រង់៖ អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវចិត្ត និងអំពើហិង្សាផ្លូវភេទ។ សហគមន៍បង្ហាញពីការយល់ដឹងតិចតួចអំពីអំពើហិង្សាផ្លូវចិត្ត និងបង្ហាញពីការអត់ឱនឲ្យអំពើហិង្សាផ្លូវកាយជាទូទៅ។ ប៉ុន្តែសហគមន៍ប្រកាន់គោលជំហរតឹងរ៉ឹងចំពោះអំពើហិង្សាផ្លូវភេទ។ ពាក់ព័ន្ធនឹងចំណុចនេះ ករណីអំពើហិង្សាក្នុងគ្រួសារភាគច្រើននៅត្រូវបានចាត់ទុកថាជារឿងផ្ទាល់ខ្លួន និងរឿងផ្ទៃក្នុងរបស់គ្រួសារ។ ករណីអំពើហិង្សាផ្លូវភេទ ដែលកើតឡើងក្រៅរង្វង់គ្រួសារ នឹងទទួលការដាក់ទណ្ឌកម្មធ្ងន់ធ្ងរពីសហគមន៍ ហើយក្នុងករណី ដែលកុមារ ឬស្ត្រី យកករណីរំលោភបំពានឬអំពើហិង្សាផ្លូវភេទក្នុងគ្រួសារមកប្រាប់ប្រធានសហគមន៍ ឬចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍  ករណីនេះនឹងត្រូវរាយការណ៍ទៅកាន់នគរបាល។ សហគមន៍ដែលបានចុះទៅស្ទើរតែទាំងអស់បានរាយការណ៍ពីករណីបំពារបំពានផ្លូវភេទ រំលោភសេពសន្ថវៈ ឬចំអែចំអន់។ មានការលើកឡើងផងដែរអំពីករណីដែលជនរងគ្រោះ និងជនប្រព្រឹត្តសុទ្ធតែជាក្មេងជំទង់ដូចគ្នា។ លើសពីនេះ ក៏មានករណីដែលជនរងគ្រោះជាកុមារផងដែរ។

**រូបភាពទី៨៖** **ភាគរយគ្រួសារដែលរាយការណ៍ថាបានដឹងពីករណីរំលោភបំពាន ឬអំពើហិង្សាផ្លូវភេទ**



ចំណុចល្អគួរឲ្យកត់សម្គាល់គឺនៅត្រង់ថាក្នុងចំណោមករណីទាំងអស់ ដែលរាយការណ៍ដោយសមាជិកសហគមន៍ យ៉ាងហោចណាស់ក៏មាន ៨១,៤ ភាគរយដែរ ដែលជនប្រព្រឹត្តត្រូវបានឃាត់ខ្លួនដោយនគរបាល និងមានចាត់វិធានការតាមផ្លូវច្បាប់។ ប៉ុន្តែដូចលើកឡើងពីខាងដើមថា វិធានការចំពោះអនីតិជនអាចមិនសមស្រប ដើម្បីឲ្យពួកគេកែខ្លួនឡើយ ហើយប្រហែលជាមិនធ្វើឲ្យពួកគេអាចធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញបានឡើយ។ប៉ុន្តែក្នុងការពិភាក្សាក្រុមគោលដៅ និងសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ប្រធានសហគមន៍ និងតំណាងអង្គការសង្គមស៊ីវិលយល់ឃើញដូចគ្នាថា ដោយសារតែមានការមាក់ងាយជនរងគ្រោះពីអំពើហិង្សាផ្លូវភេទ នោះធ្វើឲ្យករណីអំពើហិង្សាផ្លូវភេទជាច្រើនមិនត្រូវបានគេរាយការណ៍ឡើយ ព្រោះករណីបែបនេះច្រើនតែកើតឡើងក្នុងរង្វង់គ្រួសារ ហើយអ្នកប្រព្រឹត្តគឺជាសមាជិកគ្រួសារ។

លើសពីនេះ ក្នុងករណីជាច្រើន ដែលជនរងគ្រោះ និងអ្នកប្រព្រឹត្តជាក្មេងជំទង់ដូចគ្នា មានការកត់សម្គាល់ថាពួកគេមានទំនាក់ទំនងស្នេហាជាមួយគ្នា។ ករណីដែលក្មេងជំទង់ណាត់ជួបគ្នា ហើយមានអំពើហិង្សាកើតមានឡើង គឺជារឿងដែលឧស្សាហ៍កើតឡើង។ ខណៈដែលជាធម្មតា អំពើហិង្សាទាំងនេះច្រើនកើតមានក្នុងទម្រង់ជាអំពើហិង្សាផ្លូវកាយ អំពើហិង្សាក៏អាចកើតមានក្នុងទម្រង់ជាអំពើហិង្សាផ្លូវភេទ ឬផ្លូវចិត្តផងដែរ។ សមាជិកសហគមន៍បានលើកឡើងថា ពួកគេត្រូវធ្វើអន្តរាគមន៍នៅពេលដែលក្មេងស្រីណាម្នាក់ក្នុងសហគមន៍ត្រូវបានវាយដំ ឬរងការបៀតបៀនពីក្មេងប្រុសណាម្នាក់។ ពួកគេបាននិយាយថា ពួកគេប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីគាំទ្រដល់ក្មេងស្រី ប៉ុន្តែជាធម្មតា ពួកគេមិនអាចជួយក្មេងស្រីដែលជួបនឹងបញ្ហាបែបនេះឲ្យជំនះស្នាមរបួសផ្លូវចិត្តដោយសារបញ្ហាទាំងនេះបានឡើយ។ ក្នុងពេលជាមួយគ្នា សមាជិកសហគមន៍មួយចំនួនបានលើកឡើងថា មិនមែនគ្រប់គ្នាសុទ្ធតែផ្តល់ការគាំទ្របែបនេះទេ ហើយមនុស្សជាច្រើននាក់ច្រើនមិនចង់រាប់រកជនរងគ្រោះ និងចាប់ផ្តើមមានមន្ទិលសង្ស័យពីឥរិយាបថរបស់នាង។

## ការជួញដូរកុមារ

សហគមន៍ ដែលត្រូវបានបញ្ចូលក្នុងការសិក្សានេះ បានរាយការណ៍ពីករណីបាត់ខ្លួនកុមារ និងក្មេងជំទង់ពីផ្ទះ។ ក្នុងនោះមានករណី ដែលក្មេងជំទង់សម្រេចចិត្តរត់ចេញពីផ្ទះផងដែរ។ ពួកគេមួយចំនួនត្រូវបានគ្រួសារតាមរក មួយចំនួនត្រលប់មកផ្ទះវិញដោយខ្លួនឯង ហើយមួយចំនួនមិនដែលត្រលប់មកផ្ទះវិញឡើយ។ ប៉ុន្តែ មានករណីដែលក្មេងជំទង់រត់គេចចេញពីផ្ទះ ដើម្បីរត់គេចពីភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ការដាក់ទណ្ឌកម្មលើរាងកាយ។ល។ សម្រាប់ករណីកុមារបាត់ខ្លួនវិញ សមាជិកសហគមន៍ភាគច្រើនជឿថា ពួកគេត្រូវបានគេចាប់ពង្រាត់ ដោយសារតែពួកគេនៅក្មេងពេក មិនអាចរស់នៅដោយខ្លួនឯងបានឡើយ។

ក្នុងចំណោមគ្រួសារដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ មានគ្រួសារប្រមាណជា ១២,២ ភាគរយ បានរាយការណ៍ថា ពួកគេធ្លាប់ដឹងពីករណីបាត់ខ្លួនកុមារពីសហគមន៍ *"ខ្ញុំធ្លាប់ឮពីករណីកុមារបាត់ខ្លួនកាលពីពីរបីឆ្នាំមុន ខ្ញុំគិតថាមានការរាយការណ៍ពីករណីនេះដែរ ប៉ុន្តែខ្ញុំគិតថាករណីនេះមិនត្រូវបានគេដោះស្រាយឲ្យបានត្រឹមត្រូវឡើយ"*។ លើសពីនេះ មានគ្រួសារ ១៧,៨ ភាគរយទៀត លើកឡើងថា ពួកគេធ្លាប់ដឹងពីករណីដែលក្មេងជំទង់ក្នុងសហគមន៍បាត់ខ្លួនចេញពីផ្ទះ។

## រូបភាពទី៩៖ ភាគរយគ្រួសារដែលរាយការណ៍ថាបានដឹងពីករណីកុមារបាត់ខ្លួន




ប្រជាពលរដ្ឋក្នុងសហគមន៍មួយចំនួនធំ មិនបានគិតដល់ថាកុមារ និងក្មេងជំទង់ ដែលបាត់ខ្លួនអាចត្រូវបានគេជួញដូរ ឬប្រឈមនឹងមហានិភ័យនៃការជួញដូរនោះទេ។ ជាងនេះទៀត សមាជិកសហគមន៍គិតថា កុមារដែលបាត់ខ្លួនអាចប្រឈមនឹងការជួញដូរខ្ពស់ជាងក្មេងជំទង់។ ពួកគេគិតថា ក្មេងជំទង់ដែលបាត់ខ្លួនពីផ្ទះអាចសម្រេចចិត្តដោយខ្លួនឯងបានល្អជាង ឬអាចការពារខ្លួនឯងបានបើធៀបនឹងកុមារ។ គ្រួសារប្រមាណជា ៤២,២ ភាគរយរាយការណ៍ថា កុមារបាត់ខ្លួនប្រហែលជាប្រឈមនឹងហានិភ័យត្រូវបានគេយកទៅលក់ បើប្រៀបនឹងគ្រួសារប្រមាណ ៣០,៥ ភាគរយ ដែលគិតថា ក្មេងជំទង់បាត់ខ្លួនប្រហែលជាប្រឈមនឹងហានិភ័យនៃការជួញដូរ។

អ្នកដែលយល់ថា កុមារឬក្មេងជំទង់បាត់ខ្លួនអាចត្រូវគេជួញដូរនោះ ក៏បង្ហាញពីការយល់ដឹងខ្ពស់អំពីមូលហេតុដែលកុមារឬក្មេងជំទង់ងាយនឹងរងគ្រោះពីការជួញដូរផងដែរ។ ពួកគេបានលើកឡើងថា គេជួញដូរមនុស្សដើម្បីបង្ខំឲ្យដើរសុំទាន កេងប្រវ័ញ្ចកម្លាំងពលកម្ម (ដូចជាពលកម្មជាប់ចំណង និងយកទៅប្រើជាទាសករ ជាដើម) ការរកស៊ីផ្លូវភេទ និងការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍។ ក្មេងស្រីងាយនឹងត្រូវគេជួញដូរ ដើម្បីយកទៅបង្ខំឲ្យរៀបការ និងបម្រើសេវាផ្លូវភេទ។ ស្របគ្នានេះដែរ សហគមន៍ក៏លើកឡើងផងដែរថា ការជួញដូរមួយចំនួនអាចដោយសារតែគេចង់យកកុមារទៅធ្វើជាកូនចិញ្ចឹម (ដោយមិនបានគោរពទៅតាមលក្ខខណ្ឌច្បាប់)។

## រូបភាពទី១០៖ ភាគរយគ្រួសារដែលរាយការណ៍ថា កុមារបាត់ខ្លួនអាចប្រឈមនឹងហានិភ័យត្រូវបានគេយកទៅលក់



លើសពីនេះ មានគ្រួសារ ៧៨ ភាគរយ គិតថា ក្មេងស្រីក្នុងក្រុមអាយុពី៣ ដល់ ៥ឆ្នាំ ងាយបាត់ខ្លួនជាងក្មេងប្រុស។ ដូចគ្នានេះដែរ មានគ្រួសារប្រមាណ ៩៦,៨ ភាគរយ យល់ឃើញថា ក្មេងស្រីក្នុងក្រុមអាយុពី១០ ដល់ ១៩ឆ្នាំ ក៏មានហានិភ័យស្រដៀងគ្នានេះដែរ។ តួលេខប៉ាន់ប្រមាណទាំងនេះគឺស្របគ្នាទៅតាមការយល់ឃើញរបស់សហគមន៍ ដែលគិតថា ក្មេងជំទង់ច្រើនតែសម្រេចចិត្តរត់ចេញពីផ្ទះដោយខ្លួនឯង ក្នុងករណីភាគច្រើន។ ប៉ុន្តែ កុមារវិញច្រើនតែត្រូវបានគេចាប់ពង្រាត់ (និងយកទៅជួញដូរ)។

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ ដែលប្រឈមដោយកុមារកំព្រា និង/ឬកុមារដែលត្រូវបានគេបោះបង់ចោល

ការពិភាក្សាក្រុមគោលដៅជាមួយអង្គការសង្គមស៊ីវិល បង្ហាញថា *"កុមារ/ក្មេងជំទង់ភាគច្រើន ដែលត្រូវឪពុកម្តាយបោះបង់ចោលត្រូវទទួលរងវាសនាបែបនេះ ដោយសារតែពួកគេមានពិការភាព ឬមានជំងឺរ៉ាំរ៉ៃអ្វីមួយ"*។ ការខ្វះធនធានហិរញ្ញវត្ថុ ដោយសារតែចំណូលមានកម្រិតទាប បានបង្ខំឲ្យគ្រួសារក្រីក្រក្នុងទីក្រុងសម្រេចចិត្តយកកូនទៅដាក់កន្លែងថែទាំកុមារ ដូចជា មណ្ឌលកុមារកំព្រា ឬសម្រេចចិត្តបោះបង់ពួកគេចោលក៏មាន។ ផ្ទុយទៅវិញ ការពុំមានសេវាគាំទ្របន្ថែមគ្រប់គ្រាន់បង្ខំកុមារជាច្រើននាក់ឲ្យរស់នៅតាមផ្លូវ។ មានឯកសារជាច្រើនបង្ហាញពីការកើនឡើងនូវឥរិយាបថប្រឈមហានិភ័យខ្ពស់ក្នុងចំណោមកុមារទាំងនេះ ដូចជា ការប្រើគ្រឿងញៀន និងការចូលរួមប្រព្រឹត្តអំពើហិង្សាជាមួយនឹងក្រុមទំនើងជាដើម។ គ្រួសារដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុង ប្រមាណជា ១៥ ភាគរយ រាយការណ៍ថា ពួកគេស្គាល់កុមារឬក្មេងជំទង់ដែលគេបោះបង់ចោល ហើយឥឡូវនេះ ពួកគេរស់នៅអនាថាតាមផ្លូវជុំវិញតំបន់តាំងទីលំនៅរបស់ពួកគេ។ ជិត ៥០ភាគរយ នៃករណីបែបនេះ កុមារត្រូវរស់នៅតាមផ្លូវ ហើយពុំមានជម្រកជាប់លាប់ជាអចិន្ត្រៃយ៍នោះទេ។ នេះបង្ហាញថា វិធានការការពារ និងធ្វើសមាហរណកម្មកុមារទាំងនេះនៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ។

គួរកត់សម្គាល់ថា មានគ្រួសាររស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងប្រមាណជា ១៦,៦ ភាគរយ កំពុងមើលថែកុមារជាកូនកំព្រា ឬកូនដែលត្រូវគេបោះបង់ចោល។ ក្នុងការពិភាក្សាក្រុមគោលដៅជាមួយចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ មានការរកឃើញថា ជារឿយៗគ្រួសារមិនអាចឆ្លើយតបទៅនឹងតម្រូវការនៃការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារកំព្រា ឬក្មេងជំទង់ ដែលជាកូនកំព្រាឬកូនដែលត្រូវគេបោះបង់ចោលទាំងនេះឡើយ។ ការមានធនធានហិរញ្ញវត្ថុតិចតួច និងការមានពេលតិចតួចជាកត្តាដាក់កំហិតមិនឲ្យអ្នកផ្តល់ការថែទាំមើលថែកុមារដែលជាកូនចិញ្ចឹមរបស់ពួកគេបាន។ ជាធម្មតា កុមារត្រូវស្ថិតក្នុងស្ថានភាពមួយធ្ងន់ធ្ងរជាងកុមារដែលជាកូនបង្កើតរបស់ឪពុកម្តាយ។

**រូបភាពទី១១៖ ភាគរយនៃគ្រួសារដែលមើលថែកុមារដែលជាកូនកំព្រា ឬកូនដែលត្រូវបានគេបោះបង់ចោល**



ការថែទាំមិនបានជិតដល់ ការមិនអើពើជាទូទៅ ការរស់ក្នុងឋានៈដែលមិនមែនជាកូនបង្កើតក្នុងគ្រួសារ និងការទទួលបានសេវាថែទាំសុខភាព និងការអប់រំបានតិចតួច ជាកត្តាបានរុញច្រានក្មេងជំទង់ទាំងនេះឲ្យធ្លាក់ចូលទៅក្នុងការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន និង/ឬ ប្រឡូកជាមួយនឹងក្រុមទំនើង។ កុមារ/ក្មេងជំទង់ទាំងនេះកាន់តែងាយរងការរំលោភបំពានផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តថែមទៀត។ ពួកគេក៏ងាយរងគ្រោះដោយសារការជួញដូរមនុស្សផងដែរ។ ក្មេងស្រីដែលត្រូវបានគេបោះបង់ចោល ឬក្មេងស្រីកំព្រា ច្រើនរៀបការពេលដែលពួកគេនៅជាក្មេងជំទង់នៅឡើយ ឬមានផ្ទៃពោះ ពេលដែលពួកគេស្ថិតក្នុងវ័យជាក្មេងជំទង់។

ការពិភាក្សាជាក្រុមជាមួយនឹងសហគមន៍បង្ហាញថា ជារឿយៗគ្រួសារដែលយកកុមារជាកូនកំព្រា ឬកូនដែលត្រូវបានគេបោះបង់ចោលមកចិញ្ចឹម ច្រើនធ្វើបាបពួកគេ និងកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារទាំងនោះ។ សហគមន៍ដឹងពីករណីដែលកុមារទាំងនេះទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវចិត្ត (ហើយក្នុងករណីខ្លះពួកគេក៏ទទួលរងអំពើហិង្សាផ្លូវភេទផងដែរ)។

**រូបភាពទី១២៖ ភាគរយនៃគ្រួសារដែលរាយការណ៍ថា កុមារដែលត្រូវបានគេបោះបង់ចោលទទួលរងការរំលោភបំពានពីសមាជិកសហគមន៍**




ផ្អែកតាមព័ត៌មាន ដែលប្រមូលបានពីអង្គការសង្គមស៊ីវិល ដែលធ្វើការងារជាមួយយុវជនរស់នៅអនាថាតាមផ្លូវក្នុងទីក្រុងភ្នំពេញ *"រដ្ឋាភិបាលបាន និងកំពុងព្យាយាមកែលំអជីវិតរបស់កុមារទាំងនេះ តាមរយៈការប្រឹងប្រែងធ្វើសមាហរណកម្មពួកគេចូលទៅក្នុងសង្គមវិញ"*។ ប៉ុន្តែចាំបាច់ត្រូវតែមានការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ តាមរយៈការពិនិត្យតាមដានឲ្យល្អប្រសើរជាងមុន ដើម្បីធានាយ៉ាងណាកុំឲ្យមានការបញ្ជូនកុមារទាំងនេះទៅកាន់បរិយាកាសដែលពុំមានសុវត្ថិភាព ឬទៅគ្រួសារដែលមិនផ្តល់ការថែទាំដល់ពួកគេ។ លើសពីនេះ ក៏មានទង្វើដែលសាច់ញាតិសុំកូនកំព្រាទៅចិញ្ចឹមបែបក្រៅផ្លូវការផងដែរ។ មានការលើកឡើងថា *"គ្រួសារមិនចាំបាច់សុំកូនជាផ្លូវការឡើយ ហើយជាលទ្ធផល រដ្ឋមិនអាចតាមដានដឹងពីសុខុមាលភាពរបស់កុមារទាំងនោះឡើយ"*។ ការពុំមានការពិនិត្យតាមដានបែបនេះធ្វើឲ្យកុមារទាំងនេះកាន់តែរងគ្រោះ ដោយសារការមិនអើពើ និងការកេងប្រវ័ញ្ចផ្សេងទៀត។

ពាក់ព័ន្ធនឹងចំណុចខាងលើ ឧបសគ្គ ឬបញ្ហាប្រឈមមួយ ក្នុងចំណោមឧបសគ្គ ឬបញ្ហាប្រឈមសំខាន់ៗ ដែលរដ្ឋជួបប្រទះ គឺកុមារ ឬក្មេងជំទង់ជាច្រើននាក់ពុំមានសំបុត្រកំណើតឡើយ ដូច្នេះពួកគេពុំមានឈ្មោះក្នុងឯកសាររបស់រដ្ឋាភិបាលឡើយ។ ប្រជាជនជាច្រើននាក់នៅតែគិតថា ការចុះសំបុត្រកំណើតឲ្យកូនជារឿងមិនចាំបាច់ ហើយច្រើនតែចុះសំបុត្រកំណើតឲ្យកូននៅពេលក្រោយពេលដែលចាំបាច់ត្រូវបង្ហាញសំបុត្រកំណើតដើម្បីទទួលបានប្រយោជន៍ឬឧបត្ថម្ភធនពីរដ្ឋជាដើម។ កុមារប្រមាណ២៣,២ ភាគរយ និង ក្មេងជំទង់ ១៥,៥ ភាគរយ ដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងពុំមានសំបុត្រកំណើតឡើយ។

**រូបភាពទី១៣៖ ភាគរយនៃកុមារនិងក្មេងជំទង់ដែលមានសំបុត្រកំណើត**




## ពិការភាព និងការផាត់ចេញពីសង្គម

កុមារ ឬក្មេងជំទង់មានពិការភាព ដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុង គឺជាក្រុមមួយ ក្នុងចំណោមក្រុមដែលងាយរងគ្រោះជាងគេក្នុងសង្គម។ ជាធម្មតាពួកគេខ្វះលទ្ធភាពទទួលបានសេវាអប់រំ និងជួបការលំបាកដោយសារតែពុំមានសេវាថែទាំសុខភាពដែលចាំបាច់។ លើសពីនេះពួកគេក៏ត្រូវបានមនុស្សក្នុងសហគមន៍រើសអើងផងដែរ។ តំណាងសហគមន៍បាននិយាយថា ក្នុងករណីភាគច្រើន *"ពួកគេទទួលរងការរើសអើងបែបអសកម្មក្នុងផ្ទះ ឬទទួលរងការរើសអើងបែបសកម្មនៅតាមទីសាធារណៈនានា ដូចជានៅសាលារៀនជាដើម"*។ បើតាមការពិភាក្សាជាមួយនឹងតំណាងអង្គការសង្គមស៊ីវិល ការខ្វះឱកាស និងការរើសអើង ដែលកុមារពិការជួបប្រទះ គឺជាកត្តាដែលបន្ទុចបង្អាក់ពួកគេមិនឲ្យប្រើប្រាស់នូវសក្តានុពលរបស់គេឲ្យបានពេញលេញ ហើយដែលនឹងបង្កឧបសគ្គដល់ការរីកចម្រើនជារួមរបស់ពួកគេ។ ការ

ទទួលបានការអប់រំនៅមានកម្រិត ជាកត្តារារាំងដល់ការធ្វើសមាហរណកម្មពួកគេចូលទៅក្នុងសង្គម ធ្វើឲ្យពួកគេពិបាកនឹងទទួលបានភាពម្ចាស់ការខាងសេដ្ឋកិច្ចតាមរយៈការធ្វើការងារដែលមានប្រាក់ឈ្នួល។ ដូច្នេះ ចំណុចនេះបង្ហាញយ៉ាងច្បាស់ថា តម្រូវការខាងកិច្ចការពារ និងការអប់រំរបស់កុមារ និងក្មេងជំទង់មានពិការភាព គួរត្រូវបានយកចិត្តទុកដាក់នៅពេលរៀបចំគោលនយោបាយការពារកុមារ ឬនៅពេលបង្កើតគំនិតផ្តួចផ្តើម ឬកម្មវិធីនានា។ កុមារក្រីក្ររស់នៅទីក្រុងក្នុងក្រុមអាយុ៣ ដល់ ៥ឆ្នាំ ប្រមាណ ៥,៤ ភាគរយ និងក្មេងជំទង់ក្រីក្រក្នុងទីក្រុងក្នុងក្រុមអាយុ១០ ដល់ ១៤ឆ្នាំ ប្រមាណ ៥,៤ ភាគរយដែរ គឺជាអ្នកដែលមានពិការភាពក្នុងទម្រង់ណាមួយ។

**រូបភាពទី១៤៖ ភាគរយនៃកុមារ និងក្មេងជំទង់ ដែលមានពិការភាពក្នុងទម្រង់ណាមួយ**



ការវិភាគលើប្រភេទពិការភាព ដែលកុមារអាយុពី៣ ដល់ ៥ឆ្នាំ និងក្មេងជំទង់ អាយុពី១០ ដល់ ១៤ឆ្នាំ ជួបប្រទះ បង្ហាញថា ប្រភេទពិការភាពដែលកុមារមកពីសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញមាន គឺមានចម្រុះ។

**រូបភាពទី១៥៖ ប្រភេទពិការភាព**




សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយនឹងអង្គការសង្គមស៊ីវិល ដែលធ្វើការងារក្នុង និងជុំវិញសហគមន៍ក្រីក្រក្នុងទីក្រុង បានបង្ហាញថា ឥរិយាបថរបស់សហគមន៍ចំពោះកុមារ/ក្មេងជំទង់មានពិការភាព គឺជាមូលហេតុមួយ ដែលនាំឲ្យមានការព្រួយបារម្ភ។ តំណាងម្នាក់បាននិយាយថា "*ពួកគេត្រូវបានផាត់ចេញពីសង្គម ហើយឪពុកម្តាយច្រើនផ្តល់អាទិភាពលើការវិនិយោគក្នុងការអប់រំ សុខភាព និងអាហារូបត្ថម្ភសម្រាប់កុមារ/ក្មេងជំទង់ ដែលមិនមានពិការភាព*"។ ការសម្រេចចិត្តរបស់ពួកគេបែបនេះ គឺដោយសារតែពួកគេមិនរំពឹងថានឹងទទួលបានប្រយោជន៍ខាងសេដ្ឋកិច្ចមកវិញពីការវិនិយោគលើជនពិការ។ ពួកគេបន្តចាត់ទុកពិការភាពបែបនេះថាជាពិការភាពពេញមួយជីវិត ហើយជឿថានឹងពុំមានឱកាសការងារណាសមស្របសម្រាប់ជនពិការឡើយ។ ក្នុងកំឡុងនៃការពិភាក្សាក្រុមគោលដៅជាមួយសហគមន៍ ឪពុកម្តាយបានយល់ស្របជាមួយនឹងការលើកឡើងខាងលើ និងបានលើកឡើងយ៉ាងចំហថា ពួកគេមិនរំពឹងថាកុមារ ឬក្មេងជំទង់មានពិការភាពនឹងទទួលបានការងារធ្វើនាពេលអនាគតឡើយ "*កុមារដែលមិនអាចមើលថែខ្លួនឯងផង នឹងមិនអាចធ្វើអ្វីដែលមានប្រយោជន៍សម្រាប់គ្រួសារឡើយ ពួកគេត្រូវការអ្នកបញ្ចុកអាហារ និងមើលថែពេញមួយជីវិត ហើយសម្រាប់ពួកយើងដែលជាអ្នកក្រ វាគឺជាការពិបាកខ្លាំងណាស់ សម្រាប់ការយកប្រាក់ទាំងអស់ដែលយើងមានទៅចំណាយ ដើម្បីបំពេញតម្រូវការពិសេសៗរបស់ពួកគេ*"។ បើតាមការលើកឡើងរបស់តំណាងអង្គការសង្គមស៊ីវិលនាំមុខគេមួយចំនួន ដែលធ្វើការងារក្នុងទីក្រុងភ្នំពេញជាមួយកុមារ និងក្មេងជំទង់មានពិការភាពថា មានករណីខ្លះដែលឪពុកម្តាយបោះបង់កូនដែលជាកុមារ ឬក្មេងជំទង់មានពិការភាពចោលតែម្តង។ ករណីកើតឡើងពិតប្រាកដ គឺចំពោះកុមារឬក្មេងជំទង់ដែលខ្សោយបញ្ញា និងយុវជនដែលមានខ្សោយចលករធ្ងន់ធ្ងរ។ ក្នុងករណីភាគច្រើន ឪពុកម្តាយបង្ខំចិត្តបោះបង់ចោលកូនៗរបស់ខ្លួន ដោយសារតែពួកគេពុំមានលទ្ធភាពខាងហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារទាំងនោះបាន។ សហគមន៍ក៏មានការយល់ដឹងតិចតួចពីកម្សោយបញ្ញា ដូចជា បញ្ហាចិត្តវិកល និងអូទីសឹមជាដើម ហើយច្រើនតែមាក់ងាយកុមារឬក្មេងជំទង់ដែលមានពិការភាពបែបនោះ។ ជំនឿអរូបីតែងធ្វើឲ្យឪពុកម្តាយជឿថា ពិការភាពរបស់កុមារគឺកើតឡើងដោយសារតែគ្រួសាររបស់ពួកគេត្រូវបណ្តាសារ។ លើសពីនេះ គ្រួសារដែលមានកូនជាកុមារឬក្មេងជំទង់ពិការ

ពុំសូវជាមានចំណេះដឹងច្រើនអំពីរបៀបទំនាក់ទំនង និងមើលថែកុមារទាំងនេះឡើយ។ ការពុំមានយន្តការសម្រាប់កំណត់អត្តសញ្ញាណកុមារមានពិការភាពឲ្យបានទាន់ពេលវេលា ធ្វើឲ្យការឆ្លើយតបយឺតយ៉ាវពីរដ្ឋ ឬអង្គការសង្គមស៊ីវិលចំពោះករណីបែបនេះ។ ផលប៉ះពាល់អវិជ្ជមាននៃប្រភេទពិការភាពជាច្រើនអាចមានកម្រិតតិចតួច ហើយក្នុងករណីមួយចំនួន ពិការភាពអាចបាត់ទៅវិញ តាមរយៈការកំណត់អត្តសញ្ញាណ និងការផ្តល់អន្តរាគមន៍ឲ្យបានទាន់ពេលវេលា។



## អាពាហ៍ពិពាហ៍កុមារ

អាពាហ៍ពិពាហ៍កុមារត្រូវបានចាត់ទុកថាជាហានិភ័យមួយ ក្នុងចំណោមហានិភ័យសំខាន់ៗ ដែលក្មេងជំទង់ក្នុងប្រទេសកម្ពុជាជួបប្រទះ។ ខណៈដែលសហគមន៍ចាត់ទុកកុមារក្នុងក្រុមអាយុពី១០ ទៅ ១៤ឆ្នាំ ថាមានវ័យក្មេងពេកសម្រាប់រៀបការ យ៉ាងហោចណាស់ក៏មានគ្រួសារ ៤,៩ ភាគរយដែរ ដែលរាយការណ៍ថា ពួកគេឲ្យកូនដែលជាក្មេងជំទង់រៀបការ ពេលដែលគេ (ប្រុស/ស្រី) នៅអាយុក្រោម១៤ឆ្នាំនៅឡើយ។ ដូច្នេះ គួរមានការកត់សម្គាល់ថា មានគ្រួសាររស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញប្រមាណជា ២០,៥ ភាគរយ ពុំបានដឹងថារដ្ឋាភិបាលបានកំណត់អាយុអប្បបរមាសម្រាប់ការរៀបអាពាហ៍ពិពាហ៍សម្រាប់បុរស (២០ ឆ្នាំ) និងស្ត្រី (១៨ ឆ្នាំ)នោះទេ។ ផ្ទុយទៅវិញ មានករណីដែលគ្រួសារជាច្រើនដឹងពីច្បាប់នេះ ប៉ុន្តែពួកគេមានចេតនាមិនបង្ហាញពីករណីអាពាហ៍ពិពាហ៍កុមារឡើយ។ ដូច្នេះ ការប៉ាន់ប្រមាណនេះគួរចាត់ទុកថាជាការប៉ាន់ប្រមាណក្រោមកម្រិតជាក់ស្តែង។

**រូបភាពទី១៦៖ ភាគរយនៃគ្រួសារដែលរាយការណ៍ពីករណីអាពាហ៍ពិពាហ៍កុមារ**




ក្នុងចំណោមគ្រួសារដែលរាយការណ៍ពីករណីអាពាហ៍ពិពាហ៍កុមារ ប្រមាណជា ៤២,៩ ភាគរយអះអាងថា ពួកគេឲ្យកូនជំទង់របស់ខ្លួនរៀបការដោយសារតែសម្ពាធសង្គម និងដើម្បីគោរពតាមប្រពៃណី/ជំនឿរបស់គ្រួសារ។ ពួកគេប្រមាណជា ៣៥,៧ ភាគរយបានអះអាងថា អាពាហ៍ពិពាហ៍បែបនេះត្រូវបានរៀបចំឡើងដោយសារតែគូស្រករមានបំណងចង់រៀបការ និង ២១,៤ ភាគរយទៀត ឲ្យកូនរៀបការមុនអាយុ១៨ឆ្នាំដោយសារតែភាគីខាងកូនស្រីមានផ្ទៃពោះទៅហើយ។ ការពិភាក្សាជាមួយអង្គការសង្គមស៊ីវិល នៅតាមសហគមន៍

ក្រីក្រក្នុងទីក្រុងបង្ហាញឲ្យឃើញថា មានមនុស្សជាច្រើនក្នុងសហគមន៍ដឹងថា ការឆាប់រៀបការមានផលប៉ះពាល់អវិជ្ជមានលើសុខភាព និងសុខុមាលភាពរបស់ប្ដីប្រពន្ធ ប៉ុន្តែពួកគេនៅតែឲ្យកូនរៀបការទាំងវ័យក្មេង។ ពួកគេធ្វើបែបនេះដើម្បីឲ្យគូស្រករមានភាពឯករាជ្យនិងម្ចាស់ការដោយខ្លួនឯង ដែលជាការកាត់បន្ថយបន្ទុកការហូបចុកលើគ្រួសាររបស់ពួកគេ *"ខណៈពេលដែលវាជារឿងល្អដែលប្រជាជនដឹងពីផលវិបាកដ៏គ្រោះថ្នាក់នៃការរៀបការកូននៅវ័យក្មេង ពួកគេនៅតែជ្រើសយកជម្រើសបែបនេះដដែល ដោយសារតែពួកគេចាត់ទុកថាវាជាមធ្យោបាយដើម្បីកាត់បន្ថយការទទួល ខុសត្រូវរបស់គ្រួសារ"*។

**រូបភាពទី១៧៖ មូលហេតុដែលនាំឲ្យមានការរៀបអាពាហ៍ពិពាហ៍ឲ្យកុមារមុនពេលពួកគេឈានដល់នីតិភាពសម្រាប់អាពាហ៍ពិពាហ៍**




## ពលកម្មកុមារ

ភាពក្រីក្រ គឺជាមូលហេតុចម្បង ដែលនាំឲ្យមានពលកម្មកុមារ។ ការទទួលបានចំណូលទាបរបស់សហគមន៍ក្រីក្រដែលរស់នៅក្នុងទីក្រុង គឺជាកត្តាដែលបង្ខំឲ្យកុមាររកការងារធ្វើ ដើម្បីជួយរកចំណូលឲ្យគ្រួសារ។ ក្នុងករណីភាគច្រើន គ្រួសារមានបំណងចង់ផ្ដល់ការអប់រំដល់កូនៗរបស់ពួកគេ ប៉ុន្តែប្រយោជន៍ដែលបានពីការអប់រំនឹងលេចចេញជារូបរាងតែនៅពេលអនាគតប៉ុណ្ណោះ ស្របពេលដែលពលកម្មកុមារអាចផ្ដល់នូវប្រាក់កាសមកវិញនាពេលបច្ចុប្បន្ន ដែលអាចជួយដល់ការចិញ្ចឹមជីវិត និងសម្រាលបន្ទុករកចំណូលសម្រាប់គ្រួសារ។ ការបញ្ជូលកុមារទាំងនេះទៅក្នុងសាលារៀនធម្មតា ក្លាយជាការលំបាក ដោយសារតែពួកគេធ្លាប់រកប្រាក់បានដោយខ្លួនឯង និងមានភាពម្ចាស់ការខាងហិរញ្ញវត្ថុ។ កុមារច្រើនត្រូវបានគេជួលឲ្យធ្វើការងារក្នុងវិស័យមិនរៀបរយ ដែលភាគច្រើនស្ថិតនៅក្រៅវង្វង់នៃការគ្រប់គ្រងរបស់រដ្ឋាភិបាល។ ដូច្នេះ ការពិនិត្យតាមដានចំនួនម៉ោងធ្វើការនៅមានកម្រិត ហើយលក្ខខណ្ឌ និងវិធានការសុវត្ថិភាពដែលផ្ដល់ដោយនិយោជក ពុំបានផ្ដល់ការការពារដល់កុមារដែលកំពុងប្រឡូកក្នុងពលកម្មកុមារឡើយ។ ជាលទ្ធផល កុមារដែលជាពលកររឹតតែងាយរងគ្រោះដោយសារការរំលោភបំពាននៅកន្លែងធ្វើការ។ គ្រួសារភាគច្រើនដឹងថា ពលកម្មកុមារគឺជារឿងខុសច្បាប់ ប៉ុន្តែ មានគ្រួសារ ៥,៣ ភាគរយ បានរាយការណ៍ថា បច្ចុប្បន្ន ក្មេងជំទង់មកពីគ្រួសាររបស់ពួកគេកំពុងធ្វើការងារ ដើម្បីរកចំណូលបន្ថែមដល់គ្រួសារ។

ស្ថិតិដែលលើកឡើងខាងលើ គឺពិតជាពុំបានបង្ហាញពីស្ថានភាពជាក់ស្តែងនៃបញ្ហាពលកម្មកុមារនោះទេ។ សហគមន៍ដឹងថា ពលកម្មកុមារ គឺជារឿងខុសច្បាប់ ដូច្នេះពួកគេមិនចង់រាយការណ៍ពីករណីពលកម្មកុមារឡើយ។ ចំណុចខាងលើនេះត្រូវបានឯកភាពដោយ

អ្នកដឹកនាំសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញទាំង១៣ ទីតាំង ដែលត្រូវបានដាក់បញ្ចូលក្នុងការសិក្សានេះ។ អ្នកដឹកនាំសហគមន៍ប៉ាន់ប្រមាណថា ក្នុងសហគមន៍របស់ពួកគេ រៀងរាល់១០គ្រួសារ មានជិត៩គ្រួសារ ហើយ ដែលមានកូនស្ថិតក្នុងពលកម្មកុមារ។ លើសពីនេះ ក៏មានករណីជាច្រើន ដែលកុមារទៅរៀនពេលថ្ងៃ ហើយ ទៅធ្វើការងារ ក្រោយពេលចេញពីសាលា។

**រូបភាពទី១៨៖ ភាគរយនៃគ្រួសារដែលរាយការណ៍ពីការចូលរួមរបស់កុមារក្នុងកម្លាំងពលកម្ម**




លើសពីនេះ ក្នុងចំណោមករណីទាំងអស់ដែលត្រូវបានរាយការណ៍ ប្រមាណជា ៧៩,២ ភាគរយ គឺពាក់ព័ន្ធជាមួយនឹងក្មេងប្រុសក្នុងគ្រួសារ។ ប៉ុន្តែ អ្វីដែលគួរយល់គឺថា ក្មេងស្រីច្រើនតែធ្វើការងារ ដែលមើលទៅហាក់បីដូចជាមិនមែនការងារដោយសារតែពួកគេបោះបង់ចោលការសិក្សា ដើម្បីមើលថែប្អូនៗ ឬធ្វើការងារផ្ទះជាដើម។ ដោយសារតែការជួយគាំទ្ររបស់ពួកគេបែបនេះ ម្តាយរបស់ពួកគេអាចមានពេល ដើម្បីធ្វើការងាររកចំណូលប្រចាំថ្ងៃ និងអាចរួមចំណែករកចំណូលសម្រាប់គ្រួសារបាន។ សមាជិកសហគមន៍ភាគច្រើនយល់ស្របថា ពលកម្មកុមារដាក់កំហិតលើលទ្ធភាពរបស់កុមារឬក្មេងជំទង់ ដើម្បីសម្រេចសក្តានុពលសេដ្ឋកិច្ចរបស់ពួកគេឲ្យបានពេញលេញ និងរំខានដល់ការលូតលាស់ និងការអភិវឌ្ឍពួកគេផងដែរ។ ប៉ុន្តែ ពេលខ្លះវាជាជម្រើសតែមួយគត់ សម្រាប់គ្រួសារ ដែលជួបការលំបាក ក្នុងការបំពេញតម្រូវការរស់នៅប្រចាំថ្ងៃរបស់ខ្លួន។

កុមារភាគច្រើន ដែលប្រឡូកក្នុងពលកម្មកុមារ គឺធ្វើការតាមឡឥដ្ឋ ការដ្ឋានសំណង់ រោងចក្រ និងទីលានចាក់សំរាម។ កុមារជាច្រើននាក់ផ្សេងទៀតធ្វើការងារជាអ្នកជួយធ្វើការងារតាមផ្ទះ និង/ឬជាអ្នកលីសែង។ អ្វីដែលស្តែងចេញច្បាស់នោះគឺ កុមារភាគច្រើន គឺកំពុងធ្វើការងារក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់ និងជាការងារដែលទាមទារឲ្យមានការប្រើប្រាស់កម្លាំងកាយខ្លាំង ដែលនឹងបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាព និងសុខុមាលភាពរបស់ពួកគេ។

# អនាម័យបរិស្ថាន និង អនាម័យផ្ទាល់ខ្លួននៅតាមផ្ទះ

ការពុំមានបរិក្ខារគ្រប់គ្រាន់ និងការខ្វះចន្លោះខាងឥរិយាបថមួយចំនួន ពាក់ព័ន្ធនឹងសុខភាព និងអនាម័យ បង្កផលប៉ះពាល់រឹតតែខ្លាំងលើសុខុមាលភាព ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។ បរិក្ខារអនាម័យមិនគ្រប់គ្រាន់ ប្រព័ន្ធលូមិនសមស្រប ទម្លាប់អនាម័យមិនល្អ និងលទ្ធភាពតិចតួចក្នុងការទទួលបានទឹកស្អាតសម្រាប់ផឹក គឺជាកត្តាដែលមានទំនាក់ទំនងយ៉ាងជិតដល់ជាមួយនឹងស្ថានភាពសុខភាពរបស់បុគ្គលម្នាក់ៗ (ជាពិសេសគឺកុមារតែម្តង)។

ការពិភាក្សាជាមួយនឹងគ្រួសារដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញបង្ហាញថា មានគ្រួសារប្រមាណជា ៣២,៥ ភាគរយ ពុំមានបង្គន់ប្រើប្រាស់ក្នុងផ្ទះឡើយ។ ការពុំមានបង្គន់អនាម័យក្នុងផ្ទះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ។ គ្រួសារដែលគ្មានបង្គន់ប្រើប្រាស់ភាគច្រើន ស្ថិតក្នុងបញ្ជីភាគទាបជាងគេ បើគិតពីចំណូលមធ្យមប្រចាំខែរបស់សមាជិកគ្រួសារម្នាក់។ ផ្ទះរបស់ពួកគេគឺជាសំណង់ពាក់កណ្តាល អចិន្ត្រៃយ៍ ហើយពុំបានតភ្ជាប់ជាមួយនឹងបណ្តាញលូបង្ហូរទឹកស្អុយរបស់ក្រុងឡើយ។ សូម្បីតែនៅតាមគ្រួសារដែលបង្គន់តភ្ជាប់ជាមួយនឹងប្រព័ន្ធលូក៏ដោយ មានការលើកឡើងថា ការសង់បង្គន់ទាំងនេះធ្វើឡើងដោយមានការឧបត្ថម្ភធនពីអង្គការសង្គមស៊ីវិល ដែលធ្វើការងារក្នុងតំបន់នោះ។ លើសពីនេះ ក្នុងករណីភាគច្រើន ប្រព័ន្ធលូដែលសាងសង់ឡើងនេះ គឺមិនគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការផ្នែកអនាម័យរបស់ប្រជាជនតាមសហគមន៍ក្រីក្រក្នុងទីក្រុងដែលកើនចំនួនយ៉ាងឆាប់រហ័សនោះទេ។ ដោយសារតែពុំអាចទ្រាំទ្រនឹងបរិមាណសំណល់បាន ប្រព័ន្ធលូនេះត្រូវបានគេបើកគំរបវាឡើង និងមានកំណកភក់នៅកន្លែងទាបៗ ឬនៅជិតកន្លែងដែលប្រជាជនរស់នៅ។ គ្រួសារប្រមាណត្រឹម៥១ ភាគរយដែលមានបង្គន់ប្រើប្រាស់នោះ បានលើកឡើងថា បង្គន់របស់ពួកគេតភ្ជាប់ជាមួយនឹងប្រព័ន្ធលូត្រឹមត្រូវ។ ស្ថានភាពបរិក្ខារអនាម័យ និងប្រព័ន្ធលូមានសភាពកាន់តែចុះដុនដាបទៅៗ ដោយសារតែការពង្រីកទីក្រុងដ៏ឆាប់រហ័ស។ មានតំបន់តាំងទីលំនៅរបស់ប្រជាជនក្រីក្រជាច្រើនទីតាំង ទើបតែលេចចេញជារូបរាងកាលពីពេលថ្មីៗនេះតែប៉ុណ្ណោះ ហើយតំបន់ទាំងនេះមានគ្រួសារដែលត្រូវបានគេផ្លាស់ប្តូរទីលំនៅចេញ ហើយយកដីទៅកសាងជាបុរី តំបន់ការិយាល័យ ផ្សារទំនើបៗ ។ល។ គ្រួសារមួយចំនួនក្នុងចំណោមគ្រួសារទាំងនេះធ្លាប់មានបង្គន់ប្រើប្រាស់ មុនពេលដែលពួកគេបាត់បង់ទីលំនៅរបស់ពួកគេ។

ចំណុចសំខាន់ ដែលគួរឲ្យកត់សម្គាល់នោះគឺថា ដោយសារតែជាមធ្យម គ្រួសារមួយមានសមាជិកប្រមាណ៦នាក់ បង្គន់តែមួយ គឺមិនគ្រប់គ្រាន់សម្រាប់តម្រូវការរបស់គ្រួសារទាំងមូលឡើយ។ ក្នុងករណីបែបនេះ សមាជិកមួយចំនួនក្នុងគ្រួសារត្រូវបង្ខំចិត្តបន្តបន្ទោរបង់ពាសវាលពាសកាល។

វិសាលភាព និងស្ថានភាពនៃហេដ្ឋារចនាសម្ព័ន្ធអនាម័យ តាមសហគមន៍ក្រីក្រក្នុងទីក្រុង គួបផ្សំនឹងមានភ្លៀងធ្លាក់ខ្លាំងតាមខែមួយចំនួនក្នុងទីក្រុងផងនោះ ធ្វើឲ្យសហគមន៍ងាយទទួលរងការឆ្លងជំងឺតាមទឹក។ មានការកត់សម្គាល់ថា កុមាររឹតតែងាយឆ្លងជំងឺទាំងនេះទៅទៀត ដោយសារតែភាពស៊ាំរបស់ពួកគេមានកម្រិតទាប និងមិនសូវជាយកចិត្តទុកដាក់ចំពោះការរក្សាអនាម័យដើម្បីការពារខ្លួនពីជំងឺទាំងនេះឡើយ។ តាមសហគមន៍ដែលគ្រួសារភាគច្រើនមានបង្គន់ប្រើប្រាស់ក្នុងផ្ទះ គ្រួសារប្រមាណជា ៤០ ភាគរយ លើកឡើងថា ជំងឺឆ្លងតាមទឹក គឺជាការព្រួយបារម្ភមួយរបស់ពួកគេ។ គេប៉ាន់ប្រមាណថា ក្នុងចំណោមសហគមន៍ទាំងអស់នេះ ជិត ៧៥ ភាគរយ មានការគ្របដណ្តប់សេវាអនាម័យទាប។

ការពិភាក្សាជាមួយសមាជិកសហគមន៍បង្ហាញថា ស្របពេលដែលពួកគេជាច្រើននាក់យល់ដឹងពីសារៈសំខាន់នៃការសង់បង្គន់ក្នុងផ្ទះ និងការប្រើប្រាស់បង្គន់នេះ ពួកគេមានចំណេះដឹងបច្ចេកទេសតិចតួចបំផុត ដើម្បីសង់បង្គន់ដែលមានពន្លឺចូលគ្រប់គ្រាន់ មានខ្យល់ចេញចូល និងអាចប្រើប្រាស់បានត្រឹមត្រូវ។ សមាជិកសហគមន៍ជាច្រើននាក់មិនប្រើប្រាស់បង្គន់ដែលពួកគេមានស្រាប់

ក្នុងផ្ទះឡើយ ដោយសារតែពួកគេគិតថាការបន្ទោរបង់ខាងក្រៅពាសវាលពាសកាល មានអនាម័យជាងការបន្ទោរបង់ក្នុងបង្គន់។ ចំណុចនេះត្រូវបានបញ្ជាក់កាន់តែច្បាស់បន្ថែមទៀត ដោយក្នុងករណីជាច្រើន បង្គន់បង្ហូរកាកសំណល់ទៅតំបន់ទាបៗ ដែលស្ថិតក្នុងឬជិត តំបន់តាំងទីលំនៅរបស់ប្រជាជន។

**រូបភាពទី១៩៖ ភាគរយគ្រួសារដែលរាយការណ៍ថាមានបង្គន់ប្រើប្រាស់ក្នុងផ្ទះ**




គ្រួសារប្រមាណជា ៨១,៩ ភាគរយ បានរាយការណ៍ថា មនុស្សពេញវ័យក្នុងគ្រួសារលាងដៃជាមួយសាប៊ូជាប្រចាំ ក្រោយពីបានប្រើប្រាស់បង្គន់រួច ហើយកូនៗរបស់ពួកគេក៏ចាប់យកទម្លាប់នេះផងដែរ។ ខណៈពេលដែលមានឪពុកម្តាយ ៨២,៧ ភាគរយ រាយការណ៍ថា កុមារក្នុងផ្ទះរបស់ពួកគេតែងលាងដៃជាមួយសាប៊ូក្រោយប្រើបង្គន់រួច តួលេខសម្រាប់ក្មេងជំទង់គឺទាបជាងនេះបន្តិចគឺត្រឹមតែ ៧៧,៣ ភាគរយប៉ុណ្ណោះ។ ការពិភាក្សាជាមួយសមាជិកសហគមន៍បង្ហាញថា តួលេខថយចុះបែបនេះគឺដោយសារតែការពេញចិត្តជាមួយនឹងទម្លាប់ដែលខ្លួនមាន។ សមាជិកសហគមន៍ស្ទើរតែទាំងអស់ដឹងថា ការលាងសម្អាតដៃក្រោយប្រើបង្គន់រួច គឺជារឿងសំខាន់។ អ្នកដែលមិនបានលាងសម្អាតដៃ ពុំបានផ្តល់សារៈសំខាន់ដល់ឥរិយាបថបែបនេះឡើយ។ ក្មេងជំទង់ម្នាក់បានលើកឡើងថា *"មនុស្សដឹងពីមូលហេតុ ពេលវេលា និងរបៀបគួរលាងសម្អាតដៃមានមនុស្សភាគច្រើនលាងសម្អាតដៃ ប៉ុន្តែមនុស្សមួយចំនួនក៏មិនបានលាងសម្អាតដៃដែរ ដោយសារតែពួកគេខ្ជិលលាងដៃ"*។

**រូបភាពទី២០៖ ភាគរយនៃកុមារ និងមនុស្សពេញវ័យដែលលាងសម្អាតដៃ (ជាមួយសាប៊ូ) ក្រោយប្រើបង្គន់រួច**



ក្រៅពីចំណុចខាងលើគេក៏ចាំបាច់ត្រូវកែលម្អស្ថានភាពអនាម័យមាត់ធ្មេញរបស់កុមារ និងក្មេងជំទង់ផងដែរ។ កុមារប្រមាណជា ៤៩ ភាគរយ និងក្មេងជំទង់ ២៧,៧ ភាគរយ ត្រូវបានគេកត់សម្គាល់ឃើញថា ពុំបានដុសធ្មេញរបស់ខ្លួនឲ្យបានទៀងទាត់ឡើយ។ លើសពីនេះ ការពិភាក្សាក្រុមគោលដៅជាមួយឪពុកម្តាយបង្ហាញថា កុមារ/ក្មេងជំទង់ភាគច្រើនដែលដុសធ្មេញ គឺដុសធ្មេញតែម្តងប៉ុណ្ណោះ ក្នុងមួយថ្ងៃ (ភាគច្រើននៅពេលព្រឹក)។

**រូបភាពទី២១៖ ភាគរយនៃកុមារ និងក្មេងជំទង់ ដែលដុសធ្មេញជាប្រចាំ**[50]




## ទឹកស្អាតសម្រាប់ផឹកនៅផ្ទះ

របៀបមួយទៀត ដែលកុមារអាចកើតជំងឺឆ្លងដែលអាចបង្ការបាន គឺការឆ្លងតាមទឹក ដែលពួកគេផឹក។ ការពុំមានទឹកស្អាតសម្រាប់ផឹក ធ្វើឲ្យកុមារប្រឈមនឹងជំងឺដែលមេរោគឆ្លងតាមទឹក ដូចជាជំងឺរាករូសជាដើម។ គ្រួសារប្រមាណជា ៥១,៥ ភាគរយ ទទួលបានទឹកស្អាតពីប្រភពរបស់រដ្ឋាភិបាល។ គ្រួសារ ៣២,៤ ភាគរយទៀត ទិញទឹកពីប្រភពឯកជន (ដែលថ្លៃខ្ពស់ជាងទឹកពីរដ្ឋ)។ គ្រួសារ ១២ ភាគរយ យកទឹកពីទន្លេ បឹង ឬអណ្តូង។ ចុងក្រោយ គ្រួសារ ៤,១ ភាគរយ បានទឹកពីប្រភពចម្រុះ។

[50] *សម្រាប់គោលបំណងនៃការសិក្សានេះ ទៀងទាត់ សំដៅលើការអនុវត្តជាស្តង់ដាគឺការដុសធ្មេញពីរដងក្នុងមួយថ្ងៃ។*

## រូបភាពទី២២៖ ប្រភពទឹកសម្រាប់ផឹក




ក្នុងការពិភាក្សាក្រុមគោលដៅ សមាជិកសហគមន៍ភាគច្រើនលើកឡើងថា ពួកគេដាំទឹកទុកផឹក។ ប៉ុន្តែប្រជាពលរដ្ឋជាច្រើនគ្រួសាររាយការណ៍ថា ពួកគេផឹកទឹកដោយមិនបានដាំ ឬសម្អាតឡើយ។ ការលើកកម្ពស់ការយល់ដឹងដែលធ្វើឡើងដោយអង្គការសង្គមស៊ីវិលតាមមូលដ្ឋាន ធ្វើឲ្យប្រជាពលរដ្ឋដឹងថា ការផឹកទឹកមិនស្អាតអាចធ្វើឲ្យអន្តរាយដល់សុខភាព និងការអភិវឌ្ឍរបស់កុមារ។ ជាលទ្ធផល គ្រួសារដែលមានកូនអាយុពី ៣ ដល់ ៥ឆ្នាំ ប្រមាណជា ៦៦,៣ ភាគរយ រាយការណ៍ថា ខ្លួនមានប្រព័ន្ធសម្រាប់ចម្រោះទឹក។ ប៉ុន្តែ មានគ្រួសារដែលមានកូនជំទង់ត្រឹមតែ ៣៥,៧ ភាគរយប៉ុណ្ណោះ ដែលមានប្រព័ន្ធចម្រោះទឹកសម្រាប់ប្រើប្រាស់។ សមាជិកសហគមន៍ជាច្រើននាក់ក៏បានលើកឡើងផងដែរថាពួកគេដឹងពីសារៈសំខាន់នៃទឹកស្អាតសម្រាប់ផឹក នៅពេលដែលហាងក្នុងមូលដ្ឋានរបស់ពួកគេចាប់ផ្តើមលក់ទឹកផឹកដាក់ធុង ឬដប។ ការចង់ដឹងរបស់ពួកគេធ្វើឲ្យពួកគេទាក់ទងសួរនាំអ្នកលក់ ដែលធ្វើឲ្យពួកគេដឹងថា ទឹកដាក់ក្នុងធុង ឬដប គឺខុសពីទឹកដែលពួកគេផឹកក្នុងផ្ទះ។ ចាំបាច់ត្រូវមានការបង្កើនការគ្របដណ្តប់នៃប្រព័ន្ធចម្រោះទឹក ហើយបញ្ហាប្រឈមហាក់បីដូចជានៅត្រង់ថា មនុស្សជាច្រើនក្នុងសហគមន៍ ពុំបានដឹងថា តម្លៃប្រព័ន្ធចម្រោះទឹកមានការថយចុះយ៉ាងច្រើនកាលពីពេលថ្មីៗនោះទេ ឯការចំណាយសម្រាប់ការថែទាំប្រព័ន្ធទាំងនេះក៏ធ្លាក់ចុះផងដែរ។ ចំណុចមួយទៀតគឺប្រព័ន្ធចម្រោះទឹកអាចដំណើរការដោយមិនចាំបាច់មានអគ្គិសនី។

## រូបភាពទី២៣៖ ការមានប្រព័ន្ធចម្រោះទឹកក្នុងផ្ទះ



# សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ

ក្មេងជំទង់ក្នុងអាយុពី១០ ដល់១៨ឆ្នាំ ប្រមាណជា ១,៣ ភាគរយ គឺជាអ្នកដែលសកម្មខាងផ្លូវភេទ។[51] នៅពេលបែងចែកតួលេខនេះតាមយេនឌ័រពុំមានភាពខុសប្លែកគ្នាគួរឲ្យកត់សម្គាល់នោះទេ៖ ក្មេងស្រីដែលសកម្មខាងផ្លូវភេទគឺ ១,៤ ភាគរយ ហើយក្មេងប្រុសវិញមាន ១,១ ភាគរយ។ សម្ភាសន៍ពាក់ណ្តាលរចនាសម្ព័ន្ធជាមួយអង្គការសង្គមស៊ីវិល និងការពិភាក្សាក្រុមគោលដៅជាមួយនឹងសមាជិកសហគមន៍បង្ហាញថា ភាគរយនៃក្មេងជំទង់ដែលសកម្មខាងផ្លូវភេទមានការកើនឡើងគួរឲ្យកត់សម្គាល់ ក្នុងក្រុមអាយុពី១៤ ដល់ ១៨ឆ្នាំ។ តំណាងអង្គការសង្គមស៊ីវិលម្នាក់បាននិយាយថា *"នៅពេលដែលពួកគេចាប់ផ្តើមពេញវ័យ ពួកគេចង់ដឹងអំពីភេទផ្សេងទៀត និងចង់ដឹងពីការរួមភេទ ហើយដើម្បីដឹង ពេលខ្លះ ពួកគេពិសោធជាមួយនឹងរឿងផ្លូវភេទនេះ អាចមានករណីដែលពួកគេសាកល្បង ដោយសារតែពួកគេចង់ដឹងចង់ឮពីរឿងនេះ"*។ ដូច្នេះ ដោយសារតែនឹងមានក្មេងជំទង់ច្រើននាក់ចូលមកក្នុងក្រុមអាយុនេះ លទ្ធភាពដែលពួកគេនឹងសកម្មខាងផ្លូវភេទមានការកើនឡើងគួរឲ្យកត់សម្គាល់។

**រូបភាពទី២៤៖ ភាគរយនៃក្មេងជំទង់ដែលសកម្មខាងផ្លូវភេទ**




ការពិភាក្សាជាមួយក្មេងជំទង់បង្ហាញថា បើទោះបីជាពួកគេគិតថា សហគមន៍មានការបើកចំហចំពោះជម្រើសផ្លូវភេទ/ចំណង់ចំណូលចិត្តខាងភេទរបស់បុគ្គលម្នាក់ៗក៏ដោយ ករណីដែលក្មេងជំទង់មានផ្ទៃពោះដែល គេមិនចង់បាន ត្រូវបានចង់ទុកថាទង្វើឆ្គាំឆ្គងក្នុងសង្គមសម្រាប់ក្មេងស្រី *"បើទោះបីជាសង្គមរបស់យើងជាសង្គមបើកចំហក៏ដោយ ប៉ុន្តែក៏មានការប្រកាន់គុណតម្លៃសង្គមតឹងរ៉ឹងផងដែរ ពោលគឺប្រសិនបើក្មេងស្រីណាម្នាក់មានផ្ទៃពោះមិនទាន់រៀបការ គេចាត់ទុកថាវាមិនមែនជារឿងល្អឡើយ ហើយគេនឹងចោទសួរពីរបៀបដែលឪពុកម្តាយរបស់នាងចិញ្ចឹមបីបាច់នាងជាមិនខាន។ ក្នុងករណីភាគច្រើន សូម្បីតែក្នុងករណីដែលគេស្គាល់បុរសជាដៃគូក៏ដោយ អ្នកដែលប្រឈមនឹងការមាក់ងាយគឺភាគីខាងស្រី"*។ មនុស្សមួយចំនួនចាត់ទុករឿងនេះថាជាបញ្ហាដែលធ្វើឲ្យប៉ះពាល់កិត្តិយសគ្រួសារ និងចាប់ផ្តើមសួរសំណួរពីសីលធម៌របស់ក្មេងស្រីនោះ។ មនុស្សផ្សេងទៀត ចាប់ផ្តើមនិយាយទៅកាន់ក្មេងស្រីនោះប្រកបដោយក្តីអាណិត និងយល់ពីការលំបាករបស់នាង។ ពួកគេគិតថា ក្មេងស្រីនេះត្រូវចិញ្ចឹមកូនតែឯង ហើយគិតថានឹងមិនទាន់ពេញវ័យគ្រប់គ្រាន់ ដើម្បីរ៉ាប់រងការទទួលខុសត្រូវនេះបានឡើយ។ មិនមានក្មេងជំទង់ច្រើននាក់ទេដែលដឹងពីអ្វីទៅដែលហៅថាការរំលូតកូននោះ ដូច្នេះ ក្មេងស្រីម្នាក់ប្រាកដជាមិនដឹងថាតើត្រូវទៅទីណា ដើម្បីរំលូតកូនដែលនាងមិនចង់បាននោះឡើយ។ ក្មេងជំទង់

[51] *ធ្លាប់រួមភេទយ៉ាងហោចណាស់ម្តង ក្នុងឆ្នាំកន្លងទៅនេះ។*

ប្រមាណជា ៨៧,៩ ភាគរយ បានលើកឡើងថា ពួកគេមិនដឹងពីទីតាំងមណ្ឌលផ្តល់សេវារំលូតកូន ក្នុងនិងជិតសហគមន៍របស់ពួកគេឡើយ។ សហគមន៍មានការយល់ឃើញខុសគ្នាអំពីប្រធានបទនៃការរំលូតកូននេះ។ អ្នកខ្លះគិតថា ការរំលូតកូនជាអ្វីដែលអាចទទួលយកបាន ដោយសារតែពួកគេចាត់ទុកការរំលូតកូនជាមធ្យោបាយដើម្បីស្តារជីវិតរបស់ក្មេងជំទង់ឡើងវិញ។ អ្នកខ្លះចាត់ទុកការរំលូតកូនថាជាការបញ្ចប់ជីវិតរបស់កូន ហើយមានគោលជំហរប្រឆាំងនឹងការរំលូតកូននេះ។ លើសពីនេះ ការពិភាក្សាជាមួយក្មេងជំទង់មួយចំនួនតូចបង្ហាញថា ក្នុងករណីដែលក្មេងជំទង់ទៅរកសេវាពីកន្លែងផ្តល់សេវារំលូតកូន ដើម្បីបញ្ចប់ការមានផ្ទៃពោះដោយមិនចង់បានជាធម្មតា ពួកគេទៅរកគ្លីនិកឯកជន។ មូលហេតុគឺដោយសារតែពួកគេខ្លាចមន្ត្រីនៅតាមកន្លែងផ្តល់សេវារបស់រដ្ឋនឹងវិនិច្ឆ័យរិះគន់ពួកគេ និងពេលខ្លះ មិនយល់ពីទុក្ខលំបាករបស់ពួកគេ។ អ្វីដែលរឹតតែសំខាន់ទៅទៀត គឺពួកគេគិតថា មន្ទីរពេទ្យរដ្ឋមិនអាចរក្សាការសម្ងាត់ឲ្យអត្តសញ្ញាណ និងឯកសារនានារបស់ពួកគេបានឡើយ។

**រូបភាពទី២៥៖ ភាគរយនៃករណីក្មេងជំទង់មានផ្ទៃពោះ ដែលមានបញ្ហាសុខភាព**






# ហានិភ័យពាក់ព័ន្ធ
# នឹងកិច្ចការពារកុមារ
# តាមសាលារៀន

# ការចុះឈ្មោះចូលរៀន និងការចូលរួមក្នុងសកម្មភាពរៀនសូត្រ

ការទទួលបានការអប់រំក្នុងប្រព័ន្ធ ផ្តល់ឱកាសឲ្យកុមារអាចចូលរួមក្នុងសកម្មភាពបង្រៀន និងរៀន ដែលមានការរៀបចំត្រឹមត្រូវជាមួយនឹងកុមារផ្សេងទៀត ដែលមានអាយុស្របាលពួកគេ ដែលផ្តល់លទ្ធភាពឲ្យពួកគេអាចអភិវឌ្ឍបំណិនចិត្តសង្គម និងបញ្ញាស្មារតីបាន ហើយក៏អាចឲ្យពួកគេបំពេញតួនាទីកាន់តែសកម្មក្នុងសង្គមផងដែរ។ ដូច្នេះ ការទទួលបានការអប់រំតាមសាលារៀនក្នុងប្រព័ន្ធតិចតួចជាកត្តាដាក់កំហិតដល់ការទទួលបានឱកាសនាពេលអនាគត។ ការពិភាក្សាក្រុមគោលដៅជាមួយក្មេងជំទង់បង្ហាញថា សហគមន៍មានការយល់ដឹងខ្ពស់អំពីអត្ថប្រយោជន៍ផ្ទាល់ និងអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចដែលពួកគេទទួលបានពីការបន្តការសិក្សាដល់ថ្នាក់ខ្ពស់ៗបន្ថែមទៀត។ ក្មេងជំទង់ម្នាក់ដែលបានចូលរួមក្នុងការពិភាក្សាក្រុមគោលដៅបាននិយាយថា "*យើងចង់ទទួលបានការអប់រំឲ្យបានជ្រៅជ្រះ ដើម្បីឲ្យយើងអាចធ្វើការងារតាមការិយាល័យធំៗ និងទទួលបានប្រាក់ចំណូលខ្ពស់។* នាងបានបន្តទៀតថា *ការអប់រំធ្វើឲ្យជីវិតទទួលបានឋានៈខ្ពង់ខ្ពស់*"។ ការលើកឡើងបែបនេះ គឺត្រូវគ្នានឹងតួលេខដែលបានរកឃើញ ដោយមានក្មេងជំទង់ប្រមាណជា ៨១,៥ ភាគរយ ចង់រៀនឲ្យចប់យ៉ាងណាស់ត្រឹមថ្នាក់ទី១២ ហើយពួកគេប្រមាណ ២៩,៨ ភាគរយ ចង់រៀនបញ្ចប់សញ្ញាបត្រពីសកលវិទ្យាល័យ។

**រូបភាពទី២៦៖ បំណងប្រាថ្នាពីការអប់រំ តាមការលើកឡើងរបស់ក្មេងជំទង់កំពុងរៀនតាមសាលា**




ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពយ៉ាងឆាប់រហ័ស ក្នុងការបង្កើនអត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា តាមរយៈការផ្តល់ការអប់រំដោយមិនគិតថ្លៃដល់ប្រជាពលរដ្ឋគ្រប់រូប។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសនេះមិនទាន់ទទួលបានលទ្ធផលគាប់ប្រសើរនៅឡើយនៃអត្រាចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិទេ។ ការពិភាក្សាជាមួយឪពុកម្តាយឬអាណាព្យាបាលបង្ហាញថា អត្រាចូលរៀននៅកម្រិតមត្តេយ្យសិក្សាបច្ចុប្បន្ន នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ គឺមានកម្រិតទាបខ្លាំង ហើយការលើកឡើងបែបនេះគឺត្រូវគ្នានឹងទិន្នន័យដែលប្រមូលសម្រាប់ការសិក្សានេះ ដែលបង្ហាញថា កុមារក្នុងក្រុមអាយុពី៣ ដល់៥ឆ្នាំប្រមាណតែ ២៩ ភាគរយប៉ុណ្ណោះ ដែលកំពុងរៀនក្នុងសាលារៀនណាមួយ។ គួរកត់សម្គាល់

ថា អត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រី គឺខ្ពស់ជាងក្មេងប្រុស។ កុមារដែលរៀនតាមសាលារៀនក្នុងប្រព័ន្ធ ៥៦,៨ ភាគរយ កំពុងរៀនតាមសាលាមត្តេយ្យរដ្ឋ ឬមត្តេយ្យសហគមន៍ ៣១,៥ ភាគរយទៀត កំពុងរៀនតាមសាលារៀនរបស់អង្គការមិនមែនរដ្ឋាភិបាល និង ១១,៧ ភាគរយ កំពុងរៀនតាមសាលារៀនឯកជន។ ឪពុកម្តាយច្រើនចង់បញ្ជូនកូនឲ្យទៅរៀនតាមសាលាមត្តេយ្យរបស់អង្គការមិនមែនរដ្ឋាភិបាល ដោយសារតែពួកគេគិតថា កូនៗរបស់ពួកគេនឹងទទួលបានការថែទាំ និងការយកចិត្តទុកដាក់បានល្អបំផុតនៅទីនោះ។ ឪពុកម្តាយម្នាក់ដែលបានចូលរួមក្នុងការពិភាក្សាក្រុមគោលដៅបាននិយាយថា "*ការអប់រំតាមសាលារៀនដំណើរការ ដោយអង្គការមិនមែនរដ្ឋាភិបាលគឺផ្តល់ដោយមិនគិតថ្លៃ ហើយមានគុណភាពល្អជាងសាលាមត្តេយ្យរដ្ឋ ឬសាលាមត្តេយ្យសហគមន៍*"។ ការចុះឈ្មោះចូលរៀនក្នុងកម្រិតខ្ពស់នៅតាមសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសហគមន៍ គឺដោយសារតែសិស្សដែលអនុញ្ញាតិឲ្យចូលរៀនក្នុងសាលាមត្តេយ្យរបស់អង្គការមិនមែនរដ្ឋាភិបាលមានចំនួនកំណត់។

**រូបភាពទី២៧៖** **ស្ថិតិបង្ហាញពីការចុះឈ្មោះចូលរៀនរបស់កុមារក្នុងក្រុមអាយុ៣ ដល់៥ឆ្នាំ**




ចំណុចល្អដែលគួរឲ្យកត់សម្គាល់គឺថា អត្រាចុះឈ្មោះចូលរៀនមានការកើនឡើងសម្រាប់ក្រុមអាយុកាន់តែខ្ពស់ ដោយអត្រាចុះឈ្មោះចូលរៀនក្នុងចំណោមក្មេងជំទង់អាយុពី១០ ដល់១៤ឆ្នាំ តាមសាលារៀនក្នុងប្រព័ន្ធ គឺមានរហូតដល់ ៨៥ ភាគរយ។ អត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រីគឺខ្ពស់ជាងក្មេងប្រុស។ លើសពីនេះ ក្នុងចំណោមក្មេងជំទង់ដែលរៀនតាមសាលារៀនបច្ចុប្បន្ននេះ ៩៥,២ ភាគរយ កំពុងរៀននៅសាលារៀនរដ្ឋ ហើយសល់ពីនោះគឺរៀននៅសាលាឯកជន។

**រូបភាពទី២៨៖** **ស្ថិតិនៃការចុះឈ្មោះចូលរៀនរបស់ក្មេងជំទង់អាយុពី១០ ដល់១៤ឆ្នាំ**



ការវិភាគលើមូលហេតុដែលនាំឲ្យពុំមានការចុះឈ្មោះចូលរៀន បង្ហាញថា ក្នុងចំណោមឪពុកម្តាយ ដែលមិនបញ្ជូនកូនទៅសាលាមត្តេយ្យ ៣០,៣ ភាគរយ មិនគិតថា ការឲ្យកូនទៅរៀននៅសាលាមត្តេយ្យជារឿងសំខាន់នោះទេ។ ឪពុកម្តាយ ២៥,២ ភាគរយទៀត ដែលមិនបានបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យដែរនោះ ពុំបញ្ជូនកូន ដោយសារតែពួកគេមិនអាចរ៉ាប់រងចំណាយលើបង់ថ្លៃសាលាឯកជនបាន។ ឪពុកម្តាយប្រហែលជា ២៤,១ លើកឡើងថា កូនៗរបស់ពួកគេពុំមានសុខភាពល្អ ដូច្នេះមិនអាចទៅរៀនបានឡើយ។ ចុងក្រោយ ឪពុកម្តាយ ២០,៤ ភាគរយ រាយការណ៍ថា ពួកគេចង់បញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យដែរ ប៉ុន្តែពុំមានមធ្យោបាយរូបវន្ត ដើម្បីយកកូនទៅរៀន។

**រូបភាពទី២៩៖** **មូលហេតុដែលនាំឲ្យកុមារអាយុ៣ ដល់៥ឆ្នាំ មិនបានចូលរៀន**




លើសពីនេះ ក្នុងចំណោមឪពុកម្តាយក្មេងជំទង់ដែលមិនកំពុងរៀនក្នុងសាលាទាំងអស់ មាន ៥៤,៦ ភាគរយ លើកឡើងថា ពួកគេមានបំណងចង់បញ្ជូនកូនទៅសាលារៀនដែរ ប៉ុន្តែការសម្រេចចិត្តរបស់ពួកគេត្រូវជួបឧបសគ្គដោយសារតែធនធានហិរញ្ញវត្ថុមានកំណត់។ ពួកគេមួយចំនួនពុំមានធនធានហិរញ្ញវត្ថុ ដែលចាំបាច់សម្រាប់រ៉ាប់រងថ្លៃបញ្ជូនកូនទៅរៀននៅសាលាឯកជនឡើយ ហើយអ្នកខ្លះទៀតឲ្យកូនទៅធ្វើការ ដើម្បីរកចំណូលបន្ថែមឲ្យគ្រួសារ។ ឪពុកម្តាយប្រមាណជា ១០,៩ ភាគរយ លើកឡើងថា កូនរបស់ពួកគេមិនស្រួលខ្លួន និងមិនអាចទៅរៀនបានឡើយ។ ឪពុកម្តាយប្រមាណជា ៧,៣ ភាគរយ មិនបានយកកូនទៅចុះឈ្មោះចូលរៀនឡើយ ដោយសារតែគ្រួសារឧស្សាហ៍ធ្វើចំណាកស្រុក ដែលធ្វើឲ្យពួកគេពិបាកក្នុងការឲ្យកូនបន្តរៀនសូត្រ។ ចុងក្រោយ ឪពុកម្តាយប្រមាណជា ៥,៥ ភាគរយ លើកឡើងថា កូនៗរបស់ពួកគេពុំមានមធ្យោបាយរូបវន្ត ដើម្បីទៅសាលារៀនឡើយ។

**រូបភាពទី៣០៖** **មូលហេតុ ដែលនាំឲ្យកុមារក្នុងក្រុមអាយុ១០ ដល់១៤ឆ្នាំ មិនបានទៅរៀន**



ក្នុងចំណោមក្មេងជំទង់ដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រៅសាលា ៨៧,៥ ភាគរយ លើកឡើងថា ពួកគេធ្លាប់ទៅរៀនពីមុនដែរ។ ការខ្វះការយកចិត្តទុកដាក់ពីគ្រូ ក៏ដូចជាការតម្រូវឲ្យបង់ថ្លៃក្រៅផ្លូវការ ឬការផ្តល់ប្រាក់កាសដល់គ្រូ គឺជាឧបសគ្គចម្បងដែលរារាំងពួកគេក្នុងការបន្តការសិក្សា។ ដោយហេតុថាឪពុកម្តាយកំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រទៅហើយនោះ ពួកគេពុំមានលទ្ធភាពបង់ថ្លៃក្រៅផ្លូវការឡើយ។ ការពិភាក្សាជាមួយនឹងសមាជិកសហគមន៍បង្ហាញថា ជារឿយៗគ្រូយកចិត្តទុកដាក់ចំពោះសិស្សតែក្នុងពេលបង្រៀនគួរ ដែលពួកគេប្រមូលថ្លៃក្រៅផ្លូវការនេះតែប៉ុណ្ណោះ។ ដោយសារតែបញ្ហាបង់ប្រាក់ក្រៅផ្លូវការនេះ (ជារឿយៗ អស់រហូតដល់ ១០០០០ រៀលក្នុងមួយខែ) ក្មេងជំទង់មកពីគ្រួសារក្រីក្រច្រើនតែរៀនមិនទាន់គេ ហើយទីបំផុតក៏ត្រូវបោះបង់ចោលការសិក្សា។ ក្នុងចំណោមក្មេងជំទង់ដែលរៀននៅសាលាជាង៥៣ភាគរយ លើកឡើងថា ពួកគេត្រូវបង់ថ្លៃក្រៅផ្លូវការទៅឲ្យគ្រូ ហើយនេះគួរតែជាហេតុផលធំមួយ ដែលនាំឲ្យមានការព្រួយបារម្ភសម្រាប់អាជ្ញាធររដ្ឋាភិបាល។ លើសពីនេះ គួរកត់សម្គាល់ផងដែរថា គ្រូធ្វើបែបនេះដោយសម្អាងថា ប្រាក់ខែធម្មតារបស់គ្រូគឺមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារឡើយ។

**រូបភាពទី៣១៖ ការបោះបង់ចោលការសិក្សា គិតជាភាគរយនៃកុមារក្រៅសាលា**




ការវិភាគលើកម្រិតថ្នាក់ដែលសិស្សក្នុងវ័យផ្សេងៗកំពុងសិក្សាបង្ហាញថា ក្មេងជំទង់ភាគច្រើនដែលកំពុងរៀនក្នុងសាលារៀនក្នុងប្រព័ន្ធ គឺរៀននៅថ្នាក់ទាបជាងថ្នាក់ដែលអាយុរបស់គេគប្បីរៀន។ ចំណុចនេះអាចបកស្រាយបានថា មានក្មេងជំទង់ភាគច្រើនរៀនមិនទាន់គេ ហើយគួបផ្សំនឹងបញ្ហាហិរញ្ញវត្ថុ និងការខ្វះការលើកទឹកចិត្តដើម្បីរៀនជាមួយមិត្តភក្តិដែលវ័យក្មេងជាងខ្លួនផងនោះ នាំឲ្យកុមារទាំងនេះបោះបង់ចោលការសិក្សា។ និន្នាការនៃការរៀនលើសអាយុបែបនេះអាចកើតឡើងដោយសារកត្តាពីរយ៉ាង៖ ការចូលរៀនយឺត និងការឡើងថ្នាក់យឺត។ ការពិភាក្សាជាមួយក្មេងជំទង់បង្ហាញថា គ្រូយកចិត្តទុកដាក់ខ្លាំងលើសិស្សដែលរៀនពូកែ ហើយមិនសូវអើពើនឹងសិស្សដែលជួបការលំបាកក្នុងការសិក្សាឡើយ។ ការខ្វះការយកចិត្តទុកដាក់បែបនេះ គួបផ្សំជាមួយនឹងការពុំមានថ្នាក់បំប៉នបន្ថែមផង ជារឿយៗធ្វើឲ្យសិស្សរៀនមិនទាន់គេ និងត្រូវរៀនត្រួតថ្នាក់។ ការចូលរៀនយឺតធ្វើឲ្យសិស្សមិនអាចរៀនទាន់គេបាន ដោយសារតែពួកគេខ្វះចំណេះដឹងជាមូលដ្ឋាន។ លើសពីនេះ ការពុំមានប្រព័ន្ធសម្រាប់ធ្វើសមាហរណកម្ម ជារឿយៗនាំឲ្យមានការបញ្ចូលសិស្សដែលធ្លាប់បោះបង់ចោលការសិក្សា ទៅក្នុងថ្នាក់ដែលមិនសមស្របទៅនឹងសមត្ថភាពរៀនសូត្ររបស់ពួកគេ។

## តារាងទី១៖ របាយអាយុរបស់ក្មេងជំទង់ និងកម្រិតថ្នាក់ដែលពួកគេកំពុងសិក្សា

| អាយុ | ថ្នាក់ទី ១ | ថ្នាក់ទី ២ | ថ្នាក់ទី ៣ | ថ្នាក់ទី ៤ | ថ្នាក់ទី ៥ | ថ្នាក់ទី ៦ | ថ្នាក់ទី ៧ | ថ្នាក់ទី ៨ | ថ្នាក់ទី ៩ |
|---|---|---|---|---|---|---|---|---|---|
| ១០ឆ្នាំ | ១៧% | ២៦% | ៣១% | ២០% | ៧% | | | | |
| ១១ឆ្នាំ | ២% | ១៥% | ៣៤% | ២៦% | ២០% | ៣% | | | |
| ១២ឆ្នាំ | ៤% | ៩% | ១៥% | ២៩% | ១៦% | ២២% | ៤% | | |
| ១៣ឆ្នាំ | | ៣% | ១០% | ២២% | ១៧% | ៣៣% | ១២% | ៣% | |
| ១៤ឆ្នាំ | | | ១៤% | ១៤% | ២០% | ២០% | ១៧% | ១១% | ៣% |

រង្វាស់ពិតប្រាកដ សម្រាប់វាស់វែងការរៀនសូត្ររបស់សិស្សតាមសាលារៀនក្នុងប្រព័ន្ធ គឺមិនគិតត្រឹមការចុះឈ្មោះចូលរៀនប៉ុណ្ណោះទេ តែត្រូវមានការវាយតម្លៃថាតើពួកគេមករៀនញឹកញាប់កម្រិតណាថែមទៀត។ ក្មេងជំទង់ប្រមាណជា ១១,៦ ភាគរយ ពុំបានមករៀនទៀងទាត់ឡើយ។ ក្នុងចំណោមក្មេងជំទង់ដែលពុំបានទៅរៀនទៀងទាត់ ប្រហែលជា ៤១,៧ ភាគរយ លើកឡើងថា មានថ្ងៃខ្លះ ពួកគេមិនបានទៅរៀន ព្រោះត្រូវទៅធ្វើការងារ ដើម្បីជួយរកចំណូលឲ្យគ្រួសារ។ ក្មេងជំទង់ ៣០,៦ ភាគរយទៀត មានបញ្ហាសុខភាពដែលធ្វើឲ្យពួកគេមិនអាចទៅរៀនជាទៀងទាត់បាន។ ក្រៅពីនេះមានករណីដែលក្មេងជំទង់ (ប្រមាណជា ១៧ ភាគរយ) រស់នៅឆ្ងាយពីសាលារៀន ហើយច្រើនតែមិនបានទៅរៀនទៀងទាត់ដែរ ដោយសារតែមានថ្ងៃខ្លះពួកគេមិនចង់ធ្វើដំណើរទៅសាលារៀន។ ចុងក្រោយ ក្មេងជំទង់ ១១,១ ភាគរយ លើកឡើងថា ពួកគេព្យាយាមគេចពីសាលា ដោយសារចេះតែមានការរករឿងឈ្លោះពីមិត្តភក្តិ ឬត្រូវបានគ្រូរបស់ពួកគេតែចាប់កំហុសញឹកញាប់ជាដើម។

## រូបភាពទី៣២៖ មូលហេតុដែលនាំឲ្យកុមារក្នុងក្រុមអាយុ១០ ដល់១៤ឆ្នាំ មិនបានទៅរៀន



# ពិការភាព និងការទទួលបានការអប់រំ

សាលារៀនអាចបំពេញតួនាទីសំខាន់ ក្នុងការគាំទ្រដល់ការទទួលបានការអប់រំរបស់កុមារមានពិការភាពរួមជាមួយនឹងកុមារផ្សេងទៀត។ សាលារៀនអាចផ្តល់ឲ្យកុមារ និងក្មេងជំទង់មានពិការភាព នូវបរិយាកាសមួយដែលពួកគេអាចចូលរួម និងទំនាក់ទំនងជាមួយកុមារផ្សេងៗទៀត និងទទួលបានឱកាសប្រកបដោយសមធម៌ដើម្បីបន្តការរៀនសូត្រទៅកម្រិតថ្នាក់កាន់តែខ្ពស់ ដែលនេះអាចឲ្យពួកគេមានឱកាសប្រកបរបរចិញ្ចឹមជីវិត និងមានភាពម្ចាស់ការខាងហិរញ្ញវត្ថុក្នុងជីវិត។ ក្នុងចំណោមកុមារ និងក្មេងជំទង់ទាំងអស់ ដែលត្រូវបានបញ្ចូលក្នុងសំណាកនៃការសិក្សានេះ មានកុមារ ៥,៣ ភាគរយ និងក្មេងជំទង់ ៥,៤ ភាគរយ ជាជនមានពិការភាព។ ក្នុងចំណោមតួលេខនេះ កុមារពិការប្រមាណជា ៥៩,១ ភាគរយ ពុំបានរៀននៅសាលារៀនណាឡើយ។ តួលេខសម្រាប់ក្មេងជំទង់វិញគឺ ២៨,៦ ភាគរយ។ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូ និងការពិភាក្សាក្រុមគោលដៅជាមួយសមាជិកសហគមន៍បង្ហាញថា កុមារនៅក្រៅសាលា សូម្បីតែក្រោយពេលឈានដល់វ័យជំទង់ហើយក្តី ភាគច្រើនជាករណីកម្សោយចលករធុនធ្ងរ ឬកម្សោយខាងបញ្ញា។

**រូបភាពទី៣៣៖ អត្រានៃការសិក្សារបស់កុមារ និងក្មេងជំទង់មានពិការភាព**




លើសពីនេះ ក្នុងចំណោមក្មេងជំទង់មានពិការភាពដែលកំពុងនៅក្រៅសាលាបច្ចុប្បន្ននេះ ៣៦,៤ ភាគរយ មិនដែលបានរៀនឡើយ ដូច្នេះពួកគេទំនងជាខ្វះបំណិនលេខអក្សរជាមូលដ្ឋាន។ ក្មេងជំទង់ពិការដែលកំពុងនៅក្រៅសាលា ៦៣,៦ ភាគរយទៀត ធ្លាប់បោះបង់ចោលការសិក្សា បន្ទាប់ពីបានចុះឈ្មោះចូលរៀនរួច។

**រូបភាពទី៣៤៖ ស្ថានភាពនៃការសិក្សាកន្លងមករបស់ក្មេងជំទង់មានពិការភាពដែលបច្ចុប្បន្នកំពុងនៅក្រៅសាលា**



សម្ភាសន៍ពាក់កណ្ដាលរចនាសម្ព័ន្ធជាមួយលោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀនតាមសាលារៀន បង្ហាញថា សិស្សមានពិការភាពភាគច្រើនដែលកំពុងរៀនតាមសាលា គឺរៀននៅកម្រិតថ្នាក់មិនស្របតាមអាយុរបស់ពួកគេទេ។ នេះបង្ហាញយ៉ាងច្បាស់ថា ឪពុកម្ដាយច្រើនតែពន្យារពេលការចុះឈ្មោះចូលរៀនរបស់កុមារមានពិការភាព។ ការពិភាក្សាក្រុមគោលដៅជាមួយសហគមន៍ក៏ទទួលបានព័ត៌មានដូចខាងលើនេះដែរ។ ឪពុកម្ដាយលើកឡើងថា ពួកគេច្រើនតែបង្អែបង្អង់ការចុះឈ្មោះចូលរៀនរបស់កូនៗ ដោយសារតែគេចង់រង់ចាំរហូតដល់ពេលដែលកុមារអាចគ្រប់គ្រងខ្លួនឯងបានដោយឯករាជ្យពេលនៅសាលារៀនសិន។ ពួកគេមានការព្រួយបារម្ភបែបនេះគឺដោយសារតែសាលារៀន ដែលស្ថិតនៅក្នុងនិងជុំវិញសហគមន៍ក្រីក្រក្រុងភ្នំពេញ ខ្វះហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារ សម្រាប់គាំទ្រដល់តម្រូវការរបស់សិស្សដែលមានកម្សោយខាងចលករ ខ្សោយគំហើញ និងខ្សោយបញ្ញា។ សម្រាប់សិស្សដែលខ្សោយគំហើញ ការពិភាក្សាក្រុមគោលដៅជាមួយនឹងសមាជិកសហគមន៍បង្ហាញថា សាលារៀនភាគច្រើនពុំមានសៀវភៅអក្សរស្ទាប និងសៀវភៅដែលមានអក្សរធំៗឡើយ។ ប៉ុន្តែ មានករណីលើកលែងដែរ ហើយការពិភាក្សាជាមួយនឹងក្មេងជំទង់បង្ហាញថា យ៉ាងហោចណាស់ ក្នុងខណ្ឌសែនសុខ កុមារខ្សោយគំហើញអាចបានទៅរៀននៅសាលាដែលប្រើសៀវភៅអក្សរស្ទាប ហើយគ្រូក៏ចេះបង្រៀនដោយប្រើអក្សរស្ទាបនេះផងដែរ។

**រូបភាពទី៣៥៖ ការយល់ឃើញរបស់ឪពុកម្ដាយអំពីភាពគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធ/បរិក្ខារក្នុងសាលារៀនសម្រាប់សិស្សមានពិការភាព**




# គុណភាពនៃការអប់រំ

ការពិភាក្សាជាមួយនឹងឪពុកម្ដាយក្មេងជំទង់បង្ហាញថា ពួកគេភាគច្រើនពេញចិត្តនឹងកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធដែលមាននៅតាមសាលារៀនរបស់កូនពួកគេ។ សាលារៀនរបស់រដ្ឋមានកន្លែងគ្រប់គ្រាន់ ដើម្បីទទួលសិស្សមានកន្លែងផ្ដល់ទឹកផឹក និងបរិក្ខារអនាម័យផងដែរ។ ឪពុកម្ដាយប្រមាណជា ៨១,៤ ភាគរយ គិតថា សាលារៀនផ្ដល់នូវបរិយាកាសដែលមានសុវត្ថិភាព និងសន្តិសុខសម្រាប់កូនរបស់គេ ហើយកូនៗរបស់ពួកគេក៏ទទួលបានការមើលថែពីគ្រូផងដែរ បើទោះបីជាការរករឿងឈ្លោះនៅតែជាមូលហេតុមួយ ក្នុងចំណោមមូលហេតុចម្បងៗដែលនាំឲ្យសិស្សបោះបង់ចោលការសិក្សាក៏ដោយ។ ចំណុចនេះក៏បង្ហាញឲ្យឃើញពីកង្វះការយល់ដឹងរបស់ឪពុកម្ដាយឬអាណាព្យាបាលអំពីបញ្ហានេះ និងតួនាទីដែលសាលារៀន និងគ្រូអាចបំពេញ ដើម្បីទប់ស្កាត់មិនឲ្យមានករណីរករឿងឈ្លោះកើតឡើង។ តែទោះជាយ៉ាងណាក៏ដោយ ការពិភាក្សាក្រុមគោលដៅជាមួយសមាជិកសហគមន៍ បានបង្ហាញថា គេមិនគួរបកស្រាយការមានសមត្ថភាពសមស្រប ថាជាការបង្រៀនប្រកបដោយគុណភាពក្នុងថ្នាក់រៀននោះទេ។ ដូចលើកឡើងខាងដើមហើយថា ការយកចិត្តទុកដាក់របស់គ្រូបង្រៀនក្នុងការបង្រៀនក្នុងថ្នាក់នៅមានកម្រិត ហើយបានប្រើប្រាស់ជំនាញរបស់ខ្លួន ដើម្បីបង្រៀនគួរ ដែលពួកគាត់អាចរកប្រាក់ចំណូលពីម៉ោងបង្រៀនក្រៅផ្លូវការវិញ។ ដូច្នេះ គុណភាពនៃការអប់រំតាមថ្នាក់រៀនធម្មតា គឺនៅ

មានគុណភាពទាបនៅឡើយ។ តំណាងអង្គការសង្គមស៊ីវិល ដែលធ្វើការងារជាមួយនឹងសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញក៏យល់ឃើញដូចគ្នាត្រង់ចំណុចនេះ។

**រូបភាពទី៣៦៖ កម្រិតនៃការពេញចិត្តរបស់ឪពុកម្តាយជាមួយហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន សុវត្ថិភាព និងសមត្ថភាពរបស់គ្រូ**




ខណ:ដែលការពុំមានហេដ្ឋារចនាសម្ព័ន្ធសមស្រប គឺជាឧបសគ្គមួយដល់ការរៀនសូត្រ ការខ្វះគ្រូបង្រៀនដែលមានជំនាញធ្វើការជាមួយកុមារមានពិការភាព គឺជាឧបសគ្គធំជាងគេ ដែលរារាំងមិនឲ្យកុមារអាចទៅរៀនតាមសាលារៀនក្នុងប្រព័ន្ធបានឬទទួលបានការអប់រំ។ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូបង្រៀនតាមសាលារដ្ឋ ក្នុងនិងជុំវិញសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ បង្ហាញថា ពួកគេទទួលបានការបណ្តុះបណ្តាលតិចតួចបំផុត ឬពុំបានទទួលការបណ្តុះបណ្តាលសោះតែម្តងអំពីរបៀបធ្វើការជាមួយសិស្សមានពិការភាព។ បន្ទប់រៀនរបស់ពួកគេខ្វះសម្ភារឧបទ្ទេស និងឧបករណ៍សម្រាប់បង្រៀនជាមូលដ្ឋានដែលចាំបាច់សម្រាប់បង្រៀនកុមារទាំងនេះ។ គេអាចសង្ខេបសមត្ថភាពរបស់គ្រូ ក្នុងការធ្វើការងារជាមួយនឹងកុមារមានពិការភាព តាមរយ:លទ្ធផលរកឃើញដូចតទៅ៖ ឪពុកម្តាយដែលមានកូនជាកុមារពិការ ៧៧,៨ ភាគរយ និងឪពុកម្តាយដែលមានកូនជាក្មេងជំទង់ពិការ ៨១,៩ ភាគរយ យល់ថា គ្រូដែលបង្ហាត់កូនរបស់ពួកគេពុំមានជំនាញ ដែលចាំបាច់សម្រាប់បំពេញតម្រូវការនៃការអប់រំកូនរបស់ពួកគេបានឡើយ។

**រូបភាពទី៣៧៖ ការយល់ឃើញរបស់ឪពុកម្តាយអំពីសមត្ថភាពរបស់គ្រូក្នុងការបំពេញទៅតាមតម្រូវការនៃការរៀនសូត្រនៃសិស្សពិការ**



ការអប់រំសម្រាប់ទាំងអស់គ្នា តម្រូវឲ្យសិស្សទាំងអស់ចូលរួមកាន់តែច្រើនក្នុងការអប់រំ រាប់ទាំងកុមារមកពីជនជាតិភាគតិច ក្មេងស្រី និងកុមារមានពិការភាពផងដែរ។ បរិយាប័ន្នតម្រូវឲ្យមានការរៀបចំប្រព័ន្ធ វិធីសាស្រ្តនិងការអនុវត្តឡើងវិញ ហើយក្នុងពេលជាមួយគ្នា ត្រូវមានការទទួលយកលក្ខណៈខុសៗគ្នារបស់សិស្សានុសិស្សដើម្បីលើកទឹកចិត្តកុមារដែលមានប្រវត្តិសាវតារខុសៗគ្នាឲ្យបន្តការអប់រំរបស់ខ្លួន។ ក្នុងករណីសិស្សពិការជំហានទីមួយក្នុងដំណើរការរៀបចំប្រព័ន្ធឡើងវិញនេះគឺពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍសមត្ថភាព និងការបង្កើតហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែសម្ភាសន៍ពាក់កណ្តាលអាណត្តិជាមួយអ្នកគ្រប់គ្រង និងគ្រូបង្រៀននៅតាមសាលារដ្ឋ បង្ហាញពីការយល់ដឹងតិចតួចអំពី "ការអប់រំសម្រាប់ទាំងអស់គ្នា" (បរិយាប័ន្ន)។ ពួកគេមានការយល់ឃើញខុសៗគ្នាអំពីគំរូនៃការអប់រំ ដែលគួរយកមកប្រើប្រាស់ ដើម្បីបំពេញទៅតាមតម្រូវការនៃការអប់រំរបស់កុមារពិការ។ ពួកគេមួយចំនួនគិតថា កុមារពិការគួរត្រូវបានបង្រៀនក្នុងសាលារៀនដោយឡែក អ្នកខ្លះទៀតគិតថា ពួកគេគួរបង្រៀនក្នុងបន្ទប់រៀនដោយឡែក ក្នុងសាលារៀនធម្មតា ប៉ុន្តែអ្នកផ្សេងទៀតគិតថាល្អបំផុតគួរបង្រៀនពួកគេក្នុងបន្ទប់រៀនតែមួយជាមួយនឹងកុមារផ្សេងទៀតដែរ។ ចំណុចនេះបង្ហាញយ៉ាងច្បាស់ពីភាពចាំបាច់មួយចំនួន គឺដំបូងត្រូវបង្កើតបែបផែនគំរូនៃការបង្រៀនកុមារមានពិការភាព ហើយបន្ទាប់មកត្រូវផ្សព្វផ្សាយពីគំរូនេះឲ្យបានច្បាស់លាស់ ដោយបញ្ជាក់ថា នេះគឺជាគំរូដែលរដ្ឋនឹងប្រើប្រាស់ ដើម្បីបំពេញតម្រូវការនៃការអប់រំរបស់កុមារមានពិការភាព។ ការបញ្ជាក់ឲ្យបានច្បាស់លាស់បែបនេះគឺមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការរៀបចំផែនការនាពេលអនាគតក្នុងការបណ្តុះបណ្តាលគ្រូ និងបង្កើតហេដ្ឋារចនាសម្ព័ន្ធនានា។

## ការចូលរួមរបស់ឪពុកម្តាយក្នុងការអប់រំកូន

លទ្ធផលសិក្សារបស់សិស្សគឺទទួលឥទ្ធិពលពីកត្តានៅសាលារៀនផង និងកត្តាគ្រួសារផង។ ការចូលរួមរបស់ឪពុកម្តាយក្នុងការអប់រំរបស់កូន នឹងជួយឲ្យកូនទទួលបានការគាំទ្រដែលពួកគេត្រូវការពីក្រុមគ្រួសារដើម្បីបន្តការអប់រំនៅកម្រិតថ្នាក់កាន់តែខ្ពស់។ ការរួមចំណែករបស់ឪពុកម្តាយកាន់តែចាំបាច់ថែមទៀត ក្នុងករណីគ្រួសារដែលមានប្រាក់ចំណូលទាប ព្រោះគេត្រូវរៀបចំផែនការប្រើប្រាស់ធនធានហិរញ្ញវត្ថុស្តួចស្តើងរបស់ខ្លួនដោយប្រុងប្រយ័ត្ន។ ពួកគេកាន់តែត្រូវយកធនធានដែលពួកគេមាន ទៅប្រើប្រាស់សម្រាប់ការអប់រំរបស់កូន ប្រសិនបើពួកគេឃើញកូនរៀនបានពូកែនិងរីកច្រើនក្នុងល្បឿនមួយសមស្រប។ ពួកគេក៏អាចបំពេញតួនាទីសំខាន់ ដើម្បីឲ្យកូនអាចទៅរៀនបានទៀងទាត់ និងធានាយ៉ាងណាឲ្យកូនមានពេលវេលាបន្ថែម សម្រាប់រំឭកមេរៀនឡើងវិញ (នៅផ្ទះ)។ ក្នុងន័យនេះ ការប្រាស្រ័យទាក់ទងជាប្រចាំរវាងឪពុកម្តាយនិងគ្រូ ក៏មានតួនាទីសំខាន់ ដើម្បីជំរុញឲ្យមានការចូលរួមពីឪពុកម្តាយក្នុងការតាមដានលទ្ធផលសិក្សារបស់កូនផងដែរ។ ប៉ុន្តែ មានសាលាមត្តេយ្យរដ្ឋត្រឹមតែ ៤៧,៥ ភាគរយ និងសាលារៀនរដ្ឋ ៥០ ភាគរយ ប៉ុណ្ណោះដែលបានរៀបចំវេទិកាឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងឪពុកម្តាយ និងគ្រូនោះ។

ចំណុចគួរឲ្យកត់សម្គាល់គឺថា ក្នុងករណីដែលសាលារៀនរៀបចំឲ្យមានការប្រាស្រ័យទាក់ទងគ្នាបែបនេះ ឪពុកម្តាយកុមារ ៩០,៦ ភាគរយ និងឪពុកម្តាយក្មេងជំទង់ ៨៩,៦ ភាគរយ លើកឡើងថា ពួកគេបានចូលរួមក្នុងកិច្ចប្រជុំរវាងឪពុកម្តាយ និងគ្រូ។ ពួកគេនិយាយថា កិច្ចប្រជុំទាំងនេះមានប្រយោជន៍ខ្លាំង ដោយពួកគេបានយល់ច្បាស់ពីលទ្ធផលរៀនសូត្ររបស់កូនៗពួកគេ។ ការចូលរួមយ៉ាងសស្រាក់សស្រាំបែបនេះបង្ហាញថា គ្រួសារដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុង មានសេចក្តីប៉ងប្រាថ្នាខ្ពស់សម្រាប់ការរៀនសូត្រ ឬលទ្ធផលសិក្សារបស់កូនៗពួកគេ។ កម្រិតវប្បធម៌ផ្ទាល់របស់ឪពុកម្តាយហាក់ពុំមានអ្វីពាក់ព័ន្ធនឹងការសម្រេចចិត្តបញ្ជូនកូនទៅរៀនឡើយ។ ប៉ុន្តែដូចបញ្ជាក់ខាងដើមហើយថា ការលំបាកខាងសេដ្ឋកិច្ចច្រើនតែបង្ខំឲ្យពួកគេដកកូនៗគេចេញពីសាលារៀនវិញ។

# ការរករឿងឈ្លោះក្នុងសាលារៀន

ការប្រមូលទិន្នន័យតាមរយៈកម្រងសំណួរជាមួយក្មេងជំទង់មកពីសហគមន៍ក្រីក្រក្នុងទីក្រុង បង្ហាញថា ក្នុងចំណោមសិស្ស ៤នាក់ គឺមាន ១នាក់ ដែលទទួលរងការរករឿងឈ្លោះក្នុងសាលារៀន។ ក្មេងជំទង់ក៏បានលើកឡើងផងដែរថា ជាធម្មតា ពួកគេច្រើនរក្សាភាពស្ងៀមស្ងាត់អំពីបញ្ហានេះ ហើយត្រូវប្រឈមជាមួយនឹងការសម្លុតគំរាមនេះ ជាមួយនឹងទឹកមុខប្រកបដោយភាពក្លាហាន។ ប៉ុន្តែ ប្រសិនបើស្ថានភាពចាប់ផ្តើមអាក្រក់ទៅៗ ពួកគេអាចទៅប្រាប់គ្រូផ្ទាល់ ឬប្រាប់ឪពុកម្តាយរបស់ខ្លួនដែលនឹងយករឿងនេះមកនិយាយជាមួយគ្រូ។ ការពិភាក្សាជាមួយគ្រូបង្រៀនបង្ហាញថា សាលារៀនច្រើនឆ្លើយតបចំពោះករណីបែបនេះខុសៗគ្នា។ ក្នុងករណីដែលពួកគេចាត់ទុកថាការរករឿងឈ្លោះនេះកើតមានតែម្តង ហើយជារឿងតូចតាច ពួកគេនឹងមិនធ្វើអន្តរាគមន៍ឡើយ។ ការសម្រេចចិត្តបែបនេះធ្វើឡើងដោយសម្អាងលើហេតុផលដែលថា ករណីបែនេះគឺជាផ្នែកមួយនៃដំណើរផ្លូវរបស់កុមារ ក្នុងការឈានទៅរកវ័យជំទង់ និងវ័យផ្សេងទៀត។ ប៉ុន្តែ គ្រូបង្រៀនភាគច្រើនបានលើកឡើងថា ពួកគេចាត់ទុកករណីនេះជាការព្រួយបារម្ភធ្ងន់ធ្ងរ និងធ្វើអន្តរាគមន៍ ដោយហៅជនរងគ្រោះ និងជនប្រព្រឹត្តចូលទីចាត់ការរបស់នាយកសាលា។ ភាគីទាំងពីរនឹងត្រូវស្នើឲ្យរៀបរាប់ពីរឿងរ៉ាវដែលបានកើតឡើង ហើយផ្អែកទៅតាមការវិភាគរបស់ខ្លួន នាយកសាលានឹងដោះស្រាយជាមួយភាគីប្រព្រឹត្តដោយផ្ទាល់។ ប៉ុន្តែ ប្រសិនបើមានការគិតឃើញថា ភាគីប្រព្រឹត្តមិនឆ្លើយតបចំពោះវិធានការបឋមនេះទេ គណៈគ្រប់គ្រងសាលារៀននឹងហៅឪពុកម្តាយរបស់គាត់មកសាលារៀនដើម្បីជជែកគ្នាផ្ទាល់។ ការពិភាក្សាជាមួយគ្រូបង្រៀនបង្ហាញថា ជាធម្មតា ការហៅឪពុកម្តាយមកគឺគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហានេះ។ ក្នុងករណីដែលស្ថានភាពមិនបានកែលម្អ ហើយសកម្មភាពរបស់អ្នកប្រព្រឹត្តកាន់តែអាក្រក់ទៅៗ ជាធម្មតាគណៈគ្រប់គ្រងសាលារៀនតែងប្រាប់ឲ្យឪពុកម្តាយរបស់សិស្សដែលរងគ្រោះឲ្យប្តឹងនគរបាល។

គ្រូពុំបានផ្តល់ឲ្យជនរងគ្រោះនូវការគាំទ្រ ឬការផ្តល់ប្រឹក្សាអ្វីឡើយ ដោយសារតែពួកគេពុំបានទទួលការបណ្តុះបណ្តាលអំពីរបៀបធ្វើការឆ្លើយតបបែបនេះឡើយ។ លើសពីនេះ ពួកគេក៏មិនបានទទួលឯកសារ ឬការណែនាំអ្វី ដែលគេអាចយកមកប្រើប្រាស់ ដើម្បីបង្រៀនសិស្សពីប្រធានបទនេះដែរ។ ពួកគេគិតថា បញ្ហានេះមួយផ្នែកកើតឡើងដោយសារតែសិស្សដែលរៀននៅសាលារៀនរបស់ពួកគាត់ ភាគច្រើនមកពីតំបន់នៅកៀកទីនោះ និងជាអ្នកមកពីសហគមន៍តែមួយ។ ជាលទ្ធផល ការរករឿងឈ្លោះក្នុងសាលារៀន ជារឿយៗ អាចរាលដាលចេញពីករណីរករឿងឈ្លោះដែលកើតមានក្នុងផ្ទះ ឬក្នុងសហគមន៍។

**រូបភាពទី៣៨៖ ភាគរយនៃក្មេងជំទង់ដែលរាយការណ៍ថាធ្លាប់ត្រូវបានគេរករឿងឈ្លោះក្នុងសាលារៀន**



បើតាមការលើកឡើងដោយក្មេងជំទង់ ៤១,៨% ក្នុងចំណោមក្មេងជំទង់ដែលទៅរៀន អ្នកដែលរងគ្រោះដោយសារការរករឿងឈ្លោះក្នុងសាលារៀនបែបនេះជាធម្មតា គឺជាកុមារពិការកាយសម្បទា ឬខ្សោយបញ្ញា។ សិស្ស ២៥,៣ ភាគរយទៀតគិតថា ជាធម្មតាករណីទាំងនេះពាក់ព័ន្ធនឹងសាវតារសង្គមសេដ្ឋកិច្ចរបស់ជនរងគ្រោះ៖ សិស្ស ១៧,៧ ភាគរយ គិតថាជាធម្មតាករណីទាំងនេះកើតឡើងដោយសារតែមានការរើសអើងជាតិសាសន៍ ហើយ ១៥,២ ភាគរយទៀតគិតថា ករណីទាំងនេះកើតឡើងដោយសារការរើសអើងយេនឌ័រ ឬដោយសារតែទំនាក់ទំនងអំណាចយេនឌ័រមិនស្មើភាពគ្នារវាងក្មេងប្រុស និងក្មេងស្រី។

**រូបភាពទី៣៩៖ ការយល់ឃើញរបស់សិស្សពីមូលហេតុដែលករណីរករឿងឈ្លោះកើតមានឡើង**




ការពិភាក្សាក្រុមគោលដៅជាមួយឪពុកម្តាយបង្ហាញថា ជាធម្មតា ពួកគេចាត់ទុកការរករឿងឈ្លោះថាជា "ការប៉ះពាល់រាងកាយ"។ តែពួកគេមិនយល់ស្របចំពោះករណីបែបនេះឡើយ។ លើសពីនេះ ពួកគេមិនចាត់ទុកករណីលេបខាយផ្លូវភេទ និង/ឬការនិយាយចំអែចំអន់ថាជាការរករឿងឈ្លោះឡើយ ដោយចាត់ទុកករណីបែបនេះថាជាករណីធ្ងន់ធ្ងរ ដែលត្រូវមានវិធានការពីនគរបាល។ ប៉ុន្តែ ដូចអ្នកគ្រប់គ្រងសាលា និងគ្រូបង្រៀនដែរ ឪពុកម្តាយមានការយល់ដឹងតិចតួចពីការរករឿងឈ្លោះដែលកើតឡើងក្នុងរូបភាពជាការបំពារបំពានផ្លូវចិត្ត។ ពួកគេចាត់ទុកការដាក់ឈ្មោះហៅក្រៅ ការធ្វើត្រាប់តាមឥរិយាបថ ឬការផាត់ចេញពីក្រុមណាមួយក្នុងសង្គម ថាជារឿងតូចតាច។

ក្នុងពេលជាមួយគ្នានេះដែរ ក្មេងជំទង់មានពិការភាពប្រហែលជា ៩០ ភាគរយ រាយការណ៍ថា ពួកគេតែងត្រូវបានគេរករឿងឈ្លោះជាប្រចាំក្នុងសាលារៀន។ ការពិភាក្សាក្រុមគោលដៅជាមួយនឹងកុមារមួយចំនួនបង្ហាញថា សិស្សផ្សេងទៀតក្នុងសាលារបស់គេក៏ដាក់ឈ្មោះហៅក្រៅឲ្យពួកគេ និងធ្វើត្រាប់តាមពិការភាព ឬសកម្មភាពរបស់កុមារពិការផងដែរ។ មានករណីដែលកុមារទាំងនេះត្រូវបានមិត្តរួមថ្នាក់របស់គេជ្រើសរើសដើម្បីយកមកធ្វើបាបរាងកាយផងដែរ។ ពួកគេគិតថា មូលហេតុចម្បងដែលគេធ្វើបែបនេះ ដោយសារតែកុមារពិការទាំងនេះមានលទ្ធភាពតិចតួចក្នុងការឆ្លើយតប ឬតបតវិញ។ គណៈគ្រប់គ្រងសាលារៀន និងគ្រូមានតួនាទីសំខាន់ ដើម្បីពិនិត្យលើករណីទាំងនេះ។ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូបង្រៀនបង្ហាញថា ពួកគេក៏បានដឹងពីករណីទាំងនេះដែរ ហើយពួកគេជាច្រើននាក់បានលើកឡើងថា ពួកគេក៏បានប្រឹងប្រែងឃ្លាំមើលសិស្សរបស់ខ្លួនដែរ។ ប៉ុន្តែ ពួកគេគិតថា បញ្ហានេះអាចដោះស្រាយបានតែតាមរយៈការរៀបចំឲ្យមានយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដើម្បីបង្កើនការយល់ដឹងដល់សិស្សានុសិស្សអំពីបញ្ហានេះតែប៉ុណ្ណោះ។

**រូបភាពទី៤០៖** **ករណីរករឿងឈ្លោះក្នុងសាលារៀន ទៅតាមការលើកឡើងរបស់ក្មេងជំទង់ពិការ**




## ការដាក់ទណ្ឌកម្មលើរាងកាយតាមសាលារៀន

បើតាមច្បាប់ស្តីពីការអប់រំ (ឆ្នាំ២០០៧) ការដាក់ទណ្ឌកម្មរាងកាយត្រូវបានហាមឃាត់នៅតាមសាលារៀនរដ្ឋ និងសាលារៀនឯកជន។ ប៉ុន្តែ ការប្រើប្រាស់ទណ្ឌកម្មរាងកាយជាមធ្យោបាយ ដើម្បីដាក់វិន័យកូន នៅតែបន្តកើតមានជាទូទៅ ហើយក្នុងករណីជាច្រើន ឪពុកម្តាយ និងសមាជិកសហគមន៍ក៏ទទួលយក និងលើកទឹកចិត្តឲ្យមានការដាក់ទណ្ឌកម្មរាងកាយលើកូនរបស់ពួកគេផងដែរ។ ក្មេងជំទង់ទៅសាលារៀនប្រមាណជា ៣០,៥ ភាគរយ លើកឡើងថា ពួកគេធ្លាប់ទទួលរងទណ្ឌកម្មរាងកាយ ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ។ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូបង្ហាញថា ពួកគេដឹងថាច្បាប់ហាមប្រាមមិនឲ្យដាក់ទណ្ឌកម្មរាងកាយទោះជាក្នុងទម្រង់ណាក៏ដោយ។ ពួកគេអះអាងថា ទណ្ឌកម្មបែបនេះលែងមានយូរមកហើយ។ ប៉ុន្តែ ការឆ្លើយតបពីក្មេងជំទង់ដែលទៅសាលារៀនបញ្ជាក់យ៉ាងច្បាស់ថា ការដឹងបែបនេះមិនមែនមានន័យថាជាការអនុវត្តឬការធ្វើជាក់ស្តែងនោះទេ។ លើសពីនេះ ការពិភាក្សាក្រុមគោលដៅជាមួយក្មេងជំទង់បង្ហាញថា គ្រូមិនត្រឹមតែប្រើប្រាស់ការដាក់ទណ្ឌកម្មរាងកាយជាវិធានការដាក់វិន័យប៉ុណ្ណោះទេ ពួកគាត់ក៏បានប្រើប្រាស់ទណ្ឌកម្មបែបនេះ ដើម្បីបង្ខំឲ្យសិស្សកែលម្អលទ្ធផលសិក្សាទៀតផង។ គ្រូមួយចំនួនហាក់បីដូចជានៅតែយល់ថា គេអាចកែលម្អលទ្ធផលនៃការរៀនសូត្រខ្សោយរបស់សិស្ស តាមរយៈការដាក់ទណ្ឌកម្មលើរាងកាយ (រួមនឹងការវាយដំលើរាងកាយរបស់កុមារផងដែរ)។ ការវិភាគទិន្នន័យបែងចែកទៅតាមប្រភេទសាលារៀនដែលអ្នកឆ្លើយតបកំពុងរៀន បង្ហាញថា ការដាក់ទណ្ឌកម្មលើរាងកាយមិនសូវជាកើតមានតាមសាលារៀនឯកជនឡើយ។ នេះអាចដោយសារតែគណៈគ្រប់គ្រងរបស់សាលារៀនឯកជនច្រើនតែយកចិត្តទុកដាក់គោរពទៅតាមច្បាប់ និងគោលការណ៍ណែនាំនានា ដែលកំពុងមានជាធរមាន។

**រូបភាពទី៤១៖** **ភាគរយនៃក្មេងជំទង់ទៅសាលារៀន ដែលរាយការណ៍ថាធ្លាប់ទទួលរងទណ្ឌកម្មលើរាងកាយ**



លើសពីនេះ ឪពុកម្តាយរបស់កុមារប្រហែលជា ១៩,៧ ភាគរយ និងឪពុកម្តាយរបស់ក្មេងជំទង់ប្រមាណជា ២២ ភាគរយ អនុញ្ញាតិឲ្យគ្រូប្រើប្រាស់ទណ្ឌកម្មលើរាងកាយ ជាមធ្យោបាយដាក់វិន័យលើកូនរបស់ពួកគេ។ ការដែលឪពុកម្តាយទទួលយកការដាក់ទណ្ឌកម្មលើរាងកាយក្នុងសាលារៀនបែបនេះ គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗក្នុងការផ្លាស់ប្តូរឥរិយាបថរបស់គ្រូដែលប្រើអំពើហិង្សាផ្លូវកាយជាមធ្យោបាយដាក់វិន័យសិស្សរបស់ខ្លួន។

**រូបភាពទី៤២៖ ការយល់ឃើញរបស់ឪពុកម្តាយចំពោះការដាក់ទណ្ឌកម្មរាងកាយ នៅតាមសាលារៀន**




ក្នុងចំណោមឪពុកម្តាយ ដែលយល់ថាការដាក់ទណ្ឌកម្មរាងកាយជាមធ្យោបាយដាក់វិន័យលើកុមារដែលមិនអាចទទួលយកបាន ៦០,៩ ភាគរយ លើកឡើងថា ពួកគេនឹងយកករណីនេះទៅនិយាយជាមួយអ្នកគ្រប់គ្រងសាលា។ ៨,៧ ភាគរយទៀត រាយការណ៍ថា ពួកគេចាត់ទុកការដាក់ទណ្ឌកម្មរាងកាយថាជា "បទល្មើស" ហើយនឹងរាយការណ៍ពីករណីបែបនេះទៅកាន់អាជ្ញាធរ។ ប៉ុន្តែ វាក៏ជារឿងដែលគួរឲ្យបារម្ភផងដែរ ដោយឪពុកម្តាយ ៣០,៤ ភាគរយ លើកឡើងថា ពួកគេនឹងមិនចាត់វិធានការផ្លូវការអ្វីឡើយ ដោយគ្រាន់តែសង្ឃឹមថា ករណីបែបនេះនឹងមិនកើតឡើងសាជាថ្មីនាពេលអនាគតឡើយ។ តួលេខសម្រាប់ឪពុកម្តាយរបស់ក្មេងជំទង់ គឺ ៥៧,១ ភាគរយ នឹងយកករណីនេះទៅនិយាយជាមួយអ្នកគ្រប់គ្រងសាលា ១១,៤ ភាគរយ ចាត់ទុកការដាក់ទណ្ឌកម្មរាងកាយថាជា "បទល្មើស" ហើយនឹងរាយការណ៍ពីករណីបែបនេះទៅកាន់អាជ្ញាធរ និង ៣១,៥ ភាគរយ នឹងមិនចាត់វិធានការផ្លូវការអ្វីឡើយ។ ក្នុងចំណោមឪពុកម្តាយដែលលើកឡើងថា ពួកគេនឹងមិនចាត់វិធានការអ្វីទាំងអស់មានការយល់ឃើញដូចៗគ្នាថា គ្រួសាររបស់ពួកគេស្ថិតក្នុងក្រុមជនជាតិភាគតិច និងមានស្ថានភាពសេដ្ឋកិច្ចខ្សត់ខ្សោយ បើធៀបជាមួយនឹងឋានៈក្នុងសង្គម និងសេដ្ឋកិច្ចនៃគ្រូរបស់កូនពួកគេ ដូច្នេះពួកគេមានការស្ទាក់ស្ទើរមិនចង់ទៅជួបគ្រូ ឬអ្នកគ្រប់គ្រងសាលា ដើម្បីពិភាក្សាពីបញ្ហានេះឡើយ។

**រូបភាពទី៤៣៖ ការឆ្លើយតបរបស់ឪពុកម្តាយចំពោះករណីទណ្ឌកម្មលើរាងកាយក្នុងសាលារៀន**



## ទំនាក់ទំនងរវាងសុខភាព និងការអប់រំ

ដូចលើកឡើងខាងលើ ក្មេងជំទង់រស់នៅក្នុងសហាគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញមានចំណេះដឹងតិចតួច អំពីសុខភាពនិងអនាម័យ និងអំពីសុខភាពផ្លូវភេទនិងបន្តពូជ។ ការពិភាក្សាពាក់កណ្តាលរចនាសម្ព័ន្ធជាមួយអង្គការសង្គមស៊ីវិល ជាពិសេស អង្គការមិត្តសំឡាញ់ និងមូលនិធិកុមារកម្ពុជា បង្ហាញថា ក្មេងជំទង់មានការយល់ដឹងតិចតួចបែបនេះ ដោយសារតែពួកគេមានលទ្ធភាពតិចតួច ក្នុងការទទួលបានព័ត៌មានដែលពាក់ព័ន្ធ។ សាលារៀនគឺជាកន្លែងផ្តល់ការរៀនសូត្រដែលអាចបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់លទ្ធភាពឲ្យក្មេងជំទង់អាចទទួលបានព័ត៌មានទាំងនេះ។ តាមរយៈការធ្វើសកម្មភាពលើសពីត្រឹមតែផ្តោតលើការសិក្សាសុទ្ធសាធ សាលារៀនអាចរួមចំណែកធ្វើឲ្យកុមារ/ក្មេងជំទង់អាចចម្រើនវ័យប្រកបដោយសុខភាពល្អ និងមានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ។ ការពិភាក្សាក្រុមគោលដៅជាមួយនឹងក្មេងជំទង់បង្ហាញថា វគ្គទាំងនេះភាគច្រើនផ្តោតតែលើរឿងអនាម័យ ហើយមានការផ្តោតការយកចិត្តទុកដាក់តិចតួចលើស្ថានភាពសុខភាពរបស់ក្មេងជំទង់ ឬលើការផ្តល់ព័ត៌មានដល់ពួកគេអំពីបញ្ហាពាក់ព័ន្ធនឹងរបបអាហារ/អាហារូបត្ថម្ភ។ លើសពីនេះក៏មានការកត់សម្គាល់ផងដែរថា មិនមែនក្មេងជំទង់ទាំងអស់សុទ្ធតែទទួលបានព័ត៌មានពាក់ព័ន្ធនឹងរឿងអនាម័យឡើយ។ ក្មេងជំទង់មួយចំនួនបានចូលរួមត្រឹមតែវគ្គបង្កើនការយល់ដឹងអំពីសុខភាព ដែលមានការពិភាក្សាអំពីសុខភាពមាត់ធ្មេញ ហើយមួយចំនួនទៀតបានចូលរួមត្រឹមតែវគ្គ ពីការលាងសម្អាតដៃ និងការអនុវត្តអនាម័យឲ្យបានត្រឹមត្រូវតែប៉ុណ្ណោះ។

**រូបភាពទី៤៤៖** **ភាគរយនៃក្មេងជំទង់ ដែលចូលរួមក្នុងវគ្គបង្កើនការយល់ដឹងអំពីសុខភាព និងអនាម័យតាមសាលារៀន**




ការសិក្សាថ្មីមួយ សន្និដ្ឋានថា មានមនុស្សជាច្រើនក្នុងប្រទេសកម្ពុជា រួមភេទជាលើកទីមួយ នៅពេលដែលពួកគេនៅជាក្មេងជំទង់។ ដោយសារតែរដ្ឋាភិបាលពុំបានកំណត់នីតិភាពសម្រាប់យល់ព្រមរួមភេទផងនោះ ចំណុចនេះបង្ហាញពីភាពចាំបាច់ ក្នុងការអប់រំក្មេងជំទង់អំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ ក្មេងជំទង់រៀនតាមសាលាប្រមាណជា ៤០,៩ ភាគរយលើកឡើងថា ពួកគេបានចូលរួមក្នុងវគ្គផ្សព្វផ្សាយអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ ប៉ុន្តែ គួរកត់សម្គាល់ថា ពួកគេតិចនាក់ប៉ុណ្ណោះដែលអាចចងចាំសារអប់រំសំខាន់ៗពីវគ្គទាំងនោះ។ ជាលទ្ធផល អាចសន្និដ្ឋានបានថា វគ្គផ្សព្វផ្សាយចំណេះដឹងភាគច្រើន ត្រូវបានរៀបចំក្នុងបែបបទមួយប៉ុណ្ណោះ ហើយគ្រាន់តែជាគំនិតផ្តួចផ្តើមដែលមានតែម្តងចប់ប៉ុណ្ណោះ។

[52] *ការអង្កេតក្នុងទីក្រុងភ្នំពេញឆ្នាំ២០១៤។*

**រូបភាពទី៤៥៖ ភាគរយនៃក្មេងជំទង់ ដែលចូលរួមក្នុងវគ្គផ្សព្វផ្សាយអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជតាមសាលារៀន**




## ការអប់រំ និងពលកម្មកុមារ

ការអប់រំត្រូវបានគេចាត់ទុកថាជាធាតុផ្សំដ៏សំខាន់មួយ សម្រាប់ជួយសង្គមត្រៀមរៀបចំកូនៗរបស់ខ្លួនឲ្យក្លាយជាមូលធនបញ្ញាញាណ និងក្លាយជាប្រជាពលរដ្ឋប្រកបដោយការទទួលខុសត្រូវ ដែលអាចរួមចំណែកដល់ការកសាងជាតិ សម្រេចបាននូវបរិយាប័ន្ន និងបន្តភាពជឿនលឿននាពេលអនាគត។ ការទទួលបានការអប់រំនៅមានកម្រិត មិនត្រឹមតែជាឧបសគ្គដែលបន្ទចបង្អាក់ដល់ភាពជឿនលឿនដូចលើកឡើងខាងលើនោះទេ ប៉ុន្តែវាក៏អាចរុញច្រានសង្គមឲ្យដើរថយក្រោយផងដែរ។ កុមារដែលទទួលបានការអប់រំតិចតួច ឬមិនបានទទួលការអប់រំសោះ អាចត្រូវបានគេរុញច្រានឲ្យចូលទៅក្នុងសកម្មភាព ដែលជាការប្រឆាំងទៅនឹងសង្គម ឬធ្វើឲ្យការលូតលាស់ និងការអភិវឌ្ឍជារួមដើរថយក្រោយមកវិញ។ លើសពីនេះ កុមារក្រៅសាលាដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ ប្រហែលជា ២០ ភាគរយ កំពុងប្រឡូកក្នុងទម្រង់ណាមួយនៃពលកម្មកុមារ។ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយអង្គការសង្គមស៊ីវិល ដែលធ្វើការងារជាមួយនឹងសហគមន៍ទាំងនេះបង្ហាញថា ភាគរយជាក់ស្តែងគួរខ្ពស់ជាងនេះឆ្ងាយ។ ជាទូទៅគេមិនសូវផ្តល់ព័ត៌មានពិតប្រាកដអំពីករណីពលកម្មកុមារនេះឡើយ ដោយសារតែគ្រួសារ និងក្មេងជំទង់ដឹងថា ពលកម្មកុមារគឺជាទង្វើខុសច្បាប់ ដូច្នេះ ពួកគេត្រូវធ្វើការងារ ដោយមិនឲ្យអាជ្ញាធរដឹង។ លើសពីនេះ ក្មេងជំទង់ជាច្រើននាក់កំពុងធ្វើការងារក្នុងអាជីវកម្មរបស់គ្រួសារ ឬជួយធ្វើការងារប្រចាំថ្ងៃឲ្យគ្រួសាររបស់ពួកគេ ដែលអាចចាត់ទុកថាជាការធ្វើការងារផងដែរ។

**រូបភាពទី៤៦៖ ភាគរយរបស់ក្មេងជំទង់ក្រៅសាលា ដែលប្រឡូកក្នុងពលកម្មកុមារ**



ការពិភាក្សាក្រុមគោលដៅជាមួយប្រធានសហគមន៍ និងចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍បង្ហាញថា ក្មេងជំទង់ភាគច្រើន ដែលជាសមាជិករបស់ក្រុមទំនើង ច្រើនតែជាក្មេងក្រៅសាលា។ គ្រួសាររបស់ពួកគេមានកម្រិតជីវភាពខ្សត់ខ្សោយ ដូច្នេះឪពុកម្តាយពួកគេពុំមានពេលវេលា សម្រាប់ឃុំគ្រងពួកគេឲ្យបានហ្មត់ចត់នោះឡើយ។ ការមិនត្រូវបានឪពុកម្តាយមើលថែដិតដល់នៅផ្ទះ ហើយមិនបានចូលរួមក្នុងសកម្មភាពនៅសាលារៀនផងនោះ ក្មេងជំទង់ទាំងនេះងាយនឹងចូលរួមក្នុងក្រុមទំនើង ឬប្រព្រឹត្តអំពើឆ្គាំឆ្គងក្នុងសង្គមផ្សេងទៀត ដូចជា ការលេងល្បែងស៊ីសង ការប្រើគ្រឿងស្រវឹង ឬការជក់បារីជាដើម។ សហគមន៍មិនដែលប្រឹងប្រែងធ្វើការងារជាមួយសាលារៀន និងធ្វើសកម្មភាពរួមគ្នាអ្វីមួយ ដើម្បីកែប្រែកុមារទាំងនេះឡើយ ដោយសារតែពួកគេគិតថាវាជារឿងបុគ្គល ឬជាបញ្ហារបស់គ្រួសារ។ យ៉ាងណាវិញ សហគមន៍មើលងាយក្មេងជំទង់ទាំងនេះ ហើយគ្រួសារផ្សេងទៀតព្យាយាមឲ្យកូនរបស់ពួកគេនៅឆ្ងាយពីអ្នកទាំងនោះ។ សមាជិកសហគមន៍យល់ថា ការបង្កើតទម្លាប់អាក្រក់គឺងាយ ប៉ុន្តែការច្រានចោលទម្លាប់បែបនេះ ឬការកែឥរិយាបថរបស់នរណាម្នាក់ គឺជារឿងដែលពិបាក។ ក្នុងពេលជាមួយគ្នា មានសមាជិកសហគមន៍តិចនាក់ប៉ុណ្ណោះដែលគិតថា ក្មេងជំទង់ទាំងនោះគប្បីទទួលបានការគាំទ្រផ្នែកប្រឹក្សានិង/ឬការគាំទ្រចិត្តសង្គម ក្នុងទម្រង់ផ្សេងទៀតនោះ។

របកគំហើញបែបគុណវិស័យនៃការសិក្សានេះ បង្ហាញឲ្យឃើញពីទំនាក់ទំនងរវាងសុខភាព និងការទទួលបានការអប់រំក្នុងសាលារៀន។ ដូចពិភាក្សាខាងលើ ក្នុងករណីភាគច្រើន កុមារដែលមានតម្រូវការពិសេសច្រើនមិនបានទទួលការអប់រំដូចគ្នានឹងកុមារទូទៅទេ ឬពុំបានរៀនស្របត្រក្នុងថ្នាក់រៀនស្របតាមអាយុរបស់ពួកគេឡើយ។ ការពិភាក្សាបន្ថែមទៀតក៏បង្ហាញផងដែរថា ករណីឈឺថ្កាត់មួយចំនួនធ្វើឲ្យកុមារអវត្តមានរយៈពេលយូរពីសាលារៀន ដែលពេលខ្លះ ធ្វើឲ្យកុមារបោះបង់ចោលការសិក្សាតែម្តង។ ប៉ុន្តែ មានឧទាហរណ៍តិចតួចប៉ុណ្ណោះ អំពីករណីទាំងនេះ។



# ស្ថានភាព
# គោលនយោបាយ
# និងកម្មវិធីបច្ចុប្បន្ន

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ ក្នុងសហគមន៍ក្រីក្រក្នុងរាជធានី

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ការដាក់ទណ្ឌកម្មរាងកាយ និងអំពើហិង្សាក្នុងគ្រួសារ

### ស្ថានភាពបច្ចុប្បន្ន៖

ឪពុកម្តាយរបស់កុមារ ឬក្មេងជំទង់ក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ ៦០ ភាគរយ បានលើកឡើងថា ពួកគេប្រើប្រាស់កម្លាំងបាយ (ទណ្ឌកម្មលើរាងកាយ) ដើម្បីដាក់វិន័យកូនៗរបស់ពួកគេ។ លទ្ធផលរកឃើញទាំងនេះត្រូវបានបំពេញដោយព័ត៌មានពីការពិភាក្សាជាមួយនឹងក្មេងជំទង់ក្នុងសហគមន៍ទាំងអស់ ដែលបង្ហាញថា ការរំលោភបំពានផ្លូវកាយ ឬការដាក់ទណ្ឌកម្មលើរាងកាយក្នុងគ្រួសារ មានប្រេវ៉ាឡង់ខ្ពស់។ អ្នកឆ្លើយតបប្រមាណជា ៦៥,៧ ភាគរយ លើកឡើងថា ពួកគេធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារកើតឡើងក្នុងផ្ទះ ឬក្នុងសហគមន៍។ សមាជិកសហគមន៍ក៏បានបញ្ជាក់ផងដែរថា ករណីអំពើហិង្សាបែបនេះភាគច្រើនកើតឡើងលើស្ត្រី និងកុមារ និងកើតឡើងនៅពេលដែលអ្នកប្រព្រឹត្តស្ថិតក្រោមឥទ្ធិពលនៃជាតិស្រវឹង។

### ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

ក្មេងជំទង់ភាគច្រើនជឿថា ឪពុកម្តាយរបស់ពួកគេប្រើប្រាស់អំពើហិង្សាផ្លូវកាយជាមធ្យោបាយ សម្រាប់ដាក់វិន័យ គឺជារឿងសមហេតុសមផល។ នៅតាមសហគមន៍មួយចំនួន ការប្រើប្រាស់អំពើហិង្សាត្រូវបានគេចាត់ទុកថាជារឿងធម្មតា ដោយសារតែវាកើតឡើងញឹកញាប់។ លើសពីនេះ ឪពុកម្តាយឬអាណាព្យាបាលច្រើនចាត់ទុកការដាក់វិន័យលើរាងកាយថាជាការឆ្លើយតបសមស្របជាងគេ ដើម្បីកែតម្រូវឥរិយាបថរបស់កូនពួកគេ។

ករណីអំពើហិង្សាក្នុងគ្រួសារច្រើនតែមិនត្រូវបានគេរាយការណ៍ទេ។ ក្នុងចំណោមសមាជិកសហគមន៍ដែលរាយការណ៍ថាធ្លាប់ឃើញករណីអំពើហិង្សាក្នុងគ្រួសារប្រមាណជា ៥៩,២ ភាគរយ និយាយថា ពួកគេពុំបានរាយការណ៍ ទៅអាជ្ញាធរឡើយ។ ជាទូទៅ ស្ត្រីច្រើនមិនអើពើនឹងករណីអំពើហិង្សាឡើយ ដោយសារតែពួកគេខ្លាចប្តីរបស់ខ្លួនលែងលះពួកគេ និងខ្លាចទទួលរងការមាក់ងាយពីសង្គមដោយសារតែការលែងលះនេះ។ លើសពីនេះ ការពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើប្តី ធ្វើឲ្យស្ត្រីមានការស្ទាក់ស្ទើរក្នុងការរាយការណ៍ ប្រាក់ចំណូលពីប្តីមានសារៈសំខាន់ជាង សម្រាប់ការចិញ្ចឹមបីបាច់គ្រួសារ។

### ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ចាំបាច់ត្រូវមានយុទ្ធនាការបង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ ពីការដាក់ វិន័យលើរាងកាយ និងអំពើហិង្សាក្នុងគ្រួសារ ដើម្បីលុបបំបាត់ឥរិយាបថអវិជ្ជមាននេះ និងបង្ហាញពីជម្រើសផ្សេង សម្រាប់ដាក់វិន័យ និងដោះស្រាយជម្លោះ។ ពាក់ព័ន្ធនឹងចំណុចនេះ ចាំបាច់ត្រូវផ្តោតគោលដៅលើប្រធានសហគមន៍ ហើយត្រូវមានការលើកទឹកចិត្តឲ្យសហគមន៍ទទួលខុសត្រូវលើការបញ្ចប់រាល់ទម្រង់នៃអំពើហិង្សាលើកុមារ(និងស្ត្រី)។

លើសពីនេះ ក៏ចាំបាច់ត្រូវមានស្ថាប័ន និងអ្នកផ្តល់សេវា ដែលបង្កលក្ខណៈឲ្យក្មេងជំទង់អាចរាយការណ៍ពីករណីអំពើហិង្សា ទទួលបានជំនួយវេជ្ជសាស្ត្រ និងការគាំទ្រចិត្តសង្គម និងសេវាជំនួយផ្លូវច្បាប់នានា។ ចំណុចនេះតម្រូវឲ្យមានការបង្កើតអង្គភាពពិសេស នៅតាមប៉ុស្តិ៍នគរបាលមូលដ្ឋាន ដើម្បីឲ្យកុមារ និងស្ត្រីអាចរាយការណ៍ពីករណីអំពើហិង្សាក្នុងគ្រួសារ ការមានមជ្ឈមណ្ឌលផ្តល់ការគាំទ្រផ្នែកវេជ្ជសាស្ត្រ និងការគាំទ្រចិត្តសង្គម និងផ្តល់សេវាគាំទ្រផ្លូវច្បាប់។ ស្ថាប័នទាំងនេះតម្រូវឲ្យមានការបណ្តុះបណ្តាលអ្នកផ្តល់ប្រឹក្សា នគរបាលជាស្ត្រី បុគ្គលិកសុខាភិបាល មេធាវី និងមន្ត្រីការពារកុមារ។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

មាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណីចែងថា "ជនដែលមានអំណាចមេបាអាចដាក់វិន័យកូនរបស់ខ្លួនដោយខ្លួនឯងបាន ក្នុងវិសាលភាពដែលចាំបាច់"។ ដូច្នេះ ការដាក់ទណ្ឌកម្មលើរាងកាយ ដែលកើតឡើងក្នុងផ្ទះ មិនត្រូវបានចាត់ទុកថាជាទង្វើខុសច្បាប់ ក្នុងប្រទេសកម្ពុជាឡើយ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ (២០០៥) ពុំបានហាមប្រាមការដាក់ទណ្ឌកម្មរាងកាយនៅផ្ទះឡើយ ហើយបញ្ញត្តិច្បាប់ផ្សេងទៀតដែលហាមឃាត់មិនឲ្យមានការប្រព្រឹត្តអំពើហិង្សា ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ពុំបានចាត់ទុកការដាក់ទណ្ឌកម្មរាងកាយក្នុងការចិញ្ចឹមបីបាច់កូនថាជាទង្វើខុសច្បាប់ឡើយ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

មាត្រា៨នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ២០០៥ ក៏ដូចជាមាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណី ផ្តល់នូវក្របខ័ណ្ឌច្បាប់មួយ ដែលទទួលយកការប្រើប្រាស់អំពើហិង្សាផ្លូវកាយថាជាទម្រង់សមស្របមួយ សម្រាប់ដាក់វិន័យ។ ច្បាប់ទាំងនេះតម្រូវឲ្យមានការពង្រឹងថែមទៀត ដើម្បីបានដាក់បញ្ហាទណ្ឌកម្មលើរាងកាយថាជាបទល្មើសខុសច្បាប់ ពោលគឺមិនត្រឹមតែទណ្ឌកម្មលើរាងកាយដែលកើតក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទណ្ឌកម្មលើរាងកាយដែលកើតឡើងតាមផ្ទះ និងតាមមណ្ឌលថែទាំកុមារទៀតផង។ ការកែសម្រួលច្បាប់ទាំងនេះចាំបាច់ត្រូវកើតឡើងស្របគ្នាជាមួយនឹងការដាក់ឲ្យអនុវត្តនូវយន្តការពិនិត្យតាមដានតឹងរ៉ឹងដើម្បីធានាឲ្យមានការអនុវត្តបញ្ញត្តិ ច្បាប់ទាំងនេះ និងឲ្យអ្នកប្រព្រឹត្តទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។ រដ្ឋាភិបាលត្រូវការការគាំទ្រក្នុងការរៀបចំការបណ្តុះបណ្តាលសម្រាប់នគរបាល បុគ្គលិកសុខាភិបាល មេធាវី ។ល។ រដ្ឋាភិបាលក៏ត្រូវការការគាំទ្រក្នុងការរៀបចំអន្តរាគមន៍ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ សម្រាប់បង្កើតភ្នាក់ងារសង្គមកិច្ច ដែលអាចបំពេញការងារនៅកម្រិតមូលដ្ឋាន និងទីប្រឹក្សាកុមារដែលអាចផ្តល់ការគាំទ្រចិត្តសង្គម ដូចលើកឡើងខាងលើ។ មន្ត្រីរដ្ឋាភិបាលដែលមានការយល់ដឹងបច្ចេកទេសអំពី "ការពិនិត្យតាមដាន និងវាយតម្លៃ" គោលនយោបាយ និងកម្មវិធីរដ្ឋាភិបាលក៏នៅមានចំនួនតិចតួចផងដែរ។ រដ្ឋាភិបាលត្រូវការការគាំទ្រដើម្បីរៀបចំក្របខ័ណ្ឌពិនិត្យតាមដានរួមមួយសម្រាប់តាមដានវឌ្ឍនភាពនៃការផ្តល់សេវាដល់ជនរងគ្រោះ។ ការគាំទ្រក្នុងការរៀបចំក្របខ័ណ្ឌក៏ចាំបាច់ត្រូវបញ្ចូលការបណ្តុះបណ្តាលផងដែរ ដើម្បីជួយឲ្យមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធយល់ដឹងពីរបៀបប្រើប្រាស់ក្របខ័ណ្ឌនេះសម្រាប់ធ្វើការពិនិត្យតាមដានក្នុងពេលទន្ទឹមគ្នា។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

ក្នុងឆ្នាំ២០១១ មានការប្រកាសចាប់ផ្តើមកិច្ចសហប្រតិបត្តិការរវាងយូនីសេហ្វ អង្គការ Friends International និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងបំណងផ្តល់កិច្ចការពារដល់កុមារ។ កម្មវិធី3PC ផ្តោតការយកចិត្តទុកដាក់លើការរៀបចំប្រព័ន្ធការពារកុមារនៅកម្ពុជា ហើយក្រោមយុទ្ធសាស្ត្រនេះ កម្មវិធីនេះបានបង្កើតចលនាសុវត្ថិភាពកុមារ ដែលមានការចូលរួមពីអង្គការសង្គមស៊ីវិល និងសមាជិកសហគមន៍ (ដែលក្លាយខ្លួនជាភ្នាក់ងារសុវត្ថិភាពកុមារ) ដើម្បីកែលម្អ "ការរាយការណ៍" និង "ការឆ្លើយតប" ចំពោះករណីរំលោភបំពានកុមារ។ អង្គការសង្គមស៊ីវិលផ្សេងទៀតបានបង្កើតអង្គភាពការពារកុមារ ដែលផ្តល់នូវសេវាជំនួយផ្លូវច្បាប់ និងការគាំទ្រផ្នែកសុខភាពដោយមិនគិតថ្លៃ ក្នុងករណីដែលមានអំពើហិង្សាកើតមានឡើង។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

វិសាលភាព និងការគ្របដណ្តប់នៃកម្មវិធី 3PC នៅមានកម្រិត ដោយសារតែខ្វះថវិកាសម្រាប់អនុវត្តកម្មវិធីនេះជាទ្រង់ទ្រាយធំ និងសម្រាប់ផ្តល់សេវាការពារ និងសង្គ្រោះឲ្យបានកាន់តែស៊ីជម្រៅ។ អង្គការមិនមែនរដ្ឋាភិបាលត្រូវការការគាំទ្រ ដើម្បីរៀបចំយុទ្ធសាស្ត្ររៃអង្គាសថវិកា និងរកប្រភពថវិកាបន្ថែមទៀត។ ការគាំទ្រអាចធ្វើឡើងក្នុងទម្រង់ជាការបណ្តុះបណ្តាល ឬជាការរៀបចំកញ្ចប់ឧបករណ៍ដែលអង្គការទាំងនេះអាចយកទៅប្រើប្រាស់បាន។ ដូចលើកឡើងខាងដើម អ្នកផ្តល់ប្រឹក្សាដល់កុមារដែលបានឆ្លងកាត់ការបណ្តុះបណ្តាល ឬមានសមត្ថភាព ដែលអាចផ្តល់នូវការគាំទ្រចិត្តសង្គម

នៅមានចំនួនតិចតួចនៅឡើយ។ ចាំបាច់ត្រូវមានការវិនិយោគលើការបណ្តុះបណ្តាលតាមស្ថាប័ននានា ដើម្បីផ្តល់លទ្ធភាពឲ្យគេអាចអភិវឌ្ឍបំណិនទាំងនេះ។ ប៉ុន្តែទន្ទឹមនឹងមានការវិនិយោគទាំងនេះ អង្គការមិនមែនរដ្ឋាភិបាលក៏ត្រូវការការគាំទ្រ សម្រាប់បណ្តុះបណ្តាលភ្នាក់ងារសង្គមកិច្ចរបស់ពួកគេបច្ចុប្បន្ន ដើម្បីឲ្យពួកគេអាចផ្តល់ការគាំទ្រចិត្តសង្គមជាមូលដ្ឋានបាន។ អង្គការសង្គមស៊ីវិលក៏មានបំណងចង់បំពេញតួនាទីឲ្យបានសកម្មក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងការងារនេះផងដែរ។ ប៉ុន្តែលទ្ធភាពរបស់ពួកគេដើម្បីចូលរួមចំណែកឲ្យបានសកម្ម ត្រូវជួបឧបសគ្គដោយសារតែពុំមានរចនាសម្ព័ន្ធ សម្រាប់វាយតម្លៃលើការឆ្លើយតបឬសេវាកម្មនៅថ្នាក់មូលដ្ឋាន ដែលផ្តល់ដោយមន្ទីរស្ថាប័នរបស់រដ្ឋាភិបាលឬអ្នកផ្តល់សេវានានាបាន។ ក្នុងន័យនេះ អង្គការសង្គមស៊ីវិលចាំបាច់ត្រូវមានលទ្ធភាពប្រើប្រាស់ឧបករណ៍គណនេយ្យភាពសង្គមសម្រាប់វាយតម្លៃស្ថានភាព និងផ្តល់ព័ត៌មានត្រលប់ក្នុងន័យស្ថាបនាដល់រដ្ឋាភិបាល។

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ពលកម្មកុមារ

### ស្ថានភាពបច្ចុប្បន្ន៖

កម្រិតចំណូលទាបរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ ជាកត្តាជំរុញឲ្យក្មេងជំទង់ទៅរកការងារធ្វើ ដើម្បីរួមចំណែករកចំណូលសម្រាប់គ្រួសារ។ គ្រួសារប្រមាណជា ៥,៣ ភាគរយ បានលើកឡើងថា បច្ចុប្បន្នមានក្មេងជំទង់ក្នុងគ្រួសារក្រីក្រកំពុងធ្វើការងារ ដើម្បីជួយរកចំណូលសម្រាប់គ្រួសារ។ មនុស្សភាគច្រើនក្នុងសហគមន៍ដឹងថាពលកម្មកុមារជាទង្វើរខុសច្បាប់ ដូច្នេះពួកគេពុំចង់រាយការណ៍ពីករណីនេះឡើយ។ ប្រធានសហគមន៍បញ្ជាក់ថាពិតជាមានការលាក់បាំងអំពីករណីនេះមែន ហើយបានអះអាងថាក្មេងជំទង់រហូតដល់ ៩០ ភាគរយ មកពីសហគមន៍ក្រីក្រក្នុងទីក្រុង ធ្វើការងារជាពលករកុមារ (ដោយពួកគេច្រើននាក់ធ្វើការងារក្រោយចេញពីរៀន)។

### ឥរិយាបថ ឬការឆ្លើយតបរបស់សហគមន៍៖

បើទោះបីជាឪពុកម្តាយយល់ដឹងថាការអប់រំផ្តល់អត្ថប្រយោជន៍រយៈពេលវែងដល់ការអភិវឌ្ឍជារួមរបស់កូនពួកគេក៏ដោយ ភាពក្រីក្រ និងភាពចាំបាច់ ដើម្បីរកចំណូលបំពេញបន្ថែមឲ្យគ្រួសារ ធ្វើឲ្យពួកគេផ្តល់អាទិភាពខ្ពស់ដល់ការរកចំណូលភ្លាមៗ។ លើសពីនេះបន្ទាប់ពីកុមារបានធ្វើការងារមួយរយៈ ពួកគេនឹងមានភាពម្ចាស់ការផ្នែកហិរញ្ញវត្ថុក្នុងកម្រិតមួយ ដែលធ្វើឲ្យមានការពិបាកក្នុងការធ្វើសមាហរណកម្មពួកគេទៅក្នុងសាលារៀនវិញ។

### ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

បើទោះបីជាឪពុកម្តាយពិតជាទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំជាទូទៅក៏ដោយ ក៏ពួកគេចាំបាច់ត្រូវយល់ពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងអត្ថប្រយោជន៍ផ្សេងទៀត ពីការអប់រំដែរ ប្រសិនបើកូនរបស់ពួកគេរៀនចប់យ៉ាងហោចណាស់កម្រិតមធ្យមសិក្សាទុតិយភូមិ។ ដោយសារតែការអប់រំវិជ្ជាជីវៈមានទំនាក់ទំនងផ្ទាល់ជាមួយនឹងការងារដែលមានចំណូល ជាការចាំបាច់ត្រូវមានការផ្សព្វផ្សាយសារអប់រំមួយនេះ។

### បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (NPA-WFCL) ២០០៨-២០១២ ត្រូវបានដាក់ឲ្យអនុវត្ត ក្នុងគោលបំណងកាត់បន្ថយករណីពលកម្មកុមារឲ្យមកនៅ ៨% ត្រឹមឆ្នាំ ២០១៥។ ផែនការសកម្មភាពនេះប្រើប្រាស់អភិក្រមអន្តរវិស័យ សម្រាប់កាត់បន្ថយករណីពលកម្មកុមារ ដោយមានការជំរុញឲ្យមានការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធនានា។ ផែនការសកម្មភាពស្តីពីការលុបបំបាត់ពលកម្មកុមាររបស់ CAMFEBA (CAMFEBA - PAECL)

ក្នុងប្រទេសកម្ពុជា (២០១២-២០១៦) ក៏ត្រូវបានអនុវត្តជាមួយនឹងគោលបំណងដូចគ្នានេះដែរ។ លើសពីនេះ ក៏មានលិខិតបទដ្ឋានផ្សេងៗ សម្រាប់ទប់ស្កាត់ពលកម្មកុមារ នៅតាមឧស្សាហកម្មនានា ដូចជា កសិកម្ម ចំការផ្ទាំងជក់ នេសាទទឹកសាប ។ល។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

គោលនយោបាយដែលកំពុងមានបច្ចុប្បន្ន ហាមឃាត់មិនឲ្យមានការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុត នៅតាមឧស្សាហកម្មមួយចំនួន។ ប្រសិនបើពុំមានការហាមឃាត់ការប្រើប្រាស់ពលកម្មកុមាររាល់ទម្រង់នោះទេ ការអនុវត្តគោលនយោបាយនេះនឹងជួបការលំបាក និងមានចន្លោះប្រហោងជាច្រើនជាមិនខាន។ សូម្បីតែតាមវិស័យដែលមានការហាមប្រាមមិនឲ្យមានការប្រើពលកម្មកុមារក៏ដោយ ក៏គេពិបាកនឹងធ្វើការពិនិត្យតាមដានដែរ ដោយសារតែពលករកុមារភាគច្រើនធ្វើការងារ ក្នុងវិស័យមិនរៀបរយ។ ការពិនិត្យតាមដាន និងការគ្រប់គ្រងចំនួនម៉ោងធ្វើការ ក៏ដូចជាលក្ខខណ្ឌការងារ និងវិធានការសុវត្ថិភាព ដែលអនុវត្តដោយនិយោជក គឺជាសុទ្ធតែជាសកម្មភាពដែលពិបាកអនុវត្ត។ ដូច្នេះរដ្ឋាភិបាលត្រូវការការគាំទ្រ ដើម្បីរៀបចំផែនការ និងអនុវត្តកម្មវិធីបង្កើនការយល់ដឹង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ។ ចុងក្រោយ ពួកគេពុំបានដឹងពីសេវារបស់រដ្ឋ ឬសេវារបស់អង្គការមិនមែនរដ្ឋាភិបាលដែលកុមារអាចទទួលបានផ្នែកការពារ ស្តារនីតិសម្បទា ឬសមាហរណកម្ម។ ចំណុចទាំងនេះចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងកញ្ចប់បណ្តុះបណ្តាល សម្រាប់មន្ត្រីរដ្ឋាភិបាល ដូចលើកឡើងខាងលើ។

បញ្ហានេះរឹតតែពិបាកដោះស្រាយទៅទៀត ដោយសារតែទីភ្នាក់ងារអនុវត្តច្បាប់ការងារពុំមានបុគ្គលិក សម្រាប់តាមដាន និងត្រួតពិនិត្យសហគ្រាសឡើយ (ជាពិសេសក្នុងសហគ្រាសក្នុងវិស័យរៀបរយ)។ រដ្ឋាភិបាលត្រូវការការគាំទ្រ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ តាមរយៈការបង្កើតនូវទម្រង់ការសម្រាប់ពិនិត្យតាមដានមួយ ដែលមានការចូលរួមពីតួអង្គរដ្ឋ ឬតួអង្គមិនមែនរដ្ឋផ្សេងទៀត ដូចជា មេធាវី គ្រូបង្រៀន អង្គការសង្គមស៊ីវិល។ល។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

អង្គការសង្គមស៊ីវិល ដែលធ្វើការងារក្នុង និងជុំវិញសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ បាននិងកំពុងរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាច្រើន (ដូចជាយុទ្ធនាការចុះអប់រំតាមផ្ទះ ព្រឹត្តិការណ៍ក្នុងសហគមន៍ ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកជាដើម) ដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីផលវិបាកជាអវិជ្ជមាននៃការបញ្ជូនកូនទៅធ្វើការងារ។ អង្គការទាំងនេះក៏ផ្តល់ជាការបង្រៀនពេលរសៀល ដើម្បីផ្តល់ឲ្យពលករកុមារនូវជម្រើសសម្រាប់ទទួលបានការអប់រំក្រៅផ្លូវការផងដែរ។ អង្គការទាំងនេះក៏រៀបចំថ្នាក់អប់រំ សម្រាប់ជួយឲ្យកុមារបោះបង់ចោលការសិក្សាចុះឈ្មោះចូលរៀនឡើងវិញ ក្នុងការអប់រំក្នុងប្រព័ន្ធផងដែរ។ អ្វីដែលកាន់តែសំខាន់ទៅទៀត អង្គការទាំងនេះក៏អនុវត្តកម្មវិធីអប់រំវិជ្ជាជីវៈ (រួមមានការអប់រំក្រៅប្រព័ន្ធ) ដើម្បីជួយឲ្យកុមារអាចទទួលបានការងារសមរម្យបានធ្វើ ក្រោយពេលបញ្ចប់ការអប់រំរយៈពេល៩ឆ្នាំផងដែរ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

អង្គការសង្គមស៊ីវិលដែលធ្វើការងារទប់ស្កាត់ពលកម្មកុមារតាមសហគមន៍ក្រីក្រក្នុងទីក្រុងមានការយល់ដឹងខ្ពស់ពីអ្វីដែលចាំបាច់ត្រូវធ្វើ ដើម្បីទប់ស្កាត់ពលកម្មកុមារមិនឲ្យកើតឡើង។ ប៉ុន្តែ ពួកគេពុំមានថវិកាសម្រាប់ធ្វើការងារនេះក្នុងទ្រង់ទ្រាយធំឡើយ។ គួរមានការទាញប្រយោជន៍ពីជំនាញរបស់ពួកគេ សម្រាប់គាំទ្រដល់អន្តរាគមន៍ផ្លូវការរបស់រដ្ឋាភិបាល។ អង្គការទាំងនេះអាចគាំទ្រដល់សាលារៀនតាមមូលដ្ឋាន តាមរយៈការរៀបចំថ្នាក់អប់រំក្នុងទម្រង់ជាស្ពានចម្លង និងជួយអភិវឌ្ឍការអប់រំវិជ្ជាជីវៈ។ អង្គការទាំងនេះក៏អាចបំផុសឲ្យសហគមន៍ប្រឆាំងនឹងពលកម្មកុមារ និង/ឬគាំទ្រដល់មន្ត្រីមន្ទីរការងារផងដែរ ក្នុងចុះពិនិត្យសហគ្រាសរៀបរយ និងមិនរៀបរយ និងធ្វើរបាយការណ៍សវនកម្មសង្គមទៅកាន់ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល។ អង្គការសង្គមស៊ីវិលក៏អាចបំពេញតួនាទី ក្នុងការរៀបចំកម្មវិធីតស៊ូមតិ និងអប់រំផ្សព្វផ្សាយ ផ្តោតលើការបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការអប់រំ និងការចិញ្ចឹមបីបាច់កូន

តាមបែបវិជ្ជមានផងដែរ។ ដូច្នេះ បើទោះបីជាអង្គការសង្គមស៊ីវិលពុំមានតម្រូវការអភិវឌ្ឍសមត្ថភាពជាក់លាក់ក៏ដោយ អង្គការទាំងនេះរឹតតែអាចបំពេញតួនាទីកាន់តែល្អជាងនេះ ប្រសិនបើពួកគេអាចធ្វើការងារក្នុងនាមជាដៃគូផ្លូវការជាមួយនឹងរដ្ឋាភិបាលបាន។ អង្គការសង្គមស៊ីវិលភាគច្រើនគិតថា មានតែអង្គការអន្តរជាតិទេ ដែលធ្វើការសម្របសម្រួលជិតស្និទ្ធជាមួយរដ្ឋាភិបាល ដែលអាចជួយពួកគេបង្កើតភាពជាដៃគូបែបនេះបាន។

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ កុមារបាត់ខ្លួនដែលប្រឈមនឹងការជួញដូរ

### ស្ថានភាពបច្ចុប្បន្ន៖

គ្រួសាររស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញប្រមាណជា ១២,២ ភាគរយ បានរាយការណ៍ថាពួកគេដឹងពីករណីកុមារបាត់ខ្លួនពីសហគមន៍នេះ។ គ្រួសារ ១៧,៨ ភាគរយទៀត រាយការណ៍ថា ពួកគេដឹងពីក្មេងជំទង់ក្នុងសហគមន៍ដែលបាត់ខ្លួនពីផ្ទះរបស់ពួកគេ។ ជារឿយៗ កុមារបាត់ខ្លួនងាយនឹងត្រូវគេយកទៅជួញដូរ ដោយសារតែនៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ មានគ្រួសារប្រមាណជា ៤២,២ ភាគរយ លើកឡើងថា ពួកគេជឿថាកុមារដែលបាត់ខ្លួនទាំងនេះងាយនឹងត្រូវបានគេជួញដូរ ហើយ ៣០,៥ ភាគរយ ជឿថា ក្មេងជំទង់បាត់ខ្លួនក៏ប្រឈមនឹងហានិភ័យដូចគ្នានេះដែរ។

### ឥរិយាបថ ឬការឆ្លើយតបរបស់សហគមន៍៖

ការយល់ឃើញរបស់គ្រួសារអំពីករណីកុមារបាត់ខ្លួនមានចំណុចមួយគួរឲ្យកត់សម្គាល់ខុសពីករណីក្មេងជំទង់បាត់ខ្លួន។ ក្នុងករណីកុមារ សមាជិកសហគមន៍ភាគច្រើនជឿថាកុមារទាំងនោះត្រូវបានគេចាប់ពង្រាត់ដោយសារតែពួកគេនៅក្មេងពេកមិនអាចដើរឆ្ងាយដោយខ្លួនឯងបានឡើយ។ ប៉ុន្តែ ករណីនេះមិនអាចកើតឡើង ចំពោះក្មេងជំទង់ឡើយ។ សមាជិកសហគមន៍គិតថា លទ្ធភាពដែលកុមារបាត់ខ្លួនត្រូវបានគេជួញដូរ គឺខ្ពស់ជាងក្មេងជំទង់។ ពួកគេគិតថា បើធៀបជាមួយនឹងកុមារ ក្មេងជំទង់ដែលបាត់ខ្លួនច្រើនតែរត់ចេញពីផ្ទះ ជាជាងត្រូវបានគេយកទៅជួញដូរ ហើយប្រសិនបើបែបនេះមែន ពួកគេអាចធ្វើការសម្រេចចិត្ត និងការពារខ្លួនឯងបាន។ សមាជិកសហគមន៍បង្ហាញពីការយល់ដឹងអំពីផលវិបាកនៃការជួញដូរមនុស្ស។ ពួកគេលើកឡើងថា ការជួញដូរមនុស្សធ្វើឡើង ដើម្បីបង្ខំឲ្យដើរសុំទាន កេងប្រវ័ញ្ចកម្លាំងពលកម្ម (ឧ. ពលកម្មចំណងបំណុល និងប្រើជាទាសករ) ផ្តល់សេវាផ្លូវភេទ និងបង្ខំឲ្យរៀបការ ជាដើម។ ក្មេងស្រីងាយត្រូវបានគេជួញដូរ ដើម្បីបង្ខំឲ្យរៀបការ និងបម្រើសេវាផ្លូវភេទ។ សហគមន៍ក៏លើកឡើងផងដែរថា ករណីជួញដូរមនុស្សមួយចំនួន អាចធ្វើឡើង ដើម្បីយកកុមារទៅចិញ្ចឹមផងដែរ (ដោយមិនបានបំពេញទៅតាមលក្ខខណ្ឌច្បាប់សុំកូនត្រឹមត្រូវឡើយ)។

### ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

បើទោះបីជាមានការយល់ដឹងពីហានិភ័យនៃការជួញដូរមនុស្សក៏ដោយ ក៏ពុំមានយន្តការសម្រាប់ដោះស្រាយករណីកុមារបាត់ខ្លួនឡើយ។ បញ្ហានេះក៏ដូចគ្នានឹងករណីក្មេងជំទង់រត់ចេញពីផ្ទះដោយខ្លួនដែរ។ យន្តការសហគមន៍ សម្រាប់ពិនិត្យតាមដាន និងការពារកុមារ និងក្មេងជំទង់ នៅមានកម្រិតខ្សោយនៅឡើយ។ ការឆ្លើយតបចំពោះករណីកុមារឬក្មេងជំទង់បាត់ខ្លួនរួមមាន ការផ្តល់ព័ត៌មានដល់ប្រធានសហគមន៍ តែមិនមែនដល់នគរបាលនោះទេ។ ពួកគេគិតថា នគរបាលមិនយកចិត្តទុកដាក់ និងមិនឆ្លើយតបចំពោះករណីបែបនេះឡើយ (ជាពិសេស សម្រាប់ករណីក្មេងជំទង់បាត់ខ្លួន)។ ដូច្នេះ ចាំបាច់ត្រូវមានការពង្រឹងយន្តការឃ្លាំមើល និងឆ្លើយតបរបស់សហគមន៍ និងបង្កើតទំនាក់ទំនងរវាងប្រជាពលរដ្ឋ ជាមួយប្រធានសហគមន៍ និងនគរបាលនិង/ឬប្រព័ន្ធយុត្តិធម៌។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ មានគោលបំណងទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ក្នុងប្រទេសកម្ពុជា សមិទ្ធផលធំមួយ គឺការបង្កើតស្ថាប័នអន្តរក្រសួងមួយ កាលពីឆ្នាំ ២០០៨ ដែលសមាសភាពមកពីក្រសួង និងសង្គមស៊ីវិល។ គណៈកម្មាធិការជាតិនេះទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស ក្រោមការដឹកនាំរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយមិនត្រឹមតែផ្តោតលើការជួញដូរមនុស្ស ដើម្បីកេងប្រវ័ញ្ចផ្លូវភេទនោះទេ ប៉ុន្តែក៏ផ្តោតលើការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរត់ពន្ធមនុស្សផងដែរ និងមានអំណាចស្នើឲ្យក្រសួងផ្សេងទៀតចាត់វិធានការផងដែរ។ កាលពីឆ្នាំ ២០០៩ ប្រទេសកម្ពុជាបានក្លាយជាប្រទេសដំបូងគេនៅអាស៊ីអាគ្នេយ៍ ដែលបានអនុម័តគោលការណ៍ណែនាំ និងគោលនយោបាយស្តីពីការការពារជនរងគ្រោះ ដោយមានរៀបចំការបណ្តុះបណ្តាលមន្ត្រីអំពីការប្រើប្រាស់ស្តង់ដានេះផងដែរ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

បញ្ហាប្រឈមសំខាន់ៗក្នុងការអនុវត្តច្បាប់នេះ រួមមាន ដំណើរការនៃប្រព័ន្ធយុត្តិធម៌នៅមានកម្រិតខ្សោយ ដោយពុំបានធានាឲ្យមានការផ្តន្ទាទោសអ្នកដែលប្រព្រឹត្តបទល្មើសទាំងនេះឡើយ និងភាពចាំបាច់ដើម្បីពង្រឹងយន្តការ សម្រាប់ដោះស្រាយករណីកុមារបាត់ខ្លួន។ ក្នុងករណី កុមាររងគ្រោះពីជួញដូរស្វែងរកវិធានការផ្លូវច្បាប់ យន្តការសម្រាប់ធានាសុវត្ថិភាពជនរងគ្រោះ នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់ឡើយ។ លើសពីនេះ ការបង្កើនការយល់ដឹង និងអភិវឌ្ឍសមត្ថភាពនគរបាលក៏មិនទាន់បានធ្វើអោយបានឆាប់ និង/ឬអាចធ្វើឲ្យមានការផ្លាស់ប្តូរតាមដែលចាំបាច់នោះដែរ។ សៀវភៅណែនាំដែលកំពុងប្រើប្រាស់ សម្រាប់ការបណ្តុះបណ្តាលបែបនេះនៅមានចំណុចខ្វះខាត។ អ្នកបណ្តុះបណ្តាលក៏ពុំមានចំនួនគ្រប់គ្រាន់ និងនៅមានការខ្វះខាតថវិកាសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រប់មន្ត្រីទាំងអស់។ ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងចំណុចនេះ ជួបនឹងការលំបាកផ្សេងទៀត ដោយសារតែច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងនេះមិនបានផ្តល់តួនាទីសំខាន់ឲ្យប្រធានសហគមន៍ចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្របង្ការ ឆ្លើយតប និងស្តារនីតិសម្បទាឡើយ។

រដ្ឋាភិបាលត្រូវការការគាំទ្រ ដើម្បីកែលម្អកញ្ចប់បណ្តុះបណ្តាលដែលមានសម្រាប់ បណ្តុះបណ្តាលកម្លាំងនគរបាល។ ខ្លឹមសារនៃកញ្ចប់បណ្តុះបណ្តាលនេះចាំបាច់ត្រូវពង្រីកបន្ថែម ដើម្បីបញ្ចូលខ្លឹមសារសម្រាប់មេធាវី និងអ្នកដែលធ្វើការងារក្នុងប្រព័ន្ធយុត្តិធម៌។ រដ្ឋាភិបាលក៏ត្រូវការជំនួយ ដើម្បីរៀបចំ និងផ្តល់ការបណ្តុះបណ្តាល និងជំរុញឲ្យមានការចូលរួមពីសមាជិកសហគមន៍ (ជាពិសេសពីថ្នាក់ដឹកនាំ) ក្នុងយុទ្ធសាស្ត្របង្ការដោះស្រាយ និងស្តារនីតិសម្បទា។ រដ្ឋាភិបាលត្រូវការការគាំទ្រ ដើម្បីរៀបចំប្រព័ន្ធរួមនៅថ្នាក់កណ្តាលមួយ សម្រាប់តាមដានករណីកុមារបាត់ខ្លួន និងតាមដានលើការផ្តល់សេវាយុត្តិធម៌ដល់ជនរងគ្រោះ។ ការតាមដានសុវត្ថិភាព សន្តិសុខ និងការស្តារនីតិសម្បទា ជនរងគ្រោះ ចាំបាច់ត្រូវតែជាសមាសភាគស្នូលនៃប្រព័ន្ធតាមដានបែបនេះ។ ប្រសិនបើមានប្រព័ន្ធតាមដានកុមារនៅកម្រិតសាលារៀនសម្រាប់តាមដានកុមារ ក្នុងជីវិតសិក្សារបស់ពួកគេ ប្រព័ន្ធនេះនឹងជួយកំណត់រកកុមារដែលបោះបង់ចោលការសិក្សាបានទាន់ពេលវេលា។ ដូច្នេះ ចាំបាច់ត្រូវមានការពង្រឹងទំនាក់ទំនងរវាងពលកម្មកុមារ និងការអប់រំបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហានេះ។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

កម្មវិធី 3PC ដែលជាកម្មវិធីសហប្រតិបត្តិការរវាងយូនីសេហ្វ អង្គការ Friends International និងក្រសួងសង្គមកិច្ច ដែលមានគោលបំណងការពារកុមារ កំពុងផ្តោតការយកចិត្តទុកដាក់លើការបង្កើតប្រព័ន្ធការពារកុមារ ក្នុងប្រទេសកម្ពុជា។ ក្រោមក្របខ័ណ្ឌនៃអន្តរាគមន៍នេះ អ្នកធ្វើការតាមសណ្ឋាគារ និងក្រុមហ៊ុនរថយន្តក្រុងបានទទួលការបណ្តុះបណ្តាលឲ្យធ្វើជាភ្នាក់ងារសុវត្ថិភាពកុមារ ហើយយន្តការរាយការណ៍របស់អង្គការសង្គមស៊ីវិល ដែលចូលរួមក្នុងកម្មវិធី 3PC ក៏បានពង្រីកវិសាលភាពរបស់ខ្លួនផងដែរ។ កម្មវិធីនេះមានគោលបំណង

កែលម្អការរាយការណ៍ និងការឆ្លើយតបចំពោះករណីរំលោភបំពានឬជួញដូរកុមារ។ កម្មវិធីផ្សេងទៀត មានដូចជា កម្មវិធីប្រឆាំងការជួញដូរមនុស្សរបស់មូលនិធិអាស៊ីនៅកម្ពុជាជាដើម។

### បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ការកែលំអប្រព័ន្ធគាំទ្រជនរងគ្រោះនៅកម្រិតសហគមន៍ គឺជាការងារមួយដ៏សំខាន់។ ការខ្វះជំនាញ និងធនធាន បង្ករការលំបាកដល់ការកែលម្អប្រព័ន្ធ នៅកម្រិតនេះ។ នៅកម្រិតរចនាសម្ព័ន្ធ រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បាននិងកំពុងធ្វើការងាររួមគ្នា ដើម្បីបណ្តុះបណ្តាលនគរបាល និងភ្នាក់ងារសង្គមកិច្ចអំពីរបៀបឆ្លើយតបចំពោះករណីនានា និងធានាសុវត្ថិភាពដល់ជនរងគ្រោះ។ ប៉ុន្តែអន្តរាគមន៍បែបនេះពុំបាននាំឲ្យមានការឆ្លើយតបរួមគ្នាឡើយ។ ការឆ្លើយតបបែបនេះទាមទារឲ្យមានការចូលរួមពីអ្នកដឹកនាំសហគមន៍។ លើសពីនេះ ការងារទប់ស្កាត់ឬបង្ការ ក៏នៅមានកម្រិតផងដែរ។ ចាំបាច់ត្រូវមានការអភិវឌ្ឍសមត្ថភាពសហគមន៍ ដើម្បីឲ្យពួកគេអាចបន្តឃ្លាំមើលស្ថានភាពរបស់កុមារក្នុងបំណងកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារ។ អង្គការសង្គមស៊ីវិលជឿថា ការងាររបស់ពួកគេនឹងទទួលបានប្រយោជន៍ធំធេងពីរបៀបធ្វើការងារដែលមានផែនការ និងការសម្របសម្រួលសមស្របពីរដ្ឋាភិបាល។ ចំណុចនេះក៏បង្ហាញពីតួនាទីរបស់ពួកគេនៅដំណាក់កាលទប់ស្កាត់ ដោះស្រាយករណី និងស្តារនីតិសម្បទាផងដែរ។ អង្គការសង្គមស៊ីវិលភាគច្រើនផ្តោតលើការងារពាក់ព័ន្ធនឹងការទប់ស្កាត់ ហើយមានបំណងចង់ពង្រីកការងារដោះស្រាយករណី និងស្តារនីតិសម្បទាផងដែរ ដោយទាមទារឲ្យពួកគេត្រូវធ្វើការងារឲ្យបានជិតស្និទជាមួយនឹងរដ្ឋាភិបាល។

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ការរំលោភបំពានផ្លូវភេទ

### ស្ថានភាពបច្ចុប្បន្ន៖

គ្រួសាររស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ប្រមាណជា ២២,២ ភាគរយ លើកឡើងថា ពួកគេដឹងពីករណីរំលោភបំពាន និង/ឬអំពើហិង្សាផ្លូវភេទ។ សហគមន៍ដែលបានចុះទៅស្ទើរតែទាំងអស់បានលើកឡើងពីករណីរំលោភបំពានផ្លូវភេទ ការរំលោភសេពសន្ថវៈ ឬការលេបខាយ។ ក្រៅពីនេះក៏មានការលើកឡើងពីករណីដែលជនរងគ្រោះ និងជនល្មើសជាក្មេងជំទង់ដូចគ្នា និងពីករណីដែលជនរងគ្រោះជាកុមារផងដែរ។

### ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

ចំណុចល្អដែលកត់សម្គាល់ឃើញគឺថា ក្នុងចំណោមករណីដែលរាយការណ៍ដោយសមាជិកសហគមន៍ យ៉ាងហោចណាស់ក៏មានករណី ៨១,៤ ភាគរយដែរ ដែលអ្នកប្រព្រឹត្តត្រូវបាននគរបាលឃាត់ខ្លួន និងមានការចាត់វិធានការពីប្រព័ន្ធយុត្តិធម៌។ ប៉ុន្តែប្រធាននិងសមាជិកសហគមន៍ដែលចូលរួមក្នុងការពិភាក្សាពាក់កណ្តាលរចនាសម្ព័ន្ធឯកភាពជាមួយនឹងការយល់ឃើញដែលថា ការទទួលរងការមាក់ងាយក្នុងនាមជាជនរងគ្រោះពីអំពើហិង្សាគួបផ្សំនឹងដោយសារតែករណីជាច្រើនកើតឡើងក្នុងរង្វង់គ្រួសារផង (ដោយជនប្រព្រឹត្តជាសមាជិកគ្រួសារ) ធ្វើឲ្យករណីអំពើហិង្សាផ្លូវភេទជាច្រើនមិនត្រូវបានគេរាយការណ៍ឡើយ។ នៅតាមគ្រួសារវិញ ករណីរំលោភបំពាន និងអំពើហិង្សាផ្លូវភេទ នៅតែជាបញ្ហាឯកជនឬបញ្ហាគ្រួសារ។ ប៉ុន្តែ ករណីអំពើហិង្សាផ្លូវភេទដែលកើតក្រៅរង្វង់គ្រួសារនឹងទទួលរងការចាត់វិធានការធ្ងន់ធ្ងរពីសហគមន៍ ហើយក៏មានការរាយការណ៍ទៅនគរបាលផងដែរ។

### ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

មានភាពចាំបាច់អោយមានការយល់ដឹងនៅកម្រិតសហគមន៍អំពីការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាផ្លូវភេទ ក៏ដូចជាតម្រូវការនូវយន្តការសម្រាប់ឆ្លើយតបចំពោះបណ្តឹងនានា។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការអប់រំសហគមន៍ឲ្យមិនទទួលគំនិតដែលចាត់ទុកអំពើហិង្សា

ផ្លូវភេទកើតឡើងក្នុងរង្វង់គ្រួសារថាជាបញ្ហាផ្ទាល់ខ្លួនរបស់គ្រួសារផងដែរ។ គ្រួសារគឺជាផ្នែកមួយនៃសហគមន៍ ហើយសមាជិកសហគមន៍ (ជាពិសេស ប្រធានសហគមន៍) ចាំបាច់ត្រូវមានការយល់ដឹងអំពីភាពចាំបាច់នៃការធ្វើអន្តរាគមន៍ ក្នុងករណីទាំងនេះ។ អ្នកដែលងាយនឹងទទួលរងអំពើហិង្សាគឺកុមារ ហើយភាគច្រើន ពួកគេមិនយល់ថាពួកគេកំពុងត្រូវបានគេរំលោភបំពាននោះទេ ដូច្នេះពួកគេចាំបាច់ត្រូវដឹងអំពីការប៉ះពាល់ដែលធ្វើឡើងដោយមនុស្សពេញវ័យមកលើពួកគេបែបណា ដែលជាការប៉ះពាល់ល្អ និងការប៉ះពាល់មិនល្អ។ ពួកគេក៏ចាំបាច់ត្រូវដឹងផងដែរថាពួកគេនិយាយប្រឆាំងទៅនឹងទម្រង់នៃអំពើហិង្សាដែលកើតមានលើពួកគេ។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ហាមឃាត់មិនឲ្យមានការធ្វើអាជីវកម្មផ្លូវភេទ និងការរំលោភបំពានផ្លូវភេទលើកុមារ និងមនុស្សវ័យក្មេងឡើយ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ខណៈដែលករណីរំលោភបំពានផ្លូវភេទ និងអំពើហិង្សាផ្លូវភេទដែលកើតឡើងតាមសហគមន៍ត្រូវបានរាយការណ៍ទៅនគរបាល ការចាត់វិធានការរបស់នគរបាលពុំមានសង្គតិភាពឡើយ។ មនុស្សជាច្រើនពុំបានរាយការណ៍ពីករណីទាំងនេះឡើយ ដោយសារតែពុំមានការគាំទ្រឲ្យបានសមស្របពីអ្នកអនុវត្តច្បាប់ ក្នុងការរក្សាការសម្ងាត់ពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ជនរងគ្រោះ ពុំមានទីកន្លែង និងធនធានមនុស្សដោយឡែកសម្រាប់ឆ្លើយតបចំពោះករណីទាំងនេះ និងពុំមានការផ្តល់ការគាំទ្រផ្នែកវេជ្ជសាស្ត្រ ផ្លូវចិត្ត និងសង្គមសេដ្ឋកិច្ចដល់ជនរងគ្រោះ។

ដូចក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងការបំពារបំពានផ្លូវកាយដែរ រដ្ឋាភិបាលត្រូវការការគាំទ្រពីខាងក្រៅ ដើម្បីរៀបចំកញ្ចប់បណ្តុះបណ្តាល សម្រាប់បង្កើនការយល់ដឹងដល់មន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ និងរៀបចំអន្តរាគមន៍ឲ្យបានសមស្រប ដើម្បីបង្កើតក្រុមភ្នាក់ងារសង្គមកិច្ច ដែលអាចទៅបំពេញការងារនៅកម្រិតមូលដ្ឋានបាន និងបង្កើតទីប្រឹក្សាកុមារដែលអាចផ្តល់ការគាំទ្រចិត្តសង្គមខាងលើបាន។

## កម្មវិធីនិង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

ដូចលើកឡើងខាងដើមដែរ កម្មវិធី 3PC គឺជាកម្មវិធីចម្បង ដែលផ្តោតលើការបង្ការការរំលោភបំពានផ្លូវភេទ និង/ឬអំពើហិង្សាផ្លូវភេទលើកុមារ។ អង្គការសង្គ្រោះកុមារបានរៀបចំសម្ភារអប់រំផ្សព្វផ្សាយល្អៗមួយចំនួន ដើម្បីបង្កើនការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ ដែលគួរយកមកប្រើប្រាស់ឲ្យបានកាន់តែទូលំទូលាយ។ អង្គការ Hagar International ម្លប់តាប៉ាង APLE, Friends International និង First Step Cambodia គឺអង្គការមួយចំនួន ដែលផ្តល់សេវាស្តារនីតិសម្បទាដល់បុរសដែលជាជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ។ ECPAT កម្ពុជាក៏ធ្វើការងារ ដើម្បីផ្តល់សេវាសង្គ្រោះដល់ជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ និងទប់ស្កាត់ការរំលោភបំពានផ្លូវភេទ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារខាងកិច្ចការពារកុមារ បង្ហាញថា ការសម្របសម្រួលនៅមានកម្រិតខ្សោយរវាងអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធផ្សេងទៀត ដូចជា រដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារជាដើម ដែលនេះជាកត្តារាំងដល់អន្តរាគមន៍ផ្នែកការសង្គ្រោះ និងការស្តារនីតិសម្បទាជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទប្រកបដោយជោគជ័យ។ បទដ្ឋានសង្គមដូចជា ទស្សនៈយល់ឃើញបែបបិតុនិយមអំពីយេនឌ័រ ការមាក់ងាយ និងការផាត់ចេញពីសង្គមជាដើម គឺជាបញ្ហាប្រឈម ក្នុងការប្រយុទ្ធប្រឆាំងនឹងករណីរំលោភបំពានផ្លូវភេទលើស្ត្រី និងបុរស។ កម្មវិធីបច្ចុប្បន្ននេះក៏ផ្តោតការយកចិត្តទុកដាក់តិចតួចទៅទៀត ហើយបញ្ហានេះចាំបាច់ត្រូវមានការដោះស្រាយ តាមរយៈការអប់រំតាមសាលារៀន និងការកៀងគរសហគមន៍ និងការបង្កើនការយល់ដឹងដល់ប្រធានសហគមន៍។

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ការពុំមានការថែទាំសម្រាប់កុមារដែលត្រូវបានបោះបង់ចោលឬកុមារកំព្រា កុមារបាត់ខ្លួនដែលប្រឈមនឹងការជួញដូរ

### ស្ថានភាពបច្ចុប្បន្ន៖

ការលំបាកខាងហិរញ្ញវត្ថុបង្ខំគ្រួសារក្រីក្រឲ្យយកកូនរបស់ខ្លួនទៅដាក់តាមមណ្ឌលថែទាំកុមារ ដូចជាមណ្ឌលកុមារកំព្រា ឬបង្ខំចិត្តបោះបង់កូនចោលជាដើម។ ក្នុងករណីភាគច្រើន កុមារទាំងនោះមានពិការភាពអ្វីមួយ ឬមានជំងឺរ៉ាំរ៉ៃ។ ការខ្វះសេវាគាំទ្របង្ខំឲ្យកុមារទាំងនេះត្រូវរស់នៅអនាថាតាមផ្លូវ ដែលធ្វើឲ្យពួកគេកាន់តែប្រឈមនឹងការប្រើបំពានគ្រឿងស្រវឹង និង/ឬគ្រឿងញៀន ប្រឡូកក្នុងក្រុមទំនើង ប្រព្រឹត្តបទល្មើសអនីតិជន ការជួញដូរមនុស្ស និងការរំលោភបំពានជាដើម។ ក្មេងស្រីដែលត្រូវបានគេបោះបង់ចោល ឬក្មេងស្រីកំព្រា រឹតតែងាយរងគ្រោះដោយសារតែការជួញដូរមនុស្ស ការរៀបការទាំងខ្លួននៅក្មេង ឬមានផ្ទៃពោះ ពេលដែលពួកគេនៅជាក្មេងជំទង់នៅឡើយ។

### ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

គ្រួសារក្រីក្ររស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងប្រមាណជា ១៦,៦ ភាគរយ កំពុងផ្តល់ការថែទាំដល់កុមារកំព្រា ឬកុមារដែលត្រូវបានគេបោះបង់ចោល។ នេះបង្ហាញពីការឆ្លើយតបដោយស្ម័គ្រចិត្ត នៅកម្រិតសហគមន៍។ បើទោះបីជាគ្រួសារមួយចំនួនកំពុងផ្តល់ការថែទាំដល់កុមារកំព្រាក៏ដោយ ការពិភាក្សាក្រុមជាមួយចាស់ព្រឹទ្ធាចារ្យតាមសហគមន៍បង្ហាញថា ការខ្វះខាតប្រាក់កាស គឺជាឧបសគ្គធំមួយ ដែលធ្វើឲ្យពួកគេមិនអាចឆ្លើយតបចំពោះតម្រូវការផ្នែកសិក្សា និងការអភិវឌ្ឍរបស់កុមារកំព្រាទាំងនេះ។ កុមារទាំងនេះច្រើនតែត្រូវបានធ្លាក់ចូលក្នុងស្ថានភាពពលកម្មកុមារ ហើយពុំបានទទួលការឃុំគ្រងឬការថែទាំពីឪពុកម្តាយឡើយ។ នេះជាកត្តាបន្ទុចបង្អាក់ដល់ការលូតលាស់ និងការអភិវឌ្ឍរបស់ពួកគេ ហើយជារឿយៗ អាចមានផលប៉ះពាល់ជាអវិជ្ជមានមកលើទំនុកចិត្តរបស់ពួកគេ និង/ឬរូបភាពដែលពួកគេមានអំពីខ្លួនឯង។ ពាក់ព័ន្ធជាមួយនឹងកុមារដែលគេបោះបង់ចោលឲ្យរស់នៅអនាថាតាមផ្លូវវិញ គ្រួសារ ៤៣,៥ ភាគរយ លើកឡើងថា កុមារទាំងនោះទទួលរងការរំលោភបំពានពីសមាជិកសហគមន៍ ហើយពុំទទួលបានការយកចិត្តទុកដាក់ផ្នែកអភិវឌ្ឍរបស់គេឡើយ។

### ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ចំណុចល្អគួរឲ្យកត់សម្គាល់គឺថា គ្រួសារក្នុងប្រទេសកម្ពុជាជឿថា សាច់ញាតិជិត ឬសមាជិកគ្រួសារតែមួយមានការទទួលខុសត្រូវយកកុមារកំព្រាមកចិញ្ចឹម។ ប៉ុន្តែបច្ចុប្បន្ននេះ វាបានក្លាយជាការរំពឹងទុកមួយក្នុងសង្គម ហើយគ្រួសារជាច្រើនយកកូនកំព្រាមកចិញ្ចឹមទាំងខ្លួនពុំមានមធ្យោបាយ ដើម្បីគាំទ្រដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារនោះ។ ចាំបាច់ត្រូវមានការបង្កើនការយល់ដឹងរបស់សមាជិកសហគមន៍អំពីភាពចាំបាច់ដើម្បីរៀបចំផែនការអនាគតរបស់កុមារ មុនពេលយកកូននោះមកចិញ្ចឹម។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការគៀងគរចលនាសហគមន៍ឲ្យរួមគ្នាបន្តឃ្លាំមើល ដើម្បីធានាថាផលប្រយោជន៍របស់កុមារពិតជាត្រូវបានការពារដោយឪពុកម្តាយធម៌របស់ពួកគេប្រាកដមែន ហើយឪពុកម្តាយធម៌ទាំងនោះយកកុមារទៅចិញ្ចឹម បន្ទាប់ពីបានជូនដំណឹងដល់អាជ្ញាធរឬស្ថាប័នរដ្ឋ ដែលមានតួនាទីបញ្ជាក់ថា គ្រួសារដែលត្រូវបានយកកុមារទៅចិញ្ចឹមនេះពិតជាមានសមត្ថភាពបំពេញសិទ្ធិជាមូលដ្ឋានរបស់កុមារពិតប្រាកដមែន។ លើសពីនេះ ក្នុងករណីកុមារដែលគេបោះបង់ចោលឲ្យរស់នៅអនាថា ចាំបាច់ត្រូវមានការបង្កើនការយល់ដឹងដល់សហគមន៍ ដើម្បីឲ្យពួកគេមានការយល់ដឹងដូចៗគ្នាថា កុមារទាំងនេះគឺស្ថិតក្រោមការទទួលខុសត្រូវរបស់ពួកគេ។ ការបង្កើនការយល់ដឹងរបស់សហគមន៍ និងប្រធានសហគមន៍ ឲ្យចេះទំនាក់ទំនងរវាងកុមារដែលរស់នៅអនាថា ជាមួយនឹងស្ថាប័នដែលធ្វើការងារនេះ គឺជាការចាំបាច់ ដើម្បីឲ្យកុមារទាំងនេះទទួលបានការថែទាំ និងកិច្ចការពារដែលចាំបាច់។

### បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

រដ្ឋាភិបាលបានព្យាយាមលើកកម្ពស់ជីវភាពរបស់កុមារកំព្រា និងកុមារដែលត្រូវបានគេបោះបង់ចោល

តាមរយៈការខិតខំប្រឹងប្រែងធ្វើសមាហរណកម្មពួកគេចូលទៅក្នុងសង្គមវិញ។ កន្លងមក មានការដាក់ឲ្យអនុវត្តគោលនយោបាយស្តីពីការផ្តល់ការថែទាំជំនួសដល់កុមារ បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសសម្រាប់កុមារ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ដែលឯកសារទាំងនេះរួមគ្នាផ្តល់ការណែនាំ និងដាក់ចេញនូវក្របខ័ណ្ឌគតិយុត្តិ សម្រាប់ទម្រង់នានានៃការផ្តល់ការថែទាំជំនួស។ យូនីសេហ្វកំពុងសម្របសម្រួលដំណើរការសមាហរណកម្មកុមារទៅក្នុងគ្រួសារ និងសហគមន៍ក្នុងខេត្តរាជធានីចំនួន៥ដូចជា ទីក្រុងភ្នំពេញ ខេត្តព្រះសីហនុ កណ្តាល សៀមរាប និងបាត់ដំបង។ អនុក្រឹត្យលេខ១១៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងការប្តេជ្ញាចិត្តជាលាយល័ក្ខណ៍អក្សររបស់ក្រសួងនេះ គឺជាឯកសារដែលផ្តល់ការណែនាំដល់ការអនុវត្តដំណើរការនេះ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

បញ្ហាប្រឈមចម្បងៗរួមមាន ការអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ពាក់ព័ន្ធនឹងការសុំកូន និងការគ្រប់គ្រងមណ្ឌលកុមារកំព្រានៅមានកម្រិតខ្សោយ។ បើទោះបីជាមានបញ្ញត្តិច្បាប់ និងយន្តការសម្រាប់គ្រប់គ្រងមណ្ឌលទាំងនេះក៏ដោយ ក៏នៅមានចំណុចខ្វះខាត ផ្នែកការទទួលខុសត្រូវ ហើយធ្វើឲ្យកុមារត្រូវរស់នៅក្នុងបរិយាកាសដែលពុំមានសុវត្ថិភាព។ ការសុំកូនភាគច្រើនធ្វើឡើងមិនផ្លូវការ ហើយមានការសន្មត់ថាកុមារដែលគ្រួសារយកទៅចិញ្ចឹម មិនចាំបាច់មានការឃ្លាំមើលពីរដ្ឋឡើយ។ តាមពិតពុំមានប្រព័ន្ធផ្លូវការសម្រាប់ពិនិត្យតាមដានការលូតលាស់ និងការអភិវឌ្ឍរបស់កុមារដែលត្រូវបានគេយកទៅចិញ្ចឹមនោះឡើយ។ គួរមានការតម្រូវឲ្យគ្រួសារបែបនោះអនុវត្តតាមនីតិវិធីផ្លូវការដើម្បីយកកុមារទាំងនេះទៅចិញ្ចឹម ដើម្បីធានាថារដ្ឋាភិបាលអាចតាមដានដឹងពីសុខុមាលភាពរបស់ពួកគេ។ ការពុំមានការគ្រប់គ្រងបែបនេះ គឺជាកត្តាដែលធ្វើឲ្យកុមារទាំងនេះងាយរងការមិនអើពើ និងការកេងប្រវ័ញ្ច។

រដ្ឋាភិបាលក៏អាចប្រើប្រាស់ការគាំទ្រ សម្រាប់បង្កើតប្រព័ន្ធមួយ ដើម្បីតាមដានការលូតលាស់ និងការអភិវឌ្ឍកុមារ ក្រោយពេលមានការសុំកូនផ្លូវការឬស្របច្បាប់ផងដែរ។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

ការធ្វើសមាហរណកម្មកុមារដែលពុំបានទទួលការថែទាំ ទៅក្នុងរចនាសម្ព័ន្ធរបស់គ្រួសារ ឬផ្ទះរបស់ឪពុកម្តាយធម៌ ឬមណ្ឌលថែទាំ គឺជាការងារមួយទៀត ដែលកម្មវិធី 3PC ផ្តោតការយកចិត្តទុកដាក់។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ការពិភាក្សាជាមួយអង្គការសង្គមស៊ីវិល រំលេចឲ្យឃើញពីភាពចាំបាច់ឲ្យមានការពិនិត្យតាមដានជាប្រចាំលើមណ្ឌលកុមារកំព្រា និងការអភិវឌ្ឍសមត្ថភាពអ្នកថែទាំកុមារផងដែរ ដើម្បីឲ្យពួកគេមានជំនាញជួយដល់ការធ្វើសមាហរណកម្មកុមារ។ ដូច្នេះ អង្គការសង្គមស៊ីវិលមិនអាចផ្តល់ការឆ្លើយតបឲ្យបានល្អដល់កុមារកំព្រា ឬកុមារដែលរស់នៅអនាថាឡើយ។ ចំណុចសំខាន់បំផុតគឺ សូម្បីតែគ្មានការគ្រប់គ្រងត្រឹមត្រូវក៏ដោយ មណ្ឌលកុមារកំព្រា និងមណ្ឌលថែទាំកុមារបច្ចុប្បន្ន ពុំមានសេវាគ្របដណ្តប់ និងសមត្ថភាពផ្តល់ការថែទាំដល់កុមារកំព្រា និងកុមារអនាថាឡើយ។ ពាក់ព័ន្ធជាមួយនឹងចំណុចនេះ អង្គការសង្គមស៊ីវិលត្រូវការការគាំទ្របន្ថែមក្នុងការរៀបចំយុទ្ធសាស្ត្រវែងឆ្ងាយសម្រាប់ សម្រាប់គ្រប់គ្រងមណ្ឌលកុមារកំព្រា។ អង្គការទាំងនេះក៏ត្រូវការការគាំទ្រ ដើម្បីបង្កើតទំនាក់ទំនងឲ្យបានកាន់តែជិតស្និទបន្ថែមទៀតជាមួយរដ្ឋាភិបាលផងដែរ ដើម្បីឲ្យអង្គការទាំងនេះអាចបំពេញតួនាទីសំខាន់ ក្នុងការពិនិត្យតាមដានការលូតលាស់ និងការអភិវឌ្ឍកុមារកំព្រា (តាមមណ្ឌលកុមារកំព្រា និងក្រោយការសុំកូន)។ ស្ថានភាពទាំងមូលក៏ទទួលបានប្រយោជន៍យ៉ាងច្រើនផងដែរ ប្រសិនបើមានគំរូសម្រាប់ផ្តល់ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពភ្នាក់ងារសង្គមកិច្ច ក្នុងនាមពួកគេជាអ្នកផ្តល់ការថែទាំដល់កុមារទាំងនេះ។

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ការប្រើបំពានសារធាតុញៀន វប្បធម៌ទំនើង និងបទល្មើសអនីតិជន

## ស្ថានភាពបច្ចុប្បន្ន៖

ការប្រើបំពានសារធាតុញៀន ក្នុងចំណោមយុវជននៅកម្ពុជា គឺកើតមានជាទូទៅ ដោយមានអ្នកឆ្លើយតបប្រមាណជា ៨១,៤ ភាគរយ រាយការណ៍ថា ពួកគេប្រើគ្រឿងស្រវឹង (ម្តងម្កាល)។ ក្នុងចំណោមក្មេងជំទង់រស់នៅតាមតំបន់ក្រីក្រក្នុងទីក្រុងភ្នំពេញ ៩៣,៨ ភាគរយ ធ្លាប់ប្រើគ្រឿងញៀនយ៉ាងហោចណាស់ក៏ម្តងដែរ ក្នុងឆ្នាំកន្លងទៅ។ ការពិភាក្សាក្រុមគោលដៅជាមួយសមាជិកសហគមន៍ បង្ហាញថា ក្មេងប្រុសងាយនឹងប្រើគ្រឿងស្រវឹង (ឬគ្រឿងញៀន) ជាងក្មេងស្រីផងដែរ។

យុវជនទំនើងត្រូវបានគេដឹងថាកំពុងមានវត្តមាននៅច្រើនកន្លែងក្នុងទីក្រុងភ្នំពេញ។ ក្នុងចំណោមក្មេងជំទង់រស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញទាំងអស់ ជាងពាក់កណ្តាល (៥២,៤ ភាគរយ) មានមិត្តភក្តិ ឬអ្នកស្គាល់គ្នា (ក្នុងក្រុមដែលមានអាយុស្របាលគ្នា) ជាសមាជិករបស់ក្រុមទំនើង។ ក្រុមទំនើងទាំងនេះតែងតែចូលលួចតាមផ្ទះសម្បែងប្រជាជន បំផ្លាញទ្រព្យសម្បត្តិឯកជន ឬសាធារណៈ ហើយជារឿយៗ តែងចូលរួមក្នុងទំនាស់ប្រដាប់អាវុធជាមួយនឹងសមាជិករបស់ក្រុមទំនើងផ្សេងទៀត។

## ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

ជារឿយៗ ក្មេងជំទង់តែងធ្វើត្រាប់តាមការប្រព្រឹត្តរបស់ឪពុកម្តាយរបស់ខ្លួន។ ក្មេងជំទង់ប្រមាណជា ៦៥,៤ ភាគរយ បានរាយការណ៍ថា ឪពុកម្តាយរបស់ពួកគេក៏ជាអ្នកប្រើប្រាស់គ្រឿងស្រវឹងដែរ។ ការពិភាក្សាក្រុមគោលដៅជាមួយក្មេងជំទង់បង្ហាញថា ឪពុកម្តាយរបស់ពួកគេបើកឲ្យពួកគេប្រើប្រាស់គ្រឿងស្រវឹង។ នេះបង្ហាញថា ទង្វើបែបនេះត្រូវបានចាត់ទុកថាជារឿងធម្មតាក្នុងសហគមន៍ ហើយបើទោះបីជាឪពុកម្តាយពុំបានលើកទឹកចិត្តកូនរបស់ខ្លួនឲ្យប្រើគ្រឿងស្រវឹងយ៉ាងណាក៏ដោយ ពួកគេជាច្រើននាក់ក៏មិនបានហាមកូនមិនឲ្យប្រើគ្រឿងស្រវឹងដែរ។ ក្មេងជំទង់ ១០,៥ ភាគរយ លើកឡើងថា សមាជិកគ្រួសារពួកគេជាអ្នកប្រើប្រាស់គ្រឿងញៀន។ ការពិភាក្សាក្រុមគោលដៅបង្ហាញថា សមាជិកសហគមន៍យល់ពីផលវិបាកនៃការប្រើប្រាសគ្រឿងញៀន ប៉ុន្តែភាពងាយស្រួលរកនៃគ្រឿងញៀន និងកត្តាជំរុញផ្សេងទៀតបង្ខំឲ្យពួកគេប្រព្រឹត្តទង្វើទាំងនេះ។

## ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ចាំបាច់ត្រូវមានការរៀបចំយុទ្ធនាការបង្កើនការយល់ដឹង និងគៀងគរចលនាសង្គមប្រឆាំងនឹងការប្រើបំពានសារធាតុ ទើបអាចឲ្យមានការផ្លាស់ប្តូរឥរិយាបថក្នុងសហគមន៍ទាំងមូល ចំពោះការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹងបាន។

សម្រាប់ករណីវប្បធម៌ទំនើង ចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់លើឥរិយាបថ ដែលស្ថិតនៅពីក្រោយកត្តាជំរុញទាំងនេះ។ នេះរួមមានការបង្កើតយន្តការតាមសាលារៀន ដែលផ្តល់លទ្ធភាពឲ្យក្មេងជំទង់នៅបន្តរៀនសូត្រក្នុងសាលារៀន និងលើកទឹកចិត្តឪពុកម្តាយឲ្យចូលរួមកាន់តែស៊ីជម្រៅក្នុងការអប់រំ ការអភិវឌ្ឍ និងការចិញ្ចឹមបីបាច់កូនរបស់ខ្លួន។ ចាំបាច់ត្រូវធានាថា កុមារនឹងមិនចាប់ផ្តើមចូលរួមក្នុងការប្រើបំពានគ្រឿងស្រវឹង ការប្រើបំពានគ្រឿងញៀន ឬក្លាយជាសមាជិកក្រុមទំនើងឡើយ តាមរយៈការឃុំគ្រងត្រឹមត្រូវជាដើម។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

ក្នុងប្រទេសកម្ពុជា នៅមិនទាន់មានច្បាប់ ដែលកំណត់ពីអាយុអប្បបរមាសម្រាប់ប្រើប្រាស់គ្រឿងស្រវឹងនៅឡើយទេ។ កាលពីពេលថ្មីៗនេះ ប្រទេសកម្ពុជាបានដាក់ឲ្យអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលចែងពីការបង្កើតប្រព័ន្ធដាច់ដោយឡែកមួយ សម្រាប់បទល្មើសដែលប្រព្រឹត្តដោយកុមារ ដូចជាបទល្មើសដែលប្រព្រឹត្តដោយក្មេងជំទង់ ដែលចូលរួមក្នុងក្រុមទំនើងជាដើម។ លើសពីនេះ ក៏មានច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

ដែលផ្តោតលើការបង្ការការប្រើប្រាស់គ្រឿងញៀនផងដែរ។

ខណៈពេលដែលមាត្រា៣៨នៃក្រមព្រហ្មទណ្ឌមានកំណត់អាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ នៅអាយុ១៨ឆ្នាំ ក្រមនេះអនុញ្ញាតឲ្យមានការផ្តន្ទាទោសអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅក្រោមស្ថានទំងន់ទោសពិសេស និងទៅតាមលក្ខណៈនៃបទល្មើសដែលត្រូវបានប្រព្រឹត្ត។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ចំណុចខ្វះខាតក្នុងការអនុវត្តរួមមាន ការខ្វះយន្តការសម្រាប់អនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងការពុំមានមណ្ឌលស្តារនីតិសម្បទាជាប្រព័ន្ធឲ្យបានទូលំទូលាយ សម្រាប់ធ្វើសមាហរណកម្មអ្នកដែលរងគ្រោះដោយសារការញៀនគ្រឿងញៀន និងគ្រឿងស្រវឹង។

កន្លងមក ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាជួបប្រទះនឹងបញ្ហា ង្វះសមត្ថភាពហើយកុមារដែលមានទំនាស់ជាមួយច្បាប់ (ក្នុងនាមជាអ្នកប្រព្រឹត្តអំពើល្មើសច្បាប់ ឬជាជនរងគ្រោះ) ពុំបានទទួលការថែទាំ និងការការពារឲ្យបានគ្រប់គ្រាន់ឡើយ។ ពួកគេច្រើនត្រូវបានឃុំខ្លួនជាមួយនឹងមនុស្សពេញវ័យ ដែលធ្វើឲ្យពួកគេកាន់តែប្រឈមនឹងហានិភ័យឬភាពងាយរគ្រោះជាច្រើន និងមានលទ្ធភាពកាន់តែតិច ដើម្បីផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ។ ពេលកំពុងជាប់ពន្ធនាគារ កុមារទាំងនេះកាន់តែងាយទទួលរងការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។

ពេលជាប់ឃុំឃាំង ពួកគេក៏មានលទ្ធភាពតិចតួច ឬពុំមានលទ្ធភាពសោះតែម្តង ក្នុងការទទួលបានការអប់រំក្នុង ឬក្រៅប្រព័ន្ធ ឬការអប់រំវិជ្ជាជីវៈ។ កុមារទាំងនេះមិនអាចអភិវឌ្ឍជំនាញដែលចាំបាច់ ដើម្បីឲ្យពួកគេអាចរកចំណូលបានដោយខ្លួនឯងទេ ក្រោយពេលត្រូវបានដោះលែងចេញពីពន្ធនាគារ។ ជាលទ្ធផល ពួកគេច្រើនតែវិលទៅរកជីវិតប្រព្រឹត្តបទល្មើសវិញ ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។

ខណៈពេលដែលការដាក់ឲ្យអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជននឹងនាំឲ្យមានការបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនមួយ សម្រាប់ដោះស្រាយករណីកុមារដែលមានទំនាស់ជាមួយច្បាប់ គេក៏ចាំបាច់ត្រូវធានាឲ្យមានការអនុវត្តច្បាប់នេះឲ្យប្រសិទ្ធភាពផងដែរ។ ពាក់ព័ន្ធនឹងចំណុចនេះរដ្ឋាភិបាលត្រូវការការគាំទ្រ ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល សម្រាប់ចៅក្រម មេធាវី និងមន្ត្រីនគរបាល។ ស្របពេលដែលរដ្ឋាភិបាលបង្កើតហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់គាំទ្រដល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌថ្មីនេះ រដ្ឋាភិបាលក៏ត្រូវការការគាំទ្រ ក្នុងការរៀបចំយុទ្ធសាស្ត្រដើម្បីផ្តល់ឲ្យអនីតិជននូវឱកាសទទួលបានការអប់រំក្នុងប្រព័ន្ធ និង/ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្មអនីតិជនចូលទៅក្នុងសង្គម ការផ្តល់ប្រឹក្សាដល់ពួកគេ និងការគាំពារផ្នែកចិត្តសង្គមផងដែរ ។ល។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

អង្គការសង្គមស៊ីវិលនានា ដូចជា អង្គការ Action Aid មូលនិធិកុមារកម្ពុជា Friends International និងអង្គការ People in Need ជាដើម បានផ្តល់ការគាំទ្របន្ទាន់ ដល់កុមារ និងគ្រួសារ ដែលជួបការលំបាក ដោយសារតែពួកគេប្រើបំពានសារធាតុ ដែលក្នុងនោះរួមមាន កម្មវិធីប្តូរម្ជុល និងស៊ីរ៉ាំង ដើម្បីកាត់បន្ថយហានិភ័យមេរោគ/ជំងឺអេដស៍ផងដែរ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងការញៀនគ្រឿងញៀនដោយផ្ទាល់ អង្គការសង្គមស៊ីវិលវាយតម្លៃអ្នកប្រើគ្រឿញៀន យកពួកគេទៅដាក់ក្នុងមណ្ឌលបន្សាបគ្រឿងញៀន ផ្តល់សេវាស្តារនីតិសម្បទា ដែលក្នុងនោះមានសេវាប្រឹក្សាផ្លូវចិត្ត និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្មចូលទៅក្នុងសង្គម និងការថែទាំក្រោយទទួលបានសេវានេះ ដើម្បីបង្ការការលាប់មកវិញ។ អង្គការសង្គមស៊ីវិលក៏ធ្វើការងារជាមួយមន្ត្រីអនុវត្តច្បាប់ ដើម្បីកំណត់រកក្មេងជំទង់ជាសមាជិកក្រុមទំនើង ដែលកំពុងរងគ្រោះដោយសារការញៀនគ្រឿងញៀនផងដែរ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ដោយសារតែបញ្ហាខ្វះថវិកា អង្គការសង្គមស៊ីវិលត្រូវធ្វើការងារបៀបក្រៅផ្លូវការ ដោយពុំមានហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស សម្រាប់ធ្វើការងារនេះក្នុងទ្រង់ទ្រាយធំឡើយ។ បុគ្គលិកដែលមានជំនាញសម្រាប់ធ្វើការងារជាអ្នកផ្តល់ប្រឹក្សា នៅមិនទាន់មានចំនួនគ្រប់គ្រាន់នៅឡើយ ហើយតួនាទីនេះត្រូវបំពេញដោយបុគ្គលពុំមានសមត្ថភាព ប៉ុន្តែជាអ្នកដែលមានការតាំងចិត្តក្នុងការធ្វើការងារនេះ។ជាមួយនឹងការផ្លាស់ប្តូរក្នុងច្បាប់ពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌អនីតិជនក្នុងប្រទេស អង្គការសង្គមស៊ីវិលអាចបំពេញតួនាទីសំខាន់ ក្នុងការផ្តល់ការថែទាំដល់អនីតិជន។ អង្គការសង្គមស៊ីវិលអាចបំពេញតួនាទីសំខាន់ ក្នុងការផ្តល់ការរៀនសូត្រ ការអភិវឌ្ឍ និងការធ្វើសមាហរណកម្មកុមារទាំងនេះ។ ប៉ុន្តែការបំពេញតួនាទីនេះអាចធ្វើទៅបាន តែប្រសិនបើអង្គការទាំងនោះអាចចូលរួមក្នុងដំណើរការប្រែក្លាយច្បាប់ថ្មីនេះ ឲ្យទៅជាកំណែទម្រង់ឬការផ្លាស់ប្តូរជាក់ស្តែងតែប៉ុណ្ណោះ។ អង្គការសង្គមស៊ីវិលជឿថា ទីភ្នាក់ងារអន្តរជាតិអាចបំពេញតួនាទីសំខាន់ ក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ អង្គការទាំងនេះក៏ជឿផងដែរថា ពួកគេពុំមានបុគ្គលិក និងហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់ សម្រាប់ផ្តល់ការគាំទ្រក្នុងទ្រង់ទ្រាយធំឡើយ។ អង្គការទាំងនេះអាចជំនះភាពកំហិតទាំងនេះបាន ប្រសិនបើពួកគេទទួលបានការគាំទ្រ សម្រាប់រៀបចំយុទ្ធសាស្ត្ររៃអង្គាសប្រាក់ និងបណ្តុះបណ្តាលភ្នាក់ងារសង្គមកិច្ច និងអ្នកផ្តល់ប្រឹក្សាដល់កុមារ។

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ការទទួលបានសេវាសុខភាពផ្លូវភេទ និងបន្តពូជ

## ស្ថានភាពបច្ចុប្បន្ន៖

ការរៀបអាពាហ៍ពិពាហ៍របស់ក្មេងជំទង់ ឬការឆាប់រៀបអាពាហ៍ពិពាហ៍ពេក ត្រូវបានចាត់ទុកថាជាហានិភ័យមួយ ក្នុងចំណោមហានិភ័យសំខាន់ៗ ដែលក្មេងជំទង់នៅកម្ពុជាជួបប្រទះ។ សហគមន៍គិតថាក្រុមអាយុពី ១០ ទៅ១៩ឆ្នាំ គឺជាក្រុមដែលមានវ័យក្មេងពេកសម្រាប់ការរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែ មានគ្រួសារយ៉ាងហោចណាស់ ៩,៩ ភាគរយ បានលើកឡើងថា ពួកគេធ្លាប់រៀបការឲ្យក្មេងជំទង់ក្នុងគ្រួសាររបស់ពួកគេ នៅពេលដែលក្មេងនោះនៅអាយុក្រោម១៩ឆ្នាំនៅឡើយ។

ការទទួលបានព័ត៌មានត្រឹមត្រូវតិចតួចអំពីសេវាសុខភាពផ្លូវភេទ និងបន្តពូជ នាំឲ្យក្មេងជំទង់មានផ្ទៃពោះដោយពុំបានគ្រោងទុក និងធ្វើឲ្យមនុស្សវ័យក្មេងទាំងនោះកាន់តែងាយរងគ្រោះ ដោយសារជំងឺកាមរោគ មេរោគ/ជំងឺអេដស៍។ ការមានផ្ទៃពោះក្នុងវ័យជំទង់បង្កហានិភ័យសុខភាពដល់ក្មេងស្រី ដែលជារឿយៗ ពុំបានទទួលសេវាថែទាំផ្ទៃពោះ ហើយមានឪពុកម្តាយជិត ៥៦ ភាគរយ (ដែលបានរៀបការឲ្យកូនស្រី មុនអាយុ១៨ឆ្នាំ) បាននិយាយថា កូនស្រីរបស់ពួកគេប្រឈមនឹងបញ្ហាសុខភាព ក្នុងកំឡុងពេលមានផ្ទៃពោះ។

## ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

ក្នុងចំណោមគ្រួសារដែលលើកឡើងពីការរៀបអាពាហ៍ពិពាហ៍ឲ្យក្មេងជំទង់ ប្រហែលជា ៩២,៩ ភាគរយ លើកឡើងថា ពួកគេឲ្យក្មេងជំទង់រៀបការ ដោយសារតែសម្ពាធសង្គម ឬរៀបការឲ្យពួកគេ ទៅតាមប្រពៃណី និងជំនឿរបស់គ្រួសារ។ ចំណុចសំខាន់គួរឲ្យកត់សម្គាល់ គឺមានគ្រួសាររស់នៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញប្រមាណជា ២០,៥ ភាគរយ ពុំបានដឹងថា រដ្ឋាភិបាលបានកំណត់អាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍ សម្រាប់បុរស (២០ឆ្នាំ) និងសម្រាប់ស្ត្រី (១៨ឆ្នាំ) នោះទេ។

ក្មេងជំទង់ទទួលបានការអប់រំជាផ្លូវការតិចតួចអំពីផ្លូវភេទ ហើយមានក្មេងជំទង់ប្រមាណជា ៦០ ភាគរយលើកឡើងថា ប្រធានបទនេះមិនដែលត្រូវបានគេយកមកបង្រៀនក្នុងសាលាឡើយ។ ដោយហេតុនេះហើយពួកគេមានការយល់ដឹងតិចតួចអំពីផលអវិជ្ជមាននៃការរួមភេទដោយគ្មានសុវត្ថិភាព ភាពចាំបាច់ដើម្បីប្រើប្រាស់មធ្យោបាយពន្យារកំណើត និងរបៀបដែលការរួមភេទគ្មានសុវត្ថិភាពអាចឲ្យពួកគេប្រឈមនឹងការឆ្លងជំងឺកាមរោគ ឬមេរោគអេដស៍។ ដូច្នេះ ឫសគល់នៃបញ្ហា គឺការខ្វះការយល់ដឹងជាទូទៅក្នុងចំណោមក្មេងជំទង់ និងឪពុកម្តាយរបស់ពួកគេ។ បញ្ហានេះរឹតតែធ្ងន់ធ្ងរបន្ថែមទៀត ដោយសារតែឪពុកម្តាយពុំមានភាពងាយស្រួលក្នុងការនិយាយជាមួយកូនៗរបស់ពួកគេអំពីបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

## ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ចាំបាច់ត្រូវមានការបង្កើនការយល់ដឹងដល់សហគមន៍អំពីផលអវិជ្ជមាននៃការរៀបការឲ្យកុមារ និងផលប៉ះពាល់ដល់សុខភាពម្តាយ បណ្តាលមកពីការមានផ្ទៃពោះនៅវ័យក្មេង។ គប្បីមានការរៀបចំយុទ្ធនាការផ្លាស់ប្តូរឥរិយាបថបែបច្នៃប្រឌិតថ្មី ដើម្បីលុបបំបាត់បម្រាមក្នុងសង្គម ដែលហាមឃាត់មិនឲ្យមានការពិភាក្សាអំពីរឿងភេទ ក្នុងសហគមន៍។ យុទ្ធនាការទាំងនេះចាំបាច់ត្រូវផ្តោតលើតួនាទី ដែលអ្នកដឹកនាំសហគមន៍ និងចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ អាចបំពេញបាន ក្នុងការតតាំងទៅនឹងបទដ្ឋានវប្បធម៌ដែលមានស្រាប់ និងពិនិត្យលើករណីជាក់ស្តែង។

លើសពីនេះ ក៏ចាំបាច់ត្រូវមានការបង្កើនការយល់ដឹងអំពីបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ តាមរយៈមេរៀនអប់រំតាមសាលារៀនផងដែរ។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

មាត្រា៣៦នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទចែងថា ទោសសម្រាប់អ្នករួមភេទជាមួយអនីតិជន (អាយុក្រោម១៥ឆ្នាំ) គឺត្រូវជាប់ពន្ធនាគារពី៥ ដល់១០ឆ្នាំ។ កុមារដែលមានអាយុពី ១៦ ដល់១៨ឆ្នាំ អាចរៀបការបាន ប្រសិនបើឪពុកម្តាយរបស់ពួកគេយល់ព្រម ហើយប្រសិនបើគេអាយុលើសពី ១៨ ឆ្នាំ ពួកគេមានសេរីភាពក្នុងការរៀបអាពាហ៍ពិពាហ៍។ លើសពីនេះ ការរៀបការរបស់កុមារអាយុក្រោម១៦ឆ្នាំ អាចជាសកម្មភាពស្របច្បាប់ ប្រសិនបើក្មេងប្រុសធ្វើឲ្យក្មេងស្រីមានផ្ទៃពោះ ហើយពួកគេទាំងពីរនាក់ព្រមព្រៀងគ្នារៀបការ។

យុទ្ធសាស្ត្រជាតិស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ២០១៣-២០១៦ ទីពីរ មានគោលបំណងចំនួនបី៖ បង្កើនសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ លើកកម្ពស់សេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ តាមរយៈការពង្រឹងយន្តការផ្តល់សេវា និងដំណើរការអភិបាលកិច្ច និងកែលម្អការគ្រប់គ្រងព័ត៌មានសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ដែលជាផ្នែកមួយនៃការពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាល។ កាលពីឆ្នាំ២០១៣ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តលើកម្មវិធីសិក្សាដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ សម្រាប់យុវជន ដែលរៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ក៏ដូចជាអ្នកដែលមិនស្ថិតក្នុងការអប់រំក្នុងប្រព័ន្ធ។ កម្មវិធីសិក្សានេះផ្តោតការយកចិត្តទុកដាក់លើព័ត៌មានអំពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ រួមនឹងមេរោគ/ជំងឺអេដស៍ផងដែរ។ ក្រសួងកិច្ចការនារីក៏បានដាក់ឲ្យអនុវត្តកម្មវិធីមួយ ដើម្បីបង្កើនទំនាក់ទំនងរវាងម្តាយ និងកូនស្រី ពាក់ព័ន្ធនឹងការយល់ដឹងអំពីយេនឌ័រ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ។ បញ្ហានៃការរៀបអាពាហ៍ពិពាហ៍របស់កុមារកាន់តែមានសភាពធ្ងន់ធ្ងរ ដោយសារតែពុំមានគូស្រករច្រើនទេដែលមកចុះសំបុត្រអាពាហ៍ពិពាហ៍ជាផ្លូវការនោះ។ នេះកាន់តែបង្ករបញ្ហាស្មុគស្មាញបន្ថែមទៀតដល់ការគ្រប់គ្រងកូន ក្នុងករណីដែលមានការបែកផ្លូវគ្នា ដូចជា ការមិនមានការឧបត្ថម្ភអាហារកិច្ច ក្នុងករណីដែលក្មេងស្រីនោះត្រូវបានប្តី និងសាច់ថ្លៃបោះបង់ចោល ។ល។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ចាំបាច់ត្រូវតែមានការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រដែលមានស្រាប់ ពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការរៀបអាពាហ៍ពិពាហ៍កុមារ ។ល។ ជាដើម។ ប៉ុន្តែ ការពិភាក្សាបឋមជាមួយមន្ត្រីរដ្ឋាភិបាល និងអង្គការសង្គម

ស៊ីវិលបង្ហាញថា ក្រៅពីការពិនិត្យលើបញ្ញត្តិដែលត្រូវបានចែងក្នុងច្បាប់នានា ចំណុចសំខាន់មួយទៀត គឺត្រូវវាយតម្លៃលើច្រកអនុវត្តច្បាប់ ដែលកំពុងប្រើប្រាស់បច្ចុប្បន្ន។ សាលារៀននៅមិនទាន់បានបញ្ចូលការអប់រំផ្លូវភេទពិតប្រាកដ ទៅក្នុងកម្មវិធីសិក្សាធម្មតាឡើយ ប៉ុន្តែជារឿយៗ សាលារៀនបែរជាជៀសវាងមិនផ្តល់ការអប់រំផ្លូវភេទទៅវិញ ដោយសារតែសម្ពាធពីសមាជិកសហគមន៍។ ស្ថានភាពនេះរឹតតែពិបាកទៅទៀត ដោយសារតែខ្វះការសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធនានា។ ក្រៅពីនេះ នៅមិនទាន់មានការកំណត់ស្ថាប័នណាមួយ ឲ្យធ្វើជាអាជ្ញាធរដឹកនាំ ដែលទទួលខុសត្រូវដោះស្រាយករណីរៀបអាពាហ៍ពិពាហ៍របស់កុមារនៅឡើយទេ។ ចាំបាច់ត្រូវមានការកំណត់ពីស្ថាប័នបែបនេះ និងផ្តល់ការគាំទ្រដល់ការងាររបស់ស្ថាប័ននេះតាមរយៈបណ្តាញស្ថាប័នដែលមានវត្តមាននៅតាមមូលដ្ឋានស្រាប់។ អ្នកដឹកនាំសហគមន៍ ឬអាជ្ញាធរមូលដ្ឋាន គួរចូលរួមជាមួយនឹងបណ្តាញនៅមូលដ្ឋានទាំងនេះ។

ពាក់ព័ន្ធនឹងចំណុចនេះ រដ្ឋាភិបាលអាចស្វែងរកជំនួយពីខាងក្រៅ ដើម្បីរៀបចំមេរៀនអប់រំផ្លូវភេទដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអនុវត្តមេរៀននេះតាមសាលារៀន។ ការបណ្តុះបណ្តាលគ្រូ គឺជាផ្នែកដ៏សំខាន់មួយ នៃការគាំទ្រដែលរដ្ឋាភិបាលចង់បាន។ វិធានការពិនិត្យលើករណីរៀបអាពាហ៍ពិពាហ៍កុមារគួរធ្វើវិមជ្ឈការទៅឲ្យអ្នកដឹកនាំសហគមន៍។ កញ្ចប់ឧបករណ៍សម្រាប់គៀងគរចលនាសហគមន៍ ឬបង្កើនការយល់ដឹងអំពីអំពើហិង្សាលើកុមារ ការជួញដូរមនុស្ស និង/ឬការរំលោភបំពានផ្លូវភេទ គួរបញ្ចូលបញ្ហាអាពាហ៍ពិពាហ៍កុមារផងដែរ និងគួរមានការជំរុញឲ្យសហគមន៍រៀបចំផែនការសកម្មភាពនៅកម្រិតសហគមន៍ ដើម្បីបញ្ឈប់មិនឲ្យមានអាពាហ៍ពិពាហ៍កុមារកើតឡើង។ គេមិនគួរយល់ច្រលំថា មេរៀនទាំងនេះគឺជាកិច្ចខិតខំប្រឹងប្រែងបង្កើនការយល់ដឹង ឬគៀងគរចលនាសហគមន៍នោះទេ។ មេរៀនទាំងនេះគួរគាំទ្រដល់ការបម្លែងចំណេះដឹងដែលកើតឡើងជាងមុន ជាសកម្មភាពជាក់លាក់ ដែលប្រធានសហគមន៍អាចពិនិត្យតាមដានជាប្រចាំបាន។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

អង្គការសង្គមស៊ីវិលបាននិងកំពុងធ្វើការងារជាដៃគូជាមួយរដ្ឋាភិបាល ដើម្បីផ្តល់សេវាថែទាំសុខភាពផ្លូវភេទ និងបន្តពូជប្រកបដោយគុណភាព និងងាយស្រួលប្រើប្រាស់ សម្រាប់ក្មេងជំទង់។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ភាពជាដៃគូដែលលើកឡើងខាងលើ មិនត្រូវបានរៀបចំចេញជាគំនិតផ្តួចផ្តើមដែលអនុវត្តទូទាំងរាជធានីខេត្តនោះទេ។ លើសពីនេះ ភាពជាដៃគូទាំងនេះក៏ពុំមាននិរន្តរភាពនោះដែរ។ ការពិភាក្សាជាមួយអង្គការសង្គមស៊ីវិលបង្ហាញថា កិច្ចខិតខំប្រឹងប្រែងបញ្ចប់បញ្ហាអាពាហ៍ពិពាហ៍កុមារនេះគឺនៅមានកម្រិតតិចតួចនៅឡើយ។

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ បញ្ហាសេវាអនាម័យមិនគ្រប់គ្រាន់

## ស្ថានភាពបច្ចុប្បន្ន៖

ទិន្នន័យប្រមូលដោយប្រើប្រាស់កម្រងសំណួរជាមួយគ្រួសារនៅតាមសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ បានបង្ហាញថា មានគ្រួសារប្រមាណជា ៣២,៥ ភាគរយ ពុំមានបង្គន់ប្រើប្រាស់ក្នុងផ្ទះឡើយ។ ប្រជាជនជាច្រើនគ្រួសារធ្លាប់មានបង្គន់នៅផ្ទះដែរ ប៉ុន្តែពួកគេបាត់បង់ទីលំនៅចាស់របស់ពួកគេ ហើយផ្ទះថ្មីរបស់ពួកគេពុំមានបង្គន់ឡើយ។ ការផ្លាស់ទីឬការបណ្តេញចេញញឹកញាប់ ឬការពុំមានសិទ្ធិកាន់កាប់ជាប់លាប់ ជាកត្តាបន្ទុចបង្អាក់មិនឲ្យគ្រួសារវិនិយោគលើបង្គន់ ដែលនាំឲ្យពួកគេត្រូវបន្ទោរបង់ពាសវាលពាសកាល។ ដូច្នេះ ការគ្រប់គ្រងសំណល់រឹងរាវបានក្លាយជាបញ្ហាដ៏សំខាន់ក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងដែលត្រូវដោះស្រាយ។

## ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

សមាជិកសហគមន៍ និងកូនៗរបស់ពួកគេភាគច្រើនលាងសម្អាតដៃជាទៀងទាត់ ក្រោយពេលញ៉ាំអាហាររួច ឬក្រោយពេលប្រើប្រាស់បង្គន់អនាម័យរួច។ ពួកគេដុសធ្មេញទៀងទាត់ និងយល់ពីសារៈសំខាន់នៃការមានបង្គន់អនាម័យប្រើប្រាស់។ ប៉ុន្តែក្នុងករណីភាគច្រើន ការយល់ដឹងជាវិជ្ជមានបែបនេះ មិនត្រូវបានប្រែក្លាយជាសកម្មភាពជាក់ស្តែងឡើយ ដោយសារតែការពុំមានបរិក្ខារគ្រប់គ្រាន់ ឬដោយសារតែពួកគេក្រពេក ពុំមានលទ្ធភាពសង់បង្គន់សម្រាប់ប្រើប្រាស់បាន។

## ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ចាំបាច់ត្រូវធ្វើការងារជាមួយនឹងក្មេងជំទង់ ដែលបើទោះបីជាពួកគេយល់ដឹងពីសារៈសំខាន់នៃការលាងសម្អាតដៃ ឬការដុសធ្មេញជាទៀងទាត់ក៏ដោយ ក៏ពួកគេពុំបានអនុវត្តជាក់ស្តែងដែរ ដោយសារតែឥរិយាបថរបស់ពួកគេ។ ដំណោះស្រាយល្អបំផុតសម្រាប់បញ្ហានេះ គឺការផ្តល់ការបណ្តុះបណ្តាលបំណិនជីវិត និងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងអំពីសុខភាពតាមសាលារៀន ដើម្បីទាញប្រយោជន៍ពីសម្ពាធជាវិជ្ជមានពីមិត្តភក្តិជុំវិញ ដើម្បីកែឥរិយាបថរបស់ពួកគេ។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

យុទ្ធសាស្ត្រស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យទឹកស្អាត និងអនាម័យ សម្រាប់ប្រទេសកម្ពុជា (ឆ្នាំ ២០១០) កន្លងមក មានការខិតខំប្រឹងប្រែងរៀបចំសេណារីយ៉ូវិនិយោគលើអនុវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដោយមានការប៉ាន់ប្រមាណចំណាយ សម្រាប់ប្រទេសទាំងមូល (ដែលគ្របដណ្តប់លើសហគមន៍ក្រីក្រក្នុងទីក្រុងផងដែរ)។ ប៉ុន្តែយុទ្ធសាស្ត្រនេះនៅមិនទាន់បានសាកល្បង បញ្ចប់ និងអនុវត្តក្នុងទ្រង់ទ្រាយធំនៅឡើយទេ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ការសម្របសម្រួលស្ថាប័ន និងតួអង្គនានាដែលធ្វើការផ្នែកអនាម័យ គឺជាបញ្ហាប្រឈមមួយ។ ចំណុចសំខាន់ជាងគេបំផុត គឺរដ្ឋាភិបាលផ្តល់ការទទួលស្គាល់ដល់សហគមន៍ក្រីក្រក្នុងទីក្រុងទាំងនេះ។ តំបន់តាំងទីលំនៅជាច្រើន នៅមិនទាន់ត្រូវបានទទួលស្គាល់នៅឡើយ ហើយការពិភាក្សាអំពីការផ្តល់បរិក្ខារអនាម័យដល់សហគមន៍ទាំងនេះ គឺជាការពិភាក្សាដែលមានប្រយោជន៍ ដោយសារតែសហគមន៍មួយចំនួនមិនទាន់មានឈ្មោះក្នុងឯកសារផែនការរបស់រដ្ឋាភិបាលនឡើយ។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

សាលារាជធានីភ្នំពេញពុំមានបញ្ជីឈ្មោះបច្ចុប្បន្នភាពនៃអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការងារខាងអនាម័យក្នុងរាជធានីភ្នំពេញឡើយ។ លើសពីនេះ ក៏ពុំមានការវាយតម្លៃផ្លូវការ ដើម្បីកំណត់ពីតួអង្គមិនមែនរដ្ឋ ដែលកំពុងប្រតិបត្តិការការងារក្នុងទីក្រុងនេះដែរ។ ជាធម្មតា ព័ត៌មាននេះគឺទទួលបានផ្អែកទៅតាមចំណេះដឹងរបស់មន្ត្រីក្រុង។ ចំណុចនេះក៏ជាអ្វីដែលសង្កេតឃើញ នៅតាមកម្រិតរដ្ឋបាលទាបៗ ដូចជាខណ្ឌ និងសង្កាត់ផងដែរ។

### បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ការងារអនាម័យត្រូវការការវិនិយោគមូលធនយ៉ាងច្រើន ហើយអង្គការសង្គមស៊ីវិលមានធនធានហិរញ្ញវត្ថុតិចតួចបំផុត ដើម្បីធ្វើការវិនិយោគបែបនេះ។ លើសពីនេះ មានអង្គការសង្គមស៊ីវិលតិចតួចបំផុត ដែលមានបុគ្គលិកជាវិស្វករសំណង់ ដូច្នេះជារឿយៗ ដំណោះស្រាយរបស់ពួកគេពុំមានលក្ខណៈសមស្របតាមលក្ខណៈបច្ចេកទេសឡើយ។ ដូច្នេះ ដើម្បីបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការអង្គការទាំងនេះត្រូវការធនធានហិរញ្ញវត្ថុ និងបុគ្គលិកបច្ចេកទេសបន្ថែមទៀត។

អង្គការសង្គមស៊ីវិលគិតថា ការងារដែលពួកគេអាចធ្វើបានល្អបំផុត គឺការគៀងគរចលនាសហគមន៍ឲ្យប្រឆាំងការបន្ទោរបង់ពាសវាលពាសកាល ដោយរដ្ឋាភិបាលអាចផ្តោតការយកចិត្តទុកដាក់លើការបង្កើតហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់។ ពួកគេមួយចំនួនជឿថា ការងាររបស់ពួកគេពាក់ព័ន្ធនឹងការគៀងគរចលនាសហគមន៍នេះ អាចធ្វើបានកាន់តែល្អប្រសើរបន្ថែមទៀត ប្រសិនបើពួកគេទទួលបានការគាំទ្រ និងជំនួយពីស្ថាប័នខាងក្រៅ សម្រាប់រៀបចំគំរូគៀងគរចលនាសហគមន៍។ លើសពីនេះ មានស្ថាប័នមួយចំនួនបានរៀបចំឯកសារ សម្រាប់គៀងគរចលនាសហគមន៍រួចហើយ ហើយអង្គការសង្គមស៊ីវិលគិតថា ការទទួលបានឯកសារទាំងនេះនឹងជួយធានាថានឹងពុំមានការធ្វើការងារ និងការវិនិយោគត្រួតគ្នាឡើយ។

## ហានិភ័យពាក់ព័ន្ធនឹងការការពារកុមារ៖ ការខ្វះការទទួលបានទឹកស្អាតសម្រាប់ផឹក

### ស្ថានភាពបច្ចុប្បន្ន៖

ការផ្តល់ទឹកស្អាតសម្រាប់ផឹក អាចជាមធ្យោបាយដ៏មានប្រសិទ្ធភាព សម្រាប់ការពារប្រឆាំងនឹងការរាលដាលជំងឺឆ្លង។ ការពុំមានទឹកស្អាតសម្រាប់ផឹក ធ្វើឲ្យកុមារត្រូវប្រឈមនឹងជំងឺឆ្លងតាមទឹក ដូចជា ជំងឺរាក ជាដើម។

### ឥរិយាបថនិង/ឬការឆ្លើយតបរបស់សហគមន៍៖

ប្រជាពលរដ្ឋរស់នៅតាមតំបន់ក្រីក្រក្នុងទីក្រុងជាច្រើនគ្រួសារ ពុំមានប្រព័ន្ធចម្រោះទឹកឡើយ។ គ្រួសារដែលគ្មានប្រព័ន្ធចម្រោះទឹកភាគច្រើនលើកឡើងថា ការខ្វះថវិកាគឺជាមូលហេតុចម្បង ដែលធ្វើឲ្យពួកគេពុំមានប្រព័ន្ធចម្រោះទឹកប្រើប្រាស់ក្នុងផ្ទះ។

### ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ការបង្កើនការយល់ដឹងរបស់សហគមន៍អំពីភាពចាំបាច់នៃការដាំទឹក ឬការសម្អាតទឹកមុនពេលពិសានឹងនាំឲ្យមានការផ្លាស់ប្តូរជាក់ស្តែងនៅមូលដ្ឋាន។ ប៉ុន្តែចាំបាច់ត្រូវផ្លាស់ប្តូរការផ្តោតការយកចិត្តទុកដាក់លើបញ្ហាពាក់ព័ន្ធផ្សេងៗទៀត ដូចជា ភាពស្អាត និងការថែទាំប្រព័ន្ធចម្រោះទឹក ការរក្សាទឹកដែលដាំរួចក្នុងធុងដែលស្អាត មានគម្របត្រឹមត្រូវ ។ល។

### បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្ត៖

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញជាស្ថាប័នដែលទទួលបន្ទុកផ្គត់ផ្គង់ទឹកស្អាតក្នុងទីក្រុងភ្នំពេញទាំងមូល។ ប៉ុន្តែសហគមន៍ក្រីក្រក្នុងទីក្រុងជាច្រើននៅពុំទាន់ទទួលបានការកំណត់អត្តសញ្ញាណ ដូច្នេះ សហគមន៍ទាំងនោះពុំទាន់អាចភ្ជាប់ទៅនឹងបណ្តាញផ្គត់ផ្គង់ទឹកនៅឡើយ។ ពួកគេទទួលបានការផ្គត់ផ្គង់ទឹកពីអ្នកលក់ទឹកឯកជន។

### បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

អ្នកលក់ទឹកឯកជនច្រើនតែងគិតថ្លៃខ្ពស់ពេក ហើយមិនទាន់មានការគ្រប់គ្រងពួកគេឲ្យបានត្រឹមត្រូវឡើយ។ ចំណុចសំខាន់ជាងគេ គឺចាំបាច់ត្រូវកំណត់អត្តសញ្ញាណ និងផ្តល់ការទទួលស្គាល់ដល់តំបន់តាំងទីលំនៅរបស់សហគមន៍ក្រីក្រក្នុងទីក្រុងសិន ដើម្បីឲ្យពួកគេអាចភ្ជាប់

ទឹកពីបណ្តាញរបស់រដ្ឋ និងទទួលបានការផ្គត់ផ្គង់ទឹកពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបាន។ ដោយសារតែស្ថានភាពទីក្រុងមានការផ្លាស់ប្តូរ ចាំបាច់ត្រូវមានការធ្វើបច្ចុប្បន្នភាព ដើម្បីកំណត់អត្តសញ្ញាណតំបន់តាំងទីលំនៅរបស់សហគមន៍ក្រីក្រក្នុងទីក្រុង និងវាយតម្លៃពីចំនួនគ្រួសារដែលអាចភ្ជាប់បណ្តាញទឹករដ្ឋប្រើប្រាស់បាន។

ពាក់ព័ន្ធនឹងចំណុចនេះ រដ្ឋាភិបាលនឹងទទួលបានប្រយោជន៍ពីការផ្តល់ជំនួយពីស្ថាប័នខាងក្រៅ សម្រាប់ការសម្រួលផែនការប្រើប្រាស់ និងចែកចាយទឹកក្នុងទីក្រុង ដោយមានការប្រើប្រាស់គំរូអស់ចំណាយតិច ដើម្បីផ្គត់ផ្គង់ទឹកបំពង់ដល់គ្រួសារដែលកំពុងរស់នៅតាមតំបន់ក្រីក្រក្នុងទីក្រុង។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

ការងារបង្កើនការយល់ដឹង ដែលធ្វើដោយអង្គការសង្គមស៊ីវិល បានផ្តល់នូវផលជាវិជ្ជមាន និងរំលេចឲ្យឃើញយ៉ាងច្បាស់ពីតួនាទីដែលស្ថាប័នមិនរកប្រាក់ចំណេញទាំងនេះអាចបំពេញ ដើម្បីធានាយ៉ាងណាឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារក្នុងសហគមន៍អាចមានទឹកស្អាតសម្រាប់ផឹក។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ចាំបាច់ត្រូវមានការសិក្សាលម្អិត ដើម្បីកំណត់រកតំបន់ប្រឈមហានិភ័យ ដែលនៅសេសសល់ និងរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយ ជុំវិញតំបន់ទាំងនោះ។ អង្គការសង្គមស៊ីវិលមានធនធានគ្រប់គ្រាន់សម្រាប់រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយនេះ ប៉ុន្តែអង្គការសង្គមស៊ីវិលភាគច្រើនគិតថា វាកាន់តែមានប្រសិទ្ធភាពចំណាយបន្ថែមទៀត ប្រសិនបើការសិក្សានេះ ក៏ដូចជាឯកសារអប់រំផ្សព្វផ្សាយត្រូវបានបង្កើតឡើងនៅថ្នាក់កណ្តាល ហើយបែងចែកទៅឲ្យអង្គការសង្គមស៊ីវិលទាំងអស់ ដែលធ្វើការងារផ្នែកនេះ។

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ តាមសាលារៀន

## ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ការចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សានៅមានកម្រិតទាប

### ស្ថានភាពបច្ចុប្បន្ន៖

ការទទួលបានការអប់រំមត្តេយ្យសិក្សាផ្តល់ឲ្យកុមារនូវមូលដ្ឋានគ្រឹះ សម្រាប់ឲ្យកុមារអាចរៀនសូត្រ និងរីកចម្រើនកាន់តែឆាប់រហ័ស នៅឆ្នាំបន្តបន្ទាប់នៃការសិក្សារបស់គេ។ ការសិក្សានៅកម្រិតមត្តេយ្យផ្តល់នូវបំណិនជីវិតសំខាន់ៗដែលពួកគេប្រហែលជាមិនអាចទទួលបានឡើយបើកុមារទាំងនោះនៅផ្ទះ ដោយសារឪពុកម្តាយរបស់ពួកគេពុំមានពេលយកចិត្តទុកដាក់គ្រប់គ្រាន់លើតម្រូវការនៃការអភិវឌ្ឍរបស់ពួកគេ។ លើសពីនេះ ការទុកកុមារចោលនៅផ្ទះ ដោយមានការឃុំគ្រងតិចតួច ឬគ្មានការឃុំគ្រងសោះ អាចឲ្យកុមារប្រឈមនឹងហានិភ័យខាងសុវត្ថិភាព និងសន្តិសុខ។ កុមារក្នុងក្រុមអាយុពី៣ ដល់ ៥ ឆ្នាំ តិចជាង ៣០ ភាគរយប៉ុណ្ណោះ ដែលកំពុងរៀននៅមត្តេយ្យសិក្សានាពេលបច្ចុប្បន្ននេះ។ ដោយសារតែឪពុកម្តាយរបស់ពួកគេជាប់រវល់នឹងការងាររកចំណូលប្រចាំថ្ងៃនោះ កុមារទាំងនេះមិនត្រូវបានគេមើលថែឲ្យបានគ្រប់គ្រាន់ឡើយ។ នៅពេលដែលកុមារទាំងនេះពុំបានទទួលការអប់រំក្នុងប្រព័ន្ធតាមសាលាមត្តេយ្យ និង/ឬទទួលបានការរៀនសូត្រក្រៅផ្លូវការតិចតួចនៅផ្ទះ ការរៀនសូត្ររបស់ពួកគេ ក្នុងឆ្នាំដំបូងៗគឺជួបការលំបាក។

### ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

ក្
នុងចំណោមសមាជិកសហគមន៍មានមនុស្សមិនច្រើនឡើយដែលដឹងពីសារៈសំខាន់នៃការចុះឈ្មោះកូនឲ្យចូលរៀននៅមត្តេយ្យសិក្សា។ ពួកគេមានការយល់ដឹងតិចតួចអំពីរបៀបដែលការ អប់រំមត្តេយ្យសិក្សាអាចត្រៀមរៀបចំកុមារ សម្រាប់ការរៀនសូត្រនៅឆ្នាំបន្តបន្ទាប់។ កត្តានេះគឺដោយសារតែកាលពីពេលដែលឪពុកម្តាយរបស់កុមារទាំងនេះនៅក្មេង ចំនួនសាលាមត្តេយ្យនៅមានតិចតួចនៅឡើយ។ ចំណុចសំខាន់ដែលគួរឲ្យកត់សម្គាល់នោះគឺថាឪពុកម្តាយមានគំនិតបើកចំហក្នុងការចុះឈ្មោះកូនៗរបស់ពួកគេឲ្យចូលរៀនក្នុងសាលាមត្តេយ្យ ដោយសារតែវានឹងផ្តល់លទ្ធភាពឲ្យពួកគេមានពេលទៅធ្វើការងារ ដោយមិនបារម្ភពីសុវត្ថិភាព និងសន្តិសុខរបស់កូនៗ។

### ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ការមានលទ្ធភាពជាសាកលក្នុងការទទួលបានការអប់រំកម្រិតមត្តេយ្យ នឹងនាំឲ្យមានកំណើនអត្រាចុះឈ្មោះចូលរៀនក្នុងចំណោមកុមារអាយុពី៣ ទៅ៥ឆ្នាំ ។ ទន្ទឹមនឹងនេះដែរ ការធានាឲ្យសហគមន៍យល់ពីសារៈសំខាន់នៃការអប់រំនៅកម្រិតនេះក៏ជាប្រការសំខាន់ដូចគ្នាដែរ។

### បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

រដ្ឋាភិបាលបានរៀបចំគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ក្នុងគោលបំណងបង្កើនការចុះឈ្មោះចូលរៀន និងលើកកម្ពស់ការការពារកុមារអាយុពី ០ ដល់ ៦ ឆ្នាំ។ ការអប់រំកុមារតូច គឺជាការងារសំខាន់មួយក្នុងចំណោមការងារសំខាន់ៗ ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលរដ្ឋាភិបាលបានដាក់ចេញកាលពីពេលថ្មីៗនេះ។ ដើម្បីសម្រេចចក្ខុវិស័យរបស់ខ្លួន រដ្ឋាភិបាលបានបង្កើតសាលាមត្តេយ្យដែលទទួលបានថវិកាពីរដ្ឋនិងគ្រប់គ្រងដោយរដ្ឋាភិបាល។ រដ្ឋាភិបាលថ្នាក់កណ្តាលក៏ផ្តល់អំណាចឲ្យក្រុមប្រឹក្សាឃុំ សង្កាត់បង្កើតសាលាមត្តេយ្យសហគមន៍ ដើម្បីឆ្លើយតបចំពោះតម្រូវការអប់រំកុមារតូចរបស់កុមារដែលរស់នៅក្នុងតំបន់ដែលមានសាលាមត្តេយ្យរដ្ឋតិចតួច។

### បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

បញ្ហាប្រឈមសំខាន់ គឺគ្រូដែលទទួលបានការបណ្តុះបណ្តាលជាផ្លូវការនៅមានចំនួនតិចតួច គ្រូ (ជាពិសេសគ្រូមត្តេយ្យទទួលបានបៀវត្សតិចតួច) ហើយថវិកាសម្រាប់

កសាងហេដ្ឋារចនាសម្ព័ន្ធក៏មានកម្រិត ដែលធ្វើឲ្យកុមារមានលទ្ធភាពតិចតួច ក្នុងការទទួលបានការអប់រំពីសាលាមត្តេយ្យរដ្ឋ។ គុណភាពនៃការអប់រំ សម្ភារបរិក្ខារ សុវត្ថិភាព និងហេដ្ឋារចនាសម្ព័ន្ធតាមសាលារៀនទាំងនេះ គឺជាកត្តាដែលបង្វែរឪពុកម្តាយឲ្យយកកូនទៅចុះឈ្មោះតាមសាលាមត្តេយ្យរបស់អង្គការសង្គមស៊ីវិលវិញ។

រដ្ឋាភិបាលគប្បីបណ្តុះបណ្តាលគ្រូបន្ថែម អភិវឌ្ឍជំនាញគរុកោសល្យ រៀបចំឯកសារបង្រៀន និងរៀន និងបង្កើតប្រព័ន្ធសម្រាប់ពិនិត្យតាមដានការបង្រៀន និងរៀនក្នុងថ្នាក់រៀន។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិលៈ

ក្នុងចំណោមកុមារទាំងអស់ដែលរៀននៅមត្តេយ្យសិក្សា ជាង ៣០ ភាគរយ រៀនក្នុងសាលាមត្តេយ្យដែលបង្កើតឡើងដោយអង្គការសង្គមស៊ីវិល។ ការពិភាក្សាជាមួយនឹងសមាជិកសហគមន៍បង្ហាញថា ឪពុកម្តាយចូលចិត្តដាក់កូននៅសាលាមត្តេយ្យរបស់អង្គការ ជាងនៅសាលាមត្តេយ្យរដ្ឋ។ សាលាមត្តេយ្យរបស់អង្គការ ត្រូវបានបង្កើតឡើង នៅកន្លែងដែលមានទំហំតូចជាង កន្លែងដែលមានសាលាមត្តេយ្យរដ្ឋប៉ុន្តែមានការប្រើប្រាស់គរុកោសល្យ និងកម្មវិធីសិក្សាបានល្អប្រសើរជាង។ អ្វីដែលរឹតតែសំខាន់ទៅទៀតនោះ សាលាមត្តេយ្យទាំងនេះត្រូវបានគេចាត់ទុកថាមានសុវត្ថិភាពជាង ផ្តល់ឲ្យកុមារនូវអាហារដែលមានជីវជាតិ និងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ។ មានការកត់សម្គាល់ឃើញថា ចំណុចទាំងនេះនៅមានកម្រិតខ្សោយនៅឡើយ នៅតាមសាលាមត្តេយ្យរដ្ឋ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពៈ

លទ្ធភាពបង្កើនចំនួនសាលាមត្តេយ្យ តាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញនៅមានកម្រិតនៅឡើយដោយសារតែពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់។ ស្របពេលជាមួយគ្នា មានការសាកល្បងថ្មីៗ ដោយមានការរៀបចំឲ្យមានការដឹកជញ្ជូនសិស្សពីសាលារៀន ទៅកាន់ផ្ទះតូចៗ (ដែលនៅជិត) ដើម្បីឲ្យកុមារដែលនៅឆ្ងាយអាចមករៀនបាន។ សំខាន់ជាងគេ អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារផ្នែកនេះជឿជាក់ថា ប្រសិនបើពួកគេមានថវិកា ពួកគេត្រូវការពេលវេលាខ្លះ ដើម្បីពង្រីកចំនួនសាលារៀនទាំងនេះបាន។ នេះគឺដោយសារតែការពង្រីកចំនួនសាលារៀន ទាមទារឲ្យមានការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងគុណភាពនៃការបង្រៀន និងសុវត្ថិភាព និង/ឬសន្តិសុខក្នុងបរិយាកាសសាលារៀនទាំងមូលផងដែរ។ បញ្ហាទាំងនេះចាំបាច់ត្រូវដោះស្រាយ ក្នុងសាលារៀនថ្មីៗនីមួយៗ មុនពេលបើកសាលារៀនមួយទៀត។

ដូច្នេះ ខណៈពេលដែលអង្គការសង្គមស៊ីវិលពុំមានតម្រូវការអភិវឌ្ឍសមត្ថភាពជាក់លាក់ សម្រាប់បង្កើត និងដំណើរការសាលាមត្តេយ្យសិក្សា អង្គការទាំងនេះអាចបំពេញតួនាទីសំខាន់ ក្នុងការអភិវឌ្ឍសាលាមត្តេយ្យដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ គុណភាពនៃការអប់រំ

## ស្ថានភាពបច្ចុប្បន្ន៖

សាលារៀន ដែលទទួលសិស្សមកពីសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់ផ្តល់ឲ្យសិស្សទាំងនេះនូវបរិយាកាសដែលមានលក្ខណៈអំណោយផល។ គម្លាតធំជាងគេរវាងការធានាឲ្យកុមារបានទៅរៀន និងការទទួលបានការអប់រំប្រកបដោយគុណភាព គឺកម្រិតនៃការតាំងចិត្តបង្រៀនរបស់គ្រូនាពេលបច្ចុប្បន្ន។ គ្រូច្រើនមិនសូវយកចិត្តទុកដាក់ក្នុងថ្នាក់រៀនធម្មតា ហើយច្រើនលើកទឹកចិត្តកុមារឲ្យរៀនគួរបន្ថែម។ ជាទូទៅ សិស្សត្រូវបង់ប្រាក់ ដើម្បីចូលរៀនក្នុងថ្នាក់ទាំងនេះ ដែលគួរចាត់ទុកថាជាការបង់ថ្លៃក្រៅផ្លូវការ ដែលគ្រួសារពុំមានលទ្ធភាពបង់បាន ហើយដែលធ្វើឲ្យកុមាររៀនយឺតជាងកុមារផ្សេងទៀត។ ការរៀនខ្សោយ គួបផ្សំនឹងការជួយបំពេញតម្រូវការប្រចាំថ្ងៃរបស់គ្រួសារផង គឺជាមូលហេតុចម្បង ដែលនាំឲ្យកុមារបោះបង់ចោលការសិក្សា។

គ្រូក៏បានលើកឡើងផងដែរថា សាលារៀនរបស់ពួកគេនៅខ្វះសម្ភារបង្រៀន និងរៀនសមស្រប សម្រាប់ផ្តល់ការអប់រំប្រកបដោយគុណភាព។ នៅមិនទាន់មានការប្រើប្រាស់គោលវិធីគរុកោសល្យថ្មីៗ ដូចជា ការរៀនសូត្រដោយប្រើប្រាស់សកម្មភាព ការរៀនសូត្រដោយប្រើប្រាស់កុំព្យូទ័រជាជំនួយ។ល។ នៅឡើយទេ។ គ្រូភាគច្រើនគិតថាការបង្រៀនគួរនេះប្រមូលថ្លៃក្រៅផ្លូវការគឺជារឿងសមហេតុសមផល។ ពួកគេលើកឡើងថា ប្រាក់ខែធម្មតារបស់ពួកគេគឺតិចតួច ដែលមិនអាចឲ្យពួកគេបំពេញតម្រូវការប្រចាំថ្ងៃនៃគ្រួសាររបស់ពួកគេឡើយ ហើយបង្ខំឲ្យពួកគេត្រូវបង្រៀនគួរថែម។

## ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

មានការរកឃើញច្បាស់ថា គ្រួសាររស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញពិតជាបានយល់ពីសារៈសំខាន់ និងតម្លៃផ្នែកសេដ្ឋកិច្ចនៃការអប់រំ។ កម្រិតវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ ពុំមានឥទ្ធិពលលើបំណងប្រាថ្នាខាងការអប់រំ ដែលពួកគេមានសម្រាប់កូនរបស់ពួកគេឡើយ។ ពួកគេមួយចំនួនត្រូវបេះបោចធនធានហិរញ្ញវត្ថុដ៏ស្តួចស្តើងរបស់ពួកគេ ដើម្បីបង់ថ្លៃក្រៅផ្លូវការដែលគ្រូប្រមូលសម្រាប់ការបង្រៀនគួរ។ ប៉ុន្តែ ដូចបញ្ជាក់ពីខាងដើម ពួកគេមួយចំនួនក៏ដកកូនចេញពីសាលារៀនផងដែរ ដោយសារតែពួកគេមិនគិតថា កូនរបស់គេទទួលបានប្រយោជន៍ពីគុណភាពនៃការអប់រំដែលផ្តល់តាមសាលារៀនឡើយ។

## ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ឪពុកម្តាយភាគច្រើនគិតថា ពួកគេពុំមានឋានៈក្នុងសង្គម សេដ្ឋកិច្ច ដើម្បីតាមដាន និងស្តីបន្ទោសដល់គ្រូដែលពុំបានបំពេញការងារតាមការរំពឹងទុករបស់ពួកគេនោះឡើយ។ ពួកគេចាត់ទុកគ្រូថាជាមន្ត្រីរាជការ ពោលគឺជាអ្នកធ្វើការងារឲ្យស្ថាប័នដែលមានអំណាច។ ការពិភាក្សាជាមួយនឹងអង្គការសង្គមស៊ីវិល ដែលផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុង បង្ហាញថា ចាំបាច់ត្រូវមានការចងក្រងសហគមន៍ជាក្រុម (ដោយមានការចូលរួមពីប្រធានសហគមន៍) ដើម្បីធ្វើសវនកម្មសង្គមជាទៀងទាត់លើហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការបំពេញការងាររបស់គ្រូ។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

រដ្ឋាភិបាលបានរៀបចំ "គោលនយោបាយគ្រូបង្រៀន" ដោយមានដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍគ្រូ ដើម្បីឲ្យពួកគេមានសមត្ថភាព និងគណនេយ្យភាពកាន់តែខ្ពស់ជាងមុនស្របតាមក្រមសីលធម៌វិជ្ជាជីវៈ។គោលនយោបាយនេះផ្តល់ឲ្យគ្រូនូវបរិយាកាសការងារអំណោយផលដែលចាំបាច់ ដើម្បីឲ្យពួកគេអាចបំពេញការងារក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ គោលនយោបាយសាលាកុមារមេត្រីបានដាក់ចេញនូវគោលការណ៍ណែនាំមួយ សម្រាប់ជួយសាលារៀនឲ្យបង្កើតបរិយាកាសមួយ ដែលទទួលស្គាល់ និងជួយបំពេញសិទ្ធិជាមូលដ្ឋានរបស់កុមារ តាមរយៈការបំពេញការងារជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងនោះមានទាំងមាតាបិតាសិស្សផងដែរ។ គោលនយោបាយនេះមាន ៦ សមាសភាគ សម្រាប់បង្កើតបរិយាកាសរៀនសូត្រប្រកប

ដោយសុវត្ថិភាព។ សមាសភាគទាំងនេះ រួមមាន ការបង្កើនការចូលរៀន និងការបង្កើតសាលារៀន ដែលផ្តល់នូវការរៀនសូត្រប្រកបដោយបរិយាប័ន្ន និងប្រសិទ្ធភាព សុខភាព និងសុវត្ថិភាពកុមារ ការឆ្លើយតបចំពោះយេនឌ័រ ការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការអភិវឌ្ឍការអប់រំរបស់កុមារ និងធានាយ៉ាងណាឲ្យប្រព័ន្ធអប់រំជាតិគាំទ្រឲ្យសាលារៀនកាន់តែមានលក្ខណៈកុមារមេត្រី។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ប្រព័ន្ធអប់រំជួបនឹងបញ្ហាប្រឈម ដោយសារតែពុំមានការកំណត់មាគ៌ាអាជីពដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់គ្រូ ការង្វះកន្លែងផ្តល់ការបណ្តុះបណ្តាលគ្រូឲ្យបានសមស្រប (រួមនឹងគ្រូឧទ្ទេសផងដែរ) ដែនកំណត់ខាងគរុកោសល្យ និងភាពមានកម្រិតផ្នែកពិនិត្យតាមដានលទ្ធផលសិក្សា និងរដ្ឋបាល។ មន្ត្រីរដ្ឋាភិបាលយល់ស្របជាមួយនឹងការវិភាគនេះ និងជឿថា ចាំបាច់ត្រូវមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីខាងក្រៅ សម្រាប់ការពង្រឹងប្រព័ន្ធនេះ។ លើសពីនេះ ចាំបាច់ត្រូវមានការផ្តល់ការណែនាំបច្ចេកទេសសម្រាប់កែសម្រួលគោលនយោបាយ និងប្រព័ន្ធបច្ចុប្បន្នផងដែរ។

រដ្ឋាភិបាលត្រូវការជំនួយពីខាងក្រៅ សម្រាប់វាយតម្លៃ និងពង្រឹងយន្តការបណ្តុះបណ្តាលគ្រូរបស់ខ្លួន។ រដ្ឋាភិបាលអាចប្រើប្រាស់អ្នកជំនាញអន្តរជាតិ ឲ្យជួយរៀបចំផែនការមាគ៌ាអាជីពរបស់គ្រូ (ឬផែនការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់គ្រូ ផ្អែកទៅតាមលទ្ធផលសិក្សារបស់សិស្សរបស់ពួកគេ)។ រដ្ឋាភិបាលក៏ត្រូវការការគាំទ្រពីខាងក្រៅ សម្រាប់វាយតម្លៃ និងពង្រឹងការរៀបចំពិនិត្យតាមដានផ្នែករដ្ឋបាល និងលទ្ធផលការងាររបស់គ្រូផងដែរ។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ បច្ចុប្បន្ននេះ អង្គការនេះមានសមាជិកចំនួន ១២៧ ក្នុងនោះមានអង្គការក្នុងស្រុកចំនួន ៨០ និងអង្គការអន្តរជាតិចំនួន ៤៧។ NEP តែងចូលរួមសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ជាប្រចាំ និងផ្តោតការយកចិត្តទុកដាក់លើការរៀបចំឲ្យមានកិច្ចសន្ទនារវាងអាជ្ញាធររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអំពីបញ្ហានានាពាក់ព័ន្ធនឹងវិស័យអប់រំ។ នៅថ្នាក់មូលដ្ឋាន អង្គការសង្គមស៊ីវិលផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការលើកទឹកចិត្តសហគមន៍ឲ្យបញ្ជូនកូនៗរបស់ខ្លួនទៅសាលារៀន និងផ្តល់លទ្ធភាពឲ្យកុមារ (រួមទាំងកុមារបោះបង់ចោលការសិក្សាផង) អាចចូលរៀនក្នុងថ្នាក់បំប៉នបន្ថែម និងថ្នាក់ជាស្ពានចម្លងការអប់រំ ដែលអាចជួយឲ្យពួកគេអាចបន្តការសិក្សាកម្រិតមូលដ្ឋានបាន។ លើសពីនេះ ក៏មានករណីដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់ការគាំទ្រដល់សាលារៀន តាមរយៈការផ្តល់នូវសម្ភារបង្រៀន និងរៀន និងគំនិតគរុកោសល្យថ្មីៗផងដែរ។ ប៉ុន្តែ ភាពជាដៃគូបែបនេះ នៅមិនទាន់ធ្វើឡើងជាទ្រង់ទ្រាយធំនៅឡើយ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ការពិភាក្សាជាមួយអង្គការសង្គមស៊ីវិលបង្ហាញថា ត្រូវមានការពង្រឹង NEP បន្ថែមទៀត តាមរយៈការធានាឲ្យមានការសម្របសម្រួលកាន់តែប្រសើរក្នុងចំណោមអង្គការសង្គមស៊ីវិល និងរវាងអង្គការសង្គមស៊ីវិល ជាមួយនឹងរដ្ឋាភិបាល។ ការសម្របសម្រួលកាន់តែប្រសើរក្នុងចំណោមអង្គការសង្គមស៊ីវិល គឺចាំបាច់ ដើម្បីកុំឲ្យមានការធ្វើការងារត្រួតគ្នា ហើយការសម្របសម្រួលរវាងអង្គការសង្គមស៊ីវិល ជាមួយនឹងរដ្ឋាភិបាល គឺចាំបាច់ ដើម្បីឲ្យមានការពង្រីកអន្តរាគមន៍ដែលមានគុណភាព។ ការងារនេះត្រូវតែមានការគាំទ្រដោយការវាយតម្លៃលើភាពជាដៃគូនេះដើម្បីធានាថាឲ្យមានការជ្រើសរើសកម្មវិធីល្អៗ សម្រាប់ពង្រីកការអនុវត្ត។ ដំណើរការសម្របសម្រួលនេះត្រូវដឹកនាំដោយស្ថាប័នអន្តរជាតិមួយ ដែលបាននិងកំពុងធ្វើការងារសម្របសម្រួលយ៉ាងជិតស្និទជាមួយរដ្ឋាភិបាល ហើយជាលទ្ធផល គួរមានការកំណត់តួនាទីឲ្យបានច្បាស់លាស់ សម្រាប់អង្គការសង្គមស៊ីវិល ក្នុងការពង្រឹងលទ្ធផលនៃការអប់រំសម្រាប់កុមារ (ជាពិសេសកុមារមកពីសហគមន៍ក្រីក្រក្នុងទីក្រុង)។

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ការដាក់ទណ្ឌកម្មលើរាងកាយ និងការរករឿងឈ្លោះនៅសាលារៀន

## ស្ថានភាពបច្ចុប្បន្ន៖

ច្បាប់ស្តីពីការអប់រំ (២០០៧) ហាមឃាត់មិនឲ្យមានការដាក់ទណ្ឌកម្មរាងកាយ នៅតាមសាលារៀនរដ្ឋ ឬសាលារៀនឯកជនឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក្មេងជំទង់ដែលទៅរៀននៅសាលា ៣០,៥ ភាគរយ រាយការណ៍ថា ពួកគេធ្លាប់ទទួលរងទណ្ឌកម្មរាងកាយក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ។ ការដាក់ទណ្ឌកម្មរាងកាយត្រូវបានប្រើប្រាស់ មិនត្រឹមតែជាវិធានការដាក់វិន័យប៉ុណ្ណោះទេ ហើយក្មេងជំទង់លើកឡើងថា ការដាក់ទណ្ឌកម្មរាងកាយក៏ត្រូវបានគេប្រើប្រាស់ជាឧបករណ៍សម្រាប់លើកទឹកចិត្តឲ្យសិស្សកែលម្អលទ្ធផលនៃការសិក្សារបស់ខ្លួនផងដែរ។ លើសពីនេះ ក្នុងចំណោមក្មេងជំទង់ ៤ នាក់ មាន ១នាក់ បានលើកឡើងពីករណីរករឿងឈ្លោះក្នុងថ្នាក់រៀនរបស់ពួកគេ។ ក្នុងចំណោមសាលារៀនដែលត្រូវបានចុះទៅ ពុំមានសាលារៀនណាលើកឡើងថាមានប្រព័ន្ធឬរចនាសម្ព័ន្ធផ្លូវការ ដើម្បីពិនិត្យឬស៊ើបអង្កេតលើករណីដាក់ទណ្ឌកម្មរាងកាយ ឬការរករឿងឈ្លោះនោះទេ។

## ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

បញ្ហាទណ្ឌកម្មរាងកាយ និងការរករឿងឈ្លោះក្នុងសាលារៀន កើតឡើងដោយសារតែឪពុកម្តាយ និងសិស្សជាច្រើនចាត់ទុកថាជាទង្វើដែលអាចទទួលយកបាន ហើយឪពុកម្តាយជាច្រើនចាត់ទុកការរករឿងឈ្លោះក្នុងសាលារៀនថាជាផ្នែកធម្មតានៃការចម្រើនវ័យ និងការអភិវឌ្ឍរបស់ក្មេងជំទង់។ ពួកគេគិតថា ករណីទាំងនេះធ្វើឲ្យកុមារកាន់តែមានសមត្ថភាពក្នុងតទល់ជាមួយពិភពលោក នៅពេលដែលពួកគេក្លាយជាមនុស្សពេញវ័យ។

## ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ចាំបាច់ត្រូវមានការគៀងគរចលនាសហគមន៍ ដើម្បីឲ្យពួកគេយល់ពីផលវិបាកខាងផ្លូវកាយ និងខាងចិត្តសង្គម ដែលកើតឡើងដោយសារការរករឿងឈ្លោះ និងការដាក់ទណ្ឌកម្មរាងកាយ។ ចាំបាច់ត្រូវមានការបង្កើនការយល់ដឹងដល់សហគមន៍អំពីភាពចាំបាច់ក្នុងការមិនទទួលយកការដាក់ទណ្ឌកម្មរាងកាយនៅគ្រប់ទីកន្លែង ទោះក្នុងផ្ទះឬក្នុងសាលារៀនក្តី។ ចំណែកឯការរករឿងឈ្លោះក្នុងសាលារៀន គ្រួសារ ឬសហគមន៍ក៏ដូចគ្នានេះដែរ។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

បើតាមមាត្រា៣៥ នៃច្បាប់ស្តីពីការអប់រំ (២០០៧) ការដាក់ទណ្ឌកម្មរាងកាយត្រូវបានហាមឃាត់មិនឲ្យកើតមាននៅតាមសាលារៀនរដ្ឋ និងសាលារៀនឯកជនឡើយ។ ប៉ុន្តែមាត្រា៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះឆ្នាំ២០០៥ ចែងថា ការដាក់វិន័យលើកូនពីសំណាក់ឪពុកម្តាយមិនត្រូវបានចាត់ទុកថាជាអំពើហិង្សា ឬអំពើហិង្សាក្នុងគ្រួសារឡើយ។ មាត្រា៣៨ ធានាសិទ្ធិរស់រានមានជីវិតសម្រាប់បុគ្គលគ្រប់រូប និងហាមឃាត់មិនឲ្យមានការរំលោភបំពានរាងកាយលើបុគ្គលណាម្នាក់ឡើយ។ មាត្រា ៤៨ ចែងថារដ្ឋត្រូវការពារសិទ្ធិរបស់កុមារ ដូចដែលមានចែងក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិកុមារ។ អនុក្រឹត្យលេខ ១២៧ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន (២០០៨) ចែងថា "គ្រូមិនអាចធ្វើទារុណកម្មផ្លូវកាយ និងផ្លូវចិត្តលើអ្នកសិក្សាឡើយ"។ ប្រកាសលេខ៩២២ ស្តីពីបញ្ហាពាក់ព័ន្ធនឹងការដាក់ទោសលើសិស្ស (២០០៦) រៀបរាប់ពីការដាក់ទណ្ឌកម្ម ដែលត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់ក្នុងសាលារៀន។ ដូច្នេះ គោលនយោបាយផ្សេងៗបញ្ជូនសារខុសៗគ្នា ដោយគោលនយោបាយខ្លះចាត់ទុកការដាក់ទណ្ឌកម្មរាងកាយថាជាទង្វើខុសច្បាប់ក្នុងសាលារៀន ប៉ុន្តែគោលនយោបាយផ្សេងទៀតពុំបានបញ្ជាក់ឲ្យបានច្បាស់ពីការដាក់ទណ្ឌកម្មរាងកាយដែលកើតឡើងក្នុងសាលារៀនឡើយ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

ការអនុវត្តច្បាប់ និងគោលការណ៍ណែនាំ ដែលហាមឃាត់មិនឲ្យមានការដាក់ទណ្ឌកម្មរាងកាយតាមសាលារៀន នៅមានចំណុចខ្វះខាត។ គ្រូភាគច្រើនដឹងថាការដាក់ទណ្ឌកម្មរាងកាយគឺជាអំពើខុសច្បាប់ ប៉ុន្តែគ្រូ

មួយចំនួនមិនយកចិត្តទុកដាក់ចំពោះរឿងនេះឡើយ ដោយសារតែពួកគាត់គិតថា ការដាក់ទណ្ឌកម្មរាងកាយគឺសំខាន់ និងចាំបាច់សម្រាប់ដាក់វិន័យលើកុមារ។ ចាំបាច់ត្រូវមានការបង្កើនការយល់ដឹងដល់គ្រូអំពីបញ្ហានេះ និងពង្រឹងយន្តការរាយការណ៍ និងឆ្លើយតបចំពោះករណីបែបនេះ។ អ្នកគ្រប់គ្រងសាលារៀនក៏ត្រូវទទួលខុសត្រូវគ្រប់គ្រង និងពិនិត្យតាមដានថ្នាក់រៀន ដើម្បីកំណត់ពីករណីដាក់ទណ្ឌកម្មរាងកាយផងដែរ។

រដ្ឋាភិបាលពុំមានគោលការណ៍ណែនាំពិសេសសម្រាប់ដោះស្រាយករណីរករឿងឈ្លោះក្នុងសាលារៀនឡើយ។ នេះជាចំណុចគួរឲ្យព្រួយបារម្ភមួយទៀត ដែលទាមទារឲ្យអ្នកគ្រប់គ្រងសាលារៀនធ្វើការឆ្លើយតបដោយមានការរៀបចំឲ្យបានល្អ ហើយគ្រូគឺជាអ្នកដែលទទួលខុសត្រូវធានាមិនឲ្យមានការរករឿងឈ្លោះកើតមានក្នុងសាលារៀន។ ចាំបាច់ត្រូវមានការរៀបចំយុទ្ធនាការតាមសាលារៀន និងសហគមន៍ ដើម្បីធានាថាសិស្ស គ្រូ និងឪពុកម្តាយ យល់ដឹងច្បាស់ថា ការរករឿងឈ្លោះគឺជាទង្វើដែលមិនអាចទទួលយកបាន និងមានផលប៉ះពាល់ជាអវិជ្ជមានមកលើជនរងគ្រោះ។

ការរៀបចំ និងអនុវត្តអន្តរាគមន៍បញ្ចប់អំពើហិង្សាលើកុមារតាមសាលារៀន ក៏អាចមានប្រយោជន៍ដល់ស្ថានភាពនេះផងដែរ។ អន្តរាគមន៍នេះគួរផ្តោតការយកចិត្តទុកដាក់លើការដាក់ទណ្ឌកម្មរាងកាយ ដែលកើតតាមសាលារៀន ការរករឿងឈ្លោះ និងអំពើហិង្សាក្នុងគ្រួសារ។ ប៉ុន្តែ រដ្ឋាភិបាលត្រូវការការគាំទ្រពីស្ថាប័នខាងក្រៅ ដើម្បីរៀបចំ សាកល្បងបង្ហើយបញ្ចប់ និងអនុវត្តយុទ្ធនាការបែបនេះ (យកល្អ ត្រូវបញ្ចូលទៅក្នុងកម្មវិធីសិក្សា)។

## កម្មវិធី និង/ឬគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

រដ្ឋាភិបាលកំពុងធ្វើការងាររួមគ្នាជាមួយនឹងអង្គការសង្គមស៊ីវិលសំខាន់ៗ ដើម្បីរៀបចំព្រាងគោលនយោបាយការពារកុមារពីការរំលោភបំពាន ដែលធ្វើឡើងដោយអ្នកអប់រំ និងសិស្សគ្នាឯង។ គោលនយោបាយនេះគ្របដណ្តប់លើការរករឿងឈ្លោះ ការដាក់ទណ្ឌកម្មរាងកាយ និងការរំលោភបំពានផ្លូវភេទ។ ក្រសួងអប់រំ យុវជន និងកីឡា ក៏មានការប្តេជ្ញាចិត្តធានាឲ្យមានការដាក់វិធានការវិន័យ ចំពោះករណីបទល្មើស និងកំហុសវិជ្ជាជីវៈ ដែលប្រព្រឹត្តដោយគ្រូ ក្នុងសាលារៀន ជាពិសេស អំពើហិង្សាផ្លូវភេទ និងការដាក់ទណ្ឌកម្មផ្លូវកាយ និងជំរុញឲ្យមានការប្រើប្រាស់វិធីសាស្រ្តបង្រៀនបែបអហិង្សា ដើម្បីបង្ការមិនឲ្យការដាក់ទណ្ឌកម្មរាងកាយកើតឡើង។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

បច្ចុប្បន្នេះ កំពុងមានការផ្តោតការយកចិត្តទុកដាក់លើការរៀបចំគោលការណ៍ណែនាំ និងសារាចរណ៍ណែនាំនានា។ គោលការណ៍ណែនាំ និងសារាចរណ៍ណែនាំនេះ ចាំបាច់ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានសមស្របសម្រាប់គាំទ្រដល់ការអនុវត្ត ដោយត្រូវមានការបែងចែកការទទួលខុសត្រូវជាក់លាក់ដល់ស្ថាប័ន/បុគ្គលផ្សេងៗ។ គោលនយោបាយ ដែលកំពុងត្រូវបានរៀបចំឡើងនេះ ត្រូវការការគាំទ្រពីក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃសមស្រប ដែលអាចជួយដល់ការវាយតម្លៃលទ្ធផលនៃការអនុវត្តគោលនយោបាយនេះ និងត្រួសត្រាយផ្លូវឲ្យមានការកែទម្រង់ជាបន្តបន្ទាប់ និងការកែលម្អរចនាសម្ព័ន្ធពិនិត្យតាមដាន និងគ្រប់គ្រង។ ក្នុងន័យនេះអង្គការសង្គមស៊ីវិលជឿថាស្ថាប័ននានាដូចជា យូនីសេហ្វជាដើម អាចនាំមុខការងារនេះ ដោយបង្កើតជាឧបករណ៍សវនកម្មសង្គម ដែលអង្គការសង្គមស៊ីវិលអាចយកទៅប្រើប្រាស់ ដើម្បីវាយតម្លៃសុវត្ថិភាពកុមារតាមសាលារៀន និងរាយការណ៍លទ្ធផលរកឃើញដល់រដ្ឋាភិបាល។

# ហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖ ពិការភាព និងការទទួលបានការអប់រំប្រកបដោយបរិយាប័ន្ន

## ស្ថានភាពបច្ចុប្បន្ន៖

កុមារពិការប្រមាណជា ៥៩,១ ភាគរយ និងក្មេងជំទង់ពិការ ៣៦,៤ ភាគរយ បច្ចុប្បន្ននេះ មិនកំពុងរៀនសូត្រក្នុងសាលារៀនឡើយ។ សាលារៀនជួបការលំបាកក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងធនធានដែលចាំបាច់ ដើម្បីគាំទ្រដល់កុមារ និង/ឬក្មេងជំទង់ពិការ ដូចជាគ្រូដែលទទួលបានការបណ្តុះបណ្តាលឯកទេសអំពីរបៀបធ្វើការងារជាមួយកុមារដែលមានតម្រូវការពិសេសជាដើម។ សម្ភារឧបទ្ទេស និងឯកសាររៀនសូត្របែបឯកទេស ក៏នៅមានកំណត់ផងដែរ។

## ឥរិយាបថ និង/ឬការឆ្លើយតបរបស់សហគមន៍៖

ឪពុកម្តាយកុមារពិការចង់បញ្ជូនកូនទៅរៀន និងចង់ផ្តល់ឲ្យពួកគេនូវបរិយាកាស ដែលពួកគេអាចទំនាក់ទំនងជាមួយនឹងកុមារផ្សេងទៀត ដែលមានអាយុស្របាលគ្នា។ ប៉ុន្តែ ក្នុងករណីភាគច្រើន ពួកគេសម្រេចចិត្តមិនបញ្ជូនកូនទៅរៀន ឬទាញកូនចេញពីសាលារៀនវិញ ដោយសារតែពួកគេគិតថា សាលារៀនពុំបានផ្តល់ឲ្យកូនពួកគេនូវបរិយាកាសដែលមានសុវត្ថិភាព និងលក្ខណៈអំណោយផលសម្រាប់កូនពួកគេឡើយ។ គេគិតថា សាលារៀនពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរៀនសូត្ររបស់កូនៗពួកគេឡើយ។ លើសពីនេះ កូនៗរបស់ពួកគេរឹតតែងាយរងការរករឿងឈ្លោះពីមិត្តរួមថ្នាក់ ហើយគ្រូមិនសូវជាធ្វើអន្តរាគមន៍ក្នុងករណីទាំងនេះឡើយ។ ការពុំបានទៅរៀន គួបផ្សំនឹងតម្រូវការរកចំណូលផង តែងធ្វើឲ្យឪពុកម្តាយ ទៅក្រៅផ្ទះដើម្បីស្វែងរកការងារធ្វើ ហើយកុមារត្រូវបានគេទុកចោលពុំមានអ្នកមើលថែ។ កុមារទាំងនេះងាយទទួលរងអំពើហិង្សាពីសមាជិកគ្រួសារឬសហគមន៍ដោយសារតែក្នុងករណីជាច្រើន កុមារមិនអាចតបត ឬមិនអាចរាយការណ៍ពីករណីទាំងនេះឡើយ។

## ភាពចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបថ៖

ចាំបាច់ត្រូវមានការរៀបចំយុទ្ធនាការ ៣៦០ ឌឺក្រេ ដើម្បីបង្កើនការយល់ដឹងដល់សហគមន៍ គ្រូបង្រៀនតាមសាលារៀន អ្នកគ្រប់គ្រងសាលារៀន មន្ត្រីសុខាភិបាល ភ្នាក់ងារសង្គមកិច្ច និងកុមារនិង/ឬក្មេងជំទង់ អំពីការគិតគូរចំពោះកុមារពិការ។ ពាក់ព័ន្ធនឹងចំណុចនេះ ប្រធានសហគមន៍ កុមារ និង/ឬក្មេងជំទង់ និងអ្នកគ្រប់គ្រងសាលារៀនគឺជាអ្នកដែលមានសារៈសំខាន់បំផុត។

## បញ្ញត្តិក្នុងគោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តិ៖

គោលនយោបាយស្តីពីការអប់រំកុមារពិការមានគោលបំណងបង្កើនការយល់ដឹងអំពីពិការភាព និងការទទួលយកជនពិការ ដល់សហគមន៍ ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានា ការកំណត់អត្តសញ្ញាណ និងផ្តល់អន្តរាគមន៍ឲ្យបានទាន់ពេលវេលា តាមរយៈសេវាស្តារនីតិសម្បទា ផ្តល់ការអប់រំប្រកបដោយគុណភាព បំណិនជីវិត ឬការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារ/ក្មេងជំទង់ពិការ និងបង្កើនអត្រាសិក្សា អត្រាឡើងថ្នាក់ និងអត្រាគង់វង្សនៅតាមសាលារៀន។ ការអប់រំកុមារពិការ មានចែងក្នុងក្របខ័ណ្ឌគោលនយោបាយសាលាកុមារមេត្រី។ លើសពីនេះ ក៏មានការអនុវត្តគម្រោងអប់រំបរិយាប័ន្នក្នុងខេត្តចំនួន១៥ផងដែរ។ រដ្ឋាភិបាលក៏បានផ្តល់សច្ចាប័នដល់អនុសញ្ញាស្តីពីសិទ្ធិជនពិការកាលពីឆ្នាំ ២០១២ ផងដែរ។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

គោលនយោបាយ និងសារាចរណ៍របស់រដ្ឋាភិបាលគឺស្របជាមួយនឹងអ្វីដែលចាំបាច់ត្រូវធ្វើ ដើម្បីឲ្យការកំណត់អត្តសញ្ញាណ ការចុះឈ្មោះ និងការផ្តល់ការអប់រំដល់កុមារពិការកាន់តែមានលក្ខណៈល្អប្រសើរ។ ប៉ុន្តែការអនុវត្តគោលនយោបាយ និងគោលការណ៍ណែនាំទាំងនេះ នៅមានកម្រិតនៅឡើយ ដោយសារតែខ្វះបុគ្គលិកជំនាញបច្ចេកទេស ក្នុងប្រព័ន្ធសុខាភិបាលសាធារណៈ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ គណៈគ្រប់គ្រងសាលារៀន។ល។ ក្រៅពីនេះរដ្ឋាភិបាលបែងចែកធនធានហិរញ្ញវត្ថុតិចតួច ដើម្បីបង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របសម្រាប់ជនពិការតាមសាលារៀន ផ្តល់

ការបណ្តុះបណ្តាលគ្រូ ផ្តល់សម្ភារឧបទ្ទេសរៀន និងបង្រៀន ។ល។

រដ្ឋាភិបាលត្រូវការការគាំទ្រពីស្ថាប័នខាងក្រៅ ដើម្បីរៀបចំយុទ្ធសាស្ត្រដែលអស់ចំណាយតិច សម្រាប់ផ្តល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលចាំបាច់ ដើម្បីឲ្យកុមារ/ក្មេងជំទង់ពិការអាចចូលរៀនតាមសាលាធម្មតាបាន។ លើសពីនេះ រដ្ឋាភិបាលត្រូវការការគាំទ្រ សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនតាមសាលារដ្ឋឲ្យចេះឆ្លើយតបចំពោះតម្រូវការនៃការអប់រំរបស់កុមារ/ក្មេងជំទង់ពិការ។

## កម្មវិធី/គំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិលៈ

ការពិភាក្សាជាមួយអង្គការសង្គមស៊ីវិល បានបង្ហាញឲ្យឃើញពីការសហការគ្នារវាង អង្គការសុខភាពពិភពលោក យូអិនឌីភី យូនីសេហ្វ និងរដ្ឋាភិបាលអូស្ត្រាលី ជាពិសេស ក្រសួងការបរទេស និងពាណិជ្ជកម្ម ក្នុងការបង្កើតកម្មវិធីគំនិតផ្តួចផ្តើមសិទ្ធិជនពិការនៅកម្ពុជា (DRIC) ដែលអនុវត្តពីឆ្នាំ២០១៤ ដល់ ២០១៨។ កម្មវិធីគំនិតផ្តួចផ្តើមនេះមាន៤សមាសភាគធំៗ៖ ផ្តល់ការគាំទ្រដល់រដ្ឋាភិបាល គាំទ្រដល់អង្គការជនពិការ គាំទ្រដល់ប្រព័ន្ធស្តារលទ្ធភាពពលកម្ម អភិបាលកិច្ចបែបបរិយាប័ន្ន និងការអភិវឌ្ឍសហគមន៍បែបបរិយាប័ន្ន។

លើសពីនេះ យូនីសេហ្វ និងរដ្ឋាភិបាលអូស្ត្រាលីក៏បានដាក់ឲ្យអនុវត្តមូលនិធិអភិវឌ្ឍន៍បញ្ចូលបញ្ហាពិការភាពនៅកម្ពុជាផងដែរ (CDIDF) ដែលនេះជាកម្មវិធីផ្តល់ជំនួយដល់អង្គការមិនមែនរដ្ឋាភិបាល ក្រោមយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់ទាំងអស់គ្នា ២០១៥-២០២០ របស់រដ្ឋាភិបាលអូស្ត្រាលី។ ការងារសំខាន់ៗរួមមាន ការជួយកុមារដែលមានបញ្ហាសុខភាពផ្លូវចិត្ត និងកុមារពិការខាងចិត្តសង្គមការពង្រឹងការកំណត់អត្តសញ្ញាណ និងការពិនិត្យកុមារតូចៗឲ្យបានទាន់ពេលវេលា ការបង្កើនលទ្ធភាពទទួលបានការអប់រំនៅកម្រិតខ្ពស់ៗ និងការផ្តល់ការថែទាំតាមសហគមន៍។

## បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពៈ

ដូចករណីខាងដើមដែរ បញ្ហានៅទីនេះគឺការអនុវត្តការផ្លាស់ប្តូរទាំងនេះ ក្នុងទ្រង់ទ្រាយធំ។ ការងារបែបច្នៃប្រឌិតថ្មីៗជាច្រើនកំពុងទទួលបានការគាំទ្រក្រោមមូលនិធិ CDIDF ប៉ុន្តែការពង្រីកអន្តរាគមន៍ទាំងនេះក្នុងទ្រង់ទ្រាយធំនៅថ្នាក់ជាតិ ទាមទារឲ្យមានការផ្តល់មូលនិធិឲ្យបានច្រើន។ លើសពីនេះ យុទ្ធសាស្ត្រសម្រាប់ឆ្លើយតបចំពោះតម្រូវការនៃការរៀនសូត្ររបស់កុមារដែលពិការធ្ងន់ធ្ងរមានចំនួនតិចតួច។ ចាំបាច់ត្រូវមានការកៀងគរចលនាសហគមន៍ និងការបង្កើនការយល់ដឹងឲ្យបានកាន់តែស៊ីជម្រៅជាងមុន ដោយសារតែយុទ្ធសាស្ត្រដែលអនុវត្តតាមសហគមន៍ និងសាលារៀន នៅមានលក្ខណៈបែកខ្ញែកពីគ្នា និងត្រូវបានអនុវត្តដាច់ៗពីគ្នា។ ការខ្វះការសម្របសម្រួលជាទូទៅ មានន័យថា ជារឿយៗ អង្គការសង្គមស៊ីវិលត្រូវធ្វើការងារត្រួតគ្នា ជាពិសេសក្នុងការរៀបចំឯកសារអប់រំផ្សព្វផ្សាយ។ គួរមានការបង្កើតបញ្ជីដែលបង្ហាញពីឯកសារសម្ភារអប់រំផ្សព្វផ្សាយដែលមានស្រាប់ និងផ្តល់ឯកសារ និងសម្ភារទាំងនេះដល់អង្គការដែលកំពុងធ្វើការងារ ឬដែលមានបំណងធ្វើការងារផ្នែកនេះ។




# ការអភិវឌ្ឍសមត្ថភាព ក្រសួង ឬស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

ផ្នែកនេះ គឺជាការបង្ហាញដោយសង្ខេបអំពីតម្រូវការអភិវឌ្ឍសមត្ថភាពក្នុងចំណោមស្ថាប័ន ដូចដែលលើកឡើងក្នុងផ្នែក "បញ្ហាប្រឈមក្នុងការអនុវត្ត និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព" ក្នុងផ្នែកវិភាគគោលនយោបាយ និង/ឬកម្មវិធីមុននេះ។

## ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឲ្យអនុវត្តនូវច្បាប់ និងគោលនយោបាយដើម្បីបង្កលក្ខណៈឲ្យមានការទទួលបានការអប់រំប្រកបដោយគុណភាព ដូចជាផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលនយោបាយជាតិស្តីពីការគាំពារកុមារតូច គោលនយោបាយគ្រូបង្រៀន គោលនយោបាយសាលាកុមារមេត្រី ច្បាប់ស្តីពីការអប់រំ គោលនយោបាយស្តីពីការអប់រំពិការ និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។ គោលនយោបាយ និងច្បាប់ ទាំងនេះបានបង្ក ភាពងាយស្រួលដល់ការចុះឈ្មោះចូលរៀននៅកម្រិតមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សា ផ្តល់ការបណ្តុះបណ្តាលគ្រូ បង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀន ហាមឃាត់មិនឲ្យមានការដាក់ទណ្ឌកម្មរាងកាយក្នុងសាលារៀន និងផ្តល់នូវការការពារសិទ្ធិកុមារក្នុងសាលារៀន។

ប៉ុន្តែការអភិវឌ្ឍសមត្ថភាពនៅតែជាតម្រូវការនៅឡើយទាំងនៅថ្នាក់ក្រសួង និងសាលារៀន។ នៅកម្រិតសាលារៀន បញ្ហាប្រឈមសំខាន់ៗ រួមមាន ចំនួនគ្រូដែលបានទទួលការបណ្តុះបណ្តាលផ្លូវការនៅមានកម្រិត បៀវត្សគ្រូនៅមានចំនួនតិច និងមានការផ្តល់ថវិកាតិចតួចសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការពិនិត្យតាមដាន និងរដ្ឋបាលនៅមានកម្រិតខ្សោយ និងកង្វះយន្តការរាយការណ៍ និងឆ្លើយតបចំពោះករណីសម្លុតគំរាម និងករណីដាក់ទណ្ឌកម្មលើរាងកាយ។ លើសពីនេះ អ្នកដែលមានជំនាញ និងបទពិសោធន៍ខាងការបណ្តុះបណ្តាលគ្រូ ក៏នៅមានចំនួនតិចតួចផងដែរ។

កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើកត្តាជាច្រើន ជាពិសេសហេដ្ឋារចនាសម្ព័ន្ធ គុណភាពនៃការបង្រៀន ការដាក់ទណ្ឌកម្មរាងកាយ ការរកឿងឈ្លោះតាមសាលារៀន និងសមត្ថភាពរបស់សាលារៀនក្នុងការឆ្លើយតបចំពោះតម្រូវការរបស់កុមារពិការ។ ចាំបាច់ត្រូវមានការពង្រឹងយន្តការបណ្តុះបណ្តាលគ្រូដែលកំពុងមានបច្ចុប្បន្ន រៀបចំគរុកោសល្យបង្រៀនសមស្រប និងមានលក្ខណៈច្នៃប្រឌិតថ្មី រៀបចំឯកសារបង្រៀននិងរៀនឲ្យបានសមស្រប និងរៀបចំប្រព័ន្ធសម្រាប់ពិនិត្យតាមដានការបង្រៀន និងរៀន ក្នុងគោលបំណងពិនិត្យតាមដាន និងបង្កើនគុណភាពនៃការអប់រំតាមសាលារៀន។ មន្ត្រីរដ្ឋាភិបាលគាំទ្រដល់ការវិភាគនេះ និងជឿថា ចាំបាច់ត្រូវតែមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីស្ថាប័នខាងក្រៅសម្រាប់ធ្វើការពង្រឹងប្រព័ន្ធ។ លើសពីនេះក៏ចាំបាច់ត្រូវមានការផ្តល់ការណែនាំបច្ចេកទេសសម្រាប់កែសម្រួលគោលនយោបាយ និងប្រព័ន្ធដែលមានស្រាប់ឲ្យបានកាន់តែប្រសើរថែមទៀតផងដែរ ដូចជាគំរូយន្តការពិនិត្យតាមដានជាដើម។

ផ្នែកមួយទៀតនៃការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ផងដែរនោះ គឺការរៀបចំគោលការណ៍ណែនាំ និងយុទ្ធនាការ ដើម្បីទប់ទល់នឹងករណីរករឿងឈ្លោះ និងទណ្ឌកម្មរាងកាយតាមសាលារៀន។ នេះជាចំណុចគួរឲ្យព្រួយបារម្ភមួយទៀត ដែលគណៈគ្រប់គ្រងសាលារៀនចាំបាច់ត្រូវធ្វើការឆ្លើយតបដោយមានការរៀបចំឲ្យបានល្អ ដោយគ្រូត្រូវតែជាអ្នកដែលទទួលខុសត្រូវធានាថាពិតជាពុំមានការរករឿងឈ្លោះ និងការដាក់ទណ្ឌកម្មរាងកាយកើតមានក្នុងសាលារៀនឡើយ។ ចាំបាច់ត្រូវមានការរៀបចំយុទ្ធនាការតាមសាលារៀន និងសហគមន៍ ដើម្បីធានាយ៉ាងណាឲ្យសិស្ស គ្រូ និងឪពុកម្ដាយយល់ដឹងថា ការរករឿងឈ្លោះ និងការដាក់វិន័យលើរាងកាយ គឺជាទង្វើដែលមិនអាចទទួលយកបាន និងមានផលប៉ះពាល់អវិជ្ជមានលើជនរងគ្រោះ។

ក្រសួងសង្គមកិច្ច
អតីតយុទ្ធជន និងយុវនីតិសម្បទា

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បញ្ញត្តិច្បាប់ និងគោលនយោបាយ ដែលដាក់ឲ្យអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ក្នុងវិស័យការពារកុមារ រួមមាន ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ផែនការសកម្មភាពជាតិស្ដីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ គោលនយោបាយស្ដីពីការថែទាំជំនួស បទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសសម្រាប់កុមារ អនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំជំនួស យុទ្ធសាស្ត្រជាតិស្ដីពីសុខភាពបន្តពូជ និងផ្លូវភេទ ២០១៣-២០១៦ និងច្បាប់ស្ដីពីយុត្តិធម៌ព្រហ្មទណ្ឌ ដែលទើបនឹងដាក់ឲ្យអនុវត្តកាលពីពេលថ្មីៗនេះ។

ចំណុចខ្វះខាតក្នុងការអនុវត្តគោលនយោបាយ និងច្បាប់ ដូចបរិយាយខាងលើ គួបផ្សំនឹងសមត្ថភាពរបស់ស្ថាប័នដែលទទួលខុសត្រូវលើការអនុវត្ត ស្ថាប័នផ្ដល់សេវាសុខភាព និងស្ថាប័នផ្ដល់សេវាច្បាប់នៅមានក្នុងការឆ្លើយតបចំពោះជនរងគ្រោះ និងជនប្រព្រឹត្តល្មើសនៅមានកម្រិតផង គឺជាបញ្ហាប្រឈមដ៏ធំមួយរបស់រដ្ឋាភិបាល។ ចាំបាច់ត្រូវមានការវាយតម្លៃ និងកែសម្រួលច្បាប់មួយចំនួន ជាពិសេស ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះឆ្នាំ ២០០៥ ក៏ដូចជាមាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណី (ដើម្បីឲ្យការដាក់ទណ្ឌកម្មរាងកាយ ដែលមិនត្រឹមតែកើតឡើងក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងផ្ទះ និងមណ្ឌលថែទាំកុមារផងដែរ ក្លាយជាអំពើខុសច្បាប់ ដែលអាចផ្ដន្ទាទោសតាមច្បាប់បាន)។ ការកែសម្រួលច្បាប់ទាំងនេះត្រូវតែធ្វើឡើងទន្ទឹមគ្នានឹងការអនុវត្តយន្តការពិនិត្យតាមដានតឹងរ៉ឹងមួយ ដើម្បីធានាឲ្យមានការអនុវត្តបញ្ញត្តិច្បាប់ទាំងនេះ និងដើម្បីទាមទារឲ្យអ្នកប្រព្រឹត្តទទួលខុសត្រូវតាមផ្លូវច្បាប់។ រដ្ឋាភិបាលត្រូវធ្វើការវាយតម្លៃលើការអនុវត្តន៍ច្បាប់ និង/ឬ គោលនយោបាយដែលមានស្រាប់ទាំងនេះ រួមទាំងធ្វើវិសោធនកម្មផងក្នុងពេលវេលាសមស្រប។

សមត្ថភាពរបស់សមត្ថកិច្ចនគរបាល បុគ្គលិកសុខាភិបាល មេធាវី និងប្រព័ន្ធយុត្តិធម៌ទាំងមូល ចាំបាច់ត្រូវពង្រឹងបន្ថែមទៀត ដើម្បីធានាឲ្យការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងពលកម្មកុមារ ការជួញដូរ ការរំលោភបំពានផ្លូវភេទ

និងផ្លូវកាយ អំពើហិង្សាក្នុងគ្រួសារ ការផ្ដល់សេវាសុខភាពផ្លូវភេទនិងបន្តពូជ ការថែទាំកុមារតាមមណ្ឌល និងការសុំកូន អាចធ្វើទៅបានប្រកបដោយប្រសិទ្ធភាព។ យុទ្ធសាស្ត្រនានា រួមមាន ការគាំទ្រដល់រដ្ឋាភិបាល ក្នុងការរៀបចំឯកសារបណ្ដុះបណ្ដាល សម្រាប់សមត្ថកិច្ចនគរបាល បុគ្គលិកសុខាភិបាល មេធាវី ។ល។ ដើម្បីឲ្យអ្នកទាំងនេះមានការយល់ដឹងកាន់តែច្បាស់អំពីអ្វីទៅជាការបំពានច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងការការពារកុមារ និងសិទ្ធិកុមារ, ការរៀបចំរចនាសម្ព័ន្ធសម្រាប់បង្កើតភ្នាក់ងារសង្គមកិច្ចមួយក្រុមដែលអាចទៅធ្វើការងារនៅថ្នាក់មូលដ្ឋានបាន អ្នកផ្ដល់ប្រឹក្សាដល់កុមារដែលអាចផ្ដល់ការគាំទ្រចិត្តសង្គមដល់ជនរងគ្រោះ និងការបង្កើតឧបករណ៍សវនកម្មសង្គម ដើម្បីពិនិត្យ និងវាយតម្លៃលើដំណើរការរបស់មណ្ឌលកុមារកំព្រា។

លើសពីនេះ បុគ្គលិករបស់រដ្ឋាភិបាលដែលមានការយល់ដឹងបច្ចេកទេសអំពី "ការពិនិត្យតាមដាន និងវាយតម្លៃ" គោលនយោបាយ និងកម្មវិធីរបស់រដ្ឋាភិបាលនៅមានចំនួនតិចតួចនៅឡើយ។ រដ្ឋាភិបាលត្រូវការការគាំទ្រ ក្នុងការរៀបចំក្របខ័ណ្ឌពិនិត្យតាមដានរួមមួយ សម្រាប់តាមដានភាពជឿនលឿននៃការផ្ដល់សេវាដល់ជនរងគ្រោះ។ ការមានបុគ្គលិកមិនគ្រប់គ្រាន់ គឺជាចំណុចខ្វះខាតខាងសមត្ថភាពមួយទៀតដែលរដ្ឋាភិបាលជួបប្រទះ ហើយបញ្ហានេះអាចបំពេញបាន តាមរយៈការសហការ និងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល។

## អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល

មានអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលជាច្រើនដែលកំពុងធ្វើការងារក្នុងផ្នែកការពារកុមារ។ កាលពីឆ្នាំ ២០១១ កិច្ចសហការរវាងយូនីសេហ្វ Friends International និងក្រសួងសង្គមកិច្ច ផ្ដោតលើកិច្ចការពារកុមារ ត្រូវបានអនុវត្ត។ កម្មវិធី '3PC' ផ្ដោតការយកចិត្តទុកដាក់លើការបង្កើតប្រព័ន្ធការពារកុមារក្នុងប្រទេសកម្ពុជា ហើយក្រោមយុទ្ធសាស្ត្រនេះ កម្មវិធីនេះបានបង្កើតនូវចលនាសុវត្ថិភាពកុមារមួយដែលប្រមូលផ្ដុំអង្គការសង្គមស៊ីវិល និងសមាជិកសហគមន៍ (ដែលក្លាយជាទីភ្នាក់ងារសុវត្ថិភាពកុមារ) ដើម្បីធ្វើឲ្យ "ការរាយការណ៍" និង "ការឆ្លើយតប" ចំពោះករណីរំលោភបំពានលើកុមារ និងករណីជួញដូរកុមារកាន់តែល្អប្រសើរជាងមុន។ ការសហការនេះក៏ផ្ដោតការយកចិត្តទុកដាក់លើការធ្វើសមាហរណកម្មកុមារកំព្រាក្នុងមណ្ឌលថែទាំកុមារ ឬកុមារដែលត្រូវបានគេបោះបង់ចោល ទៅក្រុមគ្រួសារនិងសហគមន៍វិញ។ អង្គការសង្គមស៊ីវិលផ្សេងទៀត ដែលធ្វើការងារក្នុងវិស័យនេះបានបង្កើតអង្គភាពគាំពារកុមារសម្រាប់ផ្ដល់សេវាជំនួយផ្លូវច្បាប់ និងសេវាសុខភាព ក្នុងករណីដែលមានអំពើហិង្សាកើតមានឡើង រៀបចំយុទ្ធនាការបង្កើនការយល់ដឹង (តាមផ្ទះ ព្រឹត្តិការណ៍តាមសហគមន៍ ប្រព័ន្ធផ្សព្វផ្សាយមូលដ្ឋាន ជាដើម) ក្នុងគោលបំណងបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីផលវិបាកជាអវិជ្ជមាននៃការបញ្ជូនកូនឲ្យទៅធ្វើការងារ រៀបចំថ្នាក់បង្រៀនពេលល្ងាចដើម្បីផ្ដល់ការអប់រំក្រៅផ្លូវការដល់កុមារដែលកំពុងធ្វើការងារ និងបានបង្កើតនូវថ្នាក់អប់រំជាស្ពានចម្លង ដើម្បីជួយឲ្យសិស្សបោះបង់ចោលការសិក្សា អាចចុះឈ្មោះចូលរៀនក្នុងការអប់រំក្នុងប្រព័ន្ធឡើងវិញ។

បញ្ហាប្រឈមសំខាន់ៗខាងសមត្ថភាពនៅចំពោះមុខអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលធ្វើជាមួយសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ រួមមាន ការខ្វះថវិកា ខ្វះបុគ្គលិកជំនាញឬធនធាន និងទំនាក់ទំនងនៅមានកម្រិតជាមួយនឹងស្ថាប័នពាក់ព័ន្ធសំខាន់ៗរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ ស្រុក និងសហគមន៍។ វិសាលភាព និងការគ្របដណ្តប់របស់កម្មវិធី 3PC ក្នុងការឆ្លើយតបចំពោះករណីរំលោភបំពានកុមារ និងករណីជួញដូរកុមារ នៅមានកម្រិតនៅឡើយ ដោយសារតែខ្វះថវិកា ដែលចាំបាច់ដើម្បីពង្រីកសកម្មភាពនៅជាទ្រង់ទ្រាយធំ និងផ្តល់សេវាទប់ស្កាត់ និងសេវាសង្គ្រោះឲ្យបានកាន់តែទូលំទូលាយជាងមុនបាន។ ដូច្នេះ អង្គការមិនមែនរដ្ឋាភិបាលត្រូវការការគាំទ្រ ដើម្បីរៀបចំយុទ្ធសាស្ត្ររៃអង្គាសប្រាក់។ ការគាំទ្រនេះអាចផ្តល់ក្នុងរូបភាពជាការបណ្តុះបណ្តាលដែលមានការរៀបចំត្រឹមត្រូវ ឬជាកញ្ចប់ឧបករណ៍ ដែលអង្គការទាំងនេះអាចយកទៅប្រើប្រាស់បាន។

ផ្នែកមួយទៀត ដែលទាមទារឲ្យមានការអភិវឌ្ឍសមត្ថភាពផងដែរនោះ គឺបុគ្គលិកជំនាញប្រកបដោយសមត្ថភាព ដូចជាអ្នកផ្តល់ប្រឹក្សាដល់កុមារ ដែលអាចផ្តល់ឲ្យជនរងគ្រោះនូវការគាំទ្រចិត្តសង្គមដែលចាំបាច់ និងភ្នាក់ងារសង្គមកិច្ចដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។ ដូច្នេះ ចាំបាច់ត្រូវតែមានការវិនិយោគលើការបង្កើតស្ថាប័នរៀនសូត្រ ដែលផ្តល់លទ្ធភាពឲ្យបុគ្គលនានាអាចអភិវឌ្ឍជំនាញដែលកំពុងត្រូវការជាចាំបាច់ទាំងនេះ។ អង្គការសង្គមស៊ីវិលត្រូវការការគាំទ្រ ដើម្បីរៀបចំកញ្ចប់ឧបករណ៍សម្រាប់ប្រើប្រាស់អមជាមួយនឹងគំរូឆ្លើយតបក្នុងសហគមន៍ ដែលពួកគេអាចយកទៅប្រើប្រាស់ ដើម្បីតៀងគរចលនាសហគមន៍ឲ្យបដិសេធមិនទទួលយកអំពើហិង្សាលើកុមារ និងផ្តល់ការការពារដល់សិទ្ធិរបស់កុមារ និងក្មេងជំទង់។ ពួកគេក៏ត្រូវការការគាំទ្រ ដើម្បីរៀបចំឧបករណ៍វាយតម្លៃមួយ ដែលសហគមន៍អាចយកទៅប្រើប្រាស់ ដើម្បីវាយតម្លៃលទ្ធផលការងារដែលខ្លួនសម្រេចបានផ្នែកកិច្ចការពារកុមារផងដែរ។ អង្គការសង្គមស៊ីវិលភាគច្រើនផ្តោតការយកចិត្តទុកដាក់លើការងារពាក់ព័ន្ធនឹងការទប់ស្កាត់ និងមានបំណងចង់ពង្រីកវិសាលភាពការងារទៅក្នុងការឆ្លើយតបចំពោះបណ្តឹង និងការស្តារនីតិសម្បទាផងដែរ។ ប៉ុន្តែ ពួកគេមិនអាចធ្វើបាន ដោយសារតែការយល់ដឹងបច្ចេកទេស និងបទពិសោធន៍នៅមានកម្រិតនៅឡើយ។ ពួកគេចង់បានការគាំទ្រជាការបណ្តុះបណ្តាលអំពីការរៀបចំ និងការអនុវត្តកម្មវិធីដែលផ្តោតលើសកម្មភាពទាំងនេះ និងការគាំទ្របែបជាការដឹកដៃនាំធ្វើ ក្នុងការគ្រប់គ្រងកម្មវិធីទាំងនេះ រហូតដល់ពេលមួយដែលពួកគេមានជំនាញឯកទេសអាចធ្វើការគ្រប់គ្រងដោយខ្លួនឯងបាន។



# សេចក្ដីសន្និដ្ឋាន

កំណើនប្រជាជនយ៉ាងឆាប់រហ័ស បានដាក់សម្ពាធយ៉ាងខ្លាំងលើទីក្រុងភ្នំពេញ ជាពិសេស សហគមន៍ក្រីក្រក្នុងទីក្រុងនេះ។ កុមារ និងក្មេងជំទង់ គឺជាក្រុមមួយ ក្នុងក្នុងចំណោមក្រុមងាយរងគ្រោះជាងគេ ដែលរស់នៅតាមសហគមន៍ទាំងនេះ។ លទ្ធផលនៃការសិក្សានេះបង្ហាញថា ក្រុមនេះប្រឈមនឹងហានិភ័យជាច្រើន ដូចជាអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ការជួញដូរមនុស្ស ការឆាប់រៀបការទាំងនៅក្មេង ពលកម្មកុមារ និងការប្រើបំពានសារធាតុជាដើម។ ឧបសគ្គផ្នែកសេដ្ឋកិច្ចសង្គម និងផ្នែករចនាសម្ព័ន្ធធ្វើឲ្យកុមារ និងក្មេងជំទង់ត្រូវប្រឈមនឹងហានិភ័យយ៉ាងច្រើនពាក់ព័ន្ធនឹងសុខភាព និងអនាម័យ។ មានការកត់សម្គាល់ផងដែរថាក្មេងជំទង់ដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងគឺប្រឈមនឹងហានិភ័យ ដោយសារតែទំនាស់ជាមួយច្បាប់។ ស្ថិតិដែលប្រមូលបានតាមរយៈការសិក្សានេះបង្ហាញថាសហគមន៍ក្រីក្រក្នុងទីក្រុងពិតជាបានដឹងពីហានិភ័យពាក់ព័ន្ធជាមួយនឹងកិច្ចការពារកុមារ។

កុមារមិនសូវជាបានទៅរៀននៅសាលាមត្តេយ្យឡើយ ហើយគុណភាពនៃការអប់រំដែលផ្តល់ឲ្យក្មេងជំទង់ ក៏នៅមានកម្រិតដែរ។ បើទោះបីជានៅសាលារៀនក៏ដោយ ក្មេងជំទង់ប្រឈមនឹងហានិភ័យនានា ដូចជាការដាក់ទណ្ឌកម្មលើរាងកាយ ការរករឿងឈ្លោះ និងការមិនសូវអើពើពីគ្រូរបស់ពួកគេជាដើម។ ទំនាក់ទំនងរវាងឧបសគ្គផ្នែកសេដ្ឋកិច្ច បទដ្ឋានសង្គមវប្បធម៌ និងហានិភ័យនានាក្នុងសាលារៀន ធ្វើឲ្យកុមារ និងក្មេងជំទង់ មកពីសហគមន៍ក្រីក្រក្នុងទីក្រុង ក្លាយជាក្រុមដែលត្រូវការការថែទាំ និងការគាំទ្រភ្លាមៗពីរដ្ឋាភិបាល។

លើសពីនេះ ក្រុមកុមារតូចៗផ្សេងទៀត ដូចជាកុមារកំព្រា កុមារដែលត្រូវបានគេបោះបង់ចោលឲ្យរស់នៅតាមផ្លូវ និងកុមារមានពិការភាព ត្រូវបានគេសង្កេតឃើញថាជាក្រុមដែលប្រឈមនឹងហានិភ័យខ្ពស់ជាងគេដោយសារតែស្ថានភាពរបស់ពួកគេ ឬដោយសារតែពួកគេពុំបានទទួលការថែទាំ និងការឃុំគ្រងជិតដល់ពីមនុស្សចាស់។

គ្រួសាររស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុងភាគច្រើនគឺកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ ហើយភាពក្រីក្រនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងហានិភ័យចម្បងៗ ភាគច្រើនជុំវិញកិច្ចការពារចំពោះកុមារ និងក្មេងជំទង់។ តម្រូវការចិញ្ចឹមជីវិតរបស់គ្រួសារ បង្ខំឲ្យឪពុកម្តាយភាគច្រើន ត្រូវចំណាយពេលស្វែងរកឱកាសការងារ ដែលធ្វើឲ្យពួកគេមានពេលតិចតួចបំផុតដើម្បីថែទាំ និងឃុំគ្រងកូនៗរបស់ខ្លួន។ នេះធ្វើឲ្យក្មេងជំទង់ងាយចូលរួមក្នុងក្រុមទំនើង ប្រើប្រាស់សារធាតុប្រើគ្រឿងស្រវឹង និងមានទំនាស់ជាមួយច្បាប់។

ទាក់ទងនឹងហិង្សាក្នុងគ្រួសារលើស្ត្រី និងកុមារ ប្រជាពលរដ្ឋជាច្រើនគ្រួសារបានលើកឡើងថា ការប្រើប្រាស់ទណ្ឌកម្មរាងកាយ សម្រាប់ដាក់វិន័យលើកុមារគឺជារឿងដែលសមស្រប។

ការខ្វះការថែទាំ និងការយកចិត្តទុកដាក់ពីឪពុកម្តាយគួបផ្សំជាមួយនឹងការកើតឡើងនូវអំពើហិង្សាក្នុងគ្រួសារផងជារឿយៗ ធ្វើឲ្យក្មេងជំទង់រត់គេចចេញពីផ្ទះ។ មានករណីដែលកុមារត្រូវបានរាយការណ៍ថាបាត់ខ្លួនចេញពីផ្ទះ ហើយសហគមន៍យល់ថាកុមារ និងក្មេងជំទង់ទាំងនេះប្រហែលជាត្រូវបានគេចាប់យកទៅលក់។

ការអនុវត្តអនាម័យ និងបរិក្ខារអនាម័យនៅមានកម្រិតទាប ធ្វើឲ្យកុមារជាច្រើនងាយឆ្លងជំងឺដែលឆ្លងតាមទឹក។ គ្រួសារជាច្រើនពុំមានទឹកស្អាតសម្រាប់ផឹកឡើយ ដែលអាចធ្វើឲ្យមានផលប៉ះពាល់លើការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។

ប្រជាពលរដ្ឋជាច្រើនគ្រួសារ បានលើកឡើងពីការរៀបអាពាហ៍ពិពាហ៍របស់ក្មេងជំទង់ ហើយភាគច្រើនពេលដែលប្រជាពលរដ្ឋលើកឡើងពីបញ្ហានេះ ពួកគេក៏លើកឡើងពីករណីមានផ្ទៃពោះរបស់ក្មេងជំទង់ដែលជួបនឹងផលវិបាកផងដែរ។ ក្មេងជំទង់ជាច្រើននាក់ក្នុងសហគមន៍កំពុងសកម្មក្នុងរឿងផ្លូវភេទ ប៉ុន្តែដោយសារតែពួកគេទទួលបានការអប់រំអំពីផ្លូវភេទតិចតួច ពួកគេពុំបានប្រតិបត្តិប្រកបដោយសុវត្ថិភាពឡើយ ដែលធ្វើឲ្យពួកគេត្រូវប្រឈមនឹងមេរោគអេដស៍ និងជំងឺកាមរោគ។ សាលារៀនក្នុងរាជធានីភ្នំពេញបំពេញតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការពារសិទ្ធិរបស់កុមារ និងក្មេងជំទង់ តាមរយៈការផ្តល់ការអប់រំអំពីផ្លូវភេទ ការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងអំពីសុខភាព និងផ្តល់ឱកាសឲ្យពួកគេអាចអភិវឌ្ឍខ្លួនដើម្បីទទួលបានអនាគតផ្នែកសេដ្ឋកិច្ច

កាន់តែត្រចះត្រចង់។ លើសពីនេះ សមាជិកសហគមន៍ចាត់ទុកគ្រូបង្រៀនថាជាបុគ្គលដែលមានចំណេះដឹងខ្ពស់ និងផ្តល់តម្លៃខ្ពស់ដល់ដំបូន្មាន និងទស្សនៈយល់ឃើញរបស់ពួកគេ។

ប៉ុន្តែមកទល់នឹងពេលនេះ មិនទាន់មានការទាញប្រយោជន៍ពីបរិយាកាសសាលារៀន ដើម្បីសម្រេចនូវប្រយោជន៍ដូចលើកឡើងខាងលើនេះឡើយ។ ផ្ទុយទៅវិញ បែរជាមានហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារដោយសារតែការដាក់ទណ្ឌកម្មរាងកាយ និងការរករឿងឈ្លោះនៅតាមសាលារៀនទៅវិញ។

ទំនាក់ទំនងរវាងហានិភ័យជុំវិញកិច្ចការពារកុមារក្នុងសាលារៀន និងក្នុងផ្ទះ ត្រូវបានស្តែងចេញយ៉ាងច្បាស់តាមរយៈការកត់សម្គាល់ឃើញថាកុមារក្រៅសាលាងាយនឹងពាក់ព័ន្ធជាមួយនឹងពលកម្មកុមារ វប្បធម៌ទំនើង ការប្រើសារធាតុ។ល។

គុណភាពនៃការអប់រំតាមសាលារៀន ក៏មានកំហិតដោយសារតែកម្រិតនៃកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នរបស់គ្រូផងដែរ (នេះមិនមែនសំដៅលើគុណវឌ្ឍិ ឬជំនាញរបស់ពួកគេឡើយ) ការពុំមានចំណេះដឹងគរុកោសល្យបែបថ្មីសម្រាប់បង្រៀន ឱកាសតិចតួចដើម្បីទទួលបានការបណ្តុះបណ្តាលផ្លូវការ និងការមានឯកសារបង្រៀន និងរៀនសមស្របតិចតួច និងការរៀនសូត្រដោយប្រើកុំព្យូទ័រជាជំនួយ។ល។ ចំណុចខ្វះខាតខាងគុណភាពនៃការអប់រំ ការចំណាយផ្ទាល់ខ្លួនលើការអប់រំ និងការបង់ថ្លៃក្រៅផ្លូវការសម្រាប់ការរៀនគួរបន្ថែម នាំឲ្យឪពុកម្តាយគិតថា ការដកកូនចេញពីសាលារៀនផ្តល់នូវប្រយោជន៍ខាងសេដ្ឋកិច្ចច្រើនជាង។ ជាលទ្ធផល កុមារទាំងនេះត្រូវបានរុញច្រានឲ្យធ្លាក់ចូលទៅក្នុងពលកម្មកុមារ ឬត្រូវនៅធ្វើការងារផ្ទះមួយចំនួន (ដើម្បីឲ្យម្តាយអាចទៅធ្វើការងារបាន)។ គុណវឌ្ឍិអប់រំទាបជាកត្តាដែលកំហិតឱកាសការងារ សម្រាប់កុមារទាំងនេះ។ ដូច្នេះពួកគេច្រើនតែត្រូវជាប់គាំងក្នុងវដ្តនៃភាពក្រីក្រ ដែលទាំងនេះត្រូវបានចាត់ទុកថាជាកត្តាដែលនាំឲ្យមានកើតមាននូវហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារជាច្រើន ដែលកុមារ និងក្មេងជំទង់មកពីសហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញជួបប្រទះ។

ការឆ្លើយតបចំពោះហានិភ័យពាក់ព័ន្ធជាមួយនឹងកិច្ចការពារកុមារដូចលើកឡើងខាងលើ តម្រូវឲ្យមានយន្តការ ដើម្បីធានាឲ្យមានការអនុវត្តច្បាប់ និងគោលនយោបាយដែលមានស្រាប់ កែសម្រួលច្បាប់ និងគោលនយោបាយមួយចំនួន ដាក់ឲ្យអនុវត្តការការពារផ្នែកច្បាប់ សម្រាប់ការពារសិទ្ធិកុមារ និងកម្មវិធីដែលមានលក្ខណៈច្នៃប្រឌិតថ្មីនៅថ្នាក់មូលដ្ឋាន និងយុទ្ធនាការផ្លាស់ប្តូរឥរិយាបថ ក្នុងគោលបំណងផ្លាស់ប្តូរការយល់ឃើញ ទស្សនៈយល់ឃើញជំនឿ និងការអនុវត្តនានារបស់សហគមន៍។ មានការរកឃើញយ៉ាងច្បាស់ថាក្នុងករណីភាគច្រើន ដើម្បីឲ្យមានការឆ្លើយតបគ្រប់ជ្រុងជ្រោយ ចាំបាច់ត្រូវមានការចូលរួមឲ្យបានសកម្ម (និងការដឹកនាំ) ពីគ្រូ គណៈគ្រប់គ្រងសាលារៀន និងអ្នកដឹកនាំសហគមន៍។ ដូច្នេះ ជាការសំខាន់ណាស់ ដែលត្រូវចាត់ទុកសាលារៀនជាទីកន្លែងដែលជាផ្នែកមួយនៃកំណែទម្រង់ឬដំណោះស្រាយ។



# អនុសាសន៍

## អន្តរាគមន៍តាមរយៈ កម្មវិធីសិក្សា ផ្តោតលើអំពើហិង្សា ការរករឿងឈ្លោះ ការអប់រំផ្លូវភេទ និងការប្រើប្រាស់សារធាតុញៀន

សាលារៀនត្រូវបានចាត់ទុកថាជាកន្លែងសម្រាប់អប់រំក្មេងជំទង់អំពីបំណិនជីវិត និងបំណិនសង្គមសំខាន់ៗ។ ខណៈពេលដែលកម្មវិធីសិក្សាធម្មតាតែងផ្តល់សារអប់រំពាក់ព័ន្ធនឹងបញ្ហានានា ដូចជាអំពើហិង្សា និងការរករឿងឈ្លោះជាដើម។ មានការរកឃើញយ៉ាងច្បាស់ថា បញ្ហាទាំងនេះទាមទារឲ្យមានដំណោះស្រាយឲ្យចំបញ្ហា និងមានការរៀបចំត្រឹមត្រូវ។ បច្ចុប្បន្ននេះ យូនីសេហ្វកំពុងគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តកម្មវិធី "ដាក់វិន័យបែបវិជ្ជមាន" តាមសាលារៀនជាច្រើន ហើយកំពុងជួយរដ្ឋាភិបាលពិនិត្យតាមដានការអនុវត្តកម្មវិធីនេះផងដែរ។ កម្មវិធីនេះផ្តោតការយកចិត្តទុកដាក់លើការបង្កើនការយល់ដឹងតាមសាលារៀនអំពីមូលហេតុដែលនាំឲ្យអំពើហិង្សាប្រភេទផ្សេងៗកើតមានឡើង និងផលវិបាកនៃអំពើហិង្សាទាំងនេះ និងការទទួលខុសត្រូវដែលនាយកសាលា សិស្ស និងឪពុកម្តាយមានរួមគ្នា ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារ។ ប៉ុន្តែកម្មវិធីនេះមិនទាន់បានអនុវត្តតាមសាលារៀន សម្រាប់សិស្សមកពីតាមសហគមន៍ក្រីក្រក្នុងទីក្រុងនៅឡើយទេ។ រដ្ឋាភិបាលអាចស្វែងរកការគាំទ្របន្ថែមទៀតពីយូនីសេហ្វ ក្នុងការពង្រីកវិសាលភាពនៃកម្មវិធីនេះ ដើម្បីគ្របដណ្តប់លើសហគមន៍ក្រីក្រក្នុងទីក្រុង។ លើសពីនេះ ដោយប្រើរបកគំហើញនៃការសិក្សានេះ រដ្ឋាភិបាលអាចពិនិត្យលើមេរៀនដែលកំពុងប្រើប្រាស់ក្នុងកម្មវិធីនេះ ពង្រឹងការអនុវត្តមេរៀននេះបន្ថែមទៀតឲ្យស្របតាមតម្រូវការរបស់កុមារ និងក្មេងជំទង់ មកពីតាមសហគមន៍ក្រីក្រក្នុងទីក្រុង។ សម្រាប់ចំណុចនេះ រដ្ឋាភិបាលអាចស្វែងរកការគាំទ្រពីយូនីសេហ្វ ឬពីស្ថាប័នប្រហាក់ប្រហែលគ្នានេះដែរ។

## យុទ្ធនាការផ្លាស់ប្តូរឥរិយាបថតាមសហគមន៍ ផ្តោតលើការប្រើប្រាស់សារធាតុ ការដាក់ទណ្ឌកម្មលើរាងកាយ ការរៀបអាពាហ៍ពិពាហ៍របស់ក្មេងជំទង់ អំពើហិង្សាលើកុមារ និងករណីជួញដូរមនុស្ស

សហគមន៍មានការយល់ដឹងពីផលវិបាកអវិជ្ជមាននៃការដាក់ទណ្ឌកម្មលើរាងកាយ ការប្រើសារធាតុ អំពើហិង្សាលើកុមារ ។ល។ ប៉ុន្តែការយល់ដឹងនេះពុំមែនមានន័យថាពិតនាំឲ្យមានការផ្លាស់ប្តូរឥរិយាបថឡើយ។ ចាំបាច់ត្រូវតែមានការរៀបចំយុទ្ធនាការផ្លាស់ប្តូរឥរិយាបថផ្តោតចំគោលដៅ ដែលបន្ថែមពីលើការផ្សព្វផ្សាយព័ត៌មាន ក៏ត្រូវមានការរៀបចំផែនការសកម្មភាព ដែលសហគមន៍អាចយកទៅអនុវត្តផងដែរ។ តាមរយៈកិច្ចសហការយ៉ាងជិតស្និទជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលដែលកំពុងធ្វើការងារក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង រដ្ឋាភិបាលគួររិះរកគំនិតអភិវឌ្ឍបន្ថែមលើមេរៀនទាងនេះ តាមរយៈការសាកល្បង ការពង្រីកការអនុវត្តក្រោយពេលបានបញ្ចប់ខ្លឹមសារ និងកំណត់ដឹងពីផលវិជ្ជមានរួចហើយ។ ការជំរុញឲ្យមានការចូលរួមពីសមាជិកសហគមន៍ ក្នុងនាមពួកគេជាអ្នកទទួលការបណ្តុះបណ្តាល និងជាអ្នកដឹកនាំការងារអនុវត្តផ្ទាល់ (ការរៀបចំផែនការសកម្មភាពសហគមន៍) គឺជាការងារសំខាន់ ដើម្បីធានាឲ្យមេរៀនផ្លាស់ប្តូរឥរិយាបថទាំងនេះអាចទទួលបានមេរៀនជោគជ័យ។ អន្តរាគមន៍ស្រដៀងគ្នានេះធ្លាប់ត្រូវបានគេធ្វើតេស្តសាកល្បងជោគជ័យនៅប្រទេសឡាវ និងវៀតណាម ដែលជាប្រទេសជិតខាងនឹងកម្ពុជា។ តាមពិត អង្គការ UN Women នៅកម្ពុជា បានរៀបចំ និងធ្វើតេស្តសាកល្បងអន្តរាគមន៍ ស្រដៀងគ្នានេះដែរ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី តាមរយៈសកម្មភាពសហគមន៍។

## ក្រុមសុវត្ថិភាពតាមសហគមន៍

ភ្ជាប់ជាមួយនឹងមេរៀនផ្លាស់ប្តូរឥរិយាបថដូចលើកឡើងខាងលើ គួរមានការបង្កើតក្រុមឃ្លាំមើលមួយ សម្រាប់ពិនិត្យតាមដានសហគមន៍ និងការពារសិទ្ធិកុមារនិងក្មេងជំទង់។ ក្រុមនេះនឹងធ្វើទំនាក់ទំនងជាមួយនឹងប្រធានសហគមន៍ ធ្វើអន្តរាគមន៍ក្នុងករណីដែលមានអំពើហិង្សាលើកុមារ ការដាក់ទណ្ឌកម្មលើរាងកាយ និងការរៀបអាពាហ៍ពិពាហ៍របស់ក្មេងជំទង់កើតមានឡើង។ ក្រុមនេះក៏នឹងសម្របសម្រួលជាមួយនគរបាលផងដែរ ក្នុងករណីធំៗដែលចាំបាច់ត្រូវមានការឆ្លើយតបពីនគរបាលនិងក្នុងករណីដែលមានការរាយការណ៍ពីការបាត់ខ្លួនកុមារឬក្មេងជំទង់ពីផ្ទះ។ ក្រុមនេះក៏នឹងបន្តពិនិត្យតាមដានសហគមន៍ ដើម្បីរកសមាសភាពសង្ស័យ ដែលអាចបង្កការគំរាមកំហែងដល់កុមារឬក្មេងជំទង់ផងដែរ។ ដូចពិភាក្សាខាងក្រោម សមាជិកមួយចំនួនរបស់ក្រុមនេះក៏គួរជាសមាជិករបស់គណៈកម្មការទ្រទ្រង់សាលាផងដែរ។

## បណ្តុះបណ្តាលសមាជិកស្ថាប័នអនុវត្តច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌

រដ្ឋាភិបាលកំពុងធ្វើការងារបង្កើតអនុប្រព័ន្ធដោយឡែកមួយ សម្រាប់ធ្វើការឆ្លើយតបចំពោះករណីកុមារដែលមានទំនាស់ជាមួយច្បាប់។ ប៉ុន្តែ ជោគជ័យនៃប្រព័ន្ធថ្មីនេះគឺអាស្រ័យលើសមត្ថភាពរបស់មន្ត្រី ដែលជាអ្នកគ្រប់គ្រង និងអនុវត្តប្រព័ន្ធនេះដែរ។ ការបណ្តុះបណ្តាលមន្ត្រីទាំងនេះឲ្យយល់ដឹងពីភាពចាំបាច់ ក្នុងការឆ្លើយតបចំពោះតម្រូវការរបស់កុមារនិងក្មេងជំទង់ គឺមានសារៈសំខាន់ ដើម្បីធានាឲ្យកម្មវិធីនេះទទួលបានជោគជ័យ។ រដ្ឋាភិបាលគួរបំពេញភារកិច្ចបណ្តុះបណ្តាលមន្ត្រីទាំងនេះ។ រដ្ឋាភិបាលអាចដឹកនាំដំណើរការនេះ ហើយជំនាញបច្ចេកទេសអាចមានប្រភពចេញពីស្ថាប័ននានាដូចជា យូនីសេហ្វ ឬដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតដែលជាស្ថាប័នជំនាញខាងបញ្ហាសិទ្ធិកុមារ។ ដូចករណីបញ្ជាក់ពីខាងដើមដែរ គំនិតបែបនេះគួរយកទៅបង្កើតចេញជាមេរៀនសម្រាប់សាកល្បង ហើយប្រសិនបើជោគជ័យ រដ្ឋាភិបាលអាចពង្រីកការអនុវត្តក្នុងទ្រង់ទ្រាយធំបាន។ មេរៀននេះត្រូវរៀបចំយ៉ាងណាឲ្យមានប្រសិទ្ធិភាព សម្រាប់ធ្វើការងារជាមួយមន្ត្រីនគរបាល ចៅក្រម និងមេធាវី។ លើសពីនេះ ការបង្កើតអង្គភាពឯកទេស (ដែលបានទទួលការបណ្តុះបណ្តាល) សម្រាប់ទទួលបន្ទុកកុមារតាមប៉ុស្តិ៍នគរបាល នឹងជួយផ្តល់ការឆ្លើយតបកាន់តែសមស្របចំពោះបទល្មើសប្រឆាំងកុមារ និងចំពោះកុមារដែលមានទំនាស់ជាមួយច្បាប់។

## បង្កើនលទ្ធភាពទទួលបានទឹកស្អាតដែលមានសុវត្ថិភាពសម្រាប់ពិសា តាមរយៈគំនិតផ្តួចផ្តើមខាងផ្នែកតម្រូវការ និងខាងផ្នែកផ្គត់ផ្គង់

សមាជិកសហគមន៍ជាច្រើននាក់មិនយល់ពីភាពខុសប្លែកគ្នារវាងទឹកស្អាត និងទឹកដែលមានសុវត្ថិភាពសម្រាប់ពិសាឡើយ។ ពួកគេមួយចំនួនមានការប្រុងប្រយ័ត្ន ដោយពួកគេយកទឹកមកដាំឲ្យពុះមុននឹងពិសា ប៉ុន្តែមិនបានទុកដាក់ទឹកឲ្យមានអនាម័យឡើយ។ ស្ថានភាពនេះទាមទារឲ្យមានការឆ្លើយតបគ្រប់ជ្រុងជ្រោយ ដោយផ្តោតលើការកែទម្រង់នៅខាងផ្នែកតម្រូវការផង និងខាងផ្នែកផ្គត់ផ្គង់ផង។ រដ្ឋាភិបាលអាចផ្តួចផ្តើមបង្កើតយុទ្ធនាការផ្លាស់ប្តូរឥរិយាបថ ដើម្បីបង្កើនការយល់ដឹងដល់គ្រួសារក្រីក្រក្នុងទីក្រុងអំពីភាពចាំបាច់ ក្នុងការសម្អាតទឹកសម្រាប់ពិសាឲ្យបានត្រឹមត្រូវ និងភាពចាំបាច់ ដើម្បីរក្សាទឹកក្នុងធុងដែលស្អាត និងមានអនាម័យ។ យូនីសេហ្វ ឬដៃគូអភិវឌ្ឍន៍ផ្សេងទៀតអាចធ្វើការងារជាមួយរដ្ឋាភិបាល ដើម្បីរៀបចំយុទ្ធសាស្ត្រផ្តល់សេវាគ្រប់ជ្រុងជ្រោយមួយ ក្នុងគោលបំណងបញ្ជាក់ឲ្យបានច្បាស់ពីមធ្យោបាយ និងយន្តការ ដែលគេអាចប្រើប្រាស់សម្រាប់ដឹក និងចែកចាយទឹកជូនប្រជាពលរដ្ឋនៅតាមតំបន់ក្រីក្រក្នុងទីក្រុង។

## បញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលនៅតាមសហគមន៍ក្រីក្រក្នុងទីក្រុង

សមាជិកភាគច្រើនក្នុងសហគមន៍ដឹងថា ការបន្ទោរបង់ពាសវាលពាសកាលអាចនាំឲ្យមានការឆ្លងរាលដាលជំងឺ ដែលអាចបង្ការបាន។ បញ្ហាគឺត្រង់ថា គ្រួសារជាច្រើនពុំមានទីកន្លែង ឬប្រាក់កាស ដើម្បីសាងសង់បង្គន់។ ក្នុងករណីផ្សេងទៀត គ្រួសារអាចមានសមាជិកច្រើនពេក សម្រាប់បង្គន់មួយ។ ការផ្លាស់ប្តូរទីលំនៅញឹកញាប់ដោយសារតែការបណ្តេញចេញ ឬការផ្លាស់ប្តូរទីលំនៅ ក៏ជាកត្តាដែលបន្ទុចបង្អាក់ទឹកចិត្តប្រជាពលរដ្ឋមិនឲ្យសាងសង់បង្គន់ដែរ។ កត្តាទាំងនេះនាំឲ្យទឹកស្អុយពីបង្គន់ក្នុងសហគមន៍ទាំងនេះទៅប្រមូលផ្តុំក្នុងតំបន់ទាបៗ ក្នុង ឬជិតសហគមន៍។ ដោយសារតែឧបសគ្គខាងផ្នែកតម្រូវការផង និងខាងផ្នែកផ្គត់ផ្គង់ផង ចាំបាច់ត្រូវមានការរិះរកគំនិតសាងសង់បរិក្ខារអនាម័យតាមសហគមន៍ ដែលប្រជាពលរដ្ឋអាចប្រើប្រាស់បាន ដោយបង់ចំណាយតិចតួច (គ្រប់គ្រាន់សម្រាប់ការថែទាំ និងបន្តដំណើរការបរិក្ខារទាំងនោះ)។ សហគមន៍ក៏អាចបង់ថ្លៃសម្រាប់បរិក្ខារទាំងនេះផងដែរ ដោយសារតែបច្ចុប្បន្ននេះ សមាជិកសហគមន៍ក៏កំពុងទិញទឹកសម្រាប់ផឹកពីអ្នកផ្គត់ផ្គង់ឯកជនដែរ។ បើគិតពីការគ្រប់គ្រងទឹកស្អាត បរិក្ខារអនាម័យក្នុងសហគមន៍គឺងាយគ្រប់គ្រងជាង ហើយប្រជាពលរដ្ឋទាំងអស់ក្នុងសហគមន៍នឹងអាចប្រើប្រាស់បរិក្ខារអនាម័យទាំងអស់នោះបាន។ គំរូនេះត្រូវបានធ្វើតេស្តសាកល្បង និងអនុវត្តដោយជោគជ័យ នៅតាមប្រទេសនានា ដូចជាប្រទេសថៃ នីហ្សេរីយ៉ា និងហ្គាណាជាដើម។

## ការចុះបញ្ជី និងការគ្រប់គ្រងមណ្ឌលកុមារកំព្រា

ការពិភាក្សាជាមួយនឹងតំណាងអង្គការសង្គមស៊ីវិល និងមន្ត្រី រដ្ឋាភិបាលបង្ហាញថា មណ្ឌលកុមារកំព្រាក្នុងប្រទេសកម្ពុជាមិនមែនសុទ្ធតែបានចុះបញ្ជីជាមួយរដ្ឋាភិបាលឡើយ ហើយប្រតិបត្តិការរបស់មណ្ឌលកុមារកំព្រាទាំងនេះក៏ពុំត្រូវបានធ្វើអធិការកិច្ចបានដិតដល់ទាំងអស់ពីសំណាក់អាជ្ញាធរដែរ។ ចាំបាច់ត្រូវមានការផ្លាស់ប្តូរស្ថានភាពបែបនេះ បើមិនដូច្នោះទេ ស្ថាប័នដែលត្រូវបានបង្កើតឡើង ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារកំព្រា អាចក្លាយជាកន្លែងដែលមានការរំលោភបំពានសិទ្ធិកុមារទៅវិញ។

ប្រសិនបើពុំមានការពិនិត្យឲ្យបានត្រឹមត្រូវទេ មណ្ឌលកុមារកំព្រាអាចក្លាយជាមជ្ឈមណ្ឌលនៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ ការរករឿងឈ្លោះ អំពើហិង្សាលើកុមារ។ល។ រដ្ឋាភិបាលគួរពិនិត្យតាមដានច្បាប់ដែលតម្រូវឲ្យ "មានការចុះបញ្ជីមណ្ឌលកុមារកំព្រាជាផ្លូវការ" ដោយប្រើប្រាស់ប្រព័ន្ធសម្រាប់ពិនិត្យតាមដានមណ្ឌលកុមារកំព្រាទាំងនោះ តាមរយៈការបង្កើតអង្គភាពពង្រឹងការអនុវត្តតាមខណ្ឌ ឬសង្កាត់។ ជម្រើសមួយទៀតគឺ អាចស្នើឲ្យអង្គការសង្គមស៊ីវិលជួយពិនិត្យតាមដានមណ្ឌលទាំងនោះ។ ដើម្បីឲ្យដំណើរការសវនកម្មធ្វើទៅប្រកបដោយតម្លាភាព និងពេញលេញ ចាំបាច់ត្រូវមានការរៀបចំគោលការណ៍ណែនាំស្តីពីការបង្កើត និងដំណើរការមណ្ឌលកុមារកំព្រាដែលមានលក្ខណៈកុមារមេត្រី និងផ្តល់សុវត្ថិភាពដល់កុមារ។

## ការជម្រុញឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងសេវនកម្មសង្គម និងធានាឲ្យមានការអនុលោមទៅតាមបញ្ញត្តិច្បាប់នានា

ឧបសគ្គមួយ ក្នុងចំណោមឧបសគ្គធំៗដែលរារាំងដល់ការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិនានាប្រកបដោយប្រសិទ្ធិភាព គឺការខ្វះធនធានមនុស្ស នៅតាមក្រសួងស្ថាប័ននានារបស់រដ្ឋាភិបាល។ ការខ្វះសមត្ថភាព ដើម្បីពិនិត្យតាមដានភាពអនុលោមទៅតាមច្បាប់ នាំឲ្យមានស្ថានភាពជាច្រើន ដូចជា ហាងលក់គ្រឿងស្រវឹងទៅឲ្យក្មេងជំទង់ដែលជាអនីតិជន ហើយរោងចក្រនៅតែបន្តជួលកុមារឲ្យធ្វើការងារ។ រដ្ឋាភិបាលអាចស្វែងរកជំនួយពីស្ថាប័ននានា ដើម្បីរៀបចំគំរូឬក្របខ័ណ្ឌសវនកម្មសង្គមដែលមានលក្ខណៈស្តង់ដា និងស្នើឲ្យអង្គការសង្គមស៊ីវិលយកគំរូឬក្របខ័ណ្ឌនេះទៅប្រើប្រាស់ ដើម្បីធានាឲ្យមានភាពអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា រាយការណ៍ពីការមិនអនុវត្តច្បាប់ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងធ្វើការតាមដានបន្ត ដើម្បីឲ្យមានការចាត់វិធានការណ៍។ គេក៏អាចរៀបចំក្របខ័ណ្ឌសវនកម្មសង្គម និងក្របខ័ណ្ឌពិនិត្យតាមដាន ដើម្បីវាយតម្លៃលើប្រព័ន្ធការពារកុមារផ្សេងទៀតផងដែរ ដូចជាប្រព័ន្ធសម្រាប់ការពារកុមារដែលមានទំនាស់ជាមួយច្បាប់ កុមារដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារប្រើគ្រឿងញៀន។ល។

## បង្កើនប្រសិទ្ធភាពការងារត្រួតពិនិត្យតាមដានសាលា

ចំណុចល្អគួរឲ្យកត់សម្គាល់គឺនៅត្រង់ថា មាតាបិតាផ្តល់តម្លៃខ្ពស់ដល់លទ្ធផលសិក្សា និងភាពរីកចម្រើននៃការអប់រំរបស់កូនពួកគេ។ ប៉ុន្តែ ពួកគេក៏ជួបប្រាស្រ័យទាក់ទងតិចតួចបំផុតជាមួយនឹងគ្រូដែលបង្រៀនកូនរបស់ពួកគេដែរ ហើយមិនគិតថាពួកគេមានសិទ្ធិធ្វើសវនកម្ម ឬផ្តល់យោបល់ពីលទ្ធផលការងារសាលារៀនឡើយ។ បើទោះបីជាសាលារៀនជាច្រើនមានគណៈកម្មការទ្រទ្រង់សាលាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវតែមានការធានាឲ្យមានការចូលរួមពីឪពុកម្តាយ និងប្រធានសហគមន៍។ ភារកិច្ចមួយរបស់គណៈកម្មការទាំងនេះ គឺការរៀបចំកិច្ចប្រជុំទៀងទាត់រវាងឪពុកម្តាយ និងគ្រូបង្រៀន ហើយក្នុងពេលជាមួយគ្នាត្រូវគៀងគរសហគមន៍ឲ្យចូលរួមក្នុងការងារនេះដែរ។ ការប្រាស្រ័យទាក់ទងល្អជាងមុនរវាងឪពុកម្តាយ និងគ្រូ អាចជួយបង្កើនវត្តមាន និងលទ្ធផលសិក្សារបស់សិស្សបាន។

## កែលម្អយន្តការបណ្តុះបណ្តាលគ្រូបច្ចុប្បន្ន

បើតាមការលើកឡើងរបស់មន្ត្រីមកពីក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវតែមានការបន្តពង្រឹងយន្តការបណ្តុះបណ្តាលគ្រូបន្ថែមទៀត ដើម្បីធានាឲ្យមានការកំណត់ពីតម្រូវការបណ្តុះបណ្តាលគ្រូតាមសាលារដ្ឋ និងផ្តល់ឲ្យគ្រូទាំងនោះនូវមេរៀនបណ្តុះបណ្តាលផ្អែកតាមតម្រូវការរបស់ពួកគេ។ នេះគឺដោយសារតែប្រព័ន្ធនេះនៅខ្វះហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស។ ការពិភាក្សាជាមួយអ្នកឆ្លើយតបបង្ហាញថា រដ្ឋាភិបាលមានចំនួនគ្រូដែលមានសមត្ថភាពនៅមានកម្រិត ហើយការបណ្តុះបណ្តាលដែលមានស្រាប់លែងមានបច្ចុប្បន្នភាពទៀតឬនៅមានកម្រិតនៅឡើយ។ មានឯកសារយោងតិចតួចប៉ុណ្ណោះអំពីគរុកោសល្យបែបច្នៃប្រឌិតថ្មី ដូចជាការរៀនសូត្រផ្អែកតាមសកម្មភាព (ABL) និងការរៀនសូត្រដោយប្រើកុំព្យូទ័រ ជាជំនួយ (CAL)។ ការផ្តល់ឯកសារបង្រៀន និងរៀន និងកុំព្យូទ័រដល់គ្រប់សាលារៀនរដ្ឋទាំងអស់ត្រូវការធនធានហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់។ ប៉ុន្តែ ការផ្តល់ឯកសារ និងកុំព្យូទ័រអាចធ្វើ ក្រោយពេលមានការបណ្តុះបណ្តាលគ្រូអំពីការប្រើប្រាស់ឯកសារ និងកុំព្យូទ័រទាំងនេះសិន។ រដ្ឋាភិបាលអាចពិចារណាលើជម្រើសរៀបចំមេរៀនបណ្តុះបណ្តាលទាំងនេះ ហើយបន្ទាប់មក បណ្តុះបណ្តាលគ្រូឧទ្ទេស ដែលនឹងបន្តផ្តល់ការបណ្តុះបណ្តាលដល់គ្រូ។ ការដែលក្រសួងអប់រំ យុវជន និងកីឡា បង្កើតនូវគោលនយោបាយនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់បុគ្គលិកអប់រំ នោះគឺជាប្រការសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាដូចខាងលើ។

## បណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន

ឯកសារស្រាវជ្រាវដែលមានស្រាប់បង្ហាញថា ដើម្បីឲ្យប្រព័ន្ធអប់រំបែបបរិយាប័ន្នទទួលបានជោគជ័យ ចាំបាច់ត្រូវតែមានការដឹកនាំពីគណៈគ្រប់គ្រងសាលារៀន ទើបសាលារៀនអាចផ្តល់នូវបរិយាកាសដែលមានសុវត្ថិភាព និងសន្តិសុខដល់កុមារគ្រប់រូបបាន។ ចាំបាច់ត្រូវតែមានការបង្កើតកម្មវិធីបណ្តុះបណ្តាលអំពីការដឹកនាំសាលារៀនសម្រាប់នាយកសាលា ដោយផ្តោតលើការអប់រំបែបបរិយាប័ន្ន ការដោះស្រាយបញ្ហាការរកឿងឈ្លោះ ការដាក់ទណ្ឌកម្មរាងកាយ។ល។

## បង្កើតក្របខ័ណ្ឌពិនិត្យតាមដានសិទ្ធិកុមារ សម្រាប់រាជធានីភ្នំពេញ

ខណៈពេលដែលរបាយការណ៍នេះបង្ហាញពីទិន្នន័យដើមគ្រានៃហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងសូចនាករអប់រំជាច្រើន រដ្ឋាភិបាល អាចសហការជាមួយនឹងអង្គការណាមួយ ដូចជាយូនីសេហ្វ ឬអង្គការផ្សេងទៀត ដើម្បីបម្លែងព័ត៌មាននេះទៅជាក្របខ័ណ្ឌពិនិត្យតាមដាន ដែលរដ្ឋបាលរាជធានីភ្នំពេញអាចប្រើប្រាស់ ដើម្បីតាមដានពីលទ្ធផលនៃការអនុវត្តកំណែទម្រង់គោលនយោបាយ និងកម្មវិធីនានា ដោយធ្វើការតាមដានការកែលម្អ ធៀបនឹងទិន្នន័យដើមគ្រានេះ។